អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Feb-2012, 11:44
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី២៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោកស្រី សារ៉ាស អេនឌ្រូ
*(Ms.Sarah ANDREWS)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គីមសួន

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ុនណា

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន ស៊ីវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ឆាំង យុ | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅលោក ឆាំង យុ

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖ ........ ទំព័រ០២

សួរដោយលោក ច័ន្ទ តារាស្មី ផ្ដើមពី៖ ........ ទំព័រ០៥

សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្ដើមពី៖ ........ ទំព័រ៣៦

សួរដោយលោក ពេជ អង្គ ផ្ដើមពី៖ ........ ទំព័រ៨៤

សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្ដើមពី៖ ........ ទំព័រ៩៤

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:០០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតាមកាលវិភាគដែលបានគ្រោងទុក។ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការពិភាក្សាដេញដោលគឺសម្រាប់ថ្ងៃនេះ គឺស្តាប់សក្ខីកម្មសាក្សីឈ្មោះ ឆាំង យុ ជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីវត្តមាន អំពីភាពពាក់ព័ន្ធទៅនឹងញាតិលោកហិត ញាតិពន្ធជាមួយនឹងគូភាគី ហើយនិងការធ្វើសម្បថរបស់សាក្សីដែល ឆាំង យុ ដែលនឹងបន្តិចទៀតនឹងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ តើគាត់មានវត្តមានដែរឬទេ? ហើយភាពពាក់ព័ន្ធនេះយ៉ាងដូចម្តេចដែរ? ហើយគាត់បានស្បថហើយឬនៅ?

[០៩:០៤:៥៨]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សាក្សីឈ្មោះ ឆាំង យុ ដែលអង្គជំនុំជម្រះបានកោះហៅមានវត្តមាននៅក្នុងបន្ទប់រង់ចាំ ហើយរង់ចាំការកោះហៅពីអង្គជំនុំជម្រះ ដើម្បីចូលសាលសវនាការ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយ។ សាក្សីក៏បានបញ្ជាក់ផងដែរថា តាមសមត្ថភាពដែលគាត់បានដឹង គឺគាត់មិនមានចំណងញាតិលោកហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់នោះទេ។

សូមអរគុណលោកប្រធាន។

[០៩:០៥:៤១]

**ប្រធានអង្គជំនុំ៖**

អរគុណលោក ផារី។

ជាបន្តមន្ត្រីរដ្ឋបាលតុលាការ សូមអញ្ជើញសាក្សីចូលមកកាន់បន្ទប់សវនាការ!

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៧:០៩]

អរុណសួស្តីសាក្សី!

មុននឹងលោកនិយាយលុះត្រាតែមានភ្លើងក្រហម សឹមនិយាយ ហើយមុននឹងនិយាយលោកអាចបង្អង់បន្តិចឲ្យការបកប្រែសំណួរហ្នឹងបានចប់ សឹមលោកឆ្លើយ។ អ៊ីចឹងឲ្យមានការលទ្ធផលនៃការដេញដោលហ្នឹងវាប្រព្រឹត្តទៅឲ្យប្រសិទ្ធភាពខ្ពស់។

អរុណសួស្តីលោក ឆាំង យុ!

**លោក ឆាំង យុ៖**

ជម្រាបសួរលោកប្រធាន សូមគោរពលោកស្រី លោកចៅក្រមទាំងអស់ដែលមានវត្តមាននៅទីនេះ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើនាមត្រកូល និងនាមខ្លួនរបស់លោកឈ្មោះ ឆាំង យុ អ៊ីចឹងពិតមែនដែរឬទេ?

**លោក ឆាំង យុ៖**

**ឆ៖** ត្រកូលខ្ញុំ-- នាមត្រកូលខ្ញុំបាទឈ្មោះ ឆាំង ។ ខ្ញុំបាទ ឈ្មោះ យុ ជានាមខ្លួន។

**ស៖** លោកអាចប្រាប់ដល់អង្គជំនុំជម្រះអំពីថ្ងៃខែកំណើតរបស់លោកបានដែរឬទេ? តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំបាទកើតនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៦១។

**ស៖** អរគុណ។ តើទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទកើតនៅទួលគោក ទីក្រុងភ្នំពេញ។

**ស៖** តើទីកន្លែងលំនៅដ្ឋានសព្វថ្ងៃរបស់លោកបច្ចុប្បន្ននេះ លោកនៅទីកន្លែងណា?

[០៩:០៨:៥១]

**ឆ៖** នៅទីក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ។ ហើយតើលោកប្រកបមុខរបបរកស៊ីធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំបាទ ជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** អរគុណ។ តើលោកទទួលការអប់រំបណ្តុះបណ្តាលដល់កម្រិតណាដែរ?

**ឆ៖** ខ្ញុំបាទរៀនដល់ថ្នាក់អនុបណ្ឌិត។

**ស៖** បាទអរគុណ។ តើលោកចេះភាសាអន្តរជាតិដូច ភាសាអង់គ្លេស និងភាសាបារាំងដែរឬទេ ហើយប្រសិនបើចេះហ្នឹង គឺចេះអាន ចេះនិយាយ ចេះសរសេរ ចេះស្តាប់កម្រិតណាដែរ?

[០៩:០៩:៣៨]

**ឆ៖** ខ្ញុំបាទចេះភាសាអង់គ្លេសអាចប្រើប្រាស់ជាផ្លូវការបាន។ ភាសាបារាំងខ្ញុំរៀនតាំងពីអាយុ ៨ឆ្នាំ ហើយខានប្រើប្រាស់អស់រយៈពេលជាយូរមកហើយ ប៉ុន្តែខ្ញុំអាចអានបាន ហើយសន្ទនាក្នុងនាមជាទេសចរណ៍អាចធ្វើបាន ភាសាថៃខ្ញុំក៏ចេះខ្លះដែរ អាចប្រើប្រាស់ក្រៅផ្លូវការក្នុងការធ្វើដំណើរ ហើយនិងភាសាឡាវ។

**ស៖** បាទ អរគុណ។ លោក ឆាំង យុ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកបានដឹង លោកអាចដឹងគឺថាលោកមិនមានជាប់ញាតិលោហិតញាតិពន្ធ ដូចជាឪពុកម្តាយ បុព្វជាតិ បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ឬក៏ប្រពន្ធត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្តីនេះទេ។ ហើយលោកក៏មិនមានជាប់ពាក់ព័ន្ធអ្វីញាតិលោហិត ញាតិពន្ធជាមួយនឹងជនជាប់ចោទដែរ។ តើការណ៍នេះពិតមែនដែរឬទេ?

[០៩:១០:៣៨]

**ឆ៖** លោកប្រធាននេះ គឺជាការពិត។

**ស៖** អរគុណ។ ហើយលោកមុននឹងចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះពេលនេះ តើលោកបានស្បថរួចហើយឬនៅ?

**ឆ៖** ខ្ញុំបាទ បានស្បថរួចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះអង្គជំនុំជម្រះជម្រាបសម្រាប់អំពីសិទ្ធិ និងករណីកិច្ចរបស់លោកក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ ក្នុងនាមលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធ ឬមិនឆ្លើយនៅក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពទៅលើខ្លួនលោក។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងនោះនាំឲ្យនឹងលោកត្រូវទទួលរងការចោទប្រកាន់។

[០៩:១១:៣៤]

អំពីករណីកិច្ចក្នុងនាមលោកជាសាក្សី ដែលត្រូវផ្ដល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលបានសួរចំពោះលោក លើកលែងតែក្នុងករណីឆ្លើយតបទៅនឹងសំណួរ ឬអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធលើខ្លួនឯង។

លោកជាសាក្សីត្រូវឆ្លើយតែការណ៍ណាដែលពិត ដែលខ្លួនបានដឹង បានឮ បានឃើញដោយផ្ទាល់នូវព្រឹត្តិហេតុទាំងឡាយពាក់ព័ន្ធនឹងសំណួរដែលបានសួរចំពោះរូបលោក។

តើលោកបានអាចយល់បានទេបញ្ហានេះ?

**លោក ឆាំង យុ៖**

បាទ លោកប្រធាន ខ្ញុំអាចយល់បាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុនផ្ដល់វេទិកាទៅភាគីតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមរំឭកសាជាថ្មីម្ដងទៀត អំពីគោលនៃសវនាការពិភាក្សាដេញដោលលើសាក្សីលោក ឆាំង យុ ដែលជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា គឺដើម្បីដេញដោលនូវសំណួរទូទៅមួយចំនួនពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការទទួលបានឯកសារ ការរៀបចំឯកសារជាកាតាឡុក និងការគ្រប់គ្រងឯកសារ និង/ឬប្រភេទឯកសារជាក់លាក់មួយចំនួនផ្សេងទៀត។

[០៩:១៣:០៣]

នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមានការសួរដេញដោលលើឯកសារជាក់លាក់នីមួយៗឡើយ។ ឯកសារជាក់លាក់នីមួយៗ អាចត្រូវបានយកមកបង្ហាញ ឬយោងទៅលើ ប្រសិនបើជាការចាំបាច់សម្រាប់គោលបំណងបង្ហាញអំពីភាពពាក់ព័ន្ធ នៃបញ្ហាទូទៅណាមួយជាក់លាក់តែប៉ុណ្ណោះ។ ការជំទាស់ដេញដោលទៅលើឯកសារជាក់លាក់នីមួយៗនឹងអាចធ្វើឡើងនៅពេលក្រោយ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរចំពោះសាក្សី។

សូមអញ្ជើញ!

[០៩:១៣:៥៨]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាវស្នី៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។ ក្នុងនាមខ្ញុំតំណាងសហព្រះរាជអាជ្ញានៅពេលនេះ ខ្ញុំសូមអនុញ្ញាតសួរសំណួរមួយចំនួនទាក់ទងទៅនឹងលោក ឆាំង យុ។ យើងខ្ញុំសូមជម្រាបសួរលោក ឆាំង យុ។ សំណួរដែលខ្ញុំនឹងសួរទៅពេលនេះ គឺសំណួរដែលទាក់ទងទៅនឹងប្រវត្តិផ្ទាល់របស់លោក ទាក់ទងនឹងការងាររបស់លោក ទាក់ទងនឹងប្រវត្តិការសិក្សារបស់លោក ក៏ដូចជាការងារមួយចំនួនដែលលោកបានធ្វើនៅក្នុង ឌី.ស៊ី.ខេម កន្លងមកបាទ។

**ស៖** ខ្ញុំសូមឱ្យលោកជួយបញ្ជាក់អំពីបញ្ហាមួយចំនួន ដែលទាក់ទងនឹងការសិក្សារបស់លោកនៅសហរដ្ឋអាមេរិក នៅពេលដែលលោកចាកចេញពីប្រទេសកម្ពុជាទៅរស់នៅសហរដ្ឋអាមេរិក ហើយលោកបានបន្តសិក្សានៅទីនោះមួយចំនួន។ តើលោកបានសិក្សាទៅលើមុខជំនាញអ្វីខ្លះ?

**លោក ឆាំង យុ៖**

**ឆ៖** ខ្ញុំបានសិក្សាទៅលើមុខវិជ្ជាវិទ្យានយោបាយ បាទ។

**ស៖** មុខវិជ្ជាវិទ្យាសាស្ត្រនយោបាយ តើលោករៀននៅសាលាណាដែរ?

[០៩:១៥:០០]

**ឆ៖** សាកលវិទ្យាល័យទីក្រុងដាឡាស រដ្ឋតិចសាស។

**ស៖** លោករៀនបានប៉ុន្មានឆ្នាំនៅទីនោះ?

**ឆ៖** ខ្ញុំរៀនបាន-- បើសិនរាប់ចេញពី-- បើសិនជារាប់ពីថ្នាក់បរិញ្ញាមកដល់ថ្នាក់អនុបណ្ឌិតវាមានរយៈពេលប្រហែល៦ឆ្នាំដែរបាទ។

**ស៖** តើលោកបានទទួលសញ្ញាបត្រកម្រិតអ្វីដែរ?

**ឆ៖** អនុបណ្ឌិត។

**ស៖** ហើយបន្ទាប់មកលោកបានសិក្សា នៅសាលាណាផ្សេងទៀត នៅសហរដ្ឋអាមេរិកដែរឬទេ?

**ឆ៖** អត់មានទេបាទ។

**ស៖** ចុះជំនាញអ្វីទៀតដែលលោកបានសិក្សានៅទីនោះ?

**ឆ៖** ខ្ញុំដូចជាមិនមានជំនាញអ្វីទេបាទ សិក្សាធម្មតាដើម្បីមានចំណេះវិជ្ជា ហើយរកការងារ។

**ស៖** តើជំនាញបន្ទាប់បន្សំអ្វីខ្លះទៀត ដែលលោកបានសិក្សានៅទីនោះក្រៅពីសញ្ញាបត្រថ្នាក់ម៉ាស្ទ័រឌីគ្រី?

**ឆ៖** ខ្ញុំបានធ្វើការនៅសាកលវិទ្យាល័យយ៉ែល ហើយនៅទីនោះមានការបណ្តុះបណ្តាលផ្នែកខាងរៀបចំឯកសារ។ ខ្ញុំបានធ្លាប់ធ្វើការនៅសហគមន៍ អំពីការការពារបទឧក្រិដ្ឋនៅទីក្រុងដាឡាស រដ្ឋតិចសាស ហើយនៅទីនោះមានការបំប៉នផ្សេងៗ ដើម្បីជួយឲ្យការងារមានប្រសិទ្ធភាព។

**ស៖** បាទ អរគុណលោក យុ។ ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលវគ្គខ្លី ដូចជា វគ្គ*ត្រេនទីងខស* តើលោកបានសិក្សាលើមុខជំនាញអ្វី ដែលជាវគ្គបន្ទាប់បន្សំនៅក្នុងវគ្គខ្លីក៏ដោយ ឬក៏វគ្គមធ្យមអីក៏ដោយបាទ? តើមានដែរឬទេ?

[០៩:១៦:៣២]

**ឆ៖** ទីមួយ ខ្ញុំមិនសូវចូលចិត្តអារឿង*ត្រេនទីង*ហ្នឹងណា៎ អ៊ីចឹងខ្ញុំមិនសូវរាប់បញ្ចូល ហើយខ្ញុំមិនដែលដាក់នៅក្នុងប្រវត្តិរូបខ្ញុំដែរ ហើយការ*ត្រេនទីង*តូចតាចប្រជុំមួយថ្ងៃពីរថ្ងៃអីហ្នឹង ខ្ញុំមិនរាប់ជាជំនាញទេ។ លើកលែងតែវាទាក់ទងនឹងការងារ ដូចជានៅសាកលវិទ្យាល័យយ៉ែល ទាក់ទងការងារធំមួយអាហ្នឹងបានខ្ញុំចាត់ទុកថាវាជាវគ្គបណ្តុះបណ្តាលជំនាញ ឬក៏ដើម្បីធ្វើឲ្យការងារមានប្រសិទ្ធភាព។ ក្រៅពីនោះ ខ្ញុំធ្លាប់ចូលរួមការប្រជុំជាច្រើន ជាសន្និបាត ជាសន្និសីទ ជាការពិភាក្សាផ្សេងៗ ប៉ុន្តែវាមានជាលក្ខណៈតូចតាច ហើយខ្ញុំមិនរាប់ជាជំនាញទេ។

**ស៖** បាទ អរគុណ។ ចុះវគ្គសិក្សា ដែលលោកបានទទួលនៅក្នុងថ្នាក់បរិញ្ញាបត្រ តើលោកបានទទួលសញ្ញាបត្របរិញ្ញាបត្រក្នុងជំនាញអ្វីដែរ?

**ឆ៖** អឺ! ជាវិទ្យាសាស្ត្រនយោបាយបាទ។

**ស៖** មានតែបរិញ្ញាបត្រវិទ្យាសាស្ត្រនយោបាយតែមួយគត់ហ្នឹងទេ?

**ឆ៖** បាទៗ។

**ស៖** លោកបញ្ចប់បរិញ្ញាបត្រនៅសាលាណានៅទីកន្លែងណាដែរ?

**ឆ៖** ខ្ញុំបានប្រាប់លោករួចហើយថានៅសាកលវិទ្យាល័យទៅក្រុងដាឡាស រដ្ឋតិចសាស។

**ស៖** អរគុណ។ ខ្ញុំបានដឹងថា លោកបានអញ្ជើញទៅរស់នៅប្រទេសថៃ តើនៅទីនោះលោកបានទទួលការបណ្តុះបណ្តាលអ្វីដែរទេនៅទីនោះ?

[០៩:១៧:៤០]

**ផ៖** នៅប្រទេសថៃ ខ្ញុំរស់នៅជាជនភៀសខ្លួន នៅជំរំខាវអ៊ីដាង ពេលដែលយើងរត់ចេញពីស្រុកទៅ។ ខ្ញុំទៅនៅក្នុងជំរំ ហើយនៅទីនោះខ្ញុំរៀនភាសាបន្ថែមទៀត ខ្ញុំរៀនភាសាថៃ ខ្ញុំរៀនបណ្តុះបណ្តាលភាសាអង់គ្លេសបន្ថែមទៀត ហើយខ្ញុំធ្លាប់ធ្វើការនៅអង្គការមនុស្សធម៌ ដែលនៅទីនោះខ្ញុំរៀនវាយអង្គុលីលេខ។ បាទ ខ្ញុំចេះអង្គុលីលេខ កាលនៅជំរំហ្នឹង។ ហើយក្រោយមកទៀត ខ្ញុំធ្វើការជាជំនួយការនៅការិយាល័យតូចតាចនៅក្នុងជំរំហ្នឹង ដើម្បីទទួលបានជាអាហារ ឬក៏ជាម្ហូបមុនពេលដែលខ្ញុំត្រូវបញ្ជូនទៅរស់នៅសហរដ្ឋអាមេរិក។

**ស៖** បាទ អរគុណ។ តើលោកអាចបញ្ជាក់បានទេថា តើលោកមានលក្ខណៈសម្បត្តិអ្វីខ្លះ ដែលគេបានទទួលលោកទៅរស់នៅសហរដ្ឋអាមេរិក នៅកាលសម័យនោះ?

**ផ៖** រឿងវែងឆ្ងាយ បើសិនជាលោកចង់ដឹង រឿងហ្នឹងវែងឆ្ងាយ។ ពេលដែលខ្ញុំទៅដល់ជំរំខាវអ៊ីដាងហ្នឹង គឺជាទូទៅខ្ញុំបានទៅដល់នៅពេលវេលាមួយ ដែលជំរំនេះគឺត្រូវបានបិទមិនឲ្យមានជនភៀសខ្លួនស្របច្បាប់ទៀតទេ។ អ៊ីចឹង គឺយើងត្រូវរស់នៅរកវិធីយ៉ាងណាដើម្បីទាក់ទងបងប្អូនសាច់ញាតិដែលមាននៅសហរដ្ឋអាមេរិក ហើយពេលដែលខ្ញុំរកឃើញសាច់ញាតិខ្ញុំនៅសហរដ្ឋអាមេរិកហ្នឹង គឺខ្ញុំបានបដិសេធមិនព្រមឲ្យគាត់ធានាខ្ញុំយកទៅសហរដ្ឋអាមេរិកទេ ពីព្រោះខ្ញុំចង់ទៅក្នុងនាមជា ជាឯករាជ្យ គេហៅ ជាជនភៀសខ្លួន ដែលមាន-- ដែលត្រូវបានគេរើសយកទៅតែម្តង ដែលគ្មានអ្នកធានារ៉ាប់រងជាបងជាប្អូន។ អ៊ីចឹង ទីមួយ ខ្ញុំគិតថា ដោយសារថា ប្រហែលជាក្រុមគ្រួសារខ្ញុំធ្លាប់បម្រើឲ្យរដ្ឋាភិបាលសម័យមុន សម័យសាធារណរដ្ឋ ហើយដោយសារថា ខ្ញុំមិនចូលទៅក្នុងប្រភេទ អ្នកដែលគាំទ្រចលនាកុម្មុយនីស្ត ដែលជាលក្ខខណ្ឌមួយ នៅពេលដែលយើងធ្វើសម្ភាសនៅក្នុងជំរំហ្នឹង ហើយខ្ញុំក៏បានត្រូវបានអង្គការមួយជួយយកទៅនៅរដ្ឋតិចសាសតាំងពីនោះមក។

[០៩:១៩:៥១]

លោកយល់ ចម្លើយ *(ឮមិនច្បាស់)* ខ្ញុំសួរទេ បាទ ព្រោះនេះរឿងវែងឆ្ងាយ។ នេះជារឿងខ្សែជីវិតមួយ បើសិនជាលោកចង់ស្តាប់ ខ្ញុំអាចនិយាយបានវែងឆ្ងាយលម្អិតជាងនេះ។ ប៉ុន្តែបើនិយាយឲ្យសង្ខេបទៅ ខ្ញុំទៅនៅជំរំ រួចហើយខ្ញុំទៅនៅសហរដ្ឋអាមេរិក។

**ស៖** អរគុណ។ តើហេតុអីបានជាលោកជ្រើសរើសប្រទេសអាមេរិក ទៅរស់នៅទីនោះ? មូលហេតុអ្វី?

**ឆ៖** រឿងវែងឆ្ងាយទៀត។ កាលខ្ញុំនៅពីក្មេង ក្រុមគ្រួសារខ្ញុំមួយចំនួនបានបម្រើការងារឲ្យរបប សាធារណរដ្ឋខ្មែរ ហើយជាទូទៅអ្នកកាសែតជាច្រើនបានមកផ្ទះខ្ញុំ ហើយអ្នកទាំងអស់គ្នាគេនិយាយ ភាសាអង់គ្លេសគ្រប់ៗគ្នា។ ខ្ញុំកាលនោះអាយុប្រហែលជា១០, ១១ឆ្នាំ កាលនោះខ្ញុំកើតឆ្នាំ៦១ ហើយខ្ញុំ ចង់ក្លាយជាអ្នកកាសែត។ ហើយខ្ញុំឃើញអ្នកកាសែតស្រីម្នាក់ដែលខ្ញុំស្រឡាញ់គាត់ មិនមែនស្រឡាញ់ ក្នុងន័យស្នេហាទេ គាត់មាឧរាងខ្ពស់ ហើយខ្ញុំក៏មានចិត្តថា ថ្ងៃណាមួយខ្ញុំក្លាយជាអ្នកកាសែត ហើយរស់ នៅ ទៅនៅប្រទេសអាមេរិក។ ហើយក្រោយមកទៀត ពេលដែលខ្ញុំមកនៅជុំរុំហ្នឹង ប្រធានរបស់ខ្ញុំហ្នឹង បានសួរខ្ញុំថា ឥឡូវនេះបើខ្ញុំមិនព្រមឲ្យមានអ្នកធានា តើខ្ញុំចង់ទៅនៅរស់នៅកន្លែងណា? ខ្ញុំថា ឲ្យតែបាន ទៅសហរដ្ឋអាមេរិក កន្លែងណាក៏ខ្ញុំទៅដែរ ពីព្រោះខ្ញុំមានការស្រមើស្រមៃកាលពីក្មេង។ អ៊ីចឹងគាត់ក៏ សួរបញ្ជាក់ទៀតថា ទៅរដ្ឋមួយណា ពីព្រោះសហរដ្ឋអាមេរិកវាធំ ហើយខ្ញុំមិនដែលស្គាល់សហរដ្ឋ អាមេរិកសោះ។ អ៊ីចឹងគាត់ក៏និយាយលេងជាមួយខ្ញុំថា បើសិនជាខ្ញុំចង់ទៅអាមេរិក គាត់នឹងបញ្ជូនខ្ញុំ ទៅរដ្ឋអាឡាស្កា។ រួចខ្ញុំក៏មិននឹកស្មានថា ខ្ញុំថាទៅណាក៏ទៅដែរ ឲ្យតែសហរដ្ឋអាមេរិក។ ដល់ពេល អ៊ីចឹងទៅក្រោយមកគាត់គិតថា ជាការនិយាយលេង គាត់ឲ្យខ្ញុំសញ្ជឹងគិតពិចារណា ថារដ្ឋណាមួយដែល ខ្ញុំចង់ទៅ។

[០៩:២១:៣៥]

ហើយខ្ញុំនឹកឃើញ ហ្សាកគ្លីន កេណ្ណឌី ដែលគាត់ធ្លាប់មកស្រុកយើង។ អង្កាល់ដែលគាត់មក ហ្នឹងខ្ញុំនៅក្មេង ហើយខ្ញុំធ្លាប់ឮថា លោក កេណ្ណឌី នេះគឺជាមនុស្សដែលធ្វើឲ្យពួកស្បែកខ្មៅ ស្បែកស រស់នៅជាមួយគ្នា ជាមនុស្សដែលមានវ័យក្មេងនៅក្នុងនាមជាអ្នកដឹកនាំ ហើយខ្ញុំគិតថា គាត់ជាវីរបុរស របស់ខ្ញុំ។ អ៊ីចឹងខ្ញុំបានសួរទៅប្រធានខ្ញុំវិញថា ខ្ញុំឮថាគាត់ស្លាប់ តើគាត់ស្លាប់នៅរដ្ឋណា? ហើយប្រធានខ្ញុំ បានប្រាប់ថា គាត់ស្លាប់នៅរដ្ឋតិចសាសនៅទីក្រុងដាឡាស។ អ៊ីចឹងខ្ញុំក៏សុំទៅកន្លែងហ្នឹងតែម្តង។ ហើយ បើសិនជាលោកទៅទីក្រុងដាឡាស តិចសាស នៅក្នុងកន្លែងដែលគាត់ត្រូវបានគេសម្លាប់ហ្នឹង គេមាន សំបុត្រមួយសម្រាប់ឲ្យមនុស្សសរសេររំឭកពីគាត់ ហើយខ្ញុំចាំថា គាត់ស្លាប់នៅថ្ងៃទី២២ ខែវិច្ឆិកា។ អ៊ីចឹងរៀងរាល់ខែ ថ្ងៃទីហ្នឹងខ្ញុំតែងតែទៅកន្លែងហ្នឹងសរសេរអំពីគាត់។ អ៊ីចឹង មូលហេតុដែលខ្ញុំចង់ទៅ ហ្នឹង គឺអាចថាជាការស្រមើស្រមៃកាលពីក្មេង ហើយក្រោយមកទៀតក្លាយទៅជាការពិត ហើយ កេណ្ណឌី គឺជាមនុស្សទីមួយដែលខ្ញុំធ្លាប់ឮកាលពីខ្ញុំកើតមក។ ហើយក្រោយមកខ្ញុំបានប្រាប់រឿងរ៉ាវនេះ ទៅអ្នកស្រី សាមន្តា ផៅវ័រ គាត់គឺអ្នកនិពន្ធសៀវភៅមួយដែលមានចំណងជើងថា “បញ្ហាពីឋាននរក”

សិក្សាអំពីរឿងរ៉ាវការរំលោភសិទ្ធិមនុស្សនៅក្នុងពិភពលោក។ ហើយខ្ញុំបានប្រាប់រឿងរ៉ាវនេះទៅគាត់នៅក្នុងសៀវភៅហ្នឹងដែរ បើសិនជាលោកអាន តាមដែលខ្ញុំចាំនៅទំព័រជាងពីររយ។ អ៊ីចឹងរឿងរ៉ាវនេះគឺជារឿងដែលខ្ញុំដក់ជាប់នៅក្នុងចិត្តតាំងពីក្មេង ហើយខ្ញុំមានគំនិតចង់ទៅរស់នៅទីនោះ។

[០៩:២៣:០៨]

នៅពេលដែលខ្ញុំទៅដល់អាមេរិក ខ្ញុំបានតាមស្វែងរកស្ត្រីអាមេរិកាំងម្នាក់ ដែលខ្ញុំដក់នៅក្នុងចិត្តតាំងពីក្មេង ហើយខ្ញុំបានរកឃើញគាត់។ ខ្ញុំរកឃើញគាត់ ។ជាប្រធាន យូ.ភី.អាយ នៅប្រទេសជប៉ុន។ គាត់ឈ្មោះ ខេត វេប។ ខ្ញុំក៏បានអ៊ីម៉ែលទៅសួរគាត់ ខ្ញុំប្រាប់រឿងរ៉ាវកាលពីក្មេងដែលខ្ញុំស្រឡាញ់គាត់ដែលខ្ញុំនឹកឃើញគាត់ ហើយចង់ក្លាយជាអ្នកសារព័ត៌មាន ហើយខ្ញុំគិតថាគាត់ជាស្ត្រីអាមេរិកាំងម្នាក់ដែលអស្ចារ្យបំផុតនៅក្នុងជីវិតរបស់ខ្ញុំ។

ឆ្លើយមកវិញ គាត់បានឆ្លើយអ៊ីម៉ែលមកខ្ញុំ គាត់ថា គាត់មានអារម្មណ៍រំភើប ដែលខ្ញុំជាក្មេងមួយចងចាំគាត់ ប៉ុន្តែគាត់មិនមែនជាអាមេរិកាំងទេ គាត់មកពីញូវហ្សេឡែន។ ខ្ញុំក៏ដូចជាគួរឲ្យចង់សើចរឿងហ្នឹង ហើយគាត់ក៏បានស្លាប់ប៉ុន្មានឆ្នាំមុននេះ ហើយក៏មានចុះសារព័ត៌មាននៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ដែរ។ ហើយនៅ*អហ្វហ្វីស* ខ្ញុំមានរូបថតគាត់ទៀត ខ្ញុំនៅតែទុករូបថតគាត់អ៊ីចឹង ខេត វេប ហ្នឹងគឺជាស្ត្រីទីមួយដែលខ្ញុំគោរពហើយចង់ធ្វើតាមគាត់ ដោយសារមូលហេតុមួយទៀត តាមដែលខ្ញុំចាំគឺកាលនោះគាត់ត្រូវបានខាងខ្មែរក្រហមចាប់គាត់នៅតាំងគោក។ កាលហ្នឹងមានព័ត៌មានផ្សព្វផ្សាយ ជារឿងរន្ធត់មួយ ហើយខ្ញុំចាំថា គាត់ត្រូវបានដឹកចេញទៅព្យាបាលនៅស្រុកថៃៗ។ អ៊ីចឹងរឿងនេះវាកើន កាន់តែខ្ញុំចងចាំគាត់តែខ្លាំងឡើង។ ហើយខ្ញុំចាំបានថា គាត់បានសរសេរសៀវភៅមួយ គាត់ត្រូវបានខ្មែរក្រហមចាប់ឃុំខ្លួនអស់រយៈពេល២២ថ្ងៃ។

[០៩:២៤:៣៩]

ហើយខ្ញុំចាំថា គាត់បានសរសេរសៀវភៅមួយមានចំណងជើងថា "២២ថ្ងៃជាមួយអ្នកដែលនៅខាងក្រៅ"។ សៀវភៅហ្នឹងគាត់បានសរសេរ ហើយមកទល់សព្វថ្ងៃនេះនៅក្នុង*អាម៉ាហ្សូនដតខម* ក៏រកលែងឃើញដែរ។ លើកលែងតែនៅជាមួយអ្នកដែលមានវ័យចំណាស់ៗប្រហែលគាត់។ ប្រហែលជាអាចមានសៀវភៅហ្នឹង។

រឿងនេះខ្លីទេ នៅមានវែងឆ្ងាយទៀត ហើយបើសិនជាលោកចង់ដឹងលម្អិត ខ្ញុំបានធ្លាប់បានប្រាប់ទៅ សាមន្តា ផៅវ័រ សព្វថ្ងៃគាត់ជាទីប្រឹក្សារបស់លោកប្រធានាធិបតេយ្យ ប៉ារ៉ាក់ អូប៉ាម៉ា ហើយគាត់

បានសរសេរសៀវភៅនេះ កាលគាត់នៅសកលវិទ្យាល័យ ហាវើដ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាជាតិ អង្គជំនុំជម្រះបានកំណត់ពេលវេលាសម្រាប់សហព្រះរាជអាជ្ញាសួរដេញដោលសម្រាប់សាក្សីរូបនេះ។ ដូច្នេះសហព្រះរាជអាជ្ញាគួរត្រូវបានប្រើប្រាស់ពេលវេលាឲ្យបានប្រសិទ្ធភាពនៅក្នុងការតាំងសំណួរ ដែលពាក់ព័ន្ធទៅនឹងគោលបំណងនៃសវនាការដេញដោលចំពោះសាក្សីរូបនេះ។ អង្គជំនុំជម្រះបានជម្រាបជូនរួចហើយ មុនពេលផ្តល់វេទិកាទៅឲ្យលោកដេញដោល។ បញ្ហាពាក់ព័ន្ធនឹងបុគ្គលភាពដែលលោកបានសួរបឋមដំបូងបន្ថែមពីលើអ្វីដែលអង្គជំនុំជម្រះបានសួរនោះ ដូចជាសមល្មមហើយ។

[០៩:២៦:០១]

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តសំណួរទៀត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក យុ ខ្ញុំសូមអនុញ្ញាតសួរសំណួរលោកទាក់ទិនទៅនឹងការវិលត្រឡប់មកកម្ពុជា។ តើលោកវិលត្រឡប់មកកម្ពុជានៅពេលណា?

**លោក ឆាំង យុ៖**

**ឆ៖** ខ្ញុំមកវិញនៅក្នុងឆ្នាំ១៩៩២ កាលណោះខ្ញុំជាបុគ្គលិកអន្តរជាតិរបស់អង្គការសហប្រជាជាតិអ៊ុនតាក់។ ខ្ញុំមកធ្វើជាអ្នករៀបចំការបោះឆ្នោតនៅខេត្តកំពង់ស្ពឺ។

**ស៖** តើលោកធ្វើការនៅក្នុងអ៊ុនតាក់ហ្នឹង ក្នុងទទួលខុសត្រូវមុខតំណែង ឬកិច្ចការអ្វីដែរ?

**ឆ៖** បោះឆ្នោត។ ខ្ញុំប្រាប់លោករួចហើយ។

**ស៖** ក្រៅពីអ៊ុនតាក់ លោកបញ្ចប់ការងារជាមួយអ៊ុនតាក់ តើលោកបានធ្វើការនៅអង្គភាពណាផ្សេងទៀតដែរឬទេ?

**ឆ៖** មានរយៈពេលខ្លីមួយ នៅពេលដែលខ្ញុំធ្វើការជាមួយអ៊ុនតាក់នៅខេត្តកំពង់ស្ពឺហ្នឹង ខ្ញុំទទួលបន្ទុកបង្រៀនអ្នកបោះឆ្នោត ហើយនិងធ្វើការជាមួយគណបក្សជាង២០ ជាមួយដៃគូរបស់ខ្ញុំម្នាក់មកពីប្រទេសកូឡុំប៊ី ឈ្មោះ ខាល់ឡូស វ៉ាឡិនស្វេឡា។ ប្រធានខ្ញុំឈ្មោះ ស្មេរ៉ូស្ស គាត់ជនជាតិឥណ្ឌាទេ តែគាត់ឈ្មោះ រ៉ូស្ស ឈ្មោះគាត់ដូចរបៀបស្រីបន្តិច តែគាត់ជាមនុស្សប្រុស។ ហើយយើងបានរៀបចំ

ការបោះឆ្នោត បន្ទាប់ពីការបោះឆ្នោតហើយទៅ ខ្ញុំមានរយៈពេលខ្លីមួយមុននឹងខ្ញុំត្រឡប់ទៅសាកលវិទ្យាល័យ យែល ហ្នឹង គឺខ្ញុំធ្វើការឲ្យវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិរបស់សហរដ្ឋអាមេរិក ដែលជាភាសាអង់គ្លេសហៅថា "អាយ.អ័រ.អាយ"-- *អ៊ីនធើណាស្យូណល រីផាប់ប្លិក អ៊ីនស្ទីតស្ទូត* ។

[០៩:២៧:៣២]

**ស៖** ខ្ញុំបានដឹងថាលោកជាប្រធាន ឌី.ស៊ី.ខេម។ តើ ឌី.ស៊ី.ខេម ហ្នឹងបង្កើតនៅពេលណា ហើយបង្កើតក្នុងគោលបំណងអ្វីជាចម្បង?

**ឆ៖** ខ្ញុំសូមជម្រាបលោកសហព្រះរាជអាជ្ញា ខ្ញុំអាចឆ្លើយវែងៗ ដោយសារនេះជារឿងប្រវត្តិ វាខុសពីរឿងឯកសារ អ៊ីចឹងសូមអធ្យាស្រ័យ បើជាវែងលោកអាចកាត់ខ្ញុំបាន ប្រសិនជាវាវែងពេក។

មជ្ឈមណ្ឌលឯកសារកម្ពុជានេះ គឺមិនមែនជាអង្គការទីមួយដែលបង្កើតឡើងដើម្បីស្រាវជ្រាវឯកសារទេ។ តាមពិតការសិក្សាស្រាវជ្រាវ ប្រមែប្រមូលឯកសារនេះ កកើតឡើងដំបូងដោយសិស្សសាលាច្បាប់ម្នាក់មកពីសាកលវិទ្យាល័យ យែល គឺគាត់ឈ្មោះលោក ហ្គ្រេកគ្រី ស្ទេនសិន។ លោក ហ្គ្រេកគ្រី ស្ទេនសិន នេះ គាត់បានធ្វើដំណើរមកកម្ពុជាដំបូង តាមដែលខ្ញុំចាំនៅក្នុងឆ្នាំ១៩៧៩ ធ្វើជាមួយនឹងអង្គការអន្តរជាតិមួយចំនួន ហើយបានឃើញទុក្ខវេទនា ឃើញរណ្តៅសាកសព ឃើញអំពីការលំបាករបស់ប្រជាជន។ គាត់ក៏បានបង្កើតកម្មវិធីមួយឈ្មោះហៅថា *"ខេមបូឌាន ដេណូសាយ ប្រូចិច"* នៅក្នុងឆ្នាំ៨០ ខ្ញុំនៅមានសលាកប័ត្ររបស់គាត់នៅ*អូហ្វហ្វីស*របស់ខ្ញុំក៏មានដែរ។ ប៉ុន្តែការប្រឹងប្រែងនេះមិនត្រូវបានមានការគាំទ្រជារួម ប៉ុន្តែមានការខិតខំប្រឹងប្រែង។ បន្ទាប់មកក៏មានគណៈកម្មការឯកសារកម្ពុជាដែលដឹកនាំដោយលោក ដាវីដ ហក ហើយខ្ញុំចាំថា លោក ដាវីដ ហក នេះគឺចេញមកពីសាកលវិទ្យាល័យកូឡុំប៊ី ហើយមានការជួយឧបត្ថម្ភអំពីអង្គការទេយ្យទានប្រជាធិបតេយ្យ *"ណាស្យូណល អ៊ីនដោមិន ដេម៉ូក្រាស៊ី"* ហើយគាត់មានទីតាំងនៅឃៀងម៉ៃ ហើយគាត់ចេញចូលស្រុកខ្មែរយើង។

[០៩:២៩:២២]

បន្ទាប់ពីលោក ដាវីដ ហក មានប្រវត្តិវិទូ ប៉ែន ឃៀរនិន មានសាស្ត្រាចារ្យ ដេវីដ ឆេនឌ៍ល័រ មានអ្នកស្រី ប៊ូ ចាន់ធូ មានលោក ភីតធ័រ ម៉ាខ្វៃអ៊័រ និងមានមនុស្សជាច្រើនទៀតបានធ្វើកិច្ចការនេះ។ ហើយកិច្ចការនេះចេះតែបន្តការតស៊ូមតិនៅក្នុងប្រទេសរហូតនៅពេលដែលខ្ញុំបានទៅដល់សហរដ្ឋអាមេរិក ខ្ញុំក៏បានឮកិច្ចការនេះភ្លាម។ ក្រោយមកខ្ញុំក៏បានចាប់ផ្តើម-- ខ្ញុំចាប់ផ្តើមដឹងរឿងរ៉ាវនេះនៅក្នុងឆ្នាំ១៩៨៦-១៩៨៧ ខ្ញុំមានមិត្តភក្តិខ្ញុំម្នាក់ជនជាតិអាមេរិកាំង បានឲ្យឯកសារខ្ញុំមួយនិយាយអំពីឈ្មោះ

មេដឹកនាំខ្មែរក្រហម ឆ្នាំ៨៦។ ហើយឯកសារនេះ ក៏ខ្ញុំបានយកមកទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាសព្វថ្ងៃនេះដែរ។

[០៩:៣០:១៥]

នៅក្នុងឆ្នាំ៨៧ គ្រូភាសាអង់គ្លេសរបស់ខ្ញុំម្នាក់ឈ្មោះ គាត់ជាស្រី តែគាត់ឈ្មោះ អាន់ណា វ៉េឡាស្កូ គាត់ពាក់កណ្ដាលអាមេរិកកាំង ពាក់កណ្ដាលអ៊ីតាលី ហ្នឹង។ គាត់បានទិញសៀវភៅឲ្យខ្ញុំមួយ។ សៀវភៅហ្នឹងមានចំណងជើងថា "តើប៉ុល ពត ចូលកាន់កាប់អំណាចបែបណា?" ហើយនៅក្នុងសៀវភៅហ្នឹងគាត់បានសរសេរចំណារមួយថា "ថ្ងៃណាមួយ ខ្ញុំនឹងអាចរកការពិតនៅក្នុងជីវិតខ្ញុំដែលរសាត់អណ្ដែតចេញពីប្រទេសយ៉ាងដូច្នេះ"។

[០៩:៣០:៤៣]

អ៊ីចឹង ខ្ញុំចាប់ផ្ដើមចាប់អារម្មណ៍ទៅលើសៀវភៅអ្នកសិក្សាវៀនសូត្រ ហើយខ្ញុំក៏ចាប់ផ្ដើមស្រាវជ្រាវ ហើយខ្ញុំបានសរសេរសំបុត្រទៅលោក ប៉ែន ឃៀរនិន មុនគេ នៅតាមសៀវភៅហ្នឹង ខ្ញុំបានស្រាវជ្រាវរកឃើញប្រវត្តិរបស់គាត់ ខ្ញុំបានសរសេរសំបុត្រទៅជូនគាត់។

អ៊ីចឹងខ្ញុំក៏មានការទំនាក់ទំនងជាមួយអ្នកសិក្សាស្រាវជ្រាវនេះច្រើន មុនពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងកកើតទៅទៀត។ ហើយក្រោយមកតាមដែលខ្ញុំចាំនៅក្នុងឆ្នាំ៩០ ឬក៏ឆ្នាំ៨៩ មានយុទ្ធនាការមួយនៅសហរដ្ឋអាមេរិកដែលជាមូលដ្ឋានធំ ហើយមានសាខានៅប្រទេសអូស្ត្រាលី និងប្រទេសផ្សេងៗទៀត។ យុទ្ធនាការនេះ គេឲ្យឈ្មោះថា "យុទ្ធនាការប្រឆាំងនឹងការត្រឡប់មកវិញនៃរបបខ្មែរក្រហម"។ អ៊ីចឹងខ្ញុំក៏ស្ម័គ្រចិត្តជាមួយនឹងយុទ្ធនាការនេះ នៅរដ្ឋតិចសាស។ ហើយនៅក្នុងយុទ្ធ-នាការនេះ ខ្ញុំជួយបកប្រែ ជួយផ្សព្វផ្សាយព័ត៌មាននៅក្នុងរដ្ឋតិចសាស នៅក្នុងសហគមន៍ដែលខ្ញុំរស់នៅ។

[០៩:៣១:៤៥]

ក្រោយមកទៀត នៅក្នុងយុទ្ធនាការនេះ អ្នកដែលគ្រប់គ្រងដំបូងគឺជាស្ត្រីម្នាក់ តាមដែលខ្ញុំចាំឈ្មោះ រូសថ៍ "R-u-t-h" ហើយក្រោយគឺ គ្រេក អេតធេសាន់ សព្វថ្ងៃគាត់ធ្វើការនៅសហព្រះរាជអាជ្ញាយើងនេះ។ គ្រេក បាទ គ្រេក ហ្នឹងជាមិត្តភក្តិចាស់របស់ខ្ញុំ ហើយគាត់ជាអ្នកមើលកិច្ចការនេះ។ ហើយអ៊ីចឹងទៅ ក៏បន្ទាប់មកទៀត ខ្ញុំក៏ត្រូវបានគេប្រើប្រាស់ជាអ្នកស្ម័គ្រចិត្ត។ ខ្ញុំបានរៀបចំឲ្យមានការប្រជុំធំមួយនៅសាកលវិទ្យាល័យតិចសាស អេ.អេន.អឹម នៅទីក្រុង-- ឆ្ងាយពីទីក្រុងដែលខ្ញុំរស់នៅ។ ខ្ញុំមានរូបថតហ្នឹងដែលនៅសល់ បើសិនជាលោកចង់បាន។ ពេលដែលរៀបចំធ្វើយុទ្ធនាការនេះ គឺមាន

មនុស្សតែបួននាក់ទេចូលរួម។ កាលដែលខ្ញុំធ្វើហ្នឹងគឺជារឿងមួយគួរឲ្យសង្វេគដែរ មានមនុស្សតែបួននាក់ទេចូលរួម។

[០៩:៣២:៣៤]

ក្រោយមកទៀត ខ្ញុំក៏បានទាក់ទងជាមួយលោក ប៉ែន យៀរនិន ហើយគាត់បានប្រាប់ខ្ញុំថា យើងនឹងធ្វើគម្រោងមួយដើម្បីស្នើសុំថវិកាពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីធ្វើការកិច្ចការស្រាវជ្រាវ ហើយបើសិន-- ហើយគាត់ចង់ឲ្យខ្ញុំចូលរួមនៅក្នុងក្រុមនេះ។ តែកាលនោះ យើងបាន១ ខ្ញុំកាលនោះ ខ្ញុំកំពុងធ្វើការនៅអង្គការសហប្រជាជាតិនៅឡើយឆ្នាំ៩១ ឆ្នាំ៩២។ ហើយនៅក្នុងពេលជាមួយគ្នានឹងក្នុងឆ្នាំ៩៣ហ្នឹង គាត់ក៏ចាប់ផ្តើម ៩៤ហ្នឹងនៅសហរដ្ឋអាមេរិកមានព្រឹទ្ធសភាពបានអនុម័តច្បាប់មួយដែលមានឈ្មោះថា *"ខេមបូឌាន ជេណូសាយ ចាស្ទីស អាក"*។

[០៩:៣៣:១៨]

អ៊ីចឹង សរុបសេចក្តីទៅការបង្កើត-- កុំឲ្យវាវែង មើលទៅលោកហាក់ដូចជាធុញដែរ ព្រោះរឿងវាវែងឆ្ងាយ។ លោកបញ្ចេញអាការៈថាវាវែងពេក អ៊ីចឹងខ្ញុំសូមសង្ខេបទៅវិញ ហើយខ្ញុំអាចឆ្លើយពេលក្រោយទៀត។ គោលបំណងនៃការបង្កើតនេះ គឺដើម្បីចងក្រងឯកសារ១ ដើម្បីការផ្សះផ្សា អ៊ីចឹងដើម្បីការផ្សះផ្សានេះ គឺយើងមានជាចេតនាចម្បងរបស់យើង ប៉ុន្តែដើម្បីឲ្យមានការផ្សះផ្សា យើងមានគំនិតបីដែលយើងធ្វើ។ បើនិយាយឲ្យច្បាស់ ការចងក្រងឯកសារនេះ គឺដើម្បីសិក្សាអតីតកាល។ ហើយដើម្បីផ្សះផ្សាអតីតកាល យើងមានកម្មវិធីធំ១បីដែលយើងធ្វើ។

ទីមួយ យើងជឿជាក់ថា ពេលដែលខ្ញុំប្រើពាក្យយើង គឺទាំងអស់គ្នានៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា។ គឺយើងចង់ឲ្យមានតុលាការមួយដើម្បីរកការពិត ដើម្បីផ្តល់នូវសេចក្តីវិនិច្ឆ័យចុងក្រោយអំពីអ្វីដែលបានកើតឡើងពីអតីតកាល។ ទីពីរ គឺយើងចង់ឲ្យសិស្សានុសិស្ស ក្មេងជំនាន់ក្រោយទាំងអស់ចងចាំ ហើយបានរៀនសូត្រ។ ហើយទីបី យើងចង់ឲ្យមានកន្លែងមួយជាលក្ខណៈអចិន្ត្រៃយ៍ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍នេះមិនឲ្យត្រឡប់មកវិញ។ អ៊ីចឹងគោលបំណងតែមួយគត់ គឺដើម្បីផ្សះផ្សាជាតិ ក្នុងការរៀបចំឲ្យមានមជ្ឈមណ្ឌលឯកសារកម្ពុជានេះ។

[០៩:៣៤:៤១]

**សៈ** អរគុណលោក យុ។ ខ្ញុំសូមបន្តសំណួរទៀត។ នៅក្នុងអតីតកាលមកដល់បច្ចុប្បន្ននេះ តើលោកធ្លាប់បានសរសេរស្នាដៃជាការបោះពុម្ពឯកសារនៅក្នុងសង្គម នៅក្នុងប្រទេសខ្មែរក៏ដោយ ឬក៏

នៅអន្តរជាតិ តើលោកបានបោះពុម្ពឯកសារដែលពាក់ព័ន្ធនឹងឯកសារអ្វីខ្លះដែរឬទេ ដែលពាក់ព័ន្ធនឹងបញ្ហាហ្នឹង?

**ឆ៖** ខ្ញុំធ្លាប់បានសរសេរដែរ តែសរសេរតូចតាច។ ខ្ញុំមិនដែលគិតថា ខ្ញុំជា*ស្កូឡា* អីគេហ្នឹងឯងទេ។ អ៊ីចឹង ខ្ញុំធ្លាប់សរសេរខ្លះៗដែរ ជាអត្ថបទនៅក្នុងកាសែត សារព័ត៌មាន ជួនកាលខ្ញុំសរសេររួមជាមួយអ្នកដែលគេមានជំនាញច្បាស់លាស់បាទ។

**ស៖** តើនៅក្នុងអត្ថបទនោះ ផ្ដោតទៅលើខ្លឹមសារសំខាន់អ្វីខ្លះ?

**ឆ៖** មានច្រើនបាទ មានច្រើន។

**ស៖** លោកអាចរៀបរាប់អំពីក្នុងវិស័យធំៗ ជាហ្វៀលធំៗ?

**ឆ៖** ធំ ខ្ញុំគិតថាមានមួយដែលធំ ដោយសារថាមានមតិជាច្រើន ចង់ដឹងថាយើងមានឯកសារអ្វីខ្លះ។ អ៊ីចឹងហើយ ខ្ញុំក៏បានសម្រេចចិត្តថា សរសេរឲ្យគេដឹងផង ពីព្រោះការសិក្សាស្រាវជ្រាវកាសែត ឯកសាររាប់ម៉ឺន រាប់សែនអ៊ីចឹង វាច្រើនពេក។ អ៊ីចឹង ខ្ញុំក៏បានសរសេរ សរសេរពីរវគ្គមួយនៅក្នុងសៀវភៅមួយ បាទ និយាយអំពីឯកសារដែលយើងបានប្រមូលមក។

**ស៖** ឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកបានសរសេរហ្នឹង ទាក់ទិននឹងអ្វីខ្លះ ដែលលោកបានសរសេរដោយផ្ទាល់ដៃលោក?

[០៩:៣៦:០៨]

**ឆ៖** ចង់និយាយថាពីឯកសារ--។

**ស៖** ក្នុងរបបកម្ពុជា-- ឯកសារដែលពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ របបខ្មែរក្រហម។ ពេលលោកបានសរសេរហ្នឹង តើលោកបានសរសេរហ្នឹង ពាក់ព័ន្ធនឹងរបបហ្នឹង តើលោកមានអត្ថបទឯកសារណាខ្លះ ដែលបានចេញផ្សាយកន្លងមក?

**ឆ៖** ខ្ញុំគិតថាច្រើន។ ខ្ញុំសរសេរពីជីវិតខ្ញុំដែលរស់នៅសម័យខ្មែរក្រហម ធ្លាប់បោះពុម្ពផ្សាយនៅភ្នំពេញប៉ុស្តិ៍។ ខ្ញុំធ្លាប់សរសេរជាមតិតូចៗនៅក្នុងកាសែតរស្មីកម្ពុជា កាសែតខេលី។ ខ្ញុំធ្លាប់សរសេរអត្ថបទនៅក្នុងកាសែតញូវយ៉កថែមស៍ នៅពេលដែលអង្គការសហប្រជាជាតិដកថយចេញពីការចរចាអាហ្នឹងចាត់ទុកថា ជាអត្ថបទធំៗ។ ខ្ញុំធ្លាប់បានសរសេរជាវគ្គមួយ នៅក្នុងសៀវភៅមួយ ហើយក្រៅពីហ្នឹងច្រើនតែគេសរសេរពីខ្ញុំវិញ។ អ៊ីចឹង ខ្ញុំសរសេរ គិតទៅវាបានតិច មិនសូវជាច្រើនប៉ុន្មានទេ ហើយណាមួយរវល់ធ្វើការផង។

**ស៖** អរគុណលោក យុ។ ខ្ញុំសូមបន្តទៀត។ តើលោកបានធ្លាប់បានចូលរួមនៅក្នុងកម្មវិធីជាវេទិកាជាតិ ឬអន្តរជាតិ ហើយលោកបានចូលរួមថ្លែងបទសុន្ទរកថារបស់លោក ឬក៏ជាអត្ថបទ-- ឬក៏សេចក្តីថ្លែងការណ៍ណាមួយនៅក្នុងវេទិកាជាតិ ឬអន្តរជាតិ ក្នុងសន្និសិទក៏ដោយ ពាក់ព័ន្ធនឹងរបបខ្មែរក្រហមដែរឬទេ?

[០៩:៣៧:១៤]

**ឆ៖** ជាទូទៅ ខ្ញុំមិនចូលចិត្តសន្និបាតទេ ខ្ញុំមិនចូលចិត្តតែម្តង ហើយអ៊ីចឹងខ្ញុំមិនសូវទៅ ហើយបើសិនជាខ្ញុំទៅ ខ្ញុំមានលក្ខខណ្ឌមួយ ត្រូវឲ្យខ្ញុំ។ ខ្ញុំធ្លាប់ទៅ-- ប្រទេសដែលខ្ញុំធ្លាប់ទៅ មានដូចជា ប្រទេសស៊ុយអែត ជាការប្រជុំអន្តរជាតិធំមួយរវាងប្រទេសជាច្រើនរយប្រទេស។ និយាយអំពីការផ្សះផ្សា និយាយអំពីគណៈកម្មការស្វែងរកការពិត និយាយអំពីយុត្តិធម៌ ហើយខ្ញុំធ្លាប់បានទៅប្រទេសស៊ុយអែតជាច្រើនដង។ នៅក្នុងកម្មវិធីនេះ ដែលជាកម្មវិធីមួយរបស់នាយរដ្ឋមន្ត្រីនៃប្រទេសស៊ុយអែតតែម្តង។ ខ្ញុំធ្លាប់ទៅចូលរួមប្រជុំនៅសាកលវិទ្យាល័យប៊ឺឃ្លី នៅសាលាផ្សេងៗ និយាយអំពីសាច់រឿង ជីវិតរបស់ប្រជាជននៅក្នុងក្រោយសម័យខ្មែរក្រហម។ ខ្ញុំធ្លាប់ទៅប្រទេសសៅអាហ្វ្រិក។ ខ្ញុំធ្លាប់ជួប ដេសមិនធូធូ។ ខ្ញុំធ្លាប់ទៅប្រទេសសោតអាហ្វ្រិកា ខ្ញុំធ្លាប់ទៅប្រទេសហ្កោហ្វេ ទៅអៀរឡង់ ប្រទេសច្រើន បើសិនជាលោកចង់ឲ្យខ្ញុំរៀបរាប់ ខ្ញុំរាប់តាមទ្វីបអ្វីក៏បាន អូស្ត្រាលី អាហ្វ្រិក នៅអាមេរិក នៅអឺរ៉ុប នៅអាស៊ីយើង ខ្ញុំធ្លាប់ទៅជាច្រើន។ ប៉ុន្តែជាទូទៅខ្ញុំសរសេរអត្ថបទខ្លីៗទេ ខ្ញុំចាំទៅ *ជឺនីវ៉ា* ខ្ញុំទៅហ្សឺណែវ។ ខ្ញុំសរសេរអត្ថបទនេះ គឺខ្លីមែន តែសំខាន់ចំពោះខ្ញុំ។ ករណីទីក្រុងហ្សឺណែវនេះ មានការជជែកគ្នា ថាតើតុលាការនេះ គួរនៅស្រុកខ្មែរ ឬក៏នៅទីក្រុងឡាអេ? ហើយកាលហ្នឹង ខ្ញុំតែឯង តែម្នាក់ឯងគត់ ដែលគិតថា តុលាការនេះ គួរតែនៅទីនេះ ថ្ងៃនេះ ដូចថ្ងៃហ្នឹង អ៊ីចឹង។

[០៩:៣៨:៤៦]

អ៊ីចឹង ខ្ញុំដើម្បីអះអាងគំនិតរបស់ខ្ញុំ ខ្ញុំបានសរសេរអត្ថបទមួយ។ អត្ថបទនោះខ្លីទេ ខ្ញុំនិយាយអំពីបើនៅតុលាការនៅទីក្រុងឡាអេ វាប្រយោជន៍យ៉ាងម៉េច? នៅវាស្រុកខ្មែរប្រយោជន៍យ៉ាងម៉េច? ប៉ុន្តែសំខាន់ចំពោះខ្ញុំណាស់ ពីព្រោះខ្ញុំចង់បានតុលាការមួយនៅទីនេះ ដើម្បីឲ្យប្រជាជនបានចូលរួមដូចសព្វថ្ងៃហ្នឹងអ៊ីចឹង។ អ៊ីចឹង អត្ថបទមួយហ្នឹង ខ្ញុំសរសេរនៅទីក្រុងហ្សឺណែវ អង្កាល់ណោះ លោក ថម ម៉ាសហាម៉ាប៊ឺក ជាអ្នកណែនាំឲ្យខ្ញុំចូលរួមសិក្ខាសាលានេះ។ ជាសិក្ខាសាលាតូចមួយជាមួយនឹងអង្គការសង្គមស៊ីវិលជាច្រើន ទៅពីស្រុកខ្មែរយើងក៏មានដែរ។

[០៩:៣៩:២០]

**សៈ** ខ្ញុំសូមអនុញ្ញាតសួរទៀត បន្តទៀត។ តើកន្លងមកមានសារព័ត៌មានជាតិ និងអន្តរជាតិធ្លាប់បានសម្ភាសលោកច្រើនដែរឬទេ? ហើយបើសិនជាមាន តើអត្ថបទសារព័ត៌មានណាឈ្មោះអ្វី ទាក់ទិននឹងរបបខ្មែរក្រហម តើបានសម្ភាសច្រើនទេ ជាមួយលោកកន្លងមក?

**ឆៈ** ខ្ញុំថាបើសិនជាលោកឆែក *ហ្គូហ្គល* ដូចច្រើន ទាំងអ្នកដែលមិនចូលចិត្តខ្ញុំក៏មាន អ្នកដែលចូលចិត្តក៏មាន។ ហើយវាជាការងាយ ខ្ញុំចូលចិត្តកាសែត ខ្ញុំមិនសូវចិត្តទូរទស្សន៍ទេ។ ខ្ញុំមិនចូលចិត្តឲ្យរូបខ្ញុំនៅក្នុងទូរទស្សន៍។ អ៊ីចឹង ខ្ញុំនិយាយជាមួយអ្នកកាសែតណា ក៏ខ្ញុំនិយាយដែរ ឲ្យតែគេសួរ គ្រប់ទាំងអស់។ ឧទាហរណ៍ លោកចង់ឲ្យខ្ញុំឧទាហរណ៍ពីរបីអី។

**សៈ** បាទ អញ្ជើញ!

**ឆៈ** ស៊ី.អ៊ិន.អ៊ិន ខ្ញុំចូលចិត្ត គ្រីស្ទៀន អាមិនផួ គាត់ជាអ្នកកាសែតស្រីម្នាក់ដែលខ្ញុំគិតថាគាត់ក្លាហាន អ៊ីចឹងគាត់បានមកធ្វើអត្ថបទមួយ អំពីរឿងអំពើប្រល័យពូជសាសន៍នៅក្នុងពិភពលោក ហើយខ្ញុំចូលចិត្តគាត់។ តាមដែលខ្ញុំចាំ គាត់បានសម្ភាសម្នាក់ទៀតដែរនៅក្នុងស្រុកខ្មែរយើង។ ខ្ញុំធ្លាប់បានសម្ភាសដោយកាសែត វ៉ាស៊ីនតោនប៉ុស្ត៍, ញូវយ៉កថែមស៍, ឌីផ្លូម៉ាត, អេ.ភី, អាហ្សង់ហ្វ្រង់ប្រេស រ៉ូយទ័រ, ក្បូដូញូវ, រស្មីកម្ពុជា យើងបាទ។ នៅក្នុងស្រុកយើងក៏មាន ស៊ី.ធី.អ៊ិន, ធី.វី.ខេ, អាស៊ា, ប៊ី.ប៊ី.ស៊ី មានច្រើន។

**សៈ** បាទ អរគុណលោក យុ។ ចំពោះសំណួរបន្ទាប់ទៀត ខ្ញុំសូមសួរលោកថា តើលោកធ្លាប់បានទទួលនូវមូលនិធិដែលទាក់ទិននឹងអំពើទប់ស្កាត់បទប្រល័យពូជសាសន៍នៅកម្ពុជាហ្នឹង កន្លងមកហ្នឹង លោកបានទទួលជំនួយហ្នឹងពីប្រភពណាខ្លះ?

[០៩:៤១:០៧]

**ឆៈ** ម្ចាស់ជំនួយដែលផ្តល់ជំនួយធំជាងគេ គឺសហរដ្ឋអាមេរិក។ សហរដ្ឋអាមេរិកមិនគ្រាន់តែរដ្ឋាភិបាល តាមរយៈព្រឹទ្ធសភាទេ នៅក្នុងអង្គភាពមួយចំនួនក៏ខ្ញុំបានទទួលដែរ។ នៅក្នុងសហរដ្ឋអាមេរិកគេមានប្រព័ន្ធមួយគឺជារៀងរាល់ឆ្នាំ សភាអាមេរិកបានកំណត់ថវិកាមួយដើម្បីចំណាយទៅលើកិច្ចការមួយ ហើយខ្ញុំបានទទួលថវិកានេះនៅក្នុងសព្វថ្ងៃនេះ នៅក្នុងទេយ្យទានរបស់យើងពីថ្ងៃនេះ គឺមានទឹកប្រាក់ជាងបួនលានដុល្លារ។ ទឹកប្រាក់បួនលានដុល្លារនេះ គឺយើងតម្កល់ទុកដើម្បីឲ្យមានការប្រាក់កើនឡើងជាប្រចាំឆ្នាំ ហើយយើងអាចធ្វើកិច្ចការនេះជាអចិន្ត្រៃយ៍។ នៅក្នុងរដ្ឋាភិបាលអាមេរិកដែរ ខ្ញុំបាន

ទទួលថវិកាមកពីការិយាល័យប្រជាធិបតេយ្យសិទ្ធិមនុស្ស ហើយនិងពលកម្ម ដែលផ្តល់ថវិកាសម្រាប់ណែនាំ ជូនអ្នកស្រុកមក។ អ្នកស្រុកហ្នឹងគឺថាយើងអញ្ជើញអ្នកស្រុកៗមកចូលរួមសវនាការទៅប្រជុំជាមួយគាត់អ៊ីចឹង ឲ្យគាត់បានឃើញបានឮ។ ហើយខ្ញុំក៏បានទទួលថវិកាពីអាស៊ីប៉ាស៊ី-- អាស៊ីខាងកើត អាស៊ីប៉ាស៊ីហ្វិកខាងកើតក៏ជាប្រភពមូលនិធិដែលបានផ្តល់មកឲ្យយើងពីដំបូងដែរ។ ហើយខ្ញុំក៏ធ្លាប់បានទទួលមកពីផ្នែកជាថវិកាមួយអំពីការប្រឹក្សា ដែលរៀបចំឡើងដោយលោកព្រឹទ្ធសភា បាកឃ្លី ហ៊ី គាត់ជាព្រឹទ្ធសភាមួយដែលមានអំណាចនៅសហរដ្ឋអាមេរិក គាត់បានបង្កើតជាមូលនិធិមួយ សម្រាប់អ្នកដែលរងគ្រោះដោយសង្គ្រាម និងការផ្សះផ្សា ហើយខ្ញុំក៏ធ្លាប់បានទទួលថវិកាពីគាត់ដែរ។

[០៩:៤២:៤៣]

អ៊ីចឹងសហរដ្ឋអាមេរិកនេះ ថវិកាទាំងអស់នេះ បានមកបន្ថែមលើថវិកាដែលអង្គការអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិកដែលហៅកាត់ថាយូ.អេស.អេ.អាយ.ឌី ដែលជាទូទៅខ្ញុំបានទទួលប្រាក់ពីគាត់ចំនួនបួនសែនដុល្លារក្នុងមួយឆ្នាំទៀតផង អស់រយៈពេលជាច្រើនឆ្នាំ។ អ៊ីចឹងថវិកាដែលធំបំផុតគឺសហរដ្ឋអាមេរិក។

ទីពីរ គឺប្រទេសស៊ុយអែត តាមរយៈអង្គការស៊ីប៉ា គឺថាប្រទេសស៊ុយអែតនេះបានជួយផ្តល់ថវិកាឲ្យយើងអស់រយៈពេលជាងដប់ឆ្នាំហើយ។ សូមលោកចាំថា ឯកសារដែលខ្ញុំយកទៅហ្វូតូកូពីស្កេនមកឲ្យតុលាការនេះ គឺជាថវិការបស់ប្រទេសស៊ុយអែត ដែលខ្ញុំបានចំណាយអស់ជិតបីសែនដុល្លារក្នុងការរៀបចំឯកសារជូនដល់តុលាការនេះ។ ហើយប្រទេសស៊ុយអែតនេះ គឺបានផ្តល់ថវិកាមកយើងបើយើងគិតទៅជាលំដាប់ទីពីរ។

[០៩:៤៣:៣២]

ទីបី គឺប្រទេស បែលហ្សិក គឺជាប្រទេសដែលផ្តល់ថវិកាឲ្យយើងសម្រាប់បណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រជាង ៣ពាន់នាក់ និងផ្សព្វផ្សាយការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅក្នុងថ្នាក់មធ្យមសិក្សា និងថ្នាក់វិទ្យាល័យ។

ទីបួន គឺប្រទេសន័រវែស គឺជាប្រទេសទីមួយដែលគាំទ្រឲ្យខ្ញុំបង្កើនទស្សនាវដ្តីស្វែងរកការពិត។ ពីព្រោះនៅពេលដែលខ្ញុំបង្កើតទស្សនាវដ្តីការពិតនេះ មានការជែកគ្នាថា តើបើយើងផ្សព្វផ្សាយព័ត៌មាននេះ តើអាចមានអ្នកដែលមិនសប្បាយចិត្ត ឬក៏សប្បាយចិត្តយ៉ាងដូចម្តេច? ប្រទេសន័រវែស គឺជាប្រទេសទីមួយដែលគាំទ្រជំរុញឲ្យមានការពិភាក្សារឿងនេះ ជាសាធារណៈ ហើយជាអ្នកផ្តល់ថវិកាឲ្យខ្ញុំ

ដើម្បីថតចម្លងឯកសារជាហ្វីល ដើម្បីរក្សាទុកឲ្យបានគង់វង្ស ប្រទេសន័រវែស។

[០៩:៤៤:២៤]

ប្រទេសមួយទៀត គឺប្រទេសដេនម៉ាក គឺជាអ្នកផ្តល់ថវិកាឲ្យធ្វើការជាមួយនឹងសហគមអ៊ីស្លាម។ បានយើងបានធ្វើការជាមួយសហគមន៍អ៊ីស្លាមនេះ ទូទាំងវិហារ ទូទាំងប្រទេសតែម្តង។ យើងមានកញ្ញា ហ្វារីណា ដែលជាអ្នកសិក្សាអំពីកិច្ចការអាស៊ីអាគ្នេយ៍នេះ ជាអ្នកគ្រប់គ្រងកម្មវិធីទាក់ទងទៅនឹងក្រុមសាសនាអ៊ីស្លាម ហើយនិងជនជាតិភាគតិច។

បន្តមកទៀតមានប្រទេស ដេនម៉ាក បែលហ្សិក ន័រវែស ប្រទេសដទៃទៀតដូចជា អង់គ្លេស។ ប្រទេសអង់គ្លេសក៏ផ្តល់ថវិកាដែរ ប្រទេសកាណាដា អូស្ត្រាលី រហូតដល់ប្រទេសគុយវ៉ែត ក៏មានដែរ។ ប្រទេសគុយវ៉ែតក៏ធ្លាប់បានផ្តល់ថវិកាមកមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ នេះគ្រាន់តែជាត្រួសៗ ហើយបើសិនជាលោកត្រូវការលម្អិត បើសិនជាលោកប្រធានតុលាការអនុញ្ញាត យើងអាចទូរស័ព្ទទៅ *អូហ្វហ្វីស* ខ្ញុំ គេអាចធ្វើជាសវនកម្ម របាយការណ៍ប្រចាំឆ្នាំជូនលោកក៏បាន ជាលម្អិត។

**ស៖** អរគុណលោក ឆាំង យុ។ តើលោកអាចបញ្ជាក់បន្ថែមទាក់ទងនឹងមូលនិធិដែលបានទទួលហ្នឹង តើមានការគ្រប់គ្រងដោយគណៈមូលនិធិ ហៅថា “*បត អូហ្វ ត្រាស់ធី* ឬក៏អត់ទេ? ឬក៏គ្រប់គ្រងរបៀបម៉េច? ឬដកលុយរបៀបម៉េច ពាក់ព័ន្ធនឹងបញ្ហាមូលនិធិ ដែលលោកបានទទួលជំនួយពីអន្តរជាតិនេះ?

[០៩:៤៥:៣៦]

**ឆ៖** យើងមានអគ្គនាយកម្នាក់ ដែលគ្រប់គ្រងរឿងប្រព័ន្ធគ្រប់គ្រងគណនេយ្យ គឺលោកសាស្ត្រាចារ្យ ហេង វ៉ាន់ដា។ គាត់គឺជានាយកសាកលវិទ្យាល័យគណនេយ្យ ហេង វ៉ាន់ដា សព្វថ្ងៃនេះ។ បាទគាត់ជាអ្នកមើលអំពីប្រព័ន្ធគណនេយ្យ ហើយយើងមានការគ្រប់គ្រងអំពីសវនកម្មអន្តរជាតិ ហើយនិងស្ថាប័ន យូ.អេស.អេ.អាយ.ឌី អង្គការអភិវឌ្ឍន៍។ ថវិកាដែលចូលមកនេះ គឺយើងមានប្រព័ន្ធមួយ ហើយប្រព័ន្ធនេះគឺត្រូវបានត្រួតពិនិត្យ ហើយត្រូវបានទទួលស្គាល់ថាជាប្រព័ន្ធមួយដែលគ្មានអំពើពុករលួយ ខាងបណ្តាប្រទេសជំនួយហ្នឹងគេបានធ្វើការវាយតម្លៃ ឬក៏វាយតម្លៃស៊ើបអង្កេត ដែលយើងខ្ចីទាំងមូលហ្នឹង អាពាក្យខ្មែរយើងហ្នឹងវាមានច្រើនយ៉ាង។ តែគេបានមកមើលហើយ គេគិតថា នេះគឺជាប្រព័ន្ធមួយដែលត្រឹមត្រូវ។

[០៩:៤៦:២៨]

ជាទូទៅនៅក្នុងការចំណូលចំណាយ យើងមានក្រុមគណនេយ្យមួយដែលឯករាជ្យ ហើយជាទូទៅយើងសួរយោបល់អំពីលោកសាស្ត្រាចារ្យ ហេង វ៉ាន់ដា បើសិនជាមានបញ្ហាណាមួយ ឬក៏មានការផ្លាស់ប្តូរ ឬយ៉ាងដូចម្តេច។ ជាទូទៅប្រទេសទាំងអស់គេសហការ គ្រប់គ្រងយើងអំពីថវិកានេះ។ សហរដ្ឋអាមេរិក គឺជាប្រទេសមួយដែលមានលក្ខខណ្ឌខ្ពស់មែនទែន តឹងតែងមែនទែន។ សូម្បីតែជិះឡានមកសវនាការនេះអត់កត់លេខ ក៏ឲ្យត្រូវសងគេដែរ។ ពេលជិះឡានមកសវនាការនេះ គឺខ្ញុំត្រូវចុះនៅក្នុងបញ្ជីមួយ ថាចេញពី*អូហ្វហ្វីស* ម៉ោងប្រាំពីរកន្លះ មកដល់ អ៊ុ.ស៊ី.ស៊ុ.ស៊ី ម៉ោងប្រាំបួន ហើយត្រឡប់ទៅវិញម៉ោងប៉ុន្មាន។ កាលណាយើងមិនបានចុះអាហ្នឹង គេគិតថា អាហ្នឹងជា *មីស យូស អូហ្វ ហ្វាន់* គឺថាយើងមិនចំណាយថវិកាមិនត្រូវខ្ទង់ ហើយគេពិន័យ វាតឹងតែង។

[០៩:៤៧:១៨]

អ៊ីចឹងជាទូទៅ ប្រទេសដទៃទៀតចាំមើលការធ្វើសវនកម្ម អំពីប្រទេសសហរដ្ឋអាមេរិក ហើយប្រទេសស៊ុយអែត ជាអ្នកធ្វើសវនកម្មទៅលើការគ្រប់គ្រង។ មានបុគ្គលិកប៉ុន្មាននាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន មានការគោរពសិទ្ធិនារីដែរ ឬក៏អត់? មានការបំពាក់បំប៉នបុគ្គលិកដែរឬក៏អត់? ជាច្រើនទៀត។ អ៊ីចឹងអ៊ី នៅក្នុងនេះគេមាននៅក្នុង ពេលដែលយើងដាក់សំណើទៅ នៅពេលដែលគេ *អាប់ព្រូ* ឬក៏សម្រេចលើសំណើរបស់យើង គេមានភ្ជាប់មកនូវកិច្ចសន្យាមួយ ថាយើងត្រូវតែធ្វើតាមអំពីអ្វីដែលយើងបានស្នើសុំ ហើយចំណាយទៅតាមខ្ទង់ដែលយើងបានស្នើសុំ។ អ៊ីចឹងយើងធ្វើកិច្ចការនេះជាងដប់ឆ្នាំហើយ។

[០៩:៤៨:០៥]

**ស៖** បាទ អរគុណ។ សូមលោកជួយបញ្ជាក់អំពី តើលោកបានធ្លាប់ធ្វើការងារជាមួយនឹងក្រុម *អាហ្វីម៉ាធីវគ្រុប* ដែរឬទេ? *អាហ្វីម៉ាធីវគ្រុប* ទាក់ទងនឹងបញ្ហានេះ គឺជាក្រុមដែលទាក់ទងនឹងការគ្រប់គ្រងឯកសារ ដែលជាឯកសារ *ឌៀប* និងការប្រឈមជាមួយអតីតកាល *អ៊ិន ឌី ផាស* កន្លងមកនេះ។

**ឆ៖** សូមអធ្យាស្រ័យ បាទគឺ *អាហ្វហ្វីនីធីគ្រុប* គឺជា-- យើងបានកើតគំនិតមួយ ពីព្រោះខ្ញុំបានធ្វើការនៅប្រទេសផ្សេងៗទៀត ហើយខ្ញុំបានជួបអង្គការផ្សេងៗទៀត ដែលមានការចាប់អារម្មណ៍ប្រហាក់ប្រហែលគ្នា។ ហើយខ្ញុំបានឃើញថា ប្រទេសទាំងអស់គួរតែរៀនសូត្រពីគ្នាទៅវិញមក ចែករំលែកនៅក្នុងបរិបទប្រទេសរៀងៗខ្លួន ប៉ុន្តែបច្ចេកវិទ្យាអាចចម្លងគ្នាបាន។ អ៊ីចឹងយើងក៏មានគំនិតមួយបង្កើតជាក្រុមមួយ ដែលយើងរួមប្រជុំគ្នាមួយឆ្នាំទៅតាមប្រទេសផ្សេងៗនៃម្ចាស់ នៃអង្គការដែលខ្លួន

មានទីតាំង។

[០៩:៤៩:០៥]

អ៊ីចឹងក្រុមនេះ យើងខ្ញុំបានចូលរួម។ ខ្ញុំបានចូលរួម។ ខ្ញុំធ្លាប់ទៅប្រទេសក្វាតេម៉ាឡា ខ្ញុំធ្លាប់ទៅប្រទេសអ៊ីរ៉ាក់, ភូមា ប្រទេសផ្សេងៗទៀតនៅអាហ្វ្រិក រវ៉ាន់ដា ខ្ញុំធ្លាប់ទៅ។ ហើយយើងបានប្រជុំគ្នាដកពិសោធន៍ទៅវិញទៅមក ដើម្បីធ្វើយ៉ាងណា ដូចជា ក្វាតេម៉ាឡា គេសង្កត់ធ្ងន់ការងាររបស់គេទៅលើ *ហ្វ័រែនស៊ិក* ទៅលើការកោសល្យវិច័យឆ្អឹង។ អ៊ីចឹងគេ ជំនាញគេធ្វើតែកិច្ចការហ្នឹងទេ ប៉ុន្តែគេរៀនសូត្រពីយើងអំពីការផ្សព្វផ្សាយ ការធ្វើទស្សនាវដ្តីផ្សេងៗ ហើយខ្ញុំក៏បានជួយរៀបចំឯកសារនៅប្រទេសក្វាតេម៉ាឡាដែរ ហើយឯកសារនេះសព្វថ្ងៃ គឺយើងទុកនៅសាកលល័យវិទ្យាច្បាប់ នៅអូស្ទីន ក្នុងរដ្ឋតិចសាស។

[០៩:៤៩:៤៨]

អ៊ីចឹង ខ្ញុំធ្លាប់ចូលរួមក្រុមនេះ ហើយខ្ញុំក៏ជាអ្នកមានចំណែករៀបចំក្រុមនេះដែរ។ ក្រុមនេះ សូមបញ្ជាក់បន្តិច ជាក្រុមស្ម័គ្រចិត្ត។ អ៊ីចឹងពេលណាយើងចង់ទៅណាអ៊ីចឹង យើងធ្វើជាគម្រោងមួយ ហើយយើងក៏បើសិនជាបានថវិកា ក៏យើងទៅប្រជុំទៅ។

**ស៖** បាទ សូមអរគុណ។ សំណួរមួយទៀតគឺ តើលោកធ្លាប់បានធ្វើដំណើរទៅកន្លែងផ្សេងទៀតនៅជុំវិញពិភពលោកហ្នឹង ដើម្បីផ្តល់យោបល់ ឬក៏ពិគ្រោះយោបល់ ទាក់ទិនហ្នឹង ឬក៏ការគាំទ្រទាំងស្មារតី ដូចសម្ភារៈទាក់ទិននឹងការប្រមូលភស្តុតាង ស្តីពីអំពើសាហាវយង់ឃ្នង ក្នុងទ្រង់ទ្រាយធំដែរឬទេ? បើសិនជាមាននៅកន្លែងណាខ្លះ? ហើយក្នុងបំណងអ្វីខ្លះ?

[០៩:៥០:២៨]

**ឆ៖** ជាទូទៅបើសិនជាពាក់ព័ន្ធដល់បញ្ហានេះ គឺអ្នកស្រីឯកអគ្គរដ្ឋទូតប្រទេសហូឡង់ ណាធីត្យាវ៉ាន់ដឹម អាស្វ៊ូម គាត់គឺជា កាលនោះគាត់គឺនៅក្នុងឆ្នាំ-- សូមទោសបើសិនជាខ្ញុំច្រឡំឆ្នាំ បើមិន៩៨ ទេ ៩៩ គឺអ្នកស្រីឯកអគ្គរដ្ឋទូតរូបនេះ គិតថា ខ្ញុំនឹងអាចរៀនសូត្របានច្រើនអំពីស្តង់ដារអន្តរជាតិបើសិនជាខ្ញុំទៅកាន់តុលាការអន្តរជាតិនៅទីក្រុងឡាអេ ទៅ អាយ.ស៊ី.ធី.វ៉ាយ។ អ៊ីចឹង គាត់ក៏គិតថា ខ្ញុំគួរតែទៅទីនោះ ហើយដោយសារតែប្រទេសហូឡង់ គឺជាប្រទេសមួយដែលបានជួយយើងដែរ។ ខ្ញុំក៏បានទៅទីនោះ ហើយខ្ញុំទៅទីនោះ ខ្ញុំបានជួបជាមួយនឹងសហព្រះរាជអាជ្ញា ជួបមួយនឹងក្រុមការពារ ដូចជាតុលាការយើងអ៊ីចឹង។

[០៩:៥១:១៨]

ហើយខ្ញុំបាន ខ្ញុំចាំច្បាស់អង្កាល់ហ្នឹង ខ្ញុំបានទៅជួបជនជាតិអូស្ត្រាលីម្នាក់ឈ្មោះ ឃីត រ៉ូដស៊ីន តាមដែលខ្ញុំច្បាស់ *ឡាស់ណេម* គាត់។ គាត់គឺជាអ្នកកាន់ខាងភស្តុតាង ហើយខ្ញុំបានជួបខាងក្រុមស្រាវជ្រាវ សុំទោស! ខ្ញុំភ្លេចឈ្មោះគាត់ដែរ ប៉ុន្តែខ្ញុំអាចរកឃើញ បើសិនជាលោកត្រូវការ។ ពេលខ្ញុំទៅដល់ទីនោះ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ពីព្រោះខ្ញុំគិតថា នេះជាតុលាការអន្តរជាតិ ប៉ុន្តែទៅដល់សុទ្ធតែស្បែកស អត់មានពួកណាដែលអាស៊ី ឬក៏ជាពួកស្បែកខ្មៅសោះ។ ទៅកន្លែងណាក៏អូស្ត្រាលី ទៅកន្លែងណាក៏អាមេរិកាំងដែរ នៅកន្លែងធំៗ។ អ៊ីចឹង ខ្ញុំមានការភ្ញាក់ផ្អើលបន្តិច ខ្ញុំសួចថា ចុះអ្នកដែលប្រទេសផ្សេង គេអត់មានឃើញមានតំណែងនៅក្នុងតួនាទីសំខាន់ៗនៅក្នុងប្រព័ន្ធតុលាការនេះ។ ហើយក្រោយមក គាត់ក៏បានបង្ហាញខ្ញុំ អំពីការរៀបចំទុកដាក់ឯកសារឲ្យបានត្រឹមត្រូវ។ ហើយបង្ហាញប្រាប់ខ្ញុំអំពីការសិក្សាស្រាវជ្រាវ ហើយបាន ខ្ញុំបានជួបជាមួយនឹងសហព្រះរាជអាជ្ញា ដូចជាឈ្មោះគាត់ ចន រ៉ែលសាន់ ខ្ញុំភ្លេចឈ្មោះគាត់ជនជាតិអូស្ត្រាលីបាទ ចន រ៉ែលសាន់។ ខ្ញុំសួរថា តើខ្ញុំត្រូវធ្វើយ៉ាងម៉េចនៅស្រុករបស់ខ្ញុំមានអំពើកើតឡើង ហើយមានមនុស្សជាច្រើនបាននិយាយថា មានការកាប់សម្លាប់មនុស្សរាប់លាននាក់ តើយើងធ្វើម៉េចទៅដើម្បីបានយុត្តិធម៌? ខ្ញុំចាំអត់ភ្លេចទេ គាត់ប្រាប់ខ្ញុំ។ គាត់ប្រាប់ខ្ញុំថា កុំសួរអ្នកណាទាំងអស់ ចាំតុលាការទៅដល់។ ខ្ញុំគិតថា បើចាំតុលាការមក យើងចាំ៣០ឆ្នាំហើយហ្នឹង ហើយកាលណាបានមក? ចុះប្រជាជនដែលចង់ដឹងការពិត គិតយ៉ាងដូចម្តេច?

[០៩:៥២:៥៤]

ខ្ញុំទៅប្រទេសស៊ុយអែត ក៏អ៊ីចឹងដែរ គេនិយាយអំពីការផ្សះផ្សាជាតិអីផ្សេងៗ និយាយអំពីគណៈកម្មការស្វែងរកការពិត។ ពេលដែលខ្ញុំសួរទៅលោក អាឡិច បូរេន គាត់ជាអ្នកមនុស្សម្នាក់ ជាស្ថាបនិកម្នាក់ នៃគណៈកម្មការស្វែងរកការពិតនេះ ហើយខ្ញុំក៏បានជួបជាមួយលោកបុព្វជិត ដេសមិន ធូធូ ដែរ។ ខ្ញុំសួរថា តើអ្វីទៅដែលជាមូលដ្ឋានក្នុងការបង្កើតឲ្យមានគណៈកម្មការស្វែងរកការពិត? គាត់ថា យើងត្រូវផ្អែកទៅលើវប្បធម៌ និងការចង់បានរបស់ប្រជាជន។

ពេលខ្ញុំសម្លឹងមើលទៅគណៈកម្មការស្វែងការពិតទាំង១៦ នៅក្នុងពិភពលោក លើកលែងតែប្រទេសម៉ូរ៉ុក្កូ ប្រទេសទាំងអស់សុទ្ធតែជាអ្នកកាន់សាសនាគ្រីស្ត។ ដូច្នេះ ការអត់ឱន ការលើកលែងរបស់គេខុសអំពីយើង ប្រជាជនខ្មែរយើងដែលជាអ្នកកាន់សាសនាព្រះពុទ្ធសាសនា។ អ៊ីចឹង ខ្ញុំបានរៀនសូត្រ ខ្ញុំបានគិត ខ្ញុំបានពិចារណាថាធ្វើយ៉ាងណាដើម្បីឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ក្លាយទៅជា

កន្លែងមួយដែលមានស្តង់ដារអន្តរជាតិ ដែលអាចចែករំលែកបទពិសោធន៍ប្រទេសរបស់យើង មិនឲ្យមានការខ្មាសអៀនពីអតីតកាល ដើម្បីឲ្យយើងបានផ្សះផ្សា ហើយដើរទៅមុខទាំងអស់គ្នា។ ខ្ញុំបានទៅប្រទេស ជាប្រទេសច្រើន លោកចង់ឲ្យខ្ញុំនិយាយប៉ុន្មានប្រទេសឥឡូវ? ព្រោះវាច្រើនពេក។

[០៩:៥៤:១៣]

**សៈ** អាចរៀបរាប់បានតិចតួចបាទ ពីរបីប្រទេស។

**ឆៈ** ពីរបីប្រទេសទៀត។ ខ្ញុំទៅភូមា នៅជិតយើងម្តង ខ្ញុំទៅភូមា ខ្ញុំចូលចិត្តភូមា ខ្ញុំទៅរាល់ឆ្នាំ ខ្ញុំទៅនៅតែទៅអ៊ីចឹងរាល់ថ្ងៃហ្នឹង។ នៅភូមាគេឲ្យ គេសួរខ្ញុំថា រៀបចំឯកសារយ៉ាងម៉េច? ព្រោះគេចាប់អារម្មណ៍ពីរឿងការរៀបចំឯកសារ។ ហើយប្រទេសភូមានេះ គឺមាន-- ដូចយើងដឹងស្រាប់ហើយ ខ្មែរយើងក៏មានដើមកំណើតមនដែរ អ៊ីចឹងពេលដែលខ្ញុំទៅហ្នឹងវាហាក់ដូចជាផ្សាភ្ជាប់ជាមួយភូមាហ្នឹង លឿនជាងប្រទេសថៃ និងប្រទេសផ្សេងៗដែលខ្ញុំបានទៅដល់ ដោយសារគេគិតថា ខ្ញុំជាជនជាតិមន តែខ្ញុំមិនចេះភាសាភូមាទេ។ អ៊ីចឹង ខ្ញុំបានជួបភូមាហ្នឹង ទាំងនៅក្នុងប្រទេស ទាំងនៅតាមជំរំនៅឈៀងម៉ៃ ព្រោះមានភូមាមួយចំនួននៅតាមជំរំ មួយចំនួនទៀតនៅក្នុងប្រទេស។ ខ្ញុំថាដើម្បី-- ខ្ញុំបានបង្ហាញអំពីការរៀបចំឯកសារ ការចងក្រងទិន្នន័យអ៊ីចឹងហូរហែទៅ ខ្ញុំប្រាប់ជាច្រើនដង ហើយក៏យើង គេចាប់អារម្មណ៍អំពីការផ្សះផ្សារនិងសន្តិភាព ក៏គេបានមកការិយាល័យរបស់ខ្ញុំជាហូរហែអ៊ីចឹងទៅប្រទេសភូមា។ អ៊ីចឹង ប្រទេសភូមាមួយ ខ្ញុំច្រើននិយាយអំពីឯកសារ។ ប្រទេសបារាំង-- សូមបញ្ជាក់បន្តិចបានទេ ត្រឡប់ទៅថវិកាវិញខ្ញុំចង់និយាយកន្លែងនេះបន្តិចបានទេ? ពីរឿងប្រាក់ជំនួយ ខ្ញុំសូមបញ្ជាក់ថាមានប្រទេសជាច្រើនបានផ្តល់ថវិកាមកឲ្យយើង លើកលែងតែប្រទេសបារាំង។ ប្រទេសបារាំងគឺជាប្រទេសតែមួយគត់ដែលមិនអើពើដែលមិនបានជួយដល់ដំណើរការនៃការប្រមូលឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ ខ្ញុំសូមបញ្ជាក់កន្លែងហ្នឹងបន្តិច បារាំង។

[០៩:៥៥:៤៨]

ត្រឡប់មករឿងយើងវិញ ខ្ញុំទៅប្រទេស *សៅអាហ្វ្រិកកា* ខ្ញុំទៅ ខេនយ៉ា ប្រទេសខេនយ៉ាអាហ្វ្រិក ខ្ញុំទៅយូហ្កាន់ដា ខ្ញុំទៅ ខាំផាឡាៗនេះ ខ្ញុំទៅប្រជុំជាមួយនឹងខាង អាយ.ស៊ី.ស៊ី។ ខាងតុលាការអន្តរជាតិហើយខ្ញុំនិយាយអំពីប្រធានបទ សង្គ្រាម ទាក់ទងនឹងសន្តិភាព។ ហើយកាលណោះខ្ញុំចាំច្បាស់ ព្រោះថានៅក្នុងក្រុមខ្ញុំហ្នឹង បួននាក់សុទ្ធតែប្រុសៗ និយាយអំពីរឿងសន្តិភាព។ អ៊ីចឹង ខ្ញុំឡើងនិយាយភ្លាម ខ្ញុំ *ខំផ្លេន* ខ្ញុំថា ចុម! អត់មានស្ត្រីណាម្នាក់នៅក្នុងក្រុមនេះ និយាយអំពីសន្តិភាព ពីព្រោះស្ត្រីគឺជា

អ្នករងគ្រោះច្រើនជាងគេ ដូចនៅស្រុកយើងអ៊ីចឹង។ ៧៩ ស្ទួរថា៦០ភាគរយ ជាស្ត្រីមេម៉ាយ និងកុមារកំព្រាជាងពីរសែននាក់ ហេតុអីក៏ស្ត្រីគ្មានតួនាទីនិយាយអំពីសន្តិភាពនៅក្នុងអង្គវេទិកានេះ? ពេលខ្ញុំលើកឡើងអំពីបញ្ហានេះ ស្រាប់តែគេឲ្យស្ត្រីម្នាក់ ខ្ញុំភ្លេចគាត់មិនដឹងជាជនជាតិអីទេ មកអង្គុយពីក្រោយដើម្បីថតរូប ដើម្បីឲ្យឃើញស្ត្រីម្នាក់នៅក្នុងជួរហ្នឹងដែរ។ ហើយខ្ញុំ-- អ្នកដែលមិនដឹង បើសិនជាមើលនៅក្នុងវេបសាយ គិតថាគាត់ជាវាគ្មិន ប៉ុន្តែមិនមែនទេ គាត់គ្រាន់តែជាអ្នកអង្គុយឲ្យឃើញថាមានស្ត្រីនៅក្នុងប្រធានបទនេះ។ អ៊ីចឹងនៅពេលដែលខ្ញុំទៅប្រជុំប្រទេសផ្សេងៗហ្នឹង មានរឿងរ៉ាវច្រើនដែលខ្ញុំបានរៀនសូត្រអំពី គេហៅថា “តើពិភពលោកគិតយ៉ាងដូចម្តេចចំពោះប្រជាជាតិមួយ ចំពោះប្រទេសមួយដលឆ្លងកាត់ការលំបាកវេទនា ហើយដោះស្រាយយ៉ាងម៉េច?” អ៊ីចឹងខ្ញុំគិតថា ទោះបីយើងត្រូវការជំនួយពីខាងក្រៅ យល់ថានេះជារឿងរបស់សាកលភាវរូបនីយកម្មយ៉ាងណាក៏ដោយ ទីបំផុត យើងដែលជាអ្នករងគ្រោះ ដែលជាអ្នករស់រានមានជីវិត ត្រូវតែធ្វើដោយខ្លួនឯង គ្មានអ្នកណាធ្វើឲ្យយើងទេ ព្រោះខ្ញុំឃើញផ្ទាល់នឹងភ្នែក។

[០៩:៥៧:៣៣]

ខ្ញុំទៅប្រទេសកាណាដា ខ្ញុំប្រជុំនៅម៉ៅហ្គៀល សាលាច្បាប់ដ៏ល្បីបំផុត មានធ្វើសុន្ទរកថាដោយលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន, លោក ដាឡែ ដែលទាក់ទងនឹងរឿងការសម្លាប់រង្គាលនៅរវ៉ាន់ដា និងលោកផ្សេងៗទៀត។

ខ្ញុំចាំថាកាលណោះពេលដែលយើងកំពុងតែនិយាយស្រាប់តែប៉ុស្តិ៍ ប៊ី.ប៊ី.ស៊ី ផ្សាយអំពីការវាយដំទៅលើព្រះសង្ឃនៅប្រទេសភូមា។ អ៊ីចឹង យើងទាំងអស់គ្នាបង្វែរអារម្មណ៍ទៅមើលទូរទស្សន៍ទាំងអស់គ្នា។ ហើយនាំគ្នានិយាយថា មានអំពើព្រៃផ្សៃមួយទៀតកើតឡើងហើយ យើងត្រូវតែដោះស្រាយបញ្ហានេះ។ ក្រោយពីការប្រជុំទាំងអស់គ្នាទៅផ្ទះ ទៅហូបកាហ្វេ ហើយមិនដែលឃើញសកម្មភាពណាមួយកើតឡើងសោះមកទល់សព្វថ្ងៃនេះ។ អ៊ីចឹងការដែលខ្ញុំទៅប្រជុំនេះ ខ្ញុំរៀនសូត្រ ខ្ញុំបានឃើញ ហើយធ្វើយ៉ាងណាឲ្យកិច្ចការរបស់យើងនេះ ទទួលខុសត្រូវដោយខ្លួនឯង ឯករាជ្យដោយខ្លួនឯង។

[០៩:៥៨:២៨]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសាក្សី! សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា សូមទោសការពារក្តីលោក អៀង សារី។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោកចៅក្រម។ សូមអភ័យទោសក្នុងការរំខាននេះ សែសិននាទីនេះ គឺថាចម្លើយនេះគឺដាក់ក្នុងបរិបទមួយគឺថាជាខ្លឹមសារដែលមិនទាក់ទង ដូច្នេះ ហើយគឺជាការមិនសមរម្យ ដើម្បីសួរឲ្យគាត់ឆ្លើយបែបនេះ។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះ គឺថាមានសណ្តានចិត្តល្អណាស់ដែលថា ឲ្យមួយថ្ងៃសម្រាប់គាត់ ប៉ុន្តែសម្រាប់ថ្ងៃនេះទាក់ទងទៅនឹងអង្គហេតុដែលសហព្រះរាជអាជ្ញាគឺថា មិនបានសួរឲ្យចំសាច់រឿង ហើយសាក្សី លោកជម្រាបពីព័ត៌មានដែលមិនទាក់ទង ហើយនៅទីបំផុតហ្នឹងគឺថា យើងមិនអាចមានការតវ៉ាថា មិនមានពេលគ្រប់គ្រាន់ក្នុងការបញ្ចប់ការងាររបស់គាត់ទេ នេះសហព្រះរាជអាជ្ញា។ ដូច្នេះគឺថាអាចនឹងគួរឲ្យចាប់អារម្មណ៍ជាការសន្ទនាគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែវាគួរតែនៅក្រៅតុលាការទេ ពីព្រោះថាព័ត៌មានភាគច្រើនមិនពាក់ព័ន្ធនៅក្នុងវគ្គសវនាការនេះ។ អ៊ីចឹងសូមតុលាការណែនាំឲ្យព្រះរាជអាជ្ញាសួរសំណួរដែលទាក់ទង ឬក៏អាចរំឭកសាក្សីឲ្យលោកឆ្លើយតបទៅនឹងអ្វីដែលជាប្រធានបទនៃសវនាការនេះ។ សូមអរគុណ។

[១០:០០:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនដែលលោកមេធាវីអត់ធ្មត់ ហើយរហូតដល់មួយម៉ោងនេះ ទើបនិយាយបញ្ហានេះ។ អង្គជំនុំជម្រះបានរំឭកគាត់ហើយ ហើយសហព្រះរាជអាជ្ញាមានពេលវេលាមួយថ្ងៃនេះ ដកមួយម៉ោងចេញទុកឲ្យដើមបណ្តឹងរដ្ឋប្បវេណី។ ហើយយើងបានអានម្តងហើយម្តងទៀត អំពីគោលបំណងនៃការស្តាប់សក្ខីកម្មសាក្សីរូបនេះ ដែលជាប្រធានមជ្ឈមណ្ឌលឯកសារដើម្បីសួរដេញដោលនូវសំណួរទូទៅពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការទទួលឯកសារ ការរៀបចំឯកសារជាកាតាឡុក និងការគ្រប់គ្រងឯកសារ និងរឿងប្រភេទឯកសារជាក់លាក់មួយចំនួនទៀតដែលផ្សេងទៀតដែលពាក់ព័ន្ធ។ យើងបានរំឭកម្តងហើយម្តងទៀត ប៉ុន្តែបញ្ហាគឺនៅតែចំណាយពេលវេលាដែលមិនពាក់ព័ន្ធទៅនឹងគោលបំណងនៃការសួរដេញដោលនៅថ្ងៃនេះ ប៉ុន្តែនេះជាការចំណាយពេលវេលាសម្រាប់គាត់។ អង្គជំនុំជម្រះនឹងតឹងតែងកំណត់ជាក់លាក់យ៉ាងតឹងរ៉ឹងអំពីពេលវេលា។ ដោយសារការប្រើប្រាស់ពេលវេលាមិនមានប្រសិទ្ធភាពពាក់ព័ន្ធបញ្ហាដែលត្រូវសួរដេញដោល។

សូមលោកតំណាងសហព្រះរាជអាជ្ញាជាតិ ផ្តល់គំនិតបញ្ញាស្មារតីធ្វើការតាំងសំណួរឲ្យពាក់ព័ន្ធទៅនឹងគោលបំណងនៃការស្តាប់សក្ខីកម្មសាក្សីរូបនេះ ដែលអង្គជំនុំជម្រះបានជូនដំណឹងរួចហើយ កាល

ពីម្សិលមិញ។ ហើយព្រឹកមិញ មុននឹងដាក់បញ្ហាឲ្យដេញដោល ដោយបារម្ភថាក្រែងលោកមានការមិនជាក់ច្បាស់ ទើបយើងជាប្រធានអង្គជំនុំជម្រះរំឭកសាជាថ្មីម្តងទៀត ដើម្បីតម្រង់ទិសដៅនៃការជជែកពិភាក្សាដេញដោលនេះឲ្យចំទៅតាមបំណងដែលអង្គជំនុំជម្រះបានកំណត់។

អង្គជំនុំជម្រះជឿជាក់ថា លោកសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាជាតិយល់ច្បាស់អ្វីដែលអង្គជំនុំជម្រះបានលើកនេះ។

ហើយសូមលោក ឆាំង យុ សូមលោកឆ្លើយឲ្យខ្លីៗតបនឹងសំណួរជាក់លាក់តែប៉ុណ្ណោះ ចៀសវាងការអត្ថាធិប្បាយវែង លើកលែងតែសំណួរណាដែលមានបំណងឲ្យលោកធ្វើអត្ថាធិប្បាយតែប៉ុណ្ណោះ។

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្តសំណួរតទៅទៀត បាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក យុ ខ្ញុំសូមអនុញ្ញាតសួរសំណួរលោក សំណួរខ្ញុំសល់មិនច្រើនទេ។ សូមលោកជួយបញ្ជាក់អំពីការទទួល និងកិច្ចដំណើរការឯកសារនៅក្នុងមជ្ឈមណ្ឌលឯកសាររបស់លោក។ តើមានកិច្ចដំណើរការយ៉ាងដូចម្តេចចាប់តាំងពីពេលទទួល និងការដំណើរការឯកសារហ្នឹង?

**ឆ៖** ខ្ញុំត្រូវបានប្រាប់ថាឲ្យនិយាយយឺត អ៊ីចឹងខ្ញុំសូមនិយាយយឺតៗបន្តិច។ ខ្ញុំថា ខ្ញុំអាចសុំឆ្លើយសំណួរនេះជាពីរវគ្គបានដែរ ឬក៏អត់។ ទីមួយដោយសារថា ពាក្យខ្មែរយើងវាសម្បូរបែប បើសិនជាយើងប្រើពាក្យថា ប្រមូលឯកសារចងក្រងទៅ វាមានន័យពីរ។ ដូចថាទីមួយ យើងទៅប្រមូល ទីពីរទៀតយើងយកមកធ្វើស្ទី។ អ៊ីចឹងលោកប្រធាន តើខ្ញុំអាច-- លោកសហព្រះរាជអាជ្ញា តើខ្ញុំអាចឆ្លើយជាពីរបានដែរឬទេ? គឺថាទីមួយនិយាយអំពីថា ខ្ញុំទៅប្រមូលយ៉ាងម៉េច? ប្រមូលបានហើយមកធ្វើស្ទី?

[១០:០៣:៣០]

**ស៖** ពិត ព្រោះចំណុចនេះសំខាន់ដែលខ្ញុំខាងដឹង ហើយសម្រាប់អង្គសវនាការក៏ចង់ដឹងចំណុចនេះសំខាន់ដែរ។ បាទ សូមអញ្ជើញ។ ហើយសូមមេត្តាឆ្លើយឲ្យបានខ្លីបន្តិច ព្រោះដោយសារតែពេលវេលា។ សូមអរគុណ។

**ឆ៖** ទីមួយ គឺយើង ដូចជាលោកអនុប្រធានខ្ញុំ វ៉ាន់ថាន់ ពៅដារ៉ា បានប្រាប់រួចហើយ គឺយើងធ្វើការសេចក្តីជាលាយលក្ខណ៍អក្សរជាសាធារណៈ ស្នើសុំឲ្យបុគ្គលស្ថាប័ន និងបណ្តាប្រទេសផ្សេងៗធ្វើ

ឯកសារមកឲ្យយើង ហើយចាប់នៅចាប់តាំងពីដែលអង្គជំនុំជម្រះនេះត្រូវបានបង្កើតឡើង គឺយើងបានស្នើថា សុំឲ្យបញ្ជូនមកឲ្យអង្គជំនុំជម្រះដោយផ្ទាល់ ដោយសារយើងចង់ឲ្យតុលាការនេះបានទទួលកិច្ចការនេះមុនគេ។

អ៊ីចឹងជាទូទៅ គឺមានអ្នកខ្លះយកមកឲ្យយើងក្នុងន័យជាប្រវត្តិសាស្ត្រ គាត់ថា គាត់មិនចង់ឈឺក្បាលរឿងតុលាការទេ។ អ៊ីចឹងយកទៅទុកប្រវត្តិសាស្ត្រ ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទៅ យកទៅធ្វើម៉េចក៏ធ្វើទៅ។ អ្នកខ្លះទៀតក៏យកមកឲ្យយើងហើយមានលក្ខខណ្ឌផ្សេងដូចជា ជាពិសេសគឺជាអ្នកថតខ្សែភាពយន្តជាដើម កាលណាគេឲ្យខ្សែភាពយន្តមកឲ្យយើង គេថានេះសម្រាប់តែការសិក្សាស្រាវជ្រាវ កុំថតបន្ត ឬក៏យកចម្លងរបស់គេ ពីព្រោះវាទាក់ទងនឹងការរក្សាសិទ្ធិជាដើម។ អ៊ីចឹងការប្រមូលឯកសារនេះ គឺយើងទៅកន្លែងផ្សេងៗ ទៅក្នុងស្រុកខ្មែរយើង ទៅក្រៅប្រទេស តាមរយៈមិត្តភក្តិ តាមរយៈអ្នកដែលស្គាល់ តាមរយៈសំបុត្រផ្លូវការ យើងប្រមូលមក។

[១០:០៤:៥៩]

ដូចខ្ញុំប្រាប់អ៊ីចឹង ដូចជាលោកអនុប្រធានខ្ញុំ លោក វ៉ាន់ថាន់ ពៅដារ៉ា បានជម្រាបជូនកាលពីសប្តាហ៍មុនអ៊ីចឹង។ ពេលយើងមកដល់ភ្លាម ខ្ញុំអានឯកសារហ្នឹង។ ឯកសារនៅមជ្ឈមណ្ឌលឯកសារនេះគឺមានប្រហែលជាមួយលាន ខ្ញុំមិនចាំគ្រប់ទំព័រទេ ប៉ុន្តែគ្រប់ទំព័រខ្ញុំបានឃើញ ខ្ញុំបានមើលទាំងមួយលានមិនអាចចេញផុតពីតុខ្ញុំបានទេ។ ខ្ញុំមើលទាំងអស់ ខ្ញុំមើលរាល់ថ្ងៃ។ អានឯកសារដូចជាអាហារពេលព្រឹកអ៊ីចឹង ខ្ញុំមើលរាល់ថ្ងៃ។ អ៊ីចឹង បន្ទាប់មក ខ្ញុំបានប្រគល់កិច្ចការនេះទៅឲ្យអនុប្រធានរបស់ខ្ញុំ គឺលោក វ៉ាន់ថាន់ ពៅដារ៉ា រៀបចំទុកដាក់ ដូចជាលោកបានប្រាប់ពីលើកមុនអ៊ីចឹង ថតចម្លង ស្កេនបញ្ចូលក្នុងកុំព្យូទ័រជាដើម។

**ស៖** អរគុណ។ ទាក់ទិននឹងបញ្ហា ការប្រមូលមូលដ្ឋានទិន្នន័យ ការបង្កើតជាទិន្នន័យនៅក្នុងឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង តើការប្រមូលទិន្នន័យវិភាគទិន្នន័យហ្នឹង ដោយវិធីណាដែរ? ការវិភាគទិន្នន័យដែលមាននៅក្នុងដេតាបេស?

**ឆ៖** ខ្ញុំអាចសួរលោកសិនបានទេ មុននឹងខ្ញុំឆ្លើយនឹងសំណួរនេះ។

**ស៖** អញ្ជើញ បាទ។

**ឆ៖** លោកមានចាំទេ ថាតើនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារប៉ុន្មានប្រភេទ?

**ស៖** សំណួរដែលខ្ញុំសួរលោក គឺចង់ឲ្យលោកបញ្ជាក់អំពីការចងក្រងជាដេតាបេសបួនប្រភេទ

ដែលលោកបានបញ្ជាក់-- លោក ដារ៉ាពៅ បានបញ្ជាក់កាលលើកមុន។ ទាក់ទិននឹងដេតាបេសមានប្អូនប្រភេទ ដែលគាត់បានបញ្ជាក់លើកមុន។ អ៊ីចឹង កាលដែលចងក្រងជាទិន្នន័យបែបនេះ តើលោកចូលរួមយ៉ាងដូចម្ដេចនៅក្នុងប្រព័ន្ធហ្នឹង?

[១០:០៦:៣១]

**ឆ៖** ប៉ុន្តែលោកត្រូវចាំថា ឯកសារនៅមជ្ឈមណ្ឌលមានប៉ុន្មានប្រភេទសិន? ហើយមានប៉ុន្មានលំដាប់? បើអ៊ីចឹង កាលណាយើងខ្ញុំនិយាយអំពីការជ្រើសរើស លោកមិនអាចយល់បានទេ។ ខ្ញុំឃើញថាការជជែកគ្នាពីលើកមុន លោកអត់យល់ច្បាស់ថា នៅកន្លែងមជ្ឈមណ្ឌលឯកសារកម្ពុជានេះមានឯកសារប៉ុន្មានប្រភេទ? ហើយប៉ុន្មានលំដាប់? ដល់ពេលអ៊ីចឹង វាទៅជាបែករឿងជជែកគ្នាអំពីរឿងវាយតម្លៃ រឿងអីវែងឆ្ងាយ។ តាមពិតងាយយល់ទេ។ អ៊ីចឹង ខ្ញុំសូមឲ្យលោកចងចាំវិញ ថាតើលោកមានចាំបានទេ កាលពីអនុប្រធានខ្ញុំប្រាប់លោកថា នៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារប៉ុន្មានប្រភេទ?

[១០:០៧:០៤]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនអាចតាំងសំណួរមកត្រឡប់មកអ្នកដែលភារកិច្ចសួរលោកបានទេ។ ប្រសិនបើសំណួរឯណាដែលលកអាចឆ្លើយបាន លោកឆ្លើយ ហើយបើលោកឆ្លើយមិនបាន ដោយសារមូលហេតុការងារនុំង គឺមិនយល់។ ដោយសារសួរសំណួរហ្នឹង គឺមកពីអ្នកដែលតាំងសំណួរមិនយល់អំពីរចនាសម្ព័ន្ធនៃការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា? ឬក៏ការសួរហ្នឹង អត់មានលំដាប់លំដោយលេខរៀងដើម្បីឈានដល់ការសួរសំណួរចុងក្រោយ ដល់សួរសំណួរចុងក្រោយបញ្ច្រាសមកវិញ ដោយមិនដឹងពីមូលហេតុនៃដើមរឿង។ ដូច្នេះ លោកអាចឆ្លើយថា មិនឆ្លើយទេ ដោយសារមិនអាចឆ្លើយតបនឹងសំណួររបៀបនេះបានទេ ប៉ុន្តែលោកមិនអាចសួរសំណួរទៅអ្នកដែលតាំងសំណួរលោកវិញបានទេ។ នេះជាក្នុងនាមលោកចំពោះមុខអង្គជំនុំជម្រះ។

**លោក ផាំង យុះ៖**

សូមអរគុណលោកប្រធាន ចំពោះការណែនាំនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កាណាវាស!

[១០:០៨:២០]

**លោក ម៉ៃខល កាណាវ៉ាស៖**

ជាការពិត លោកប្រធាន លោក លោកស្រីចៅក្រម គឺខ្ញុំរីករាយ និងសូមអរគុណ បើសិនបើបង្គាប់ឲ្យសាក្សីឆ្លើយសំណួរវិញ។ គឺគាត់មិនអាចសួរសំណួរ ថាតើគាត់ចាំទេ អនុប្រធានគាត់និយាយយ៉ាងម៉េច កាលពីសប្តាហ៍មុន? ហើយប្រសិនបើគាត់ចង់បំភ្លឺបញ្ជាក់ទៅលើចម្លើយរបស់អនុប្រធានរបស់គាត់ នោះគឺគាត់អាចធ្វើទៅបាន។ ដូច្នេះ នៅពេលនេះ គឺគាត់អាចផ្តល់ព័ត៌មានដែលគាត់បានដឹងគាត់ធ្វើអ្វីខ្លះ គាត់អាចរំឭកនូវអ្វីដែលលោកអនុប្រធានរបស់គាត់អាចលើកឡើង និងការកែតម្រូវទៅលើចំណុចទាំងអស់នោះ ហ្នឹងគឺជាការឆ្លើយបញ្ជាក់នៅទីនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមលោកឆ្លើយនឹងសំណួរអម្បាញ់មិញ ដូចយើងបានជម្រាបរួចហើយ អំពីបញ្ហា ហើយបញ្ហាផ្សេងទៀត ភាគីគប្បីចៀសវាងផងដែរ ដោយប្រើពេលវេលាក្នុងការសួរដេញដោលសាក្សី ក្នុងនាមជាតំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ជាស្ថាប័នឯករាជ្យមួយ គឺយើងបានសួរអនុប្រធានរួចហើយ ក្នុងនាមតំណាងស្ថាប័នដូចគ្នា ហើយបញ្ហាមានច្រើន។ ដូច្នេះ គឺអាចលៃត្រិះរិះពិចារណារកសំណួរណាដែលមិនច្រំដែល ដែលបានតាំងសំណួររួចហើយ ចំពោះលោកអនុប្រធានដែលបានផ្តល់សក្ខីកម្ម កាលពីដើមសប្តាហ៍មុន។

[១០:០៩:៥៦]

**លោក ឆាំង យុ៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ បាទអ៊ីចឹង ខ្ញុំឆ្លើយតែម្តង ហើយបើសិនជាមានការមិនច្បាស់លាស់ ខ្ញុំអាចឆ្លើយតទៀត លោកអាចសួរសំណួរតមកទៀត។ នៅពេលដែលយើងបានឯកសារហើយ គឺយើងមានក្រុមមួយ គេហៅថា *វើកស៊ីត* គេមានក្រដាសមួយសម្រាប់ឲ្យបុគ្គលិកយើងហ្នឹងអានឯកសារហើយបញ្ចូលទិន្នន័យទៅក្នុងក្រដាសមួយនេះ ដែលគេហៅ វើកស៊ីត ហ្នឹង ឬក៏ជាក្រដាសកិច្ចការហ្នឹង មុននឹងបញ្ចូលទៅក្នុងកុំព្យូទ័រ។ ហើយក្រដាសទាំងអស់ហ្នឹង ក៏បានយើងរក្សាទុកជាឯកសារមួយសម្រាប់ផ្ទៀងផ្ទាត់ដែរ។ តាមដែលខ្ញុំចាំគឺមាន១២ជំហានមុននឹងចេញ មុននឹងយើងដាក់ទិន្នន័យទៅក្នុងកុំព្យូទ័រ មានការបញ្ចូល មានការត្រួតពិនិត្យ មានការបកប្រែ មានការធ្វើសង្ខេបសាច់រឿង មានការផ្គូផ្គងគ្នាទៅនឹងឯកសារដែលយើងបានមើលពីឯកសារហ្វូតូកូពី ដើម្បីធ្វើយ៉ាងណាធានាឲ្យបាននូវភាពសុក្រឹតដែលអាចធ្វើទៅបាន។

អ៊ីចឹងនៅក្នុងនេះខ្ញុំ ខ្ញុំមិនមែនជាអ្នកបញ្ចូលទិន្នន័យទេ ប៉ុន្តែខ្ញុំដឹងអំពីប្រព័ន្ធនេះ នូវការរៀបចំនៅកន្លែងរបស់ខ្ញុំ។

[១០:១១:០៣]

**ស៖** បាទ សូមអរគុណ។ សំណួរធំរបស់ខ្ញុំចុងក្រោយគឺទាក់ទងនឹងបទពិសោធន៍របស់លោកក្នុងការធ្វើការងារជាមួយនឹងឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ។ សំណួរធំនេះ គឺខ្ញុំមានសំណួរតូចៗមួយចំនួន ហើយជាសំណួរដែលចុងក្រោយរបស់ខ្ញុំ។ សូមលោកមេត្តាឆ្លើយបញ្ជាក់ ប្រសិនជាលោកអាចឆ្លើយបាន។ តើលោកបានចូលរួមដោយផ្ទាល់ខ្លួន និងដោយត្រង់ ទាក់ទិននឹងការ អាឯកសារទាំងឡាយដែលលោកបានប្រមូលចងក្រងនៅក្នុង ឌី.ស៊ី.ខេម កន្លងមកនេះ តើលោកបានចូលរួមដោយផ្ទាល់ទាំងអស់ ឬក៏ខ្លះ ឬក៏យ៉ាងម៉េច?

**ឆ៖** ការប្រមូលឯកសារនេះគឺធ្វើឡើងទាំងអស់គ្នា មិនមែនខ្ញុំតែម្នាក់ទេ បុគ្គលិកផ្សេងៗទៀតពេលដែលគេចុះទៅ និយាយពាក្យសាមញ្ញថាចុះទៅខេត្ត។ ពេលចុះទៅខេត្តអ៊ីចឹងកាលណាបានជារូបថតក្តី បានជាឯកសារផ្សេងៗក្តី ក៏បុគ្គលិកខ្ញុំក៏ជាអ្នកប្រមូលដែរ។ ប៉ុន្តែគ្រាន់ថា ពេលដែលយកមកខ្ញុំត្រូវបានគេប្រាប់ថាបានឯកសារអីខ្លះ ហើយខ្ញុំអានឯកសារទាំងអស់នោះ។ អ៊ីចឹងនៅកន្លែងយើងគឺសុទ្ធសឹងតែទាំងអស់គ្នា ប្រមែប្រមូលឯកសារយកមក។

[១០:១២:១០]

**ស៖** ចុះចំពោះឯកសារមកពីប្រភពក្រៅប្រទេសវិញ?

**ឆ៖** ជាទូទៅខ្ញុំ ហើយនិង នៅប្រទេសស៊ុយអែតមានបុគ្គលិកខ្ញុំម្នាក់បានជួយដែរ គឺកញ្ញា សាន់ កល្យាណ សព្វថ្ងៃនេះធ្វើការនៅតុលាការយើងដែរ នៅប្រទេសស៊ុយអែតគឺបាន សាន់ កល្យាណ ជួយប្រមែប្រមូលឯកសារខ្ញុំដែរ។ ព្រោះកាលនោះ កល្យាណ រៀននៅប្រទេសស៊ុយអែត។ ហើយប្រទេសផ្សេងទៀត ដូចជានៅប្រទេសជប៉ុន ប្រទេសអាមេរិក ជាទូទៅខ្ញុំខ្លួនឯងតែម្តង។ មួយទៀត យើងអាចថាអ៊ីចេះក៏បាន ដោយសារថាជាទូទៅខ្ញុំមានបុគ្គលិករៀនសូត្រនៅប្រទេសជាច្រើន ហើយកាលណាខ្ញុំទៅកាន់ប្រទេសនោះ គឺខ្ញុំតែងទាក់ទងទៅបុគ្គលិករបស់ខ្ញុំឲ្យជួយរៀបចំកាលវិភាគ ពេលវេលាផ្សេងៗ ហើយខ្ញុំគិតថាគេក៏មានចំណែកចូលរួមក្នុងការប្រមូលឯកសារនេះដែរ ទោះបីមិនផ្ទាល់ កាន់ដោយផ្ទាល់ដៃ ដឹកយកមកស្រុកខ្មែរយ៉ាងណាក៏ដោយ។

[១០:១៣:០២]

**ស៖** អរគុណ។ គ្រប់ឯកសារដែលលោកបានប្រមូលទាំងក្នុងប្រទេស និងក្រៅប្រទេស តើលោកបានសិក្សាឯកសារនោះលម្អិតទាំងអស់គ្រប់ទំព័រ គ្រប់រូបភាពទាំងអស់ គ្រប់ទិន្នន័យទាំងអស់ឬយ៉ាងម៉េច?

**ឆ៖** បើទាំងអស់ដូចជាពិបាកឆ្លើយណាស់លោក ពាក្យថា ដូចជាយ៉ាប់ឆ្លើយបន្តិចថាទាំងអស់ ពីព្រោះវាច្រើនពេក ប៉ុន្តែខ្ញុំមើល ៗច្រើន ខ្ញុំអាន ហើយជាទូទៅខ្ញុំអានពីរបីដង។ ខ្ញុំមិនមែនអានតែម្តងខ្ញុំឈប់ទេ។ អានឯកសារ ដូចខ្ញុំជម្រាបលោកអ៊ីចឹង ដូចជាយើង១ សូមទោសលោកប្រធាន ខ្ញុំច្រើនតែនិយាយប្រៀបធៀបបន្តិច។ អានឯកសារ ដូចជាយើងរើសបាយមួយគ្រាប់សម័យអាពតយកមកហូប អ៊ីចឹងណ៎ា ផ្អែមតែម្តង មានរសជាតិ គឺថាដូចមានទឹកចិត្តណ៎ា។ អ៊ីចឹងគ្រប់ឯកសារខ្ញុំមើលទាំងអស់ឲ្យតែមានខ្ញុំមើលតែម្តង គ្រប់ទាំងឯកសារ មិនថាជាឯកសារក្រដាស មិនថាឯកសារជាវត្ថុតាង មិនថាឯកសារជាបទសម្ភាស មិនថាឯកសារជារូបថត។ ខ្ញុំចូលចិត្តរូបថតជាងគេ ខ្ញុំច្រើនតែមើលរូបថតដដែល១មិនចេះធុញទ្រាន់ ហើយនិងឯកសារ-- ខ្ញុំមើលកុនខ្សែរឿងស្ទើរតែទាំងអស់។ ប៉ុន្តែឲ្យថាខ្ញុំចាំគ្រប់ទំព័រហ្នឹង ខ្ញុំគិតថាមិនអាចមានការចងចាំដល់ថ្នាក់នោះទេ។

**ស៖** អរគុណ។ តើឯកសារដែលលោកបានអាន បានពិនិត្យហ្នឹង ក្រោយលោកអាន ពិនិត្យហើយ លោកបានពិភាក្សាជាមួយនឹងអ្នកជំនាញ *អេចស្តឹត* ជាតិខ្មែរ ឬក៏បរទេសដែរឬទេ?

[១០:១៤:២១]

**ឆ៖** ជាទូទៅពេលដែលអានហើយយើងបញ្ចូលទៅក្នុងទិន្នន័យ។បញ្ចូលទៅនឹងទិន្នន័យ *ប្រូសេស* របស់យើងគឺពេលយើងអានហើយ យើងត្រូវហ្វូតូកូពី យើងបញ្ចូលក្នុងកាតាឡុក។ ការពិភាក្សាគឺវាទាក់ទងនឹងការសិក្សាស្រាវជ្រាវស្វែងយល់ចង់ដឹងអំពីរឿងរ៉ាវទាំងអស់នេះ ដើម្បីធ្វើយ៉ាងណាកុំឲ្យអំពើនេះវាកើតឡើងម្តងទៀត។ អ៊ីចឹងវានៅក្នុងដំណាក់កាលមួយទៀត។ ចំពោះខ្ញុំអានឯកសារហើយគឺត្រូវសម្រេចថាឯកសារណាមួយចូលទៅក្នុង*ប៊ីប្លូក្រាហ្វី បាយអូក្រាហ្វី* ឬក៏ហ្វូតូកូពី ឬ*ជីអូក្រាហ្វី*។ ហើយបញ្ចូលទៅ។ ចំពោះការពិភាក្សា គឺជារឿងក្រោយដែលទិន្នន័យបានបញ្ចូលទេ ជាការសិក្សាស្រាវជ្រាវ។

[១០:១៥:00]

**ស៖** បាទ អរគុណ។ តើលោកអាចបញ្ជាក់បានច្បាស់ទេថា លោកអាចសន្និដ្ឋានបានច្បាស់ទាក់ទិននឹងបញ្ហាចំណេះដឹងរបស់លោក ទាក់ទងនឹងចំណេះដឹងផ្ទាល់ខ្លួនពាក់ព័ន្ធនឹងកំណត់ត្រានានារបស់

កម្ពុជាប្រជាធិបតេយ្យ សារទូលេខ កំណត់ហេតុអង្គប្រជុំ បទបញ្ជា ចម្លើយសារភាពរបស់អ្នកទោស ...។ល។ តើលោកអាចបញ្ជាក់បានថា លោកមានចំណេះដឹងជ្រៅជ្រះ ការយល់ដឹងជ្រៅជ្រះទាក់ទងនឹងបញ្ហាទាំងអស់នេះដែរឬទេបាទ?

[១០:១៥:២៩]

**ឆ៖** បើគិតទៅ ខ្ញុំធ្វើកិច្ចការនេះ២០ឆ្នាំ បើសិនជារាប់តាំងពីខ្ញុំចាប់ផ្តើមចាប់អារម្មណ៍តាំងពីឆ្នាំ ៨៧។ អ៊ីចឹងខ្ញុំអានឯកសារនេះ ទោះបីខ្ញុំទៅធ្វើការ ទោះបីខ្ញុំទៅរៀនកន្លែងណា ក៏ខ្ញុំនៅតែចាប់អារម្មណ៍ទៅលើបញ្ហានេះ។ ហើយអ៊ីចឹង ២០ឆ្នាំនេះ គឺវាបានបង្រៀនឲ្យខ្ញុំ បង្រៀនខួរក្បាលខ្ញុំឲ្យយល់ ឲ្យឃើញ ឲ្យដឹង ប៉ុន្តែមិនមែនជាលក្ខណៈជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ទេ ដែលខ្ញុំអាចដឹងទេ។ ហើយមួយទៀត ដោយសារថាខ្ញុំជាខ្មែរ ខ្ញុំនិយាយភាសាខ្មែរ ខ្ញុំស្គាល់វប្បធម៌ខ្មែរ ខ្ញុំដឹងអំពីអត្តចរិត និងការគោរពរបស់យើងខ្មែរ។ អ៊ីចឹង វាជាការងាយសម្រាប់ខ្ញុំក្នុងការអានឯកសារទាំងអស់នេះ ហើយឯកសារទាំងអស់នេះភាគច្រើនជាភាសាខ្មែរ ទោះបីជាភាសាអង់គ្លេស ខ្ញុំក៏អាចមានលទ្ធភាពអានបានដែរ។

អ៊ីចឹងរយៈពេល២០ឆ្នាំនេះ ខ្ញុំអាចដឹងបានៗ ថាតើឯកសារនេះមួយជាឯកសារអ្វី? ហើយមួយទៀតមិនមែនជាការពិបាកទេលោក ឯកសារខ្មែរក្រហម និងឯកសារមិនមែនជារបបខ្មែរក្រហម សូមទោស! ខ្ញុំសូមអនុញ្ញាតប្រើពាក្យ "ខ្មែរក្រហម" ព្រោះជាពាក្យទូទៅដែលយើងប្រើស្រុកយើង។ គឺមើលភ្លាមដឹងភ្លាម បើសិនជាលោកចាក់ចម្រៀងខ្មែរក្រហមមួយបទ អ្នកស្រុកដឹងភ្លាម ព្រោះវាជាភាសាខ្មែរមែន ប៉ុន្តែវាមានលក្ខណៈមួយខុសពីភាសាដែលយើងប្រើរាល់ថ្ងៃ។ មិនពិបាកថា ទាល់តែទៅរៀនបានបណ្ឌិត បានអាចយល់បានទេបាទ អ្នកស្រុកក៏គាត់យល់បានដែរ។

[១០:១៦:៥១]

**ស៖** បាទ អរគុណ។ តើលោកអាចសន្និដ្ឋាន ឬក៏លោកអាចគិតថា ខ្លួនលោកអាចក្លាយជាអ្នកជំនាញខាងកំណត់ត្រាកម្ពុជាប្រជាធិបតេយ្យបានដែរឬទេ?

**ឆ៖** ក្រោយពី--

**ប្រធានអង្គជំនុំ៖**

មិនអាចឆ្លើយនឹងសំណួរនេះទេ។ សំណួរភាគីពាក់ព័ន្ធនឹងសាក្សីមិនអាចឲ្យទទួលលទ្ធផលសាក្សីឆ្លើយជាការសន្និដ្ឋាន និងការយល់ដឹងផ្ទាល់ខ្លួននោះបានទេ។ បញ្ហានេះអង្គជំនុំជម្រះដូចជារំឭក និងជម្រាបជូនដល់ភាគីច្រើនលើកច្រើនសាហើយ។

[១០:១៧:២៥]

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន ខ្ញុំសូមសួរពីរសំណួរចុងក្រោយ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ឆាំង យុ ខ្ញុំសូមសួរពីរសំណួរចុងក្រោយ។ ទាក់ទិននឹងឯកសារដែលលោកបានទទួលហ្នឹង មានឯកសារមានប្រភពដើម ឬក៏លោកថតចម្លងពីគេមក។ តើលោកអាចយល់យ៉ាងម៉េចចំពោះពាក់ព័ន្ធនឹងបញ្ហាឯកសារដែលគ្មានច្បាប់ដើម ឬក៏មានច្បាប់ដើមទាំងស្រុង ឬមានច្បាប់ដើមហ្នឹងមាននៅទីកន្លែងណា? ពាក់ព័ន្ធនឹងការលំបាកនៃការរកឯកសារច្បាប់ដើមហ្នឹង តើលោកយល់ឃើញយ៉ាងម៉េចដែរពាក់ព័ន្ធនឹងបញ្ហាហ្នឹង? លទ្ធភាពនៃការវាយតម្លៃទៅលើឯកសារហ្នឹង?

[១០:១៨:០០]

**ឆ៖** ឯកសារទាំងប្រាំប្រភេទរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចែកជាចេញជាពីរលំដាប់។ ហើយនេះ គឺជាអ្វីដែលលោកអនុប្រធានខ្ញុំមិនបានជម្រាបជូន។ អ៊ីចឹងនៅក្នុងលំដាប់ទីមួយនេះ គឺយើងធ្វើតែទៅលើឯកសារដើម។ ឯកសារដើមបានន័យថា ជាឯកសារៗដើមតែម្តង ប៉ុន្តែចំពោះឯកសារណាដែលពុំមានវត្តមាននៅក្នុងកម្ពុជា ទោះបីជាឯកសារចម្លងក៏យើងចាត់ទុកជាឯកសារដើមដែរ។ ខ្ញុំសូមជូនលោកឧទាហរណ៍ ហាក់ដូចជាឆ្លើយទៅនឹងសំណួរកាលពីសប្តាហ៍មុនទៅចុះដូចជា សៀវភៅខ្មៅ។ បាទ សៀវភៅខ្មៅនេះ តាមពិតទៅ សៀវភៅខ្មៅនេះ ដែលលោក សុន អរុណ បានលើកឡើងនេះ គឺជាបកប្រែជាភាសាអង់គ្លេសទេ។ ឯកសារនេះបកប្រែនៅក្នុងឆ្នាំ៧៨ ផ្សព្វផ្សាយនៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។

[១០:១៨:៤៨]

ឯកសារដើមរបស់វា គឺជាភាសាបារាំងដែលមានចំណងជើងថា *"លីវរ៍ុនែរ-ណ័រ"*។ ហើយឯកសារនេះ គឺមាននៅជាមួយនឹងលោក ហ្គុនណា ប៊ិយស្ត្រុង ដែលគឺជាសកម្មជនម្នាក់ដែលគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យ ឬលោកក៏អាចរកបាននូវសាកលវិទ្យាលីន នៅប្រទេសស៊ុយអែត ឬក៏លោកអាចទាក់ទងទៅនឹងអ្នកស្រី ឡូរ៉ា សាំម៉ី សព្វថ្ងៃនេះគឺជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យហ៊ុល។ អ៊ីចឹងនៅពេលដែលយើងដឹងថា ឯកសារទាំងអស់នេះ ដែលយើងមិនយកមកបាន ព្រោះវាជាកម្មសិទ្ធរបស់បណ្ណាល័យ យើងចាត់ទុកថា ឯកសារថតចម្លងនេះ គឺជាឯកសារដើម ដោយនៅក្នុង លើឯកសារ

ដើមនេះ គឺយើងចុះលេខពណ៌ គឺយើងឃើញហើយនៅក្នុងឯកសារដើមមានលេខពណ៌ក្រហម ជួនកាលពេលខ្លះពណ៌ខៀវ ប៉ុន្តែជាទឹកប៊ិកដើម ដើម្បីសម្គាល់ថា ឯកសារមួយនេះនៅក្នុងប្រទេសយើងអត់មានឯកសារដើមទេ។ អ៊ីចឹងគឺយើងត្រូវមានការប្រុងប្រយ័ត្នខ្លាចបាត់ ខ្លាចបង់ អ៊ីចឹងយើងបានថតវាជាច្រើនសំណៅដើម្បីធ្វើការសិក្សាស្រាវជ្រាវ។

[១០:១៩:៤៩]

អ៊ីចឹងឯកសារនេះ គឺយើងដឹងច្បាស់ណាស់ថា បើសិនជារកមិនឃើញឯកសារដើម យ៉ាងហោចណាស់ ក៏យើងបានទៅដល់មនុស្សដែលបានឲ្យយើង ទៅបានឃើញឯកសារដំបូងដែរ។ ខ្ញុំសូមលើកមានឯកសារមួយចំនួន គឺយើងតាមទៅរករហូតដោយសារថាមានការសំណើសុំ គឺយើងបានតាមទៅរករហូត ប៉ុន្តែឯកសារដើមវាបាត់បង់ទៅហើយ។

[១០:២០:១១]

ប៉ុន្តែបើសិនជាលោកពិនិត្យទៅមើលខ្លឹមសារវិញ មិនគួរមានជាការសង្ស័យទេ ដោយសារឯកសារនេះវាប្រហាក់ប្រហែលទៅនឹងឯកសារផ្សេងទៀត ទាំងខ្លឹមសារ ទាំងពាក្យពេចន៍ ទាំងកាលបរិច្ឆេទ និងឈ្មោះមនុស្សនៅក្នុងឯកសារដែរ។ អ៊ីចឹងវាអាស្រ័យទៅលើលោកចៅក្រម ធ្វើការសម្រេចថាតើគួរចាត់ទុកនៅក្នុងប្រភេទណា? តែចំពោះយើងឯកសារហ្វូតូកូពីទាំងអស់នេះ ថតចម្លងទាំងអស់នេះដោយសារគ្មានវត្តមានឯកសារដើម យើងចាត់ទុកថា វាជាឯកសារដើមនៅក្នុងស្រុកយើង។ លោកស្តាប់ខ្ញុំទាន់? បាទ អរគុណ។

**ស៖** សូមអនុញ្ញាតសួរសំណួរចុងក្រោយ។ តើឯកសារមួយដែលមិនមែនជាឯកសារក្លែងបន្លំលោកអាចវិនិច្ឆ័យ លោកអាចសន្និដ្ឋានបានតាមវិធីសាស្ត្របែបណា ដើម្បីឲ្យដឹងថា ឯកសារមួយមិនមែនជាឯកសារក្លែងបន្លំទេ? តើមានវិធីសាស្ត្របែបណា ដើម្បីសន្និដ្ឋានបែបដូច្នេះ? សូមលោកជួយបញ្ជាក់។ បាទ សូមអរគុណ។

[១០:២១:១៤]

**ឆ៖** ទីមួយ ពេលដែល-- លោកដូចសួររបៀបបញ្ច្រាស់បន្តិច។ លោកចង់សួរថា តើធ្វើយ៉ាងម៉េច ឲ្យដឹងថានេះជាឯកសារដើម? ត្រូវទេ?

**ស៖** ចង់ដឹងថាតើលោកមានវិធីបែបណា ដើម្បីសន្និដ្ឋានថា ឯកសារមួយមិនមែនជាឯកសារក្លែងបន្លំទេ មានន័យថា ជាឯកសារត្រឹមត្រូវ?

**ឆ៖** ត្រឹមត្រូវបាទ។ អរគុណបាទ។ ទីមួយ ពេលដែលយើងកាន់ឯកសារមួយ មនុស្សយើងសំដៅបំផុតទៅលើពណ៌ អ៊ីចឹងទីមួយ យើងចាប់ទៅលើពណ៌ហើយ ពណ៌ឯកសារ។ អ៊ីចឹងយើងអាចដឹងហើយថា ពណ៌ឯកសារនេះវាពណ៌ស្លេត ឬក៏ពណ៌ចាស់ យើងដឹងភ្លាម។ គឺភ្នែកមនុស្សដក់ទៅលើពណ៌ ដូចជាវិចិត្រករម្នាក់ឈ្មោះ អាសាសាក់ គាត់បាននិយាយថា បើសិនជាគ្មានពណ៌មនុស្សនឹងស្លាប់។ អ៊ីចឹង មុនដំបូងយើងមើលពណ៌ឯកសារ យើងដឹងភ្លាមថា ឯកសារចាស់ ឬក៏ឯកសារហ្នឹងវាថ្មី យើងដឹងទេ។

[១០:២១:៥៥]

ទីពីរទៀត លោកអាចមើលទៅនឹងកាលបរិច្ឆេទ នៅក្នុង--។ ទីបី អ្នកនិពន្ធ ព្រោះជាទូទៅឯកសារខ្លះមានអ្នកនិពន្ធ ឯកសារខ្លះអត់មានអ្នកនិពន្ធទេ។ ទីបួន លោកអាចមើលទៅលើខ្លឹមសារ សាច់រឿង។ ឯកសាររបបកម្ពុជាប្រជាធិបតេយ្យ មិនអាចនិយាយពីរឿងទ្រព្យសម្បត្តិ ឬក៏អ្នកចម្រៀងសម័យឥឡូវមិនអាចមានទេបាទ។ អ៊ីចឹងយើងអាចដឹងថា នេះមិនមែនជាឯកសាររបស់សម័យឥឡូវទេ។ អ៊ីចឹងលោកអាចមើលខ្លឹមសារ។ ហើយដូចខ្ញុំជម្រាបលោកអ៊ីចឹង ភាសានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាភាសាខ្មែរមែន ប៉ុន្តែមានលក្ខណៈមួយខុសពីដែលយើងប្រើរាល់ថ្ងៃ។ អ៊ីចឹងយើងអាចវិនិច្ឆ័យបាន ហើយពេលអាចឯកសារនេះទៀតសោត មិនមែនអានតែខ្ញុំម្នាក់ឯងទេ បុគ្គលិកទាំងអស់អាន អ្នកផ្សេងទៀតគេអានដែរ។ ហើយឯកសារនេះ គឺថាត្រូវបានយកទៅប្រើប្រាស់ ដោយមនុស្សជាច្រើននាក់ទៀត។ អ៊ីចឹងយើងមានមនុស្សច្រើន ដែលបានជួយធ្វើការអះអាង ឬសំអាងថា នេះពិតជាឯកសារមកពីរបបកម្ពុជាប្រជាធិបតេយ្យមែន។

[១០:២២:៥៥]

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោក ឆាំង យុ ដែលបានឆ្លើយសំណួររបស់ខ្ញុំយ៉ាងក្បោះក្បាយ។

សូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំបានសួរសំណួរ។ សូមអរគុណ។ ហើយខ្ញុំសូមបញ្ចប់ការសួររបស់ខ្ញុំត្រឹមប៉ុណ្ណេះ ហើយសូមបន្តទៅលោក ថារីក ដែលជាសហការីរបស់ខ្ញុំ ដើម្បីសួរសំណួរទៀត។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ដោយសារពេលវេលាសមល្មមនឹងឈប់

សម្រាកហើយដែរ អង្គជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយបង្គាប់ទៅមន្ត្រីរដ្ឋបាលតុលាការសូមសម្របសម្រួលផ្តល់នូវកន្លែងសម្រាកសមរម្យ សម្រាប់សាក្សីសម្រាក ហើយនិងសូមអញ្ជើញគាត់ចូលមកកាន់បន្ទប់សវនាការវិញ ឲ្យបានមុនអង្គជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញមេធាវី!

[១០:២៣:៥២]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ដោយសារមូលហេតុសុខភាព ជាពិសេសបញ្ហាឈឺចង្កេះ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់នៅក្នុងបន្ទប់នេះ តែសូមតាមដានសវនាការនៅបន្ទប់រង់ចាំខាងក្រោមសម្រាប់រយៈពេលថ្ងៃនេះទាំងមូល។ អាស្រ័យនេះ សូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជម្រះអនុញ្ញាតតាមសំណើសុំរបស់លោក អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់ខ្លួន សុំលះបង់សិទ្ធិក្នុងការចូលរួមតាមដាន កិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយដកខ្លួនថយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះ។ តែអង្គជម្រះតម្រូវឲ្យមេធាវីការពារក្តីប្រគល់មកអង្គជម្រះភ្ជាមនូវលិខិតលះបង់សិទ្ធិរបស់លោក អៀង សារី សម្រាប់ថ្ងៃនេះ។ ហើយបង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ រូបភាព និងសំឡេង ទៅបន្ទប់ខាងក្រោមដែលសម្រាប់លោក អៀង សារី បន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលធ្វើសវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យនាំលោក អៀង សារី ត្រឡប់ទៅកាន់បន្ទប់ខាងក្រោម ដើម្បីឲ្យគាត់ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយចុះ ហើយអង្គជម្រះសម្រាក។

សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:២៦ នាទី ដល់ម៉ោង១០:៤៨ នាទី)*

[១០:៤៨:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីតាំងសំណួរចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន សូមគោរពចៅក្រម មេធាវីការពារ ហើយសូមជម្រាបសួរលោក ឆាំង យុ ហើយសូមអរគុណដែលលោកបានអញ្ជើញមកដើម្បីឆ្លើយតបសំណួរទាំងឡាយទាក់ទងទៅនឹងការប្រមូលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** អ្វីខ្ញុំស្នើធ្វើព្រឹកនេះ គឺពិភាក្សាជាមួយលោកអំពីបញ្ហាមួយចំនួន ប្រហែលជាការប្រមូលនូវឯកសារដ៏ធំធេងដែលមជ្ឈមណ្ឌលបានរក្សាទុកនូវឯកសារទាំងនោះ។ ហើយនៅល្ងាចថ្ងៃនេះ ហើយយើងពិនិត្យឧទាហរណ៍ជាក់លាក់មួយចំនួន ជាឯកសារនៅក្នុងប្រព័ន្ធរបស់មជ្ឈមណ្ឌលរបស់លោក ដើម្បីឲ្យយើងខ្ញុំបានយល់អំពីនីតិវិធី ឬក៏ខ្លឹមសារ ហើយដើម្បីវាយតម្លៃពីប្រភពដើមនៃឯកសារទាំងអស់នោះផងដែរ។

មុននឹងឈានទៅដល់ចំណុចនោះ មុននឹងទៅដល់និយាយអំពីដំណើរការនៃការប្រមូលឯកសារនោះ ប្រសិនបើលោកអាចជម្រាបតុលាការដោយសង្ខេបគ្រាន់តែឲ្យតុលាការជ្រាប អំពីប្រភេទនៃប្រភពនៃបណ្ណសារដែលលោកបានទទួលឯកសារទាំងអស់នោះ។ ប្រសិនបើលោកអាចនិយាយពីប្រភពបណ្ណសារសំខាន់ៗដែលជាប្រភពដែលលោកបានទទួលនូវឯកសារទាំងអស់នោះ។

[១០:៥០:១៤]

**លោក ឆាំង យុ៖**

**ឆ៖** សូមអរគុណលោកមេធាវី។ ប្រភពឯកសារមកពីច្រើនកន្លែង មកពីស្ថាប័នរដ្ឋ មកពីក្រៅប្រទេស និងមកពីបុគ្គល។

**ស៖** ប្រហែលសង្កត់ទៅលើជាបណ្ណសាររបស់រដ្ឋាភិបាល ដែលជាពិសេសចេញពីក្រសួង ឬក៏ស្ថាប័នអ្វី ឬក៏កន្លែងតម្កល់ឯកសារហ្នឹង មានប្រភេទអ្វីខ្លះ?

[១០:៥១:00]

**ឆ៖** លោកប្រហែលជាចង់សំដៅទៅលើប្រភពឯកសារមកពីក្រសួងមហាផ្ទៃ ហើយយើងក៏ធ្លាប់បានយកឯកសារមួយចំនួនមកពីបណ្ណសារដ្ឋានជាតិ សារមន្ទីរទួលស្លែង ហើយនិងមានមួយទៀតដែលកាលពីជំនាន់រដ្ឋកម្ពុជាហ្នឹង គេហៅថា ការិយាល័យឃោសនាអប់រំមជ្ឈិម ហើយនិងក្រសួងវប្បធម៌ និងព័ត៌មាន។ នេះជាស្ថាប័នរដ្ឋមួយចំនួន។ ក្រសួងអប់រំក៏មានដែរ បាទ ក្រសួងអប់រំ យុវជន និងកីឡា ក៏យើងធ្លាប់ធ្លាប់បានយកឯកសារពីក្រសួងអប់រំ យុវជន និងកីឡាដែរ។ ហើយនេះនៅក្នុងប្រទេសបាទ។ ហើយនៅក្នុងប្រទេសយើងហ្នឹងគឺមានបុគ្គល មានជាបុគ្គល មានជាទេសចរ អ្នកទេសចរបរទេសមានជាអតីតអ្នកសារព័ត៌មាន មានជាអ្នកស្រុក អ្នកភូមិ ដែលយើងចុះធ្វើបទសម្ភាសក៏គាត់បានយកមកឲ្យយើងដែរ។

[១០:៥១:៥៨]

មួយទៀត មានអ្នកនៅក្នុងធ្វើការនៅការិយាល័យស្រុក ដូចជា អាចថាជាស្ថាប័នរបស់រដ្ឋដែលប៉ុន្តែនៅក្នុងថ្នាក់ស្រុក ជាការិយាល័យស្រុក ក៏យើងបានធ្លាប់យកឯកសារពីគាត់ដែរ ទាំងខេត្តទៀតផង។

**ស៖** សូមអរគុណ។ តើលោកអាចធ្វើការប៉ាន់ប្រមាណបានទេ មុននឹងចូលទៅដល់ប្រធានបទនៃការប្រមូលផ្សេងនោះ តើលោកអាចប៉ាន់ប្រមាណប្រហែលជាតាមន័យទូទៅ ដើម្បីឯកសារដែលវាចេញមកពីចន្លោះឆ្នាំ១៩៧៥ ដល់៧៩ តើឯកសារប្រហែលប៉ុន្មានដែលលោកយល់ឃើញថាជាឯកសារដើមដែលចេញក្នុងសម័យកាលហ្នឹងបាទ?

**ឆ៖** ដូចខ្ញុំប្រាប់ពីដំបូងអ៊ីចឹង ចំពោះឯកសារដែលគ្មានវត្តមាន ឯកសារដើមនៅក្នុងកម្ពុជាយើងចាត់ទុកជាឯកសារដើមដែរ។ អ៊ីចឹងនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា មានឯកសារប្រហែលជាមួយលាន ហើយនេះគឺជាប្រភេទឯកសារប្រាំយ៉ាងលំដាប់ទីមួយ គឺជាឯកសារដើម។ អ៊ីចឹងបានន័យថាដូចជាឯកសារមកពីប្រទេសស៊ុយអែត ប្រទេសហូឡង់ អ៊ីចឹង យើងគ្មានឯកសារដើមទេនៅកន្លែងយើងប៉ុន្តែក៏គ្មាននៅស្រុកខ្មែរដែរ។ អ៊ីចឹងយើងចាត់ទុកថាឯកសារទាំងអស់នោះ គឺជាឯកសារដើម។ អ៊ីចឹងបើយើងនិយាយសរុបទៅ នៅក្នុងលំដាប់ទីមួយនេះ គឺសុទ្ធសឹងតែជាឯកសារដើម ដែលឯកសារជាក់ស្តែងមានវត្តមាននៅក្នុងស្រុកខ្មែរយើង និងមិនមានវត្តមាននៅក្នុងស្រុកខ្មែរយើង ប៉ុន្តែមានជាឯកសារថតចម្លង ហើយទាំងអស់ប្រហែលជាមួយលាន។

[១០:៥៣:៤៤]

**ស៖** សូមអរគុណ។ ហើយខ្ញុំសួរមួយទៀត តើមានន័យថាភាគច្រើន ឬក៏ទាំងអស់ ជាច្បាប់ចម្លងដែលលោកមានហ្នឹង ហើយច្បាប់ដើមនៃឯកសារទាំងអស់នោះមានរក្សាទុកនៅកន្លែងផ្សេងដែរឬទេ ឬក៏យ៉ាងដូចម្ដេច?

**ឆ៖** បាទ ដូចជាឯកសារមកពីប្រទេសស៊ុយអែតអ៊ីចឹង គឺមានប្រហែលជាជិតមួយសែន ជាងប្រាំមួយទៅប្រាំពីរម៉ឺនទំព័រ។ ឯកសារទាំងអស់នេះ គឺត្រូវបានប្រមែប្រមូលចងក្រងឡើង ដោយគណៈកម្មាធិការមិត្តភាពកម្ពុជា វៀតណាម ឡាវ និងស៊ុយអែត ដែលគឺជាអង្គភាពមួយដែលគាំទ្រចលនាកម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ៧៩។ ហើយប្រធានគណៈកម្មការនេះ-- សមាជិកគណៈកម្មការនេះបួនរូប ដែលធ្លាប់មកទស្សនកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងខែសីហា ឆ្នាំ៧៨នេះ គឺនៅមានរស់រានមានជីវិតនៅឡើយ។ ហើយឯកសារទាំងអស់នេះ ក៏បានមកពីបុគ្គលម្នាក់ទៀតដែរ គាត់ឈ្មោះ អ៊ីហ្សី យ៉ាំង ៗ គាត់ជាជនជាតិអាមេរិកាំងទេ ប៉ុន្តែបានទៅរស់នៅប្រទេសស៊ុយអែតតាំងពីក្នុងពេលអំឡុងសង្គ្រាមនៅវៀតណាម។ ហើយគាត់ក៏បានផ្ដល់ឯកសារនេះមកលោក ហ្គុនណា ដែលជាអ្នកគ្រប់គ្រងឯកសារទាំងស្រុង។

[១០:៥៥:០៦]

ឯកសារទាំងអស់នេះ មុននឹងពេលដែលបានធ្លាក់មកដល់ដៃខ្ញុំ គឺយើងបានស្នើសុំឲ្យសាមីខ្លួន នេះបញ្ជូនទៅឲ្យសាកលវិទ្យាល័យលូនដ៍ “L-U-N-D” ដើម្បីធានាថា ឯកសារនេះ ត្រូវបានរក្សាទុក ព្រោះខ្ញុំយល់ឃើញថា វាជាសម្បត្តិមួយដែលប្រទេសស៊ុយអែត ប្រជាពលរដ្ឋស៊ុយអែតបានខំប្រឹងប្រែង ហើយយើងបានសុំយកតែឯកសារចម្លងមកកាន់កម្ពុជាទេ។ ដោយឡែក ឯកសាររបស់លោក ហ្គុនណា ផ្ទាល់ខ្លួន នៅក្នុងផ្ទះរបស់គាត់ និងរបស់លោក អ៊ីហ្សី យ៉ាំង ដែលនៅក្នុងដៃរបស់គាត់ គឺខ្ញុំយកបានឯកសារដើមមកទាំងស្រុង។ ឯកសារប្រភេទមួយទៀតដែរ គឺបានមកពីអ្នកស្រីសាស្ត្រាចារ្យ ឡូរ៉ា សាំម៉ឺ។ ឯកសាររបស់គាត់ ជាទូទៅគឺសុទ្ធសឹងជាឯកសារដើម រួមទាំងហ្វីលម៉ៃក្រូហ្វីមដែរ ដែលគាត់បានផ្ដល់មកខ្ញុំទាំងស្រុង។

អ៊ីចឹងក្នុងការបែងចែកថា មានប៉ុន្មានភាគរយដើម ប៉ុន្មានភាគរយមិនដើមហ្នឹង? វាពិបាកបន្តិច បើសិនជាលោកនៅមានការចងចាំ លោកធ្លាប់ដឹងហើយថា នៅគ្រប់ពេលដែលយើងផ្ដល់ជូនមកតុលាការ យើងបានបញ្ជាក់ច្បាស់ ថាឯកសារនេះ ចេញមកពីឯកសារដែលយើងស្កេនចេញ ឬក៏ថត

ចម្លងពីដើម ឬក៏ហ្វូតូកូពី ហើយយើងបានប្រាប់ថា ឯកសារហ្វូតូកូពីនេះ នៅកន្លែងណា។ ប៉ុន្តែ បើសិនជាសួរជារបៀបរួម ខ្ញុំហាក់ដូចជាមិនមានតួលេខពិតប្រាកដ ប៉ុន្តែបើសិនលោកសួរមួយៗខ្ញុំអាចឆ្លើយបាន ប្រាប់បានភ្លាម។

[១០:៥៦:៤១]

**ស៖** សូមអរគុណលោក។ អ៊ីចឹង ខ្ញុំសូមអនុញ្ញាតចូលទៅប្រភេទជាក់លាក់តទៅទៀត ហើយយើងអាចនឹងត្រឡប់មកបញ្ហានេះឡើងវិញដែរ ប៉ុន្តែខ្ញុំតទៅមុខទៀត លោកបានយោងទៅក្រសួងមហាផ្ទៃដែលលោកលើកអំមិញនេះ ជាកន្លែងតម្កល់ឯកសារ ដែលលោកបានទៅប្រមូលយកនោះ។ តើលោកអាចជម្រាបតុលាការដោយសង្ខេបបានទេ ថាតើប្រភេទឯកសារអ្វីខ្លះដែលលោកប្រមូលបាននៅទីនោះ?

**ឆ៖** នៅឯកសារទីនោះ មានពីរប្រភេទ គឺមានជារូបថត ហើយនិងជាឯកសារជាក្រដាស មានពីរប្រភេទ។ នៅក្នុងឯកសារជាក្រដាសនេះ ប្រវត្តិវិទូ ប៉ែន យៀរនិន បានវាយតម្លៃថា ឯកសារហ្នឹងគឺជាប្រភេទឯកសារសន្តិបាល។ សន្តិបាលនេះ បើយើងនិយាយឲ្យស្រួលស្តាប់ជាភាសាខ្មែរ មានន័យថាឯកសារសន្តិសុខជាតិ។ ហើយលោកក៏បានសរសេរសង្ខេបមួយ ពន្យល់អំពីសំណុំឯកសារ នេះគឺវាមានច្រើន។ នៅក្នុងនោះ ខ្ញុំគិតថាមានប្រហែលជាមួយពាន់សំណុំ បាទ មួយពាន់សំណុំរឿង បើតាមដែលខ្ញុំចាំ ហើយនៅក្នុងនោះ ក៏មានជារូបថតដែរ។ សូមទោស មានជាប្រវត្តិរូបផង មានជាសំណេរផង មានជាសំបុត្រទាក់ទងគ្នា ហើយនិងមានខ្លះទៀត ជាប្រភេទចម្លើយសារភាព។

[១០:៥៨:១៤]

**ស៖** សូមអរគុណលោក។ តើលោកតាមលោកដឹង ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលយកឯកសារពីក្រសួងមហាផ្ទៃនោះ នៅក្នុងពេលណាដែរ? ឆ្នាំណាដែរ?

**ឆ៖** ខ្ញុំដូចគិតថា ឆ្នាំ៩៩។ ៩៦ ឬ៩៩ ពីព្រោះជាទូទៅកន្លែងដែលខ្ញុំប្រមូល ខ្ញុំមិនមែនទៅតែមួយម្តងទេបាទ ដែលខ្ញុំគិតថាប្រហែលជាមាននៅកន្លែងផ្សេងៗទៀត នៅក្នុងការិយាល័យដែលបុគ្គលិកនៅទីនោះ មិនស្គាល់អំពីតម្លៃឯកសារ។ ការប្រមូលឯកសារ គឺយើង-- លោកត្រូវស្គាល់ពី អត្ថន័យអំពីខ្លឹមសាររបស់វា។ ជាទូទៅ នៅកន្លែងមួយហ្នឹង ខ្ញុំទៅច្រើនដងៗ ទោះបីយើងយកបានហើយយកមកយ៉ាងណាក៏ដោយ យើងទៅម្តងទៀត ទៅពីរបីដងទៀត ជួនកាលខ្ញុំសួរបុគ្គលិកផ្សេងៗ ហើយជួនកាលយើងរកឃើញថា គាត់យកទៅខ្ចប់ចេកចៀនក៏មាន ជួនកាលគាត់យកទៅជក់បារីក៏មាន ជួនកាលគាត់ទុកនៅផ្ទះក៏មាន ដូចជាឯកសារនៅសារមន្ទីរទួលស្លែង លោក អ៊ឹង ប៊ុច ដែលជាអតីត ប្រធានគុក

ទួលស្លែង នៅផ្ទះគាត់តែម្តង ក៏មានដែរ។ គាត់យកទៅផ្ទះតែម្តង។ អ៊ីចឹង ជាទូទៅ បើសិនជាលោករាប់ពេលវេលាដាក់ស្តែង វាអាច-- មកទល់សព្វថ្ងៃ ក៏ខ្ញុំតែទៅដែរ បើសិនជាមាន លទ្ធភាពទៅ។

**ស៖** សូមអរគុណ។ នៅពេលដែលផ្ទេរឯកសារហ្នឹងមក តើមជ្ឈមណ្ឌលឯកសារកម្ពុជា បានឯកសារដើម ឬក៏ជាឯកសារចម្លងពីច្បាប់ដើមនោះ ដែលលោកបានរកឃើញនៅក្រសួងមហាផ្ទៃនោះ?

**ឆ៖** ជាឯកសារដើម បាទ។

[១១:០០:១២]

**ស៖** តាមការដឹងរបស់លោក មុនពេលដែលឯកសារទាំងអស់នេះនៅ ដាក់នៅកន្លែងតម្កល់ឯកសារនៅក្រសួងមហាផ្ទៃ។ ថាតើឯកសារនៅកន្លែងណាមុនពេលដែលគេយកទៅដាក់នៅទីនោះ?

**ឆ៖** ខ្ញុំបានស្រាវជ្រាវរកប្រភពឯកសារនេះ ហើយតាមរយៈនៅក្នុងឆ្នាំ១៩៨០ តាមដែលខ្ញុំដឹងគឺមានក្រុម មនុស្សមួយក្រុមដែលប្រមែប្រមូលឯកសារដើម្បីរៀបចំទុកដាក់ ដើម្បីបង្កើនជាកន្លែងធ្វើការងារ ដោយសារថាជំនាន់នោះវា របស់វានៅរប៉ាត់រប៉ាយច្រើនកន្លែង។ ឯកសារនេះតាមដែលខ្ញុំស្រាវជ្រាវតាមរយៈអ្នកដែលធ្លាប់បានធ្វើការលើឯកសារនេះ ហើយឈ្មោះដែលអ្នក ដែលខ្ញុំបានជួយសួរ គឺខ្ញុំបានផ្តល់ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ។ ឯកសារនេះ តាមដែលខ្ញុំយោងតាមការដែលខ្ញុំបានសាកសួរ គឺស្ថិតនៅក្នុងផ្ទះមួយ ផ្ទះនេះគឺនៅក្នុងផ្លូវមួយដែលចាក់ឆ្ពោះទៅកាន់គេហដ្ឋានរបស់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកបច្ចុប្បន្ន នៅម្តុំកន្លែងហ្នឹង។ ហើយនៅទីនោះ ឯកសារត្រូវបានប្រមូល នេះតាមដែលខ្ញុំបានសួរគាត់ គឺបានប្រមូល ហើយយកទៅទុកដាក់ចោលនៅអគារណាមួយនៅក្នុងការិយាល័យរបស់ក្រសួងមហាផ្ទៃ។ ហើយក្រោយមក គឺរៀបដាក់ផ្ទេរៗអ៊ីចឹងទៅ។

[១១:០១:៤០]

ហើយមានក្រុមៗធ្វើការឯកសារនៅក្រសួងមហាផ្ទៃ ដែលធ្វើកិច្ចការនេះ បោសសម្អាតដាក់ចូលទៅក្នុងសឺមី ឬក៏រៀបចំដាក់នៅក្នុងទូរឲ្យបានស្រួលបួល។

**ស៖** លោកបាននិយាយថា លោកបានទាក់ទងជាមួយនឹងអ្នកដែលធ្វើការងារទៅលើឯកសារទាំងអស់នោះ។ ថាតើអ្នកដែលធ្វើការលើឯកសារហ្នឹងគឺគាត់ជាបុគ្គលិកមកពីក្រសួងមហាផ្ទៃ ឬក៏មិនមែនទេ?

**ឆ៖** ទាំងអស់គ្នាគឺសុទ្ធសឹងតែជាបុគ្គលិករបស់ក្រសួងមហាផ្ទៃ ហើយតាមដែលខ្ញុំចាំដូចជាមានម្នាក់ ឬពីរនាក់សព្វថ្ងៃរស់នៅប្រទេសអូស្ត្រាលី។

**សៈ** តើលោកមានបានពិភាក្សាអំពីសំណុំឯកសារទាំងអស់នោះដែរឬទេ ជាមួយនឹងអ្នកដែលគាត់ផ្ទេរឯកសារនេះពីផ្ទះមួយដែលគេផ្ទុកឯកសារមុនពេលដែលបញ្ជូនមកក្រសួងមហាផ្ទៃនោះ?

[១១:០២:៤៦]

**ធៈ** សូមទោសស្តាប់អត់សូវច្បាស់ សូមម្តងទៀត។

**សៈ** លោកបានរៀបរាប់យ៉ាងលម្អិតថា លោកបានមើលទៅលើប្រភពនៃឯកសារទាំងអស់នេះ។ ដូច្នេះ សំណួររបស់ខ្ញុំចង់សួរថា តើលោកមានលទ្ធភាពធ្វើការកំណត់ ឬក៏បាននិយាយជាមួយនឹងបុគ្គលដែលគាត់ចូលរួមនៅក្នុងការផ្ទេរឯកសារដើមពីកន្លែងដែលរកឃើញនោះដែរឬទេ? តើលោកមាននិយាយជាមួយអ្នកដែលចូលរួមប្រមូលឯកសារផ្ទេរពីកន្លែងដើមដាក់មកក្រសួងមហាផ្ទៃដែរឬទេ?

**ធៈ** អត់ទេបាទ។

**សៈ** នៅពេលដែលលោកពិភាក្សាជាមួយនឹងបុគ្គលិកនៅក្រសួងមហាផ្ទៃ តើលោកបានដឹងដែរឬទេថា ពួកគេទាំងអស់នោះអាចប្រហែលជាបានដឹង និងស្គាល់បុគ្គលទាំងឡាយដែលគេបានផ្ទេរឯកសារពីផ្ទះនុំងមកក្រសួងមហាផ្ទៃ?

**ធៈ** គេបានស្គាល់ បាទ គឺស្គាល់។

[១១:០៤:១០]

**សៈ** តាមការស្រាវជ្រាវរបស់លោក តាមការពិភាក្សារបស់លោកជាមួយនឹងអ្នកក្រសួងមហាផ្ទៃ តើលោកបានទទួលព័ត៌មានដែរឬទេ ថាតើផ្ទះនោះជារបស់អ្នកណាដែរ ដែលយើងរក ឯកសារឃើញនោះ? អ៊ីចឹងផ្ទះនោះ គឺកាន់កាប់ដោយអ្នកណាដែរ?

**ធៈ** លោកចង់សួរថា តើផ្ទះនេះកាន់កាប់ដោយអ្នកណានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏បច្ចុប្បន្ន?

**សៈ** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ធៈ** មិនមានព័ត៌មានច្បាស់លាស់ថា ផ្ទះនេះជាកម្មសិទ្ធិរបស់កម្មាភិបាលណាមួយ គ្រាន់តែដឹងថានៅក្នុងម៉ុ-- បើយើងនិយាយភាសាសាមញ្ញនៅម៉ុផ្សារស៊ីឡិបៗហ្នឹង គឺឯកសារហ្នឹងត្រូវបានរកឃើញ។

**សៈ** តើលោកបានដឹងអំពីកាលបរិច្ឆេទដែរឬទ ថាគេរកឯកសារទាំងអស់នោះ នៅឃើញនៅផ្ទះនោះនៅពេលណាដែរ? ប្រហែលបាទ។

**ឆះ** ប្រហែលជានៅក្នុងអំឡុងឆ្នាំ៨០ជាង បាទ ៨២ ឬក៏៨៣។ ពីព្រោះតាមដែលខ្ញុំសាកសួរ អ្នកដែលគេបានធ្វើកិច្ចការទាំងអស់នេះ គឺគេបានធ្វើកិច្ចការនេះយូរមកហើយ។ អ៊ីចឹងខ្ញុំគិតថា នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០។

**សះ** លោកបាននិយាយខាងដើមថា ក្រសួងមហាផ្ទៃបានដឹង បុគ្គលដែលផ្ទេរឯកសារនោះមកក្រសួង។ ថាតើលោកស្គាល់អត្តសញ្ញាណរបស់បុគ្គល ដែលផ្ទេរឯកសារនោះមកក្រសួងមហាផ្ទៃដែរឬទេ បាទខ្លួនលោកហ្នឹង?

[១១:០៦:០០]

**ឆះ** បើយើងនិយាយក្រសួងមហាផ្ទៃវាទូលំទូលាយបន្តិច ប៉ុន្តែបុគ្គលិកដែលធ្វើការផ្នែកឯកសារស្គាល់បុគ្គល ដែលបានយកឯកសារចេញពីផ្ទះនៅម្តុំផ្សារស៊ីឡិប មកក្រសួងមហាផ្ទៃ ហើយគេក៏ប្រាប់ឈ្មោះមកខ្ញុំដែរ។ ហើយខ្ញុំបានចងក្រងព័ត៌មានឯកសារទាំងអស់នេះ ទៅឲ្យសហចៅក្រមស៊ើបអង្កេត នៅពេលដែលគេសាកសួរខ្ញុំអំពីឯកសារនេះ។

**សះ** សូមអរគុណលោកច្រើន។ លោកបានបញ្ជាក់ខាងដើមថា សំណុំឯកសារទាំងអស់នោះរួមមាន ចម្លើយសារភាព ប្រវត្តិរូប និងលិខិតឆ្លើយឆ្លង។ តើលោកអាចជម្រាបបានដែរឬទេ អាចរៀបរាប់ដោយសង្ខេបបានដែរឬទេ តើឯកសារជីវប្រវត្តិនោះមានទម្រង់យ៉ាងម៉េចដែរ? សូមឲ្យលោកជម្រាបជូនអង្គសវនាការ។

[១១:០៧:០៣]

**ឆះ** ឯកសារប្រវត្តិរូបនេះ គឺជាឯកសារប្រវត្តិរូបរបស់-- ឯកសារប្រវត្តិរូបមានជាពីរសណ្ឋាន។ ឯកសារប្រវត្តិរូបម៉្យាង គឺជាឯកសារប្រវត្តិរូបរបស់កម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារប្រវត្តិរូបម៉្យាងទៀត គឺជាអ្នកទោសដែលត្រូវបានចាប់មកពីមូលដ្ឋាន ហើយបញ្ជូនមកមន្ទីរឃុំឃាំង។ នៅក្នុងប្រភេទឯកសារដែល ប្រវត្តិរូបដែលខ្ញុំរកឃើញនៅក្នុងក្រសួងមហាផ្ទៃនេះ គឺជាប្រភេទប្រវត្តិរូបអ្នកទោសដែលត្រូវបានចាប់មកពីមូលដ្ឋាន ប៉ុន្តែក៏មានឯកសារមួយចំនួនជាប្រវត្តិរូប ជាជីវទស្សន៍របស់កម្មាភិបាល នៃកម្ពុជាប្រជាធិបតេយ្យដែរ ក្នុងនោះមានលោក សួង ស៊ីគឿន បាទ សមមិត្ត គង់។

[១១:០៧:៥២]

ខ្ញុំបានរកឃើញប្រវត្តិរូបរបស់គាត់នៅក្នុងសំណុំឯកសារនេះ។ ប៉ុន្តែដូចយើងដឹងហើយថា គាត់មិនមែនជាអ្នកទោសទេ។ អ៊ីចឹងវាមានការចម្រុះគ្នានៅក្នុងប្រវត្តិរូបនេះ វាមិនមែនដាច់ដោយឡែក

តែមួយសំណុំរឿងអ្នកទោស ប៉ុន្តែក៏មានអតីតកម្មាភិបាលខ្មែរក្រហមដែរ។

**ស៖** ចំពោះចម្លើយសារភាព តើលោកអាចបញ្ជាក់ដែរឬទេ ថាចម្លើយសារភាពទាំងអស់នោះ គឺវាចេញមកពីប្រភពណាដែរ? ឬក៏វាចេញមកពីមន្ទីរសន្តិសុខគុកមួយណាដែរ?

**ឆ៖** ខ្ញុំសូមពន្យល់បន្តិចរឿងចម្លើយ រឿងឯកសារចម្លើយសារភាព។ ជាទូទៅយើងយល់ច្រឡំថា កាលណាយើងនិយាយអំពីឯកសារចម្លើយសារភាព យើងនិយាយអំពីគុកទួលស្លែង។ នៅគុកទួលស្លែងមានចម្លើយសារភាពប្រហែលជា៤000 ដែលគង់វង្សសព្វថ្ងៃនេះ។ នៅក្នុងចម្លើយសារភាព ៤000នេះ គឺយកចេញមកពីអ្នកទោសប្រមាណ១២000នាក់។ ឯកសារចម្លើយសារភាព ដែលខ្ញុំនិយាយនេះប្រហែល១000 ដែលចេញមកពីក្រសួងមហាផ្ទៃ ដែលលោកប្រវត្តិវិទូ ប៉ែន យៀរនិន បានសន្និដ្ឋានថា ជាឯកសាររបស់សន្តិបាល នៃរបបកម្ពុជាប្រជាធិបតេយ្យ។

[១១:០៩:០៩]

នៅក្នុងឯកសារទាំងពីរនេះមិនដូចគ្នាទេ។ យើងបានផ្ទៀងផ្ទាត់រួចហើយ មានដូចគ្នាប្រហែលជាមួយចំនួនតូច តូចមែនទែន ប្រហែលជាប្រាំ ឬប្រាំមួយ។ ប៉ុន្តែទោះបីជាដូចគ្នា ឯកសារចម្លើយសារភាពនៅ ដែលយើងរកឃើញនេះមានកម្រាស់ច្រើនជាង អំពីឯកសារចម្លើយសារភាពនៅសារមន្ទីរទួលស្លែង។ អ៊ីចឹងប្រភេទឯកសារវាហាក់ដូចជាមានការឆ្លើយឆ្លងគ្នា ប៉ុន្តែវាមិនមែនចម្លើយសារភាពស្ទួនគ្នាទេ ទោះបីជាវាស្ទួនគ្នា កម្រាស់ និងអត្ថន័យ គឺខុសគ្នា។ ឯកសារចម្លើយសារភាពទាំងអស់នេះជាទូទៅ សំដៅទៅលើអ្នកទោសនៅមន្ទីរស-២១ ហើយក៏សំដៅទៅលើអ្នកទោសមកពីកន្លែងផ្សេងទៀតដែរ។

[១១:០៩:៥៥]

**ស៖** លោកបានបញ្ជាក់ថា នៅក្នុងករណីមួយចំនួន ចម្លើយសារភាពនោះ គឺវាវែងជាងចម្លើយសារភាពនៅ ស-២១។ តើលោកអាចបញ្ជាក់ទេ ហេតុអ្វីបានជាចម្លើយសារភាព ដែលរកឃើញនៅក្នុងផ្ទះនុំងវាវែងជាងចម្លើយសារភាព ដែលរកឃើញនៅមន្ទីរស-២១?

**ឆ៖** ខ្ញុំមិនច្បាស់ដែរ ថាហេតុអ្វីបានជាវែងជាង តាមដែលខ្ញុំចាំដូចជា ចម្លើយសារភាព--សូមទោស! ខ្ញុំមិនច្បាស់ថា កុយ ធួន ឬក៏ មានម្នាក់ ឬក៏ពីរនាក់ឯកសារហ្នឹងវែងជាង។ ហើយជាទូទៅឯកសារដែលយកចេញមកពីក្រសួងមហាផ្ទៃ ជាទូទៅមានចំណារ មានចំណារសរសេរនៅខាងលើក្របនៅចម្លើយសារភាព វាខុសពីឯកសារចម្លើយសារភាពនៅទួលស្លែង ដែលជាទូទៅគឺមានតែក្របមួយ ឬក៏ជាចំណាររបស់មេគុកទួលស្លែងតែប៉ុណ្ណោះទេ។

[១១:១០:៥៨]

**ស៖** តើលោកអាចបញ្ជាក់ដែរឬទេថា អ្នកណាគេដែលសរសេរចំណារទៅលើឯកសារដែលរកឃើញពីផ្ទះនោះៗ?

**ឆ៖** ចំពោះចំណាររបស់ ឌុច ងាយស្រួល ព្រោះគាត់ចុះហត្ថលេខាខ្លួនឯង អ៊ីចឹងយើងមើលយើងដឹង គាត់សរសេរហើយគាត់ហត្ថលេខា។ ចំណារផ្សេងទៀត គឺតម្រូវឲ្យមានការសិក្សាស្រាវជ្រាវដោយសារថា គាត់ប្រើឈ្មោះកាត់ ដូចជា សមមិត្ត វ៉ាន់ ដូចជា អ៊ំ នួន ដូចជា អ្នកផ្សេងៗទៀតដែលយើងថា ឈ្មោះដើមមិនដឹងជានរណា ជួនកាលគេប្រើជាលេខ ហើយនៅក្នុងចំណារខ្លះទៀត មានដាក់ថា តាម៉ុក អ៊ីចឹង យើងអាចដឹងថា តាម៉ុក។ អ៊ីចឹង យើងចំណារទាំងអស់នេះ ចំណារខ្លះយើងអាចដឹងដោយខ្លួនឯង ព្រោះមើលទៅឃើញតែម្តង មិនចាំបាច់សិក្សាស្រាវជ្រាវទេ ព្រោះម្ចាស់ដែលសរសេរចំណារហ្នឹង បានចុះហត្ថលេខាថ្ងៃខែនៅលើគម្របនោះតែម្តង។

[១១:១១:៥៦]

**ស៖** លោកអាចឃើញឈ្មោះមាននៅលើឯកសារនុ៎ង អ៊ីចឹងតាមដែលលោកចាំនោះ ថាតើវាមានសញ្ញា មានឈ្មោះអ្វីខ្លះ? មានសញ្ញាអ្វីខ្លះដែលគេកំណត់ថា ជារបស់បុគ្គលមួយជាក់លាក់នោះ?

**ឆ៖** ជាទូទៅ មានចំណារខ្លីៗ។ យើងអាច-- មានឯកសារមួយ ខ្ញុំចាប់អារម្មណ៍ដោយសារថា មានចំណារមនុស្សបួនប្រាំនាក់នៅលើនោះ ហាក់ដូចជាឆ្លើយឆ្លងគ្នាបើសិនជាយើងមើលទៅលើកាលបរិច្ឆេទ។ ខ្ញុំមិនចាំកាលបរិច្ឆេទច្បាស់លាស់ ប៉ុន្តែឧទាហរណ៍ថា ថ្ងៃ១២ ឌុច គាត់បានសរសេរចំណារថា ឈ្មោះ "ក" បានធ្វើអ៊ីចេះមួយៗ ហើយយើងឃើញថ្ងៃ១៤ ឃើញ ខៀវ ឃើញសមមិត្ត ខៀវ បានឆ្លើយថា អ៊ីចេះមួយៗបញ្ជូនទៅមនុស្សផ្សេងទៀត។ ហើយនៅខាងឆ្វេងយើងឃើញចំណារមួយទៀតពណ៌ក្រហមនិយាយថា "អានរួចហើយ" ឬមួយក៏ចំណារមួយទៀត បាននិយាយថា "បញ្ជូនទៅខាងបូព៌ា" ជាឧទាហរណ៍។ អ៊ីចឹងចំណារមួយៗនេះ ជួនកាលវាបង្ហាញអំពីមនុស្សម្នាក់រួចទៅហើយនៅក្នុងចំណារទាំងបួន ហើយជាការងាយ យើងអាចសួរមនុស្សម្នាក់ហ្នឹង ថាតើបីនាក់ទៀតជានរណា ដោយសារឈ្មោះគាត់គឺត្រូវបានចុះហត្ថលេខា ដោយខ្លួនគាត់រួចស្រេចទៅហើយ។

**ស៖** តើអ្នកណាគេដែរជាសមមិត្ត ខៀវ នោះ?

**ឆ៖** តាមការសិក្សាស្រាវជ្រាវ របស់ប្រវត្តិវិទូ ប៊ែន ឃៀរនិន គាត់គិតថា សមមិត្ត ខៀវ នេះគឺជា សុន សេន។ បាទ សុន សេន គឺជារដ្ឋមន្ត្រីក្រសួងការពារជាតិ នៃរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** លោកបាននិយាយថា លោកសាស្ត្រាចារ្យ ឃៀរនិន បានរៀបរាប់ថា សំណុំឯកសារនោះជាសំណុំឯកសារសន្តិបាល។ ហេតុអ្វីបានជាគាត់រៀបរាប់ដូច្នោះ? តើលោកអាចពន្យល់ដែរឬទេ?

**ឆ៖** ពិបាកដែរ ព្រោះខ្ញុំពន្យល់ដែលខ្ញុំបានគិត ប៉ុន្តែគាត់បានសរសេរអ៊ីចឹង។ គាត់បានសរសេរអ៊ីចឹង ហើយតាមដែលខ្ញុំយល់ ពីព្រោះលោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន គាត់ចេះភាសាខ្មែរ។ នៅក្នុងពិភពលោកនេះ អ្នកដែលបរទេសចេះភាសាខ្មែរច្បាស់ជាងគេ គឺលោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន ទីពីរ គឺលោក ស្ទីវ ហេដឌ័រ ដែលខ្ញុំចាត់ទុកថា ជាអ្នកចេះភាសាខ្មែរដែលច្បាស់លាស់ គាត់ចេះទាំងជេរទៀត។ ស្ទីវ គាត់អាចជេរជាភាសាខ្មែរទៀតបាទ។

[១១:១៤:២៥]

អ៊ីចឹងតាមដែលខ្ញុំដឹង គាត់បានអានៗ ហើយនៅលើឯកសារនេះ ខាងឆ្វេងដៃមានដាក់ថា "សន្តិបាល" ខ្ញុំក៏ធ្លាប់ឃើញដែរ។ អ៊ីចឹងប្រហែលជាគាត់យោង ថានៅក្នុងគ្រប់ឯកសារមានដាក់សន្តិបាល អ៊ីចឹងប្រហែលវាជារបស់សន្តិបាល ហើយពាក្យសន្តិបាល គឺជាពាក្យខ្មែរ សំដៅទៅលើនគរបាល ឬក៏សន្តិសុខ ព្រោះវាជាពាក្យបាលី។ អ៊ីចឹងវាហាក់ដូចជាមិនមែនជាការវិភាគទេ ព្រោះវាពាក្យហ្នឹងមានហើយស្រេចតែម្តងនៅក្នុងឯកសារហ្នឹងរួចទៅហើយ។ តែដោយសារគាត់ជាបរទេស ហើយគាត់អានចេះអានភាសាខ្មែរទៅ យើងហាក់ដូចជាគិតថា គាត់ប្រហែលជាបានវែកញែក សិក្សាស្រាវជ្រាវ តែតាមពិតហ្នឹងគឺមានហើយស្រេចនៅលើឯកសារ។

[១១:១៥:០៩]

**ស៖** សូមអរគុណច្រើន។ លោកបាននិយាយខាងដើមថា សំណុំឯកសារនោះរួមមានលិខិតឆ្លើយឆ្លងផងដែរ។ ថាតើប្រភេទលិខិតឆ្លើយឆ្លងនោះជាអ្វីដែរ ជាលិខិតបញ្ជូនទៅមក ឬក៏ជាប្រភេទអ្វីដែរ?

**ឆ៖** លិខិតឆ្លើយឆ្លងនេះមានច្រើនយ៉ាង។ ខ្ញុំសូមលើកឧទាហរណ៍ពីរ។ លិខិតឆ្លើយឆ្លងមួយគឺហាក់ដូចជាកំណត់ហេតុនៃការប្រជុំរបស់ក្រសួងពាណិជ្ជកម្មចិនជាមួយនឹង សមមិត្តវ៉ាន់ ហើយមានកំណត់ហេតុ ហើយមានការឆ្លើយឆ្លងទៅវិញទៅមក។ ហើយកំណត់ លិខិតឆ្លើយឆ្លងមួយទៀត អំពីស្ត្រីម្នាក់ ខ្ញុំចាំច្បាស់ណាស់ ព្រោះខ្ញុំចាប់អារម្មណ៍សំបុត្រនេះជាងលិខិតណាផ្សេងៗគឺ លិខិតរបស់ស្ត្រីម្នាក់ដែលបានស្នើសុំឱ្យ ស្នើសុំពន្លូតកូន ពីព្រោះគាត់គិតថាកូនដែលនៅក្នុងផ្ទៃនេះ គឺជាកូនរបស់ខ្មាំង។ ហើយខ្ញុំបានតាមរកឯកសារគាត់ ខ្ញុំគិតថាតើម្តាយអាចមានចេតនាសម្លាប់កូនដោយយ៉ាងដូចម្តេចកើត ហើយ

ខ្ញុំបានរកឃើញថា គាត់បានខុសសីលធម៌ មានចម្លើយមួយវែងទៀត បានខុសសីលធម៌ ហើយខ្លាចស្លាប់ ហើយខ្ញុំគិតថា ពេលដែលគាត់យកមូលហេតុថា ចង់សម្លាប់កូននៅក្នុងផ្ទៃគឺដើម្បីគាត់ចង់រស់។ ហើយ ឯកសារមួយនេះ ខ្ញុំចាំច្បាស់ណាស់គឺមានជាលិខិតដែល-- ហើយបើយើងមើលទៅនៅក្នុងលិខិតនេះ តាមកម្រិតវប្បធម៌នៃអ្នកសរសេរនេះ គឺជាមនុស្សដែលមិនសូវចេះអក្សរប៉ុន្មានទេ។ ប៉ុន្តែគាត់ចង់រស់ ហើយគាត់បានសរសេរលិខិតនេះ ហើយលិខិតនេះត្រូវបាន ប្រហែលជាត្រូវបានចាប់បាន ហើយទុកនៅ ក្នុងឯកសារនុ៎ង។

[១១:១៦:៥៩]

**ស៖** ថាតើលិខិតឆ្លើយឆ្លងទាំងអស់នោះ វាលេចចេញឲ្យយើងថាជាលិខិតឆ្លើយឆ្លងរបស់រដ្ឋាភិបាល ឬក៏ជាលិខិតឆ្លើយឆ្លងរបស់ស្ថាប័នណាផ្សេង?

**ឆ៖** មានឯកសារមួយចំនួនបញ្ជាក់អំពីការឆ្លើយឆ្លងរបស់រដ្ឋាភិបាល ព្រោះមានត្រាបាទ មានត្រាកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងនេះ គឺជាលិខិតផ្លូវការ។

**ស៖** ខ្ញុំសូមសួរដោយសង្ខេបចំពោះសំណុំឯកសារទាំងអស់នេះ ប្រសិនបើខ្ញុំស្វែងរកឯកសារណាមួយនៅក្នុងសំណុំឯកសារហ្នឹងដោយប្រើលេខកូដដែលខាងស្ថាប័នរបស់លោកប្រើប្រាស់ ថាតើប្រព័ន្ធទិន្នន័យនោះ ដូចដែលលោកបានបញ្ជាក់ពីខាងដើមអ៊ីចឹងវាអាចលេចចេញជាប្រភពថា វាមកពីក្រសួងមហាផ្ទៃ ឬក៏មកពីកន្លែងផ្សេងឲ្យខ្ញុំដឹងដែរឬទេ?

[១១:១៨:០៥]

**ឆ៖** បាទ ដូចក្នុងទិន្នន័យរបស់យើង គឺយើងបានបញ្ជាក់ច្បាស់ណាស់អំពីប្រភពនៃឯកសារ។ មានមូលហេតុពីរ ទីមួយគឺយើងដើម្បីរក្សាភាពសុក្រឹតភាព ទីពីរដើម្បីលើកទឹកចិត្តដល់អ្នកដែលផ្តល់ឯកសារមកឲ្យយើង ថាឯកសារនេះត្រូវបានដាក់ប្រើប្រាស់ជាសាធារណៈ។ ពីព្រោះជាទូទៅប្រជាជនដែលគាត់យកឯកសារមកឲ្យយើង គាត់ចង់ឲ្យឯកសារនេះ គាត់គិតថាឯកសារនេះជាឯកសារប្រវត្តិសាស្ត្រ ចង់ឲ្យមនុស្សពិភពលោកដឹងអំពីការឈឺចាប់។ អ៊ីចឹងដើម្បីជាការដឹងគុណរបស់គាត់ យើងបានរក្សាប្រភពដើមអំពីម្ចាស់ដែលបានឲ្យឯកសាររបស់យើង ដរាបណាគាត់មិនចង់ឲ្យឈ្មោះគាត់កើតមានឡើងនៅក្នុងទិន្នន័យរបស់យើង។

**ស៖** នៅពេលដែលចៅក្រមស៊ើបអង្កេតបានសម្ភាសលោក លោកបាននិយាយអំពីសំណុំឯកសារផ្សេងទៀត ដែលក្នុងនោះហៅថាជា “ឯកសារ លន់ នល់”។ តើលោកអាចរៀបរាប់ដោយ

សង្ខេបដែរឬទេថា ហេតុអ្វីបានជាសំណុំឯកសារប្រភេទនោះហៅថាជា "សំណុំឯកសារ លន់ នល់"?

**ឆ៖** យើងមានការភ្ញាក់ផ្អើលនៅពេលដែលខ្ញុំរកឃើញឯកសារនេះ។ ឯកសារហ្នឹងគឺបានប្រាប់ហើយរួចជាស្រេចនៅលើខ្នងទំព័រហ្នឹង ដាក់ថាឯកសាររបបសាធារណរដ្ឋខ្មែរ ប៉ុន្តែនៅពេលដែលខ្ញុំបើកម្តងមួយទំព័រៗ ខ្ញុំឃើញជាឯកសារខ្មែរក្រហមទៅវិញ។ ខ្ញុំគិតថាប្រហែលជាអ្នករៀបចំឯកសារពីមុនមានការភ័ន្តច្រឡំ ឬក៏មិនស្គាល់ឯកសារ ឬក៏ដាក់បញ្ចូលគ្នា ឬក៏ខ្វះធនធានក្នុងការបំបែកឯកសារ។ អ៊ីចឹងហើយបានយើងហៅ ដោយសារថាយើងចង់រក្សាភាពដើមនៃឯកសារ។ ហើយដោយសារឯកសារនេះបានប្រើពាក្យ លន់ នល់ យើងក៏ប្រើពាក្យ លន់ នល់ តាមឯកសារដើមតែម្តងទៅ។

សូមបញ្ជាក់ថា នៅក្នុងប្រភេទឯកសារនេះមានពីរប្រភេទ។ មានប្រភេទឯកសាររបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏មានឯកសារមកពីរបបសាធារណរដ្ឋខ្មែរដែរ។

[១១:២០:០០]

**ស៖** លោកលើកឡើងខាងដើមថា ឯកសារនីមួយៗនៅពេលដែលទទួលបាននោះ គឺគេបានរៀបចំបញ្ចូលនៅក្នុង *វ៉ើកស៊ីត* ថាតើការបញ្ចូលនៅក្នុងវ៉ើកស៊ីត នេះធ្វើឡើងនៅពេលដែល ឯកសារបញ្ជូនមកពីក្រសួងមហាផ្ទៃ មក ឌី.ស៊ី.ខេម ផងដែរ តើមែនដែរឬទេ?

**ឆ៖** លោកចង់និយាយថា ពេលដែលយើងយកឯកសារមក តើយើងបញ្ចូលព័ត៌មាននៅក្នុងវ៉ើកស៊ីត ដែរឬអត់។ យើងបានបញ្ចូលប្រភពឯកសារនៅក្នុងហ្នឹងដែរ ថាមកពីកន្លែងណា នៅក្នុងវ៉ើកស៊ីតហ្នឹង។ ព្រោះវ៉ើកស៊ីតនេះ វាចេញទៅក្នុងទិន្នន័យបញ្ចូលក្នុងកុំព្យូទ័រ។ អ៊ីចឹងវ៉ើកស៊ីតនេះត្រូវមាន យើងហៅថា ហ្វៀល បាទមានហ្វៀលជាច្រើនដែលបង្ហាញអំពីឈ្មោះ អាសយដ្ឋាន សង្ខេបនៃឯកសារជាដើម ហើយយើងបានដាក់មានកន្លែងមួយជាប្រភព។

ខ្ញុំសូមបញ្ជាក់កន្លែងនេះទៀត តាមពិតនៅក្នុងទិន្នន័យនេះ ឯកសារជាច្រើនត្រូវបានស្កេន ហើយបង្ហោះនៅលើគេហទំព័រនេះយូរមកហើយ ប៉ុន្តែហាក់ដូចជាយើងមិនដឹង ឬមិនចេះរក ដោយសារថាវាមាន មានហ្វៀលមួយដាក់ថា ភី.ឌី.អេហ្វ ហ្វាល គឺកន្លែងហ្នឹងគឺជាឯកសារទាំងស្រុង ដែលយើងបានស្កេនដាក់នៅកន្លែងហ្នឹងយូរមកហើយ។ ប៉ុន្តែជាទូទៅ យើងមើលត្រឹមតែវ៉ើកស៊ីត ហើយយើងឈប់ តែបើយើងមើលមកក្រោមទៀត លោកអាចឃើញកន្លែងខ្លះ លោកអាចបើកឃើញទាំង ស្រុកតែម្តង។ មានហើយស្រេច យូរមកហើយនៅកន្លែងហ្នឹង។

[១១:២១:៣៣]

**ស៖** ដូច្នេះ ជាសង្ខេបមកឯកសារទាំងអស់ គឺរៀបចំបញ្ចូលទៅក្នុងរ៉ឺកស៊ីត ដូចឯកសារទូទៅផងដែរ។ បានន័យថាគ្រប់ឯកសារ វារៀបចំតាមប្រភេទ តាមលក្ខណៈហ្នឹងដូចគ្នា?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។ ឯកសារទាំងអស់គឺធ្វើឡើងទៅតាមក្បួនខ្នាតមួយដែលយើងបានរៀបចំ សម្រាប់ការបញ្ចូលឯកសារនេះដូចៗគ្នា។

**ស៖** សូមអភ័យទោស បើសិនជាលោកឆ្លើយសំណួរនេះរួចហើយ ប៉ុន្តែយើងខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់។ ថាតើឯកសារទាំងអស់នោះទំនងលេចឡើងមកបង្ហាញថាជាឯកសារដើមដែរឬទេនៅពេលដែលទទួលឯកសារនេះមកពីក្រសួងមហាផ្ទៃ តើឯកសារហ្នឹងជាឯកសារដើមដែរឬទេ? ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់។

**ឆ៖** ខ្ញុំគិតថាជាឯកសារដើម ដូចខ្ញុំជម្រាបលោកពីដំបូងអ៊ីចឹង។ ភ្នែកមនុស្សយើង ដំបូងឡើងយើងចាប់អារម្មណ៍ទៅលើពណ៌ អ៊ីចឹងបើសិនជាលោកកាន់ឯកសារនេះ យើងដឹងថានេះជាក្រដាសជួតមាត់ វាខុសពីយើងកាន់ឯកសារមួយដែលមានវ័យចំណាស់ ដែលមានពណ៌ចំណាស់។ ទីមួយគឺពណ៌វាជួយភ្នែកយើង ឲ្យយើងពិចារណា។ ទីពីរទៀត លោកមើលទៅលើការបរិច្ឆេទ ទីបីលោកមើលទៅលើអ្នកនិពន្ធ ព្រោះឯកសារខ្លះមានអ្នកនិពន្ធ។ ហើយដូចខ្ញុំជម្រាបលោកអ៊ីចឹង នៅក្នុងឯកសារនេះ មានទាំងរូបថតទៀត។ ហើយអ៊ីចឹងហើយ យើងលើកមើលទៅលើចំណារទាំងអស់នេះ ពីព្រោះ ឌុច គាត់មិនអាចសរសេរចំណារនៅលើឯកសារបច្ចុប្បន្នទេ អ៊ីចឹងគាត់រស់នៅក្នុងសម័យនោះ អ៊ីចឹងឯកសារដែលគាត់សរសេរហ្នឹង គឺជារឿងមួយកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងអ្នកនិពន្ធរបស់ឯកសារនីមួយៗសំខាន់ណាស់។ ពណ៌ ចំណាស់នៃឯកសារ អ្នកនិពន្ធ កាលបរិច្ឆេទ និងសាច់រឿង។ ដូចខ្ញុំជម្រាបលោកអ៊ីចឹង សាច់រឿងនៃរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាភាសាខ្មែរយ៉ាងណាក៏ដោយ ប៉ុន្តែមានលក្ខណៈខុសពីភាសាខ្មែរដទៃទៀត ដែលយើងប្រើប្រាស់រាល់ថ្ងៃ ឬពីមុន។ អ៊ីចឹងយើងមើលទៅ គឺដឹងតែម្តង។

[១១:២៣:៣៥]

ហើយការវិនិច្ឆ័យទាំងអស់នេះ យើងមិនមែនមើលឯកសារតែមួយទេ គឺយើងបានមើលឯកសារជិតមួយលាន។ អ៊ីចឹងវាមានរូបរាង ទិដ្ឋភាពប្រហាក់ប្រហែលគាត់។ អ៊ីចឹងយើងអាចវិនិច្ឆ័យបានថាឯកសារនេះ គឺជាឯកសារដើម។

**ស៖** សូមអរគុណលោកច្រើន។ តើលោកអាចរៀបរាប់ជូនអង្គសវនាការដោយសង្ខេបដែរឬទេ

ដោយសារតែនៅពេលឯកសារនោះបានទទួលនោះ ថាតើអ្នកណាជាអ្នកចាត់ចែងវា ហើយដាក់លេខកូដនោះ គឺដោយរបៀបណា ដាក់លើឯកសារហ្នឹងដោយផ្ទាល់ ឬក៏យ៉ាងម៉េច?

**ឆ៖** គ្រប់ឯកសារទាំងអស់ ដំបូងឡើងគឺខ្ញុំអាន ដូចខ្ញុំជម្រាបលោកអ៊ីចឹង គឺដូចជាអាហារពេលព្រឹករបស់ខ្ញុំអ៊ីចឹង ខ្ញុំអានឯកសាររាល់ថ្ងៃ។ ពេលខ្ញុំអានហើយ ខ្ញុំបានប្រគល់ឯកសានេះទៅឲ្យអនុប្រធានរបស់ខ្ញុំ គឺលោក វ៉ាន់ថាន់ ពៅដារ៉ា ហើយយើងបានចំណាត់ថ្នាក់របស់វា ថាតើវាជាប្រភេទឯកសារប្រវត្តិរូប ជាឯកសាររូបថត ឬក៏ជាឯកសារជាឯកសារទូទៅ។

[១១:២៥:០០]

នៅពេលហ្នឹងហើយ លោក វ៉ាន់ថាន់ ពៅដារ៉ា មានក្រុមរបស់គាត់មួយ មានអ្នកចុះលេខ។ ជទូទៅ យើងមិនចុះលេខនៅលើឯកសារដើមទេ ដើម្បីបញ្ជាក់អំពីយថាភាពពិតប្រាកដរបស់វា យើងចុះតែនៅលើឯកសារថតចម្លង។ នៅក្នុងឯកសារថតចម្លង យើងមានធ្វើរង្វង់ក្រចកមួយ ដើម្បីសម្គាល់ថាឯកសារនេះចេញមកពីកន្លែងណា។ អ៊ីចឹង បើសិនជាខ្ញុំឃើញឯកសារមួយ មានលេខ “D” ឧទាហរណ៍លេខ “D” ឬក៏លេខ “J” ឬក៏ “K” ខ្ញុំអាចដឹងបានភ្លាម ថានៅក្នុងលេខនេះ នៅខាងក្រោមលេខនេះ មានសញ្ញា តូចមួយ អក្សរកាត់ពីរ ឬក៏បី ខ្ញុំអាចដឹងថា ឯកសារនេះ មកពីកន្លែងណា។ បន្ទាប់ពីចុះលេខហើយ គឺយើងឲ្យមានក្រុមធ្វើម៉ៃក្រូហ្វីម យើងបានថតចម្លងឯកសារទាំងអស់នៅក្នុងម៉ៃក្រូហ្វីម ហើយបន្ទាប់ មក យើងយកឯកសារនេះ ទៅដាក់នៅក្នុងទូរ ដែលមានចុះលេខរៀបចំជាខ្មែរយើងហៅថា សឺមីបាទ សឺមី ក៏បាន ហ្វូលដឺ ក៏បាន ឬក្រដាសបត់ក៏បាននៅក្នុងហ្នឹង ហើយយើងចុះលេខថា នៅក្នុងសំណុំមួយនេះ មានពីលេខណាដល់លេខណា។ បន្ទាប់ពីធ្វើចុះនៅក្នុងទូរហើយយើងមានក្រុមមួយយកឯកសារចេញពីក្នុងទូរ រៀបចំនៅក្នុង វើកស៊ីត ចែកជាក្រុមៗ ហើយនៅក្នុងក្រុមធ្វើ វើកស៊ីត នេះ មានដំណាក់កាលវា១២យ៉ាង កុំភ្លេចថា ឯកសារទាំងអស់នេះ ភាគច្រើនជាភាសាខ្មែរអ៊ីចឹងយើងត្រូវមានក្រុមមួយទៀត បកប្រែជាភាសាខ្មែរ មកជាភាសាអង់គ្លេសទៀត ហើយត្រូវការរយៈពេលដើម្បីត្រួតពិនិត្យការបកប្រែហ្នឹងទៀត ឲ្យវាបានច្បាស់លាស់។

[១១:២៦:៣៤]

ហើយបន្ទាប់មក បានយើងយកឯកសារដាក់ទៅក្នុងទូរវិញ។ សូម្បីតែឯកសារ ជាឯកសារហ្វូតូកូពីក៏ដោយ អ្នកដែលអាចបើកសោហ្នឹងបាន ទាល់តែទាក់ទងមកអនុប្រធានរបស់ខ្ញុំ។ អ៊ីចឹង មនុស្សមិនអាចបើកផ្តេសផ្តាសបានទេ ដោយសារថាយើងខ្លាចបាត់បង់ ឬក៏យើងគិតថា វាខាតពេលវេលា

ព្រោះជួនកាលមនុស្សទៅរកឯកសារដដែលៗ។ អ៊ីចឹង នៅពេលដែលមានសំណើឯកសារដដែលៗ យើងបង្កើតសំណុំរឿងមួយ ឬក៏ហ្វូលដឺមួយ ឬក៏សឺមីមួយហ្នឹង ដើម្បីអ្នកមកក្រោយទៀត យើងហុចឱ្យតែម្តង ឱ្យវាលឿន ពីព្រោះជាទូទៅ នៅស្រុកយើងដូចលោកដឹងស្រាប់ហើយ ថាមានមនុស្សប្រហែលតែប្រាំភាគរយទេ ដែលប្រើអ៊ីនធឺណែត ជាទូទៅគឺមានអ្នកនៅតុលាការនេះ ប៉ុន្តែអ្នកស្រុកស្រែចម្ការគាត់គ្មានអ៊ីនធឺណែតប្រើទេ អ៊ីចឹង គាត់ចង់បានឯកសារដែលជាក្រដាសផ្ទាល់ៗតែម្តង។ អ៊ីចឹង បន្ទាប់ពីហ្នឹងហើយ យើងដាក់ឯកសារចូលវិញ ហើយក្រោយមក យើងមានក្រុមមួយទៀត ដែលចាំត្រួតពិនិត្យអ្នកដែលបញ្ចូលទិន្នន័យ។ ជាទូទៅ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានសុំឱ្យបុគ្គលិកទាំងអស់រាយការណ៍ប្រចាំសប្តាហ៍ ដើម្បីដឹងថា ក្នុងម្នាក់បញ្ចូលបានទិន្នន័យប៉ុន្មានហើយ ហើយចំពោះខ្ញុំ ខ្ញុំចូលចិត្តត្រួតពិនិត្យ ឬក៏អេឌីត កែសម្រួលហ្នឹងនៅលើក្រដាស ជាជាងនៅលើកុំព្យូទ័រ។ អ៊ីចឹងខ្ញុំជាទូទៅ ខ្ញុំឱ្យគាត់ព្រីនចេញ គាត់ព្រីនចេញពីម៉ាស៊ីន ដាក់នៅក្នុងហ្វូលដឺមួយ ស្រួលខ្ញុំបើកមើល ពេលណាដែលខ្ញុំទំនេរ។ ជួយកែសម្រួលអ្នកដែលបានកែសម្រួលមួយជាន់ទៀត ដើម្បីឱ្យធានាបានថាព័ត៌មាននេះវាសុក្រឹត ដែលយើងអាចធ្វើទៅបាន។ អ៊ីចឹង ដំណើរការនេះ វាធ្វើដដែលៗអ៊ីចឹង ដូចជារោងចក្រមួយអ៊ីចឹង បាទ ដដែលៗហ្នឹង អស់រយៈពេលជាង១០ឆ្នាំ។

[១១:២៨:១០]

**ស៖** សូមអរគុណលោកច្រើន។ ខ្ញុំសូមសួរចូលទៅប្រភពឯកសារដែលយើងបានពិភាក្សានៅក្នុងសវនាការ ហើយនិងបង្ហាញជាឧទាហរណ៍នៅពេលក្រោយ។ ជាពិសេស ខ្ញុំចង់សួរអំពីបណ្ណសារដ្ឋានជាតិ។ តើលោកជម្រាបជូនអង្គសវនាការដែរឬទេ ថាតើមានឯកសារទាំងឡាយដែលទទួលបានដោយ ឌី.ស៊ី.ខេម នោះក៏មានមកពីខាងបណ្ណសារដ្ឋានជាតិដែរ។ តើមែនដែរឬទេ?

**ឆ៖** ពិតជាមែនបាទ។ យើងបានយកមកពីខាងបណ្ណសារដ្ឋានជាតិមែន។

**ស៖** តើលោកចាំដែរឬទេ ថាតើឯកសារទាំងអស់នោះ ទទួលបានមកពេលណាដែរ?

**ឆ៖** ខ្ញុំសូមនិយាយលើសបន្តិច។ សូមជម្រាបថា នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមកដល់ដំបូង គឺយើងត្រូវបានផ្តល់យោបល់ដោយរដ្ឋាភិបាលកម្ពុជាឱ្យធ្វើការជាមួយបណ្ណាល័យជាតិ បណ្ណសារដ្ឋានជាតិ និងសារមន្ទីរទួលស្លែង។ អ៊ីចឹង បើយើងនិយាយឱ្យខ្លីទៅ គឺថាជាអ្នកដែលធ្វើកិច្ចការជួយដល់យើង។ គំនិតរបស់ខ្ញុំ គឺយើងមិនទៅយកឯកសារពីទួលស្លែងមកដាក់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬទៅយកឯកសារពីសារមន្ទីរជាតិមកដាក់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ នៅពេល

ដែលស្ថាប័នទាំងពីរនេះ ជាស្ថាប័នជាតិ មានអនុក្រឹត្យ មានភាពស្របច្បាប់។ ម្ល៉ោះហើយ បើសិនជាទាក់ទងនឹងការសិក្សាស្រាវជ្រាវយើងសំណើសុំជាហ្វូតូកូពី ដើម្បីយើងស្រួលធ្វើការសិក្សាស្រាវជ្រាវជាប្រចាំថ្ងៃ។

[១១:២៩:៤៨]

នៅបណ្ណសារដ្ឋានជាតិនេះ តាមដែលខ្ញុំដែលចាំ យើងចាប់ផ្តើមចុះទៅសិក្សាស្រាវជ្រាវតាំងពីឆ្នាំ៩៥មកម្ល៉េះ។ ហើយកាលនោះ យើងមានបុគ្គលិកបីនាក់ ប្រាក់ខែគាត់ក្នុងមួយខែ២០ដុល្លារទេ បាទ ហើយគាត់ទៅស្រាវជ្រាវ ហើយខ្ញុំជាអ្នកឲ្យគាត់ទៅស្រាវជ្រាវ ពីព្រោះខ្ញុំជឿថាគេមានឯកសារផ្សេងៗទៀត ដែលអ្នកសិក្សាស្រាវជ្រាវបរទេសមិនបានឃើញ មិនបានយកមកពិភាក្សា មិនបានយកមកប្រើប្រាស់។ អ៊ីចឹងជារៀងរាល់ថ្ងៃ ខ្ញុំមានបុគ្គលិកចុះទៅបណ្ណសារស្ថានជាតិ ហើយស្នើសុំ ទៅមើលបញ្ជីឯកសារផង ចុះទៅផ្ទាល់តែម្តង។ ដូចខ្ញុំជម្រាបលោកអ៊ីចឹង នៅក្នុងកន្លែងមួយៗខ្ញុំទៅច្រើនដងណាស់ មិនមែនទៅតែម្តង ហើយយកមកចប់ទេ ខ្ញុំទៅទៀត ទៅច្រើនដង។ ពីព្រោះនៅក្នុងទសវត្សរ៍៨០ នៅពេលដែលប្រទេសក្រីក្រ នៅពេលដែលប្រទេសកំពុងតែជួបប្រទះនឹងការអត់អាហារអត់អីហ្នឹង គឺថាមនុស្សភាគច្រើនគឺមិនសូវចាប់អារម្មណ៍លើបញ្ហាឯកសារទេ គឺវានៅរាយប៉ាយ នៅកន្លៀតតុ នៅក្រោមទូរ ក្រោមអីក៏មានដែរ។ អ៊ីចឹង ខ្ញុំទៅច្រើនដង ហើយពេលយើងចុះទៅហ្នឹង គឺយើងចាប់ផ្តើមដំបូងយើងមើលបញ្ជីឯកសារណា ដែលជាលក្ខណៈផ្លូវការ ជាមុនហើយៗ យើងបានសុំអនុញ្ញាតដល់បណ្ណសារស្ថានជាតិ ដើម្បីមើលទៅកន្លែងផ្សេងៗទៀត ក្រែងលោវាមានសេសសល់ ឬក៏គាត់ភ្លេចនៅក៏នៅកន្លែងណាមួយដែលគាត់នឹកស្មានមិនដល់។

[១១:៣១:០៨]

អ៊ីចឹងគឺយើងបានចុះទៅ ហើយនិងចុះទៅនេះ មូលហេតុដែលខ្ញុំចុះទៅបណ្ណសារស្ថានជាតិនេះ គឺខ្ញុំបានអានសៀវភៅមួយរបស់លោកប្រវត្តិវិទូ ប៉ែន ឃៀរនិន និយាយអំពីពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយគាត់បានយោងឯកសារនៅបណ្ណសារស្ថានជាតិ។ ហើយគិតថា មិនអាចមានឯកសារតែពីរបីសន្លឹកទេ អាចច្រើនពីនេះ។ អ៊ីចឹងខ្ញុំក៏ដោយសារការអានសៀវភៅនេះ ខ្ញុំក៏ទៅកន្លែងនោះតែម្តង ហើយក៏បានឃើញមែន។ ហើយទៅដល់ទីនោះ គឺមានការបើកទូលាយ សព្វថ្ងៃគឺយ៉ាងណាក៏ដោយ ហើយឯកសារទាំងអស់នេះ ខ្ញុំបានថតទាំងស្រុង ខ្ញុំមិនដឹងថាប៉ុន្មានម៉ឺនសន្លឹកទេ ហើយបានប្រគល់ជូនទៅឲ្យក្រុមមេធាវីការពារជនជាប់ចោទទាំងស្រុង។ ខ្ញុំបានប្រគល់ទៅឲ្យលោក រីឆាត រ៉ូជឺ

គាត់បានសុំទាំងស្រុងតែម្តង។ កាលនុំងដឹកទៅប៉ុន្មានកេស។ ខ្ញុំហ្វូតូកូពីជូនទាំងស្រុងតែម្តង ពីព្រោះគាត់ចាប់អារម្មណ៍លើឯកសារហ្នឹង ហើយជាទូទៅគាត់ច្រើនតែសំណើមកប្រាប់ខ្ញុំថា ឯកសារ បាត់មិនឃើញនៅក្នុងសំណុំរឿង។ ហើយខ្ញុំថា ហេតុអីក៏មិនចេះសហការគ្នាធ្វើការជាមួយគ្នា? ខ្ញុំឱ្យ មកតុលាការ ហេតុអីចេះតែមានការទំនាស់គ្នាអ៊ីចឹង? ខ្ញុំគិតថា ដើម្បីបញ្ចប់រឿងនេះ យកទាំងស្រុងតែម្តងទៅ។ អ៊ីចឹងខ្ញុំក៏បានកូពីនេះជូនគាត់ទាំងស្រុង ឯកសារនេះ។

[១១:៣២:២៥]

**ស៖** លោកបានរៀបរាប់ដ៏មានប្រយោជន៍ពីប្រភេទមួយនៃឯកសារមួយ ជាពិសេសគឺឯកសារភាគច្រើន។ នៅពេលដែលលោកនិយាយថា ឯកសារ *ខំម៉ើស* ដែលថាពាណិជ្ជកម្មហ្នឹង គឺថាតើឯកសារហ្នឹងវាចេញមកពីមន្ទីរពាណិជ្ជកម្ម ឬក៏ក្រសួងពាណិជ្ជកម្មនោះ? ក្រសួងរបស់របបនោះ ឬក៏យ៉ាងដូចម្តេច?

**ឆ៖** មានឯកសារនៅក្នុងសំណុំឯកសារនេះ ដែលមានសរសេរនៅខាងឆ្វេងដាក់ថា "មន្ទីរពាណិជ្ជកម្ម" ហើយមានឯកសារមួយចំនួនមានជាត្រា ដែលដាក់ថា "មន្ទីរពាណិជ្ជកម្ម"ដែរ។ អ៊ីចឹងខ្ញុំគិតថានេះវាជាលក្ខណៈផ្លូវការរបស់ឯកសារនេះ ដែលអាចបញ្ជាក់បាន។

**ស៖** តើលោកអាចជម្រាបតុលាការបានដោយសង្ខេបទេ ថាតើប្រភេទឯកសារខុសពីឯកសារពាណិជ្ជកម្មហ្នឹងមានប្រភេទអ្វីទៀតទេ ដែលលោកអាចបញ្ជាក់ថាជាឯកសារហ្នឹងចេញមកពីបណ្ណសារដ្ឋានជាតិនោះ ដែលបានរកឃើញនៅទីនោះ?

[១១:៣៣:៥១]

**ឆ៖** ជាទូទៅនៅក្នុងសំណុំឯកសារធំៗតែងតែមានលាយឡំទៅដោយឯកសារផ្សេងទៀត ដែលជាលក្ខណៈជាបុគ្គល ឬរវាងបុគ្គលទៅបុគ្គល ឬក៏ជាកំណត់ហេតុការប្រជុំណាមួយ។ ប៉ុន្តែដោយសារថាមានលក្ខណៈជារួមអ៊ីចឹង គឺយើងហៅអ៊ីចឹងទៅ។ ប៉ុន្តែបើសិនជាលោកមើលលម្អិត វាអាចមានខុសពីហ្នឹង អាចមាន-- តាមដែលខ្ញុំចាំ នៅក្នុងនេះ មានជាតារាងបញ្ជី ឧទាហរណ៍ភស្តុភារ មានតារាងបញ្ជីអំពីស្រូវ អង្ករជាដើម ពីព្រោះនៅក្នុងឯកសារនេះ ខ្ញុំបានជួយដល់អ្នកសិក្សាស្រាវជ្រាវម្នាក់ គឺលោកវ៉េនឌុល ឌូហ្វាកូ គាត់បានសិក្សាអំពីការអត់អាហារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយខ្ញុំបានទៅមើលឯកសារនេះ ហើយឃើញមានឯកសារជាច្រើននិយាយអំពីអង្ករ ស្រូវ វត្ថុធាតុដើមផ្សេងៗជាតារាង ជាបញ្ជី។

អ៊ីចឹងក្រៅពីឯកសារ ជាសំណេរក៏មានជាតារាងៗ ហើយមានឯកសារជាបុគ្គលដែរបាទ។

[១១:៣៤:៥៦]

**សៈ** តាមដែលខ្ញុំយល់ ដែលលោកបញ្ជាក់ពីខាងដើមនោះគឺថា ឯកសារទាំងអស់នេះគឺមាននៅក្នុងបណ្ណសារនោះ គឺពិនិត្យមើលទៅជាឯកសារច្បាប់ដើម។ តើមែនឬទេ?

**ឆៈ** ខ្ញុំថា យើងយកពីឯកសារពីបណ្ណសារដ្ឋានជាតិជាឯកសារហ្វូតូកូពី។ អ៊ីចឹងនិយាយអំពីយថាភាពនៃឯកសារដើម ខ្ញុំគិតថាទាល់តែបណ្ណសារដ្ឋានជាតិជាអ្នកនិយាយជម្រាបជូនលោក ដោយសារគាត់ជាអ្នកកាន់កាប់។ ប៉ុន្តែចំពោះខ្ញុំៗបានយកចេញមកពីបណ្ណសារដ្ឋានជាតិ។

**សៈ** តើចំពោះលោក ដែលលោកមើលទៅឃើញថាឯកសារទាំងអម្បាលម៉ាននោះចេញមកពីសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆៈ** ពិតប្រាកដតែម្តង។ ដោយសារថាសាច់រឿង ដោយសារថាកាលបរិច្ឆេទ ដោយសារថាឯកសារនេះ-- ភាសាដែលប្រើប្រាស់ ដោយសារអ្នកនិពន្ធ ដោយសារថាមនុស្សដែលធ្វើការនៅកន្លែងនេះ គឺលោក វ៉ាន់ រិត ខ្ញុំធ្លាប់ជួបលោក វ៉ាន់ រិត ដែលគាត់ទទួលបន្ទុកផ្នែកខាងសេដ្ឋកិច្ចនេះដែរ ខ្ញុំបានជួបគាត់ នៅក្នុងស្រុកស្អាង ហើយគាត់ក៏បានបញ្ជាក់ដែរថា នេះគឺជាឯកសារពិតរបស់របបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែជាអកុសលលោក វ៉ាន់ រិត បានស្លាប់បាត់ទៅហើយ។

[១១:៣៦:៣០]

**សៈ** លោកបានបញ្ជាក់ថា គាត់បានបញ្ជាក់ថា ឯកសារហ្នឹងជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ តើលោកអាចជម្រាបតុលាការបានដែរឬទេ ថាគាត់ជម្រាបលោកហ្នឹង ថាគាត់ធ្វើឯកសារហ្នឹង ឬក៏ឯកសារហ្នឹងចេញពីកន្លែងណា កាលពីសម័យនោះ?

**ឆៈ** នៅក្នុងឯកសារហ្នឹងមានហត្ថលេខារបស់គាត់ ហើយគាត់ជាកម្មាភិបាលម្នាក់នៅក្នុងក្រសួងពាណិជ្ជកម្ម។ លោកអាចបើកមើលឃើញនៅក្នុងហ្នឹងតែម្តង។ ហើយឯកសារនេះ ដូចខ្ញុំបានជម្រាបលោកអ៊ីចឹង វាមានរាប់ម៉ឺនទំព័រ។ វាស្រាក់គ្នា វាមិនមែនឯកសារតែមួយទេ យើងយកវាមកពិចារណា ហើយឯកសាររាប់ម៉ឺន រាប់សែន អ៊ីចឹងបើលោកមើលទាំងអស់វាឃើញសាច់រឿងតៗគ្នា។ យើងឃើញរឿងដែលថា ស្រូវអង្ករយកទៅកន្លែងណា? ពោតយកទៅកន្លែងណា? អ្នកណាអត់អាហារសំណាបដកស្ទូងអីអ៊ីចឹងវាមានស្រាក់គ្នាទាំងអស់។ អ៊ីចឹងរឿងហេតុទាំងអស់នេះ វាអត់មានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រៅពីរបបកម្ពុជាប្រជាធិបតេយ្យទេ។ ហើយមួយទៀត កាលបរិច្ឆេទ និង

អ្នកនិពន្ធ គឺសុទ្ធសឹងតែរស់នៅ មានតួនាទីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១១:៣៧:៣៥]

**ស៖** សូមអរគុណ។ នៅពេលដែលលោកបានប្រមូលឯកសារទាំងអស់នេះ តើបានពិភាក្សាជាមួយបុគ្គលិក ឬក៏មន្ត្រីនៅបណ្ណសារដ្ឋានជាតិដែរឬទេ?

**ឆ៖** ខ្ញុំបានពិភាក្សាឯកសារនេះ ជាមួយអ្នកស្រី លឹម គី សព្វថ្ងៃគាត់នៅកាន់កាប់បណ្ណសារដ្ឋានជាតិដដែល ហើយនិងលោក ស៊ិន ឃិន គាត់ជាប្រធាន សព្វថ្ងៃគាត់ប្រហែលជាគាត់ចូលនិវត្តន៍ហើយ អំពីឯកសារនេះ ថាតើគាត់បានមកពីណា? ហេតុអ្វីបានជានៅកន្លែងនេះ? ខ្ញុំបានសួរគាត់ ហើយសព្វថ្ងៃគាត់នៅធ្វើការកន្លែងដដែល។

**ស៖** តើលោកនៅចាំទេថា ចំពោះការប្រមូលឯកសារជាក់លាក់មួយចំនួន ថាតើឯកសារនោះគេបានប្រមូលពីដំបូងហ្នឹង យកមកពីកន្លែងណា? មុននឹងយកមកដាក់នៅបណ្ណសារដ្ឋានជាតិនេះ?

**ឆ៖** តាមដែលខ្ញុំចាំ ខ្ញុំបានសួរគាត់ដែរ ហើយកាលនោះ នេះនិយាយតាមការចងចាំ ពីព្រោះវាយូរឆ្នាំដែរ។ ខ្ញុំចាំថា ឯកសារនេះដំបូងទុកនៅក្រសួងវប្បធម៌និងព័ត៌មាន ដែលជាក្រសួងមួយគ្រប់គ្រងដោយលោក កែវ ចិន្តា ដែលជាប្រធានតុលាការនៅក្នុងខែសីហា ឆ្នាំ១៩៧៩។ អ៊ីចឹង ឯកសារទាំងអស់ត្រូវបានទុកនៅទីនោះៗ ហើយបន្តក្រោយមក ដោយសារបណ្ណសារដ្ឋានជាតិមានក្របខ័ណ្ឌអំពីការប្រមែប្រមូលរក្សាឯកសាររបស់ជាតិ។ អ៊ីចឹង ឯកសារទាំងអស់ត្រូវបានប្រគល់មកឲ្យបណ្ណសារដ្ឋានជាតិដើម្បីថែរក្សា។

[១១:៣៩:៣១]

នៅក្នុងបណ្ណសារដ្ឋានជាតិក៏មានឯកសារមកពីតុលាការកាត់ទោសឆ្នាំ៧៩ ដែរ ដោយសារកាលនោះលោក កែវ ចិន្តា ជាប្រធានតុលាការផង ជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងព័ត៌មាន (សុំទោស) ប្រហែលជាព័ត៌មាន និងឃោសនាការ នៅក្នុងពាក្យហ្នឹង។ អ៊ីចឹង ឯកសារទាំងអស់ដំបូងឡើងនៅក្នុងអគារនោះ ហើយតាមដែលខ្ញុំចាំអគារនោះនៅជិតផ្សារអូរឫស្សី នៅផ្លូវមុន្នីវង្ស ឥឡូវសព្វថ្ងៃនេះកំពុងតែសង់អីផ្សេងមួយទៀតហើយ។ ប៉ុន្តែត្រូវបានបញ្ជូនទៅឲ្យបណ្ណសារដ្ឋានជាតិ ដោយសារថាមានគោលការណ៍ច្បាប់ មានគោលការណ៍របស់ជាតិ ជាកន្លែងផ្ទុកតម្កល់ឯកសាររបស់ជាតិ។ អ៊ីចឹង ឯកសារតុលាការ៧៩ ក៏នៅហ្នឹង ឯកសារដែលពាក់ព័ន្ធនឹងរឿងតុលាការនុ៎ង ក៏នៅកន្លែងហ្នឹងដែរ។

**សៈ** នៅពេលដែលលោកប្រមូលច្បាប់ចម្លងឯកសារចេញពីបណ្ណសារដ្ឋានជាតិនោះ ថាតើច្បាប់ចម្លងទាំងអស់នោះ ត្រូវឆ្លងតាមដំណើរការដូចដែលលោកបានជម្រាបតុលាការរួចមកហើយថា ឯកសារចេញពីក្រសួងមហាផ្ទៃជាដើមនោះ គឺត្រូវឆ្លងបែបបទដូចគ្នាដែរឬទេ?

**ឆៈ** ក្នុងការធ្វើចុះបញ្ជី គឺដូចៗគ្នាបាទ។

**សៈ** ខ្ញុំអាចនឹងឆ្លងទៅដល់ប្រធានបទផ្សេង គឺប្រភេទឯកសារផ្សេង ខ្ញុំគិតថា លោកបានបញ្ជាក់ពីខាងដើមអំមិញនោះគឺថា ក្នុងចំណោមអង្គការជាច្រើន ហើយអ្នកដែលប្រមូលឯកសារទាំងអស់នោះ ដែលជាឯកសារក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹងគឺថា ម្នាក់ក្នុងនោះគឺមានលោក ដេវីដ ហក ហើយនិងគណៈកម្មការប្រមូលឯកសារកម្ពុជា។ តើលោកអាចរៀបរាប់ជូនតុលាការបានទេ តាមអ្វីដែលលោកបានដឹងនោះ ថាតើប្រភេទឯកសារអ្វីខ្លះដែលគណៈកម្មការនោះបានប្រមូល ក្នុងសម័យក្រោយពីកម្ពុជាប្រជាធិបតេយ្យមកនោះ?

[១១:៤១:៥៨]

**ឆៈ** មានជារូបថត បាទមានជារូបថត។ រូបថតនេះមានពីរសណ្ឋាន។ រូបថតមួយគឺជារូបថតមកពីសារមន្ទីរទួលស្លែង។ រូបថតមួយទៀតគឺជារូបថតទីតាំងគុក ឬក៏រណ្តៅសាកសពដែលលោក ដេវីដ ហក ថតដោយខ្លួនឯង។ ដូចជារូបថតវត្តអារាមដែលបាក់បែក រណ្តៅសាកសពដែលគាត់បានទៅដល់។ អ៊ីចឹងនៅក្នុងនេះ ទីមួយមានរូបថតពីរប្រភេទ។ រូបថតមកពីសម័យកម្ពុជាប្រជាធិបតេយ្យ ហើយនិងរូបថតដែលគាត់ថតខ្លួនឯង។ ទីពីរមានជាខ្សែអាត់ថតសំឡេង បទសម្ភាសជាមួយនឹងចាម អ៊ីស្លាម ឬក៏ព្រះសង្ឃ ឬក៏ជនភៀសខ្លួនមានជារបៀបជាបទសម្ភាស មានជាកាសែតផង មានជាអក្សរផង ដែលវាយអង្គុលីលេខទៅលើក្រដាស មានជាលិខិតឆ្លើយឆ្លងរបស់គាត់ក្នុងការស្នើសុំសិក្សាស្រាវជ្រាវ ឬក៏មានលិខិតដែលលោក អ៊ឹង ប៊ុច កាលនោះជាប្រធានសារមន្ទីរទួលស្លែងបានអនុញ្ញាតឲ្យយកឯកសារជាដើម មានជានិក្ខេបបទ ហើយចាំដែលចាំមាននិក្ខេបបទមួយសរសេរដោយលោក យ៉ង់ សែម អំពីពុទ្ធសាសនានៅកម្ពុជា អំពីជនជាតិចិននៅកម្ពុជា មានជានិក្ខេបបទ មានជាឯកសារដែលគាត់បានរៀបចំដោយខ្លួនឯង ហើយបកជាភាសាអង់គ្លេស មានជាបញ្ជីអ្នកដែលស្លាប់ អ្នកទោសដែលស្លាប់ មានជា ឯកសារដែលគាត់យកពីក្រៅស្រុកខ្មែរ ហើយបញ្ចូលទៅក្នុងសំណុំរឿងរបស់គាត់ដែរ។ ឯកសារដែលគាត់យកមកបានពីអ្នកសិក្សាស្រាវជ្រាវផ្សេងទៀត ដូចជាលោក ដេវីដ ឆេនដ៍ល័រ ដូចជាលោក ហ្វូលីយ៉ូ ហៀលជ្រេស ដូចជា ស្ទីវ ជាដើម ដូចជាអ្នកស្រី អេលីហ្សាប៊េត បេកយ័រ ក៏មាននៅក្នុងហ្នឹង

ដែរ។

[១១:៤៣:៥៤]

**ស៖** ខ្ញុំសូមផ្តោតទៅលោកផ្នែកឯកសារមួយ ដែលលោកបានបញ្ជាក់នោះគឺថា បញ្ជីអ្នកទោសដែលចេញមកពីរបបកម្ពុជាប្រជាធិបតេយ្យ ថាតើមានឯកសារអ្វីទៀតដែលលោកបានដឹងថា គេប្រមូលដែរ ប៉ុន្តែប្រមូលនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ?

**ឆ៖** លោកចង់មានប្រសាសន៍ថា នៅក្នុង ដេវីដ ហាក *ខូឡិចសិន*? នៅក្នុងហ្នឹង?

**ស៖** បាទ ខ្ញុំចង់មានន័យដូច្នោះ។

**ឆ៖** ក្នុងនោះបញ្ជីអ្នកទោស តាមដែលខ្ញុំចាំ គឺជាបញ្ជីអ្នកទោសដែលគាត់បានយកមកពីសារមន្ទីរទួលស្លែង។ ប៉ុន្តែគាត់យកមករៀបជាកូនសៀវភៅមួយ ៗកាលនុំង ហើយខ្ញុំមិនគិតថាមានបញ្ជីអ្នកទោសផ្សេងទៀតមកពីកន្លែងផ្សេងទេ។ មិនអាចមាន។ ខ្ញុំគិតថាមានតែមកពីទួលស្លែង។

**ស៖** តាមដែលលោកបានដឹង រីឯរូបថតទាំងអស់ដែលយកមកពីទួលស្លែងនោះគឺស្ថិតនៅក្នុងប្រភេទដូចគ្នាសុទ្ធតែរូបចេញពីទួលស្លែង ឬក៏អាចរូបមកពីកន្លែងផ្សេងទៀត?

**ឆ៖** រូបថតមានពីរប្រភេទ។ រូបថតមួយគឺជារូបថតនៅទួលស្លែងមកពីរបបកម្ពុជាប្រជាធិបតេយ្យ រូបថតអ្នកទោស។ ខ្ញុំសូមជម្រាបបន្តិច ជាទូទៅយើងយល់ច្រឡំ ពេលយើងទៅសារមន្ទីរទួលស្លែង យើងយល់ថារូបថតទាំងអស់សុទ្ធសឹងតែជាអ្នកទោស មិនមែនទេ។ រូបថតខ្លះទៀតគឺជាកម្មាភិបាលដែលនៅធ្វើការទីនោះ។ អ៊ីចឹងមានការភ័ន្តច្រឡំតាំងពីឆ្នាំ១៩៧៩មកម្ល៉េះ។ ហ្នឹងជាបញ្ហាមួយ។ អ៊ីចឹងរូបថតរបស់លោក ដាវីត ហាក ហ្នឹងមានរូបថតមកពីសម័យកម្ពុជាប្រជាធិបតេយ្យ ដែលអាចជាអ្នកទោសផង អាចជាកម្មាភិបាលដែលធ្វើការនៅមន្ទីរសន្តិសុខនោះផង។ រូបថតប្រភេទទីពីរ គឺជារូបថតដែលគាត់ចុះទៅដល់មូលដ្ឋាន ឬក៏ភាសាសាមញ្ញាថាយើងចុះទៅខេត្ត។ គាត់ទៅថតនៅកន្លែងផ្សេង ៗទៀត ប៉ុន្តែមានលក្ខណៈជាពណ៌។ គាត់ថតវត្តអារាម គាត់ថតមន្ទីរ ព្រះវិហារអ៊ីស្លាម គាត់ថតអ្នកស្រុក គាត់ថតអីផ្សេងៗទៀត ហើយគាត់ដាក់បញ្ចូលជាមួយគ្នាតែម្តង។

[១១:៤៦:១៨]

**ស៖** តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារជាក់លាក់ដែលលោក ដាវីត ហាក បានមានឬក៏របស់គណៈកម្មការចងក្រងឯកសារកម្ពុជានោះដែរឬទេ?

**ឆ៖** ខ្ញុំមានទាំងស្រុងតែម្តង គឺគាត់ដឹកផ្ញើមក។ ខ្ញុំសូមបញ្ជាក់បន្តិច គឺថាឯកសារដឹកមកទាំងកប៉ាល់ មកពីរដ្ឋញូវជឺស៊ី ដែលជា-- គាត់រស់នៅរដ្ឋនោះ ហើយដឹកមកតាមកប៉ាល់។ ហើយរូបថតមកជាមុន ខ្ញុំកាន់ខ្លួនឯងផ្ទាល់។ យួរមកពីសហរដ្ឋអាមេរិក តាមកប៉ាល់ហោះមកតែម្តង។ អ៊ីចឹងយើងមានទាំងស្រុង គឺថាយើងបោសសម្អាតកន្លែងដាក់ឡានគាត់ហ្នឹងគឺ សូន្យ។ យើងដឹកមកទាំងអស់តែម្តង។

**ស៖** សូមអរគុណ។ នៅពេលដែលសល់បន្តិចបន្តួចនេះ ខ្ញុំនឹងពិនិត្យមើលដោយសង្ខេបទៅលើប្រភពមួយដែលលោកបានពិភាក្សាខាងដើមថា លោកបានច្បាប់ចម្លងនៃឯកសារមកពីសារមន្ទីរទួលស្លែង។ តើមជ្ឈមណ្ឌលឯកសារកម្ពុជាបានរក្សាទុកឯកសារច្បាប់ដើមដែលមានប្រភពដើមមកពីសារ-មន្ទីរទួលស្លែងដែរឬទេ?

[១១:៤៨:០០]

**ឆ៖** លោកចង់ឲ្យខ្ញុំឆ្លើយវែង ឬក៏ឆ្លើយខ្លី? ព្រោះអានេះវាអាចវែងបន្តិច។

**ស៖** ប្រសិនបើ បើសិនជាអាចទៅរួចសូមលោកមេត្តាដោយសង្ខេបបាទ។

**ឆ៖** អ៊ីចឹង ខ្ញុំសង្ខេបជូន ឯកសារដើមទាំងអស់របស់សារមន្ទីរទួលស្លែង គឺនៅសារមន្ទីរទួលស្លែង។ អ៊ីចឹង បើយើងត្រូវការសិក្សាស្រាវជ្រាវដោយសារយើងមានអនុញ្ញាត ការអនុញ្ញាតពីរាជរដ្ឋា-ភិបាលកម្ពុជា យើងអាចចុះទៅស្ថាប័នណាមួយក៏បានដែរ។ អ៊ីចឹង ចំពោះសារមន្ទីរទួលស្លែងដែលមានការថែទាំងរក្សាដោយសាកលវិទ្យាល័យ ខុនណែល តាំងពីឆ្នាំ៩២មកម្លេះ បានថែរក្សាឯកសារនេះ បានដាក់នៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់។ អ៊ីចឹងយើងគ្មានហេតុផលអ្វីទៅយកចេញពីកន្លែងហ្នឹងទេ។ ប៉ុន្តែខ្ញុំធ្លាប់បានជូនយោបល់ទៅសារមន្ទីរទួលស្លែងដែរ គួរតែមានទូដែកសុវត្ថិភាពក្នុងករណីមានអគ្គីភ័យជាដើម ប៉ុន្តែជារួម គឺឯកសារនេះត្រូវបានថែរក្សាទុកដោយត្រឹមត្រូវដោយសាកលវិទ្យាល័យ ខុនណែល តាំងពីឆ្នាំ៩២។ ហើយក្រោយមកសាកលវិទ្យាល័យយ៉ែល និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅថតចម្លង ដើម្បីសម្រាប់បម្រើការសិក្សាស្រាវជ្រាវ ដោយសារថាវាជាគោលនយោបាយមួយរបស់រដ្ឋាភិបាលកម្ពុជាក្នុងការផ្សព្វផ្សាយ។ ហើយបានអនុញ្ញាតឲ្យយើងបានប្រមូល ហើយដើម្បីផ្សព្វផ្សាយ។ អ៊ីចឹងយើងបានទៅថតចម្លងយកចេញមក។

[១១:៤៩:២៧]

**ស៖** ខ្ញុំត្រឡប់មកសំណួរមួយទៀតថា តើមានឯកសារច្បាប់ដើមរបស់កម្ពុជាប្រជាធិបតេយ្យដែរឬទេ ដែលលោករក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលថា ឯកសារនោះពីមុននៅសារមន្ទីរ

ទួលស្លែងទេ?

**ឆ៖** ខ្ញុំអត់យល់ ដូចកន្លែងមជ្ឈមណ្ឌលឯកសារកម្ពុជា យើងមានឯកសារដើមដែរ ប៉ុន្តែមិនមែនយកចម្លើយសារភាពពីទួលស្លែងមកទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ គឺជាប្រភេទឯកសារផ្សេងទៀត ដែលប្រហែលជាទាក់ទងនឹងសារមន្ទីរទួលស្លែង ឬមកពីកន្លែងផ្សេងទៀត ហើយយើងទុកនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងទូដែកសុវត្ថិភាព។ អ៊ីចឹងយើងមានឯកសារដើមនៅមជ្ឈ-មណ្ឌលឯកសារកម្ពុជាដែរ។

**ស៖** តើត្រូវដែរឬទេ ដែលថាលោកមានទំនាក់ទំនងជិតស្និទ្ធជាមួយសារមន្ទីរទួលស្លែងនោះ?

**ឆ៖** ថាជិតស្និទ្ធក៏បាន ថាមិនសូវជិតស្និទ្ធក៏បាន។ ដោយសារថាយើង ធ្វើការជាមួយគ្នា ហើយយើងត្រូវគោរពបែបបទការងាររបស់ស្ថាប័នរបស់គេ ដែលជួនកាលវាមិនមែនជាអ្វីដែលយើងទម្លាប់ការងាររបស់យើង។ ឧទាហរណ៍ ទោះបីយើងត្រូវបានអនុញ្ញាតដោយរាជរដ្ឋាភិបាលកម្ពុជាយ៉ាងណាក៏ដោយ នៅពេលដែលយើងចុះទៅស្ថាប័នមួយ គឺយើងត្រូវទាក់ទងសាម៉ីក្រសួងដោយផ្ទាល់ទៀត អំពីពេលវេលារបស់គេ អំពីបុគ្គលិករបស់គេ អំពីធនធានរបស់គេ និងដែលគេអាចសហការជាមួយនឹងយើងបាន។ អ៊ីចឹងគឺថាយើងមិនមែនមានលិខិតហើយ យើងអាចចុះទៅដោយស្វ័យប្រវត្តិ ដេញមនុស្សចេញ យើងត្រូវចូលមកមើល ក៏អ៊ីចឹងដែរ។ អ៊ីចឹងយើងបានធ្វើកិច្ចការនេះ ហើយយើងចាត់ទុកថាមិនមែនជាបញ្ហាទេ គឺជាការងារបែបបទ ដើម្បីធានាឲ្យបាននូវភាពសុក្រឹត និងច្បាស់លាស់។

អ៊ីចឹងយើងជាមួយសារមន្ទីរទួលស្លែងហ្នឹង គឺយើងបានធ្វើការងារជាមួយគ្នាអស់រយៈពេលជាងដប់ឆ្នាំហើយ ក៏ដូចជាបណ្ណសារដ្ឋានជាតិដែរ។

[១១:៥១:៣៣]

**ស៖** លោកបានបញ្ជាក់ថា លោកបានពិនិត្យមើលនៅទួលស្លែង សារមន្ទីរទួលស្លែង បានស្រាវជ្រាវនៅទីនោះ តើផ្អែកលើការងាររបស់លោកថា តើផ្អែកក្រៅពីឯកសារដែលលោកបានបញ្ជាក់ពីខាងដើមនោះ តើមានប្រភេទឯកសារអ្វីទាំងឡាយណាដែលធ្វើឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានរកឃើញនៅក្នុងបរិវេណទួលស្លែងដែរឬទេ គឺឯកសារផ្សេងៗទៀតនោះ?

**ឆ៖** មាន បាទ មាន។ ដោយសារដូចខ្ញុំជម្រាបពីខាងដើមអ៊ីចឹង ខ្ញុំកម្រទៅកន្លែងដែលមានឯកសារមួយតែម្ដងណាស់ ខ្ញុំទៅច្រើនដង ទៅតាមដែលខ្ញុំអាចទៅបាន។ ខ្ញុំមិនអស់ចិត្ត ខ្ញុំគិតថានៅទួលស្លែងមនុស្សស្លាប់ជាងមួយម៉ឺននាក់ ហេតុដូចម្ដេចចម្លើយសារភាពមានជាងតែបួនពាន់ ហេតុដូចម្ដេច

រូបថតមានតែជាងប្រាំពាន់។ តើទៅណាអស់? តើមនុស្សទាំងអស់គ្នាត្រូវបាននាំយកមកថតរូប មុននឹងធ្វើទារុណកម្ម មុននឹងយកទៅសម្លាប់ ឬយ៉ាងដូចម្ដេច? ចុះឯកសារវានៅកន្លែងណា? អ៊ីចឹងខ្ញុំបានតាមស្រាវជ្រាវរក ហើយខ្ញុំបានសួរទៅប្រធានសារមន្ទីរទួលស្លែង ដែលកាលណោះ គឺលោក ជ័យ សុធារ៉ា ខ្ញុំសួរថាតើមានអគារណាមួយ បន្ទប់ណាមួយដែលលោកមិនធ្លាប់ចូលដែរឬទេ? គាត់ថា អ៊ូ! មានច្រើនណាស់ សុទ្ធតែសំរាម សុទ្ធតែឃ្លាំង។ អ៊ីចឹងខ្ញុំក៏បានស្ម័គ្រចិត្ត ថាខ្ញុំសុំទៅបោសឃ្លាំងហ្នឹង សុំទៅសម្អាតដោយផ្ទាល់ដៃ។ អ៊ីចឹងខ្ញុំបានទៅ អំបោសមួយ ខ្ញុំទិញអំបោសមួយ ហើយខ្ញុំបានហៅបុគ្គលិកខ្ញុំពីរបីនាក់តាមដែលខ្ញុំចាំ គឺអ្នកស្រី អែម សុខឃីម ក៏ធ្លាប់ទៅជាមួយគ្នាដែរ។ គឺខ្ញុំសុំទៅបោសសម្អាតបន្ទប់តែម្ដងពេលដែលខ្ញុំបើកបន្ទប់ទៅ គឺបន្ទប់នេះមិនធ្លាប់ត្រូវបានប៉ះពាល់ទាល់តែសោះតាំងពីឆ្នាំ៨០ យូរណាស់មកហើយ។

[១១:៥៣:២០]

អ៊ីចឹងខ្ញុំទៅបោសធូលីគរដូចភ្នំ ហើយខ្ញុំបានមើលថតតុ មើលក្រោម ក៏បានប្រទះឃើញឯកសារផ្សេងៗ។ ឆ្លងតាមការបោសសម្អាតបន្ទប់មួយចំនួននេះ ខ្ញុំបានរកឃើញកំណត់ហេតុរបស់កម្មាភិបាលរហូតដល់ជាងបួនរយៗ ជាកំណត់ហេតុរបស់កម្មាភិបាល ដែលប្រហែលជាកំណត់ហេតុរបស់កម្មាភិបាលដែលត្រូវបានចាប់ខ្លួនយកមកមន្ទីរស-២១ ហើយត្រូវបានបន្សល់ទុកនៅពេលដែលខ្លួនត្រូវបានយកទៅសម្លាប់ ហើយនៅមានឯកសារផ្សេងៗទៀតដែលខ្ញុំបានរកឃើញដែរ។ ខ្ញុំបានរកឃើញសៀវភៅរូបថតមួយៗដែលនៅក្នុងនោះមានរូបថតអាពាហ៍ពិពាហ៍របស់អតីតមេគុកព្រៃស ដែលខ្ញុំបានយកមកប្រើប្រាស់នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺជារូបថតដែលខ្ញុំរកឃើញនៅបន្ទប់ដែលមិនត្រូវបានគេចុះទៅបោសសម្អាត អ៊ីចឹងខ្ញុំទៅច្រើនដង ខ្ញុំទៅច្រើនដង ហើយកាលណាដែលខ្ញុំទៅ ខ្ញុំច្រើនតែសម្លឹងទៅលើបន្ទប់ដែលគេបោះបង់ចោល ឬក៏អគារដែលគេមិនត្រូវបានចាប់អារម្មណ៍។

[១១:៥៤:២១]

អ៊ីចឹងទួលស្លែងនេះ ខ្ញុំបានទៅបោសសម្អាតជាច្រើនបន្ទប់ ហើយបានរកឃើញឯកសារផ្សេងទៀត។ នៅពេលដែលយើងរកឃើញឯកសារផ្សេងទៀតនេះ គឺយើងបានឲ្យទៅទួលស្លែង ធ្វើបញ្ជីមួយដើម្បីសម្រាប់ប្រើប្រាស់ទាំងអស់គ្នា។ អ៊ីចឹងហើយ បានជាលោកឃើញថានៅក្នុងឯកសារមួយចំនួនមានអក្សរ ធី.អេស.អិល (TSL) ឬក៏ ធី.អិល (TL) គឺជាប្រភេទឯកសារដែលរកក្រោយពេលដែលសាកលវិទ្យាល័យខុនណែល បានបញ្ចប់ការធ្វើម៉ៃក្រូហ្វីម ឯកសារចម្លើយសារភាពនៅក្នុងឆ្នាំ៩២។

អ៊ីចឹងមានន័យថានៅក្រោយឆ្នាំ៩២ មានឯកសារផ្សេងទៀតដែលត្រូវបានរកឃើញ ហើយខ្ញុំបានរកឃើញថា មានមនុស្សមួយចំនួនបានខ្ចីឯកសារ ហើយមិនបានត្រឡប់មកវិញក៏មានដែរ។ ពីព្រោះនៅទួលស្លែងមានបញ្ជីមួយបញ្ជាក់អំពីថាអ្នកណាខ្លះបានខ្ចី។ ហើយនៅពេលដែលយើងបានតាមទៅសួរអ្នកទាំងអស់នោះ គេថាបានប្រគល់មកវិញហើយ ប៉ុន្តែតាមពិតពេលដែលយើងទៅរក គឺអត់ឃើញទេ។

[១១:៥៥:០៩]

អ៊ីចឹង មានឯកសារមួយចំនួនត្រូវបានបាត់បង់ ឬក៏យកទៅកាន់គេហដ្ឋាន ខ្ញុំបានរកឃើញផែនទី-- គំនូរប្លង់សាងសងជើងឯក នៅក្នុងផ្ទះរបស់លោក អ៊ុំង ប៊ុច ទៅវិញ មិនមែននៅក្នុងសារមន្ទីរទួលស្លែងទេ គឺនៅហ្នឹងផ្ទះតែម្តង។ ហើយក្រោយមក កូនរបស់គាត់ក៏បានប្រគល់វាយកមកឲ្យខ្ញុំ។ អ៊ីចឹង វានៅអាពាត់អាវាយ សភាពការណ៍ពេលនោះ ក៏វាមិនអំណោយផល ហើយមួយទៀត ប្រជាជនមិនហាក់ដូចជាមិនយល់អំពីតម្លៃនៃឯកសារ។ អ៊ីចឹងហើយឯកសារវានៅច្រើនកន្លែងណាស់ អ៊ីចឹងពាក្យថា ទួលស្លែង សូមលោកកុំសំដៅតែទៅលើចម្លើយភាព វាមានផ្សេងៗទៀត ហើយកន្លែងមួយៗដែលខ្ញុំទៅ ខ្ញុំទៅលើសពីមួយដង ដោយខ្ញុំគិតថា ប្រហែលជាមាននៅកន្លែងផ្សេងទៀត ដោយសារថាអ្នកដែលធ្វើការនៅកន្លែងនោះក្តី ឬក៏យើងទាំងអស់គ្នាក្តីមិនចាប់អារម្មណ៍ ឬគិតថា មិនសំខាន់ ឬក៏ថាគ្រប់គ្រាន់ហើយ។ អ៊ីចឹង ដើម្បីស្វែងរកការពិត យើងត្រូវធ្វើឲ្យអស់ទៅតាមលទ្ធភាពដែលយើងអាចធ្វើបាន។

[១១:៥៦:១៣]

**ស៖** បាទ អរគុណ។ ហើយចំពោះឯកសារដែលរក្សាទុកនៅសារមន្ទីរទួលស្លែងនោះ តាមដែលលោកដឹងច្បាស់នោះ ដែលលោកបានពិភាក្សាជាមួយបុគ្គលិកនោះ ថាតើលោកពិនិត្យឃើញទៅ ថាជាឯកសារច្បាប់ដើមចេញមកពីសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ដូចខ្ញុំជម្រាបលោកអ៊ីចឹង ថាឯកសារនេះ ខ្ញុំមិនមែនជាមនុស្សទីមួយដែលបានឃើញ។ ឯកសារនេះ ត្រូវបានប៉ះ ឬក៏ត្រូវមើល គឺសិក្សាដោយមនុស្សជាច្រើនតាំងពីឆ្នាំ៧៩មកម្ល៉េះ ហើយខ្ញុំបានឲ្យឈ្មោះលោករួចមកហើយ ដូចជាប្រវត្តិវិទូ ប៉ែន យៀវនិន, ដេវីដ ឆេនដ័ល័រ, ស្ទីវ ហេដឌ័រ ហ្វូលីយ៉ូ ហៀលជ្រេស, ភីតធ័រ ម៉ាខ្វៃអ៊ែរ, លោក អ៊ុំង ប៊ុច អ្នកផ្សេងៗជាច្រើនទៀត។ ហើយក្រោយមកទៀត គឺសាកសវិទ្យាល័យខុនណេល ដែលជាស្ថាប័ន សាកលវិទ្យាល័យលំដាប់អន្តរជាតិមួយបានធ្វើការថតចម្លង ដោយមានការអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជានៅក្នុងពេលនោះ។ អ៊ីចឹង សាលាមួយ

ដូចជាសាលាខុនណេលនេះ មិនមែនចេះធ្វើមកម៉ែក្រូហ្វីមឯកសារដែលមិនពិតនោះទេ។ អ៊ីចឹង វាមានហេតុផលច្រើនដែលធ្វើឲ្យខ្ញុំជឿថា ឯកសារទាំងអស់នេះ គឺជាឯកសារពិត ជាឯកសារដើម ហើយជាពិសេសទៀត នៅក្នុងឆ្នាំប្រហែលជា២០០៣ ឬ២០០៤ ខ្ញុំបានជួយធ្វើការសិក្សាស្រាវជ្រាវឲ្យលោក ឫទ្ធី ប៉ាន់ ផលិតខ្សែភាពយន្តដែលមានចំណងជើងថា "ឌី យៀលលីង ម៉ាស៊ីន" គឺខ្ញុំបានយកឯកសារទាំងអស់នោះ តាមរកមនុស្សនៅក្នុងឯកសារ ដើម្បីឲ្យគាត់មកថតជាខ្សែភាពយន្ត។ ហើយមានមនុស្សមួយចំនួនទៀត បានប្រាប់តៗគ្នា ថាអ្នកណាជាអ្នកណា។ អ៊ីចឹង យើងមានទាំងឯកសារ យើងមានទាំងអ្នកធ្លាប់មើលពីមុនមក យើងមានមនុស្សរស់ ហើយដែលបានសរសេរនៅលើឯកសារ ឬចុះហត្ថលេខនៅឯកសារ ហើយយើងមានរហូតដល់ប្រធានគុកទួលស្លែង ឌុច ដែលរស់នៅសព្វថ្ងៃនេះ ដែលអាចបញ្ជាក់ថា ឯកសារនេះពិត ឬក៏មិនពិត។ អ៊ីចឹង ចំពោះខ្ញុំ ហេតុផលទាំងអស់នេះ ធ្វើឲ្យខ្ញុំជឿជាក់ថាប្រវត្តិឯកសារចម្លើយសារភាពទាំងអស់ គឺជាឯកសារដើម គឺជាឯកសារពិត របស់កម្ពុជាប្រជាធិបតេយ្យមែន។

[១១:៥៨:២៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកសាក្សី ហើយឥឡូវនេះ ខ្ញុំមើលម៉ោងទៅ លោកប្រធាន ដូចជាម៉ោងជិតដប់ពីរហើយ តើសមល្មមនឹងតុលាការលើកដើម្បីពិសាអាហារថ្ងៃត្រង់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញាអន្តរជាតិ។ អរគុណសាក្សី ឥឡូវហ្នឹង ដល់ពេលសមល្មមនឹងឈប់សម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ សូមសាធារណជន និងភាគីជ្រាប ហើយមន្ត្រីរដ្ឋបាលតុលាការ សូមសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សី ឆាំង យុ នៅក្នុងរយៈពេលសម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់ទីកន្លែងផ្តល់សក្ខីកម្មនេះ នៅរសៀលនេះ ឲ្យអង្គជំនុំជម្រះចូលមកកាន់អាសនៈក្នុងរយៈពេលម៉ោងមួយ និងសាមសិបនាទី។

បាទ សូមអញ្ជើញលោកមេធាវីអន្តរជាតិ ការពារក្តី នួន ជា!

[១១:៥៩:៤១]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន សូមឲ្យកូនក្ដីរបស់ខ្ញុំ គឺចង់តាមដានសវនាការបន្ទាប់ទៅទៀតនេះ ពីបន្ទប់ខាងក្រោមបាទ ហើយខ្ញុំនឹងជូនលិខិតបោះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នេះ តាមរយៈក្រឡាបញ្ជី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី បានស្ដាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅសវនាការរសៀលនេះ ដោយលះបង់សិទ្ធិក្នុងការមិនចូលរួមតាមដានកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ហើយអង្គជំនុំជម្រះយល់ព្រមតាមសំណើសុំ។ ហើយយអង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្ដីផ្ដល់នូវលិខិតផ្ទេរសិទ្ធិ លិខិតលះបង់សិទ្ធិប្រគល់ជូនមកអង្គជំនុំជម្រះដោយមានចុះហត្ថលេខរបស់ជនជាប់ចោទជាក់ច្បាស់ ហើយនិងបង្គាប់ឲ្យមន្ត្រីសោតទស្សន៍ភ្ជាប់នូវប្រព័ន្ធសោតទស្សន៍សំឡេងរូបភាពសម្រាប់ជនជាប់ចោទរូបនេះ តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅបន្ទប់ខាងក្រោយបន្ទប់សវនាការសម្រាប់ដំណើរការសវនាការនៅរសៀលនេះ។

[១២:០១:០៥]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប ទៅកាន់បន្ទប់សម្រាកនៅខាងក្រោម ហើយរសៀលនេះ បង្គាប់ឲ្យនាំលោក-- នាំខ្លួនលោក ខៀវ សំផន ឡើងមកកាន់សាលសវនាការនៅរសៀលនេះ ឲ្យមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣១:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោល ក្នុងការស្ដាប់សក្ខីកម្មសាក្សីលោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយជាបន្តគឺពេលវេលាដែលត្រូវបន្ត

គឺខាងសហព្រះរាជអាជ្ញា ហើយអង្គជំនុំជម្រះសូមជម្រាបថា សហព្រះរាជអាជ្ញាមានពេលវេលាចាប់ផ្តើមពីឥឡូវនេះទៅរហូតដល់ពេលសម្រាក នឹងអស់ពេលវេលាត្រឹមអង្គជំនុំជម្រះប្រកាសសម្រាក។

សូមអញ្ជើញ!

[១៣:៣២:៤៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

លោក ឆាំង យុ បន្តទៅការពិភាក្សារបស់យើងកាលពីព្រឹកមិញ អ្វីដែលយើងចង់ចោទសួរនៅពេលនេះ គឺចង់សួរអំពីបណ្តាញនៃឯកសារ និងសូមបង្ហាញដាក់ជូនលោកផងដែរ។ ហើយសូមឲ្យលោកជួយធ្វើការបកស្រាយទៅលើសណ្ឋាននៃឯកសារ និងកំណត់សម្គាល់ ឬសញ្ញាផ្សេងៗដែលមាននៅលើឯកសារទាំងអស់នោះ?

លោកប្រធាន ប្រសិនបើអនុញ្ញាតគឺខ្ញុំសូមឲ្យភ្ជាប់ *អេ.វី ប៊ូត* ភ្ជាប់កុំព្យូទ័ររបស់យើង ដើម្បីបង្ហាញនូវសំណុំ និងបណ្តាញឯកសារ ហើយប្រសិនបើអាចនោះ គឺខ្ញុំនឹងហៅលេខ និងឯកសារនីមួយៗនៅពេលដែលយើងដំណើរការបង្ហាញឯកសារ សូមអរគុណ។

[១៣:៣៣:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ យើងកំពុងតែព្យាយាមបើកចូលទៅលើ ទៅក្នុងឯកសារ។ មុនពេលដែលយើងចាប់ផ្តើម យើងចាំឲ្យបើកបង្ហាញឯកសារជាមុនសិន។ ដូច្នេះនៅពេលនេះ ខ្ញុំសូមសួរលោកឆាំង យុ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** តើលោកអាចជម្រាបជូនអង្គសវនាការបានដែរឬទេថា តើ ឌី.ស៊ី.ខេម មានបានជួយជ្រោមជ្រែងមន្ត្រីតុលាការ ដើម្បីឲ្យគាត់ហ្នឹងអាចធ្វើការពិនិត្យមើលឯកសារនៅក្នុងបណ្ណសារដ្ឋានរបស់លោកបានដែរឬទេ?

[១៣:៣៤:៥៥]

**ឆ៖** បាទ ជាទូទៅនៅ ចាប់តាំងពីឆ្នាំ២០០៦ គឺយើងបានជម្រាបជូនទៅអង្គតុលាការ ថាយើងនឹងបើកពេលវេលាមួយសម្រាប់ឲ្យមន្ត្រីតុលាការទាំងអស់ដើម្បីទៅសិក្សាស្រាវជ្រាវ ហើយជាពិសេសបើសិនជាគាត់ចង់ជួបខ្ញុំផ្ទាល់ ខ្ញុំនឹង ផ្តល់ពេលវេលាជូន។ នៅក្នុងថ្ងៃចន្ទ ថ្ងៃអង្គារ អីគឺយើងបានជម្រាបជូនថា ខាងសហព្រះរាជអាជ្ញាអាចអញ្ជើញទៅពេលណាក៏បានក្នុងថ្ងៃចន្ទ ថ្ងៃអង្គារ។ ថ្ងៃពុធ យើងឲ្យទៅខាងដើមបណ្តឹងរដ្ឋប្បវេណី។ ថ្ងៃព្រហស្បត្តិ៍ខាងសហព្រះរាជអាជ្ញា ហើយថ្ងៃសុក្រ គឺខាងមេធាវីការពារជនចុងចោទ។ អ៊ីចឹងជារៀងរាល់ថ្ងៃនេះ ចាប់តាំងពីឆ្នាំ២០០៦ មានក្រុមខ្លះក៏អញ្ជើញទៅក្រុមខ្លះក៏អត់ ក្រុមខ្លះក៏អញ្ជើញទៅញឹកញាប់ទៅតាមតែពេលវេលារបស់គាត់។ ហើយនៅពេលដែលទៅដល់ទីនោះ គេសួរបញ្ហាផ្សេងៗដូចជា ឧទាហរណ៍ដូចជាសួរ ជួនកាលគេទៅៗ គេពិភាក្សាក្រុមរបស់គេ ជួនកាលគេមានសំណួរផ្សេងៗទាក់ទងទៅនឹងបញ្ជីឯកសារ គេសួរមកខ្ញុំដែរ។

[១៣:៣៦:០៣]

**ស៖** ដូច្នេះបន្តទៅនឹងចម្លើយរបស់លោក គឺលោកបានបើកលទ្ធភាពទៅឲ្យភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះចូលទៅមើលឯកសារ ស្រាវជ្រាវឯកសាររួមបើកឲ្យសាធារណជនផងដែរ មែនដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** សូមអរគុណច្រើន។ នៅពេលនេះគឺខ្ញុំសូមចាប់ផ្តើមបង្ហាញជូនលោកនូវឯកសារមួយដែលមាននៅក្នុងសំណុំរឿង ហើយប្រសិននៅពេលនេះ អេ.វី នេះសូមជួយភ្ជាប់អេក្រង់របស់ខ្ញុំ។ ឯកសារនេះសម្រាប់ប្រតិចារឹក គឺឯកសារលេខ D108/28.243។ ដូច្នេះ សូមឲ្យធ្វើការបង្ហាញភ្ជាប់ជាមួយនឹងអេក្រង់របស់ខ្ញុំ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមឲ្យខាង អេ.វី បាទជួយធ្វើការបង្ហាញបញ្ចាំងអេក្រង់របស់ខ្ញុំ!

លោកប្រធាន ប្រហែលជាមានបញ្ហាបច្ចេកទេស ដូច្នេះហើយគឺខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការបង្គាប់ទៅដល់មន្ត្រីតុលាការឲ្យធ្វើការចាត់ចែង និងទាក់ទងជាមួយខាង អេ.វី។

[១៣:៣៧:៤៤]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការ! បានហើយៗ ចេញហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណច្រើន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ឆាំង យុ នៅលើអេក្រង់ វាអាចមានព្រិល មានលក្ខណៈព្រិល យើងមានឯកសារជាក្រដាស ប្រសិនបើលោកចង់បាន។ យើងមិនមានការផ្ដោតសំខាន់ទៅលើខ្លឹមសារនោះទេនៅពេលនេះ ដោយសារតែយើងចង់ពិនិត្យទៅលើប្រភេទនៃឯកសារ និងចំណារនៅលើឯកសារនេះ។ ដូច្នេះតើលោកអាចជម្រាបជូនអង្គសវនាការបានដែរឬទេ ថាតើកំណត់សម្គាល់ និងសញ្ញានៅខាងស្ដាំជ្រុងខាងស្ដាំខាងលើនោះ គឺវាចង់បានន័យថាយ៉ាងម៉េចដែរ? គឺចំណារដែលចាប់ផ្ដើមពីលេខ D29 ហ្នឹង។

**លោក ឆាំង យុ៖**

**ឆ៖** លោកមេធាវី លេខនេះ គឺជាលេខដែលបុគ្គលិករបស់ខ្ញុំបាទចុះសម្គាល់ឯកសារ គឺលេខ D29060 ហើយខាងក្រោមនេះគឺមានអក្សរ SE2007 គឺជាឯកសារមកពីប្រទេសស៊ុយអែត នៅក្នុងឆ្នាំ ២០០៧។

**ស៖** ប្រសិនបើលោកស្គាល់ឯកសារនេះ តើឯកសារនេះជាប្រភេទឯកសារអ្វីដែរ?

**ឆ៖** ឯកសារនេះ គឺមាននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ចាត់ទុកជាប្រភេទឯកសារប្រភេទទីមួយ គឺជាឯកសារក្រដាស។ ហើយដោយសារថាឯកសារនេះយកមកពីប្រទេសស៊ុយអែត គឺឯកសារដើមនៅស្រុកខ្មែរយើងគឺមានតែឯកសារនេះទេ។ អ៊ីចឹងវាចូលទៅក្នុងប្រភេទទីមួយ លំដាប់ទីមួយជាឯកសារដើម ហើយឯកសារនេះ ឯកសារដើមជាក់លាក់តែម្ដងគឺអាចរកបាននៅសាកលវិទ្យាល័យ លូនដ៍នៅប្រទេសស៊ុយអែត។

**ស៖** នៅពេលដែលយើងមើលសញ្ញាសម្គាល់នៅលើឯកសារនេះ តើលោកស្គាល់សញ្ញាសម្គាល់ខាងលើហ្នឹងដែរឬទេ? សូមបញ្ចាំងម្ដងទៀត ឲ្យលោកមើលចំណារខាងស្ដាំហ្នឹងឡើងវិញ។ ខ្ញុំសំដៅទៅលើសញ្ញាសម្គាល់នៅក្បាលទំព័រខាងលើ តើវាជាសញ្ញាសម្គាល់អ្វីដែរ?

**ឆ៖** បាទ នេះគឺជានិមិត្តសញ្ញារបស់កម្ពុជាប្រជាធិបតេយ្យ ដែលមានសរសេរអក្សរខ្មែរនៅលើហ្នឹងស្រាប់ នៅក្នុងរូបហ្នឹងមានអក្សរ ហើយខាងក្រោមក៏មានអក្សរដែរ។ សញ្ញាសម្គាល់ជានិមិត្តសញ្ញារបស់កម្ពុជាប្រជាធិបតេយ្យ។

[១៣:៤០:៤៧]

**ស៖** សូមអរគុណលោកច្រើន។ យើងខ្ញុំសូមសួរបន្តទៅលើឯកសារមួយទៀត។ ខ្ញុំសូមអនុញ្ញាតធ្វើការបង្ហាញតាមអេក្រង់។ សូមធ្វើការបង្ហាញឯកសារនេះ សូមអរគុណ។ លោក ឆាំង យុ តើលោកអាចជម្រាប ជាដំបូងនេះអាចជម្រាបអង្គសវនាការបានដែរឬទេ ខ្ញុំសូមអានលេខឯកសារគឺ D243/2.2.13 ដូច្នេះ សូមឲ្យលោក ឆាំង យុ ជម្រាបជូនអង្គសវនាការ ថាឯកសារនេះជាឯកសារអ្វីដែរ?

**ឆ៖** ឯកសារនេះ គឺជាឯកសារទង់បដិវត្ត ជាទូទៅយើងហៅថា "ទស្សនាវដ្ដីទង់បដិវត្ត" ជាលេខពិសេសចុះនៅក្នុងខែតុលា វិច្ឆិកា ឆ្នាំ១៩៧៧។ ឯកសារនេះជាឯកសារស្កេន ឬថតចម្លងពីឯកសារដើម។ ឯកសារដើម គឺទង់នេះ គឺមានពណ៌ក្រហម។

**ស៖** សូមអរគុណ។ តើលោកខ្លួនឯងបានឃើញឯកសារដើមផ្ទាល់ដែរឬទេ ទៅលើឯកសារមួយនេះ?

**ឆ៖** បាទ ខ្ញុំធ្លាប់ឃើញ។

**ស៖** តើលោកចាំដែរឬទេថា តើឯកសារនេះដើមនៅឯណាដែរ? ហើយបច្ចុប្បន្ននេះទុកនៅឯណាដែរ ឯកសារដើមហ្នឹង?

**ឆ៖** ឯកសារទង់បដិវត្តនេះមានច្រើនលេខនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក៏មាន យើងបានមកពីបុគ្គល។ ហើយលោកក៏អាចរកឯកសារនេះឃើញនៅសារមន្ទីរទួលស្លែងដែរ។

[១៣:៤៣:២២]

**ស៖** តើលោកអាចមើលឯកសារដើមដែលដាក់នៅទួលស្លែងដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ឃើញ។

**ស៖** តាមការចងចាំរបស់លោកថា តើឯកសារនេះសល់-- ឯកសារដើមហ្នឹងដល់ពីមុនមកប៉ុន្មានឆ្នាំហើយ បើសិនយើងគិតពីពេលដែលវានៅសល់តាំងពីដើមមក គង់វង្ស?

**ឆ៖** ឯកសារនេះ ខ្ញុំបានឃើញដំបូងនៅក្នុងឆ្នាំ១៩៩៥ នៅស្រុកខ្មែរយើង។ ហើយឯកសារនេះដូចខ្ញុំជម្រាបជូនលោកមេធាវីអ៊ីចឹង គឺវាមានពណ៌ៗ គឺថាខ្ញុំចាប់អារម្មណ៍ទៅលើពណ៌ដូចជាវិចិត្រករអក្សរសាស្ត្រដែរ គឺថាចាប់ឯកសារមកភ្លាម យើងចាប់មើលសម្លឹងទៅលើពណ៌។ អ៊ីចឹងគឺថាវាមានពណ៌ចំណាស់ សន្លឹកវាក៏មានលក្ខណៈចំណាស់ ហើយសូម្បីតែទំហំៗ ទស្សនាវដ្ដីនេះគឺខុសពីទំហំសៀវភៅផ្សេងៗដែលយើងបានឃើញនាពេលបច្ចុប្បន្ន។ អ៊ីចឹងវាមានលក្ខណៈពិសេសមួយ បើសិនជាលោកមើលទំហំរបស់សៀវភៅហ្នឹង គឺមានលក្ខណៈមិនដូចជាសៀវភៅដែលយើងបោះពុម្ពរាល់ថ្ងៃទេ

ហើយមួយទៀតនៅក្នុងខ្លឹមសារ ខ្ញុំបានអានអត្ថបទគឺជាខ្លឹមសារពាក្យពេចន៍ដែលប្រើប្រាស់នៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យ។

[១៣:៤៤:៥៧]

**ស៖** សូមអរគុណច្រើនចំពោះការឆ្លើយ។ លោកបានលើកឡើងថា វាជាលេខពិសេសចេញ ឆ្នាំ១៩៧៧ តើលោកបានដឹងទេថា មានទង់បដិវត្តប៉ុន្មានដែលនៅសល់ បើទម្រង់ដើមដែលនៅសល់ហ្នឹង មានសល់ ប្រហែលសល់ប៉ុន្មានច្បាប់ដែរ?

**ឆ៖** ខ្ញុំមិនបានរាប់ចំនួន ប៉ុន្តែយើងបានព្យាយាមរកគ្រប់លេខតាមដែលខ្ញុំចាំ ពីព្រោះយើងដឹង ថាមានលេខមួយចំនួនវាចន្លោះ។ អ៊ីចឹងខ្ញុំគិតថាមាន ៧៦ក៏យើងមាន ៧៧ក៏យើងមាន ៧៨ក៏យើងមាន ហើយបើយើងគិតថាក្នុងមួយឆ្នាំមាន១២ខែ អ៊ីចឹងមានអាចដល់ទៅ៣៦ ហើយអាចមានលេខខ្លះបាត់បង់ អ៊ីចឹងវាអាចថាមានចំនួនពី២០ ទៅ២៥។ អ៊ីចឹងឯកសារវាមាន បាទមានចំនួនប្រហែលប៉ុណ្ណឹង។ សូម បញ្ជាក់ដែលថាឯកសារនេះខ្លះ វាមានស្ទួន ជួនកាលវាមានលេខ៧៦ពីរដង បីដងក៏មាន ព្រោះថាវាជា ឯកសារស្ទួនដែលដូចគ្នា និងឯកសារពិសេសក៏អ៊ីចឹងដែរ។

[១៣:៤៦:០៣]

**ស៖** សូមអរគុណច្រើន។ ខ្ញុំសូមបន្តទៅលើប្រភេទឯកសារមួយទៀត ឯកសារមួយប្រភេទ ទៀត។ សូមឲ្យបញ្ចាំងឯកសារនេះតាមអេក្រង់។ សូមអភ័យទោសម្តងទៀត គឺរូបភាពវាមិនសូវច្បាស់ ទេ វានៅតែស្រពិល ឯកសារនេះមានលេខ D22/174.5 ជាបឋមសូមឲ្យលោកជម្រាបអង្គសវនាការ ថាតើលោកស្គាល់ឯកសារហ្នឹងដែរឬទេ ហើយជាប្រភេទឯកសារអ្វីដែរ?

**ឆ៖** ឯកសារនេះ គឺជាឯកសារយើងហៅថាប្រភេទ “I” គឺជាប្រភេទឯកសារប្រវត្តិរូប ដូចជា មានសរសេរនៅក្នុងស្រោប គឺនៅក្នុងប្រអប់មួយដែលមានខាងលើហ្នឹង គឺដាក់ថាប្រវត្តិរូបអ្នកទោសជាប់ ឃុំឃាំង។ ហើយនៅក្នុងឯកសារនេះគឺជាឯកសារដែលមិនមែនមកពីសារមន្ទីរទួលស្លែងទេ គឺជាឯកសារ មកពីសំណុំឯកសារសន្តិបាល។ បើសិនជាមានឯកសារទួលស្លែង យើងដាក់អក្សរ ធី.អេស.អិល តែ ឯកសារនេះគឺអក្សរ I។ ហើយសូមជម្រាបលោកដែរ លេខខាងលើនេះមិនមែនលេខរបស់មជ្ឈមណ្ឌល ឯកសារកម្ពុជាទេ ប្រហែលជាខាងតុលាការជាអ្នកសរសេរ។ លេខដែលពួកខ្ញុំសរសេរ គឺ I08375។

[១៣:៤៧:៥០]

**ស៖** សូមអរគុណច្រើន។ ខ្ញុំសូមអនុញ្ញាតចូលបង្ហាញបន្តឯកសារមួយទៀត ខណៈពេលដែល

យើងរង់ចាំ ដោយសារវាជាឯកសារចុងក្រោយហើយនោះ ខ្ញុំសូមសួរសំណួរមួយសំណួរ ប្រសិនបើខ្ញុំយល់មិនខុសនោះទេ ឯកសារដែលប្រមូលបានអំមិញហ្នឹង ឯកសារមួយអំមិញហ្នឹងគឺប្រមូលបានមកពីក្រសួងមហាផ្ទៃ តើមែនដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** គឺចំពោះការរៀបរាប់ទៅលើឯកសារអំមិញ មួយអំមិញហ្នឹង គឺនៅ ឌី.ស៊ី.ខេម មានឯកសារដើមទេ ឯកសារហ្នឹង?

**ឆ៖** មាន បាទ។

**ស៖** សូមអរគុណច្រើន។ នៅពេលនេះ ខ្ញុំសូមបង្ហាញឯកសារមួយទៀត គឺខ្ញុំសូមអនុញ្ញាតឲ្យបញ្ចាំងឯកសារនេះតាមអេក្រង់។ សូមអរគុណ។ សម្រាប់ប្រតិចារឹក ឯកសារនេះមានលេខ D366/7.1.27។ ពាក់ព័ន្ធទៅនឹងឯកសារនេះ សូមឲ្យលោក ឆាំង យុ ជួយពន្យល់តើឯកសារនេះ ជាឯកសារអ្វីដែរ ហើយជួយពន្យល់លេខសម្គាល់នៅខាងស្តាំ ខាងលើ?

**ឆ៖** បាទ លេខសម្គាល់នេះ គឺជាប្រភេទឯកសារប្រវត្តិរូប។ សូមទោស សូមបើកមកមុខវិញអំមិញលោតទៅវិញហើយ។ បាទ អរគុណ។ ឯកសារនេះ គឺជាឯកសារប្រភេទប្រវត្តិរូបលេខ I02908 គឺជាលេខដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការចុះបញ្ជី។ ខ្ញុំសូមទាញការចាប់អារម្មណ៍ដែរ។ នៅពេលដែលខាងតុលាការចុះទៅធ្វើការសំណើសុំឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺតុលាការបានបង្កើតលេខខ្លួនឯងមួយទៀតទៅលើឯកសារនេះ។ អ៊ីចឹង លេខខាងក្រោយនេះ មិនមែនជាលេខរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ខ្ញុំគិតថា ជាលេខរបស់តុលាការ ពីព្រោះនៅពេលដែលតុលាការចុះទៅស្នើសុំឯកសារគាត់បានធ្វើការស្កេនឯកសារហ្នឹង ហើយគាត់បានប្រើលេខគាត់ ដូចជា ERN ដែលតាមដែលខ្ញុំចាំ ជាលេខសម្គាល់របស់តុលាការ។ អ៊ីចឹង សូមឲ្យភាគីទាំងសងខាងយកការចិត្តទុកដាក់ គឺលេខ I ទេ ដែលយើងជាអ្នកចុះ ហើយនេះជាប្រភេទប្រវត្តិរូប ហើយអក្សរខ្មែរ គឺបានសរសេរហើយស្រេចសមមិត្ត រី ពិនិត្យប្រវត្តិរូបបដិវត្តន៍។ អ៊ីចឹង វាជាឯកសារប្រវត្តិរូប។

**ស៖** ដូច្នេះខ្ញុំ តើខ្ញុំយល់ថា I នេះ គឺជាឯកសារដែលវាប្រមូលចេញមកពីក្រសួងមហាផ្ទៃ វាដូចទៅនឹងឯកសារមុន តើមែនដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ខ្ញុំសូមបង្ហាញនូវទំព័រទីបី-- ទំព័រទីពីរ និងទីបី នៃឯកសារដដែលនេះ ដែលវាហាក់ដូចជា

មានលក្ខណៈខុសពីឯកសារមុនៗ ដូច្នេះហើយ សូមឲ្យបញ្ចាំងលើអេក្រង់នូវឯកសារអម្បាញ់មិញ។ ឯកសារដែលយើងឃើញមុនហ្នឹង គឺមានតែមួយទំព័រនោះទេ ក៏ប៉ុន្តែឯកសារនេះ វាមានច្រើនទំព័រ បើប្រហែលគឺ២០ទំព័រឯណោះ។ តើលោកស្គាល់ និងមើលស្គាល់ប្រភេទឯកសារនេះដែរឬទេ? ហើយលោកអាចជម្រាបដោយសង្ខេបដែរឬទេ តាមការយល់របស់លោក តើគេប្រើក្នុងគោលបំណងអ្វីដែរ? ហើយវាមានជាប្រភេទឯកសារអ្វី?

**ឆ៖** ឯកសារនេះ គឺជាប្រភេទឯកសារប្រវត្តិរូបរបស់កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ គឺជាគេហៅថា ឯកសារប្រវត្តិរូប ឬក៏ជីវទស្សន៍របស់សមាជិកម្នាក់ៗ ហើយឯកសារនេះ មិនមែនជាឯកសាររបស់ទោស ដូចជាឯកសារដំបូងដែលមានរូបថតមួយសន្លឹកនោះទេ។ អ៊ីចឹង ប្រវត្តិរូបមានពីរសណ្ឋាន ហើយបើសិនជាលោកជាមានការ-- ខ្ញុំមិនដឹងថា ខាងតុលាការបានទទួល ឬក៏អត់។ លោកសាស្ត្រប្រវត្តិវិទូ ប៉ែន ឃៀរនិន បានសរសេរពន្យល់អំពីប្រវត្តិរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបញ្ជាក់ ហើយយើងបានសរសេរពន្យល់អំពីប្រភេទទាំងអស់នេះ។ អ៊ីចឹង ឯកសារមួយនេះ គឺជាឯកសាររបស់កម្មាភិបាលណាម្នាក់ដែលបម្រើឲ្យរបបកម្ពុជាប្រជាធិបតេយ្យ។

[១៣:៥២:៤៥]

**ស៖** តាមការស្រាវជ្រាវរបស់លោក តើលោកមានឃើញឯកសារប្រភេទនេះទៀតដែរឬទេ ហើយប្រសិនបើលោកបានឃើញ តើលោកអាចសន្និដ្ឋានដែរឬទេ ថាតើគេប្រើឯកសារនេះ ដើម្បីគោលបំណងអ្វីដែរ? សូមឲ្យលោកនិយាយដោយសង្ខេប។

**ឆ៖** មានប្រភេទប្រវត្តិរូបផ្សេងៗទៀត ដូចខ្ញុំបានជម្រាបអ៊ីចឹង ឧទាហរណ៍ដូចប្រវត្តិរូបរបស់លោក សួង ស៊ីគឿន ហៅសមមិត្ត គង់ គឺជាប្រវត្តិរូបដែលសរសេរ ដោយខ្លួនឯងតែម្តង។ និយាយអំពីប្រវត្តិរបស់ខ្លួន និយាយអំពីសកម្មភាពដែលខ្លួនបានចូលបដិវត្តន៍ និងផ្សេងៗទៀត។ ហើយឯកសារនេះ វាហាក់ជាដូចទម្រង់បំពេញ គេហៅបំពេញជីវទស្សន៍ ប្រាំមួយខែម្តង ឬក៏មួយឆ្នាំម្តង ហើយប្រវត្តិរូបមួយទៀតគឺសម្រាប់អ្នកទោស។ មានច្រើនសណ្ឋាន ប៉ុន្តែមិនជាការពិបាកស្វែងយល់ទេ ដោយសារថាវាមានជាលាយលក្ខណ៍អក្សរនៅក្នុងនោះតែម្តង យើងអាចមើល ហើយយើងអាចយល់បាន។

[១៣:៥៣:៤៨]

**ស៖** សូមអរគុណច្រើន។ ខ្ញុំសូមសួរប្រភេទឯកសារមួយប្រភេទទៀត ប្រសិនបើយើងអាចបង្ហាញឯកសារបន្ទាប់នេះ ឯកសារនេះ គឺលេខ D366/7.1.789 សូមឲ្យបង្ហាញឯកសារនេះ នៅលើ

អេក្រង់។ តើលោក-- ជាបឋម លោក ឆាំង យុ លោកអាចជម្រាបដោយរៀបរាប់ តើប្រភេទឯកសារនេះ ជាប្រភេទឯកសារអ្វីដែរ?

**ឆ៖** ឯកសារនេះ គឺជាប្រភេទឯកសារក្រសួងពាណិជ្ជកម្ម ពីព្រោះនៅខាងឆ្វេងសរសេរជាក្រសួងពាណិជ្ជកម្ម លេខ 015977 ហើយលេខខាងស្តាំគឺជាលេខដែលបុគ្គលិករបស់ខ្ញុំបាទ បានធ្វើការចុះបញ្ជីគឺអក្សរ D20638។ នៅខាងក្រោមលេខនេះ គឺយើងបានដាក់នៅក្នុងរង់ក្រចកមួយ គឺយើងប្រើអក្សរ "អេ.អ៊ិន.ស៊ី" (ANC) បញ្ជាក់អំពី *"ណាស្យូណាល អាកខាយ អូហ្វ ខេមបូឌា"* នៅក្នុងជួរទី៤៥ ប្រអប់លេខ០៩។ អ៊ីចឹងបើសិនលោកត្រូវការឯកសារដើម ចំពោះឯកសារមួយនេះ លោកអាចអញ្ជើញទៅបណ្ណសារដ្ឋានជាតិ ហើយប្រាប់លេខ៤៥ ប្រអប់០៩ យើងនឹងអាចរកឃើញឯកសារដើម។

**ស៖** ខ្ញុំដឹងថា ឯកសារនេះជាឯកសារខ្មែរនៅលើអេក្រង់នេះ តើលោកប្រកាន់ទេប្រសិនជាខ្ញុំឲ្យអានជាភាសាខ្មែរនេះ សូមឲ្យលោកអានតែប្រហែលជាជួរទីពីរ តែពីរជួរហ្នឹងបានហើយ។ ជួរទីមួយទីពីរខាងលើហ្នឹង ដើម្បីឲ្យយើងបានស្តាប់។

**ឆ៖** ជូនចំពោះបងហែម ជាទីគោរពស្នេហា។ សូមរាយការណ៍ស្តីពីការជួបមិត្តចិន ពីម៉ោងប្រាំបួន ដល់ម៉ោងដប់ ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧៧ នៅស្ថានទូតចិន។ ខាងកម្ពុជាមានសមមិត្តហុង និងសមមិត្តវ៉ាន់ ខាងមិត្តចិនមានសមមិត្តម៉ា សមមិត្តចៃ និងសមមិត្តហុង នៅក្នុងមូសិកទន្ត គឺបង្ហាញថាសមមិត្តហុង នេះជានារីភេទ។

[១៣:៥៦:៣៤]

**ស៖** សូមអរគុណច្រើន។ ដូច្នេះខ្ញុំសូមសួរត្រឡប់ទៅចម្លើយរបស់លោក ដែលលោកនិយាយអំពីឯកសារចេញមកពីបណ្ណសារដ្ឋានជាតិថា តើឯកសារមួយនេះគឺជាប្រភេទឯកសារដែលលោកលើកឡើងថា បានទៅថតចម្លងពីបណ្ណសារដ្ឋានជាតិនោះ មែនដែរឬទេ?

**ឆ៖** បាទជាការត្រឹមត្រូវ។

**ស៖** សូមអរគុណច្រើន។ ខ្ញុំចង់បង្ហាញលោកនូវឯកសារមួយទៀត ឯកសារនេះគឺលេខ "D" គឺឯកសារ D366/7.1.159 ខ្ញុំសូមឲ្យបង្ហាញឯកសារនេះតាមអេក្រង់។ ប្រសិនបើលោកអាច នៅពេលនេះខ្ញុំសួរអំពីសញ្ញាលេខសម្គាល់សិន នៅជ្រុងខាងលើ ខាងស្តាំ យើងឃើញមានលេខដែលចាប់ផ្តើមដោយ"D" បន្ទាប់មកនិង TSL តើលោកអាចពន្យល់ទេ លេខដែលមានអក្សរ ហើយបន្ទាប់មកមានលេខនោះ?

**ឆ៖** បាទ ឯកសារនេះគឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះលេខដោយខ្លួនឯងគឺលេខ D18678 ខាងក្រោមគឺជាលេខសម្គាល់ថា ឯកសារនេះមកពីសារមន្ទីរទួលស្លែង គឺអក្សរ TSL លេខ៤ លេខ៨ និងលេខ៣៨។

[១៣:៥៨:២៥]

**សៈ** ជាថ្មីម្តងទៀត ចំពោះអ្នកដែលគាត់មិនចេះអានជាភាសាខ្មែរ យើងសូមបង្ហាញឯកសារនេះលើអេក្រង់សាថ្មី សូមឲ្យលោកអានពីខាងលើរហូតមកដល់ចំណុចលេខមួយ។

**ឆ៖** គណៈក្រសួងពាណិជ្ជកម្ម ក្រោយពីការសាកសួរមតិយោបល់គ្រប់ផ្នែកសម្រេច បញ្ជូនទៅមន្ទីរអប់រំរបស់សន្តិសុខដូចមានរាយឈ្មោះខាងក្រោមនេះគឺ ១) ផ្នែកផ្គត់ផ្គង់ឈ្មោះ ហៃ ជាប់ជិតស្និទ្ធ អាសាត, ដេត, កូនបន្ទុក--

**សៈ** សូមអរគុណលោកច្រើន។ តើវាត្រឹមត្រូវដែរឬទេ នេះគឺជាឯកសារចេញមកពីក្រសួងពាណិជ្ជកម្ម?

**ឆ៖** ឯកសារនេះនៅខាងឆ្វេងមានសរសេរថា ក្រសួងពាណិជ្ជកម្ម។ ប៉ុន្តែហាក់ដូចជាឯកសារនេះត្រូវធ្លាក់រកឃើញនៅទួលស្លែងទៅវិញ។ អ៊ីចឹងខ្ញុំមិនដឹងថា វាទៅដល់ទីនោះដោយរបៀបណា ប៉ុន្តែគឺជាលេខ និងជាប្រភេទឯកសារចេញពីក្រសួងពាណិជ្ជកម្ម។

**សៈ** តើលោកអាចនឹកឃើញ ឧទាហរណ៍ផ្សេងទៀតដែលថាឯកសារនៅក្នុងសំណុំឯកសារមួយវាអាចចេញ ហើយវាទៅដល់កន្លែងរក្សាឯកសារនៅកន្លែងផ្សេង?

**ឆ៖** លោកចង់និយាយថា ពីមន្ទីរមួយឯកសារទៅដល់កន្លែងមួយទៀត ចេញពីកន្លែងមួយទៅកន្លែងមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**សៈ** បាទ ពិតជាត្រឹមត្រូវ។ ដើម្បីខ្ញុំសួរឲ្យជាក់លាក់នោះ ឯកសារនេះវាហាក់ដូចជាចេញមកពីក្រសួងពាណិជ្ជកម្ម ក៏ប៉ុន្តែលេខកូដនោះ គឺបានបញ្ជាក់ថារកឃើញនៅទួលស្លែង ករណីនេះគឺវាចម្លែកដែរឬទេ ហើយវាមានករណីដូចគ្នាអ៊ីចឹងកើតឡើងចំពោះឯកសារផ្សេងទៀតដែរឬទេ?

[១៤:០០:៥៨]

**ឆ៖** មិនចម្លែកទេ ពីព្រោះមានឯកសារផ្សេងទៀតមកពីឃុំ មកពីស្រុក ក៏មានរកឃើញនៅទួលស្លែងដែរ ហើយមានជារូបថតដែលថតនៅកន្លែងផ្សេងក៏ធ្លាក់មកដល់ទួលស្លែងដែរ។ ហើយនិងមានឯកសារផ្សេងៗទៀត ដែលយើងបានរកឃើញគឺមកពីកន្លែងផ្សេង។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំចូលទៅដល់ឯកសារមួយទៀត។ ជាថ្មីម្តងទៀត ខ្ញុំនឹងបង្ហាញជាភាសាខ្មែរទេ ឯកសារនេះសម្រាប់ប្រតិចារឹកគឺ ឯកសារ D43/IV ហើយនិងមានអក្សរខាងក្រោមទៀត អេ.អ៊ិន (AN)។ សូមអនុញ្ញាតបង្ហាញលើអេក្រង់។ ប្រហែលជាសូមឲ្យលោកអញ្ជើញអានសម្រាប់ភាគីដែលមិនចេះភាសាខ្មែរ សូមលោកអានអត្ថបទនៅក្នុងដែលសរសេរជាអក្សរពណ៌ខ្មៅ។

**ឆ៖** "សូមគោរពគណៈ ៨៧០ ជាទីស្នេហា ខ្ញុំសូមជូនឯកសារចម្លើយរបស់ឈ្មោះ៖ ១. សាន់ អ៊ាត ហៅ ខុន ពាណិជ្ជកម្ម១០៣ ប្រចាំនៅភ្នំពេញ, ២. ស៊យ ហៅ ផង សន្តិសុខ១០៣ ដើម្បីគណៈពិនិត្យ ហើយនិងជាឯកសារស្រាវជ្រាវខ្សែក្បត់បង្កប់ស៊ីរូងផ្ទៃក្នុង។ ជូនពរគណៈសុខភាពបរិបូណ៍។ ថ្ងៃទី១៧ ខែបួន ឆ្នាំ៧៨ ភភ ៨០១ ហត្ថលេខា សែ"។

[១៤:០៣:១១]

**ស៖** តើលោកអាចអានបន្ទាត់ដែលចុះហត្ថលេខា ថាតើអ្នកណាជាអ្នកសរសេរឯកសារនេះទេ?

**ឆ៖** ឈ្មោះ សែ បាទ។

**ស៖** តើលោកអាចជម្រាបតុលាការបានទេ ថាតើនរណាជា-- សែ នោះជាបុគ្គលណាដែរ? បាទ អ៊ីចឹងសូមអនុញ្ញាតបង្ហាញលើអេក្រង់ម្តងទៀត។

**ឆ៖** នៅក្នុងឯកសារនេះមានឈ្មោះ សែ ប៉ុន្តែខ្ញុំមិនដឹងថា សែ ជាអ្នកណាទេ។

**ស៖** ពិនិត្យមើលឯកសារនេះ យើងហាក់ដូចជានឹងមានរូបថតមួយនៅលើឯកសារនោះ។ តើលោកយល់ស្របអ៊ីចឹងទេ ថាអាចនឹងមានជាថត ជារូបថតពណ៌ពីឯកសារដើមពី ឯកសារនេះបាទ?

**ឆ៖** បាទ ឯកសារនេះ គឺថត១ ឬក៏ស្កេនចេញពីឯកសារដើម ដោយសារខ្ញុំធ្លាប់កាន់ឯកសារនេះផ្ទាល់ដៃ។ ឯកសារនេះមានលក្ខណៈតូចប្រហែលប៉ុណ្ណេះបាទ ប្រហែលជាទំហំប៉ុណ្ណេះ ហើយឯកសារនេះ គឺស្កេនចេញពីឯកសារដើមដែលមានពណ៌ ដូចដែលយើងឃើញអ៊ីចឹងទ្រង់ក្រហម ហើយសម្បុររបស់ក្រដាសក៏អ៊ីចឹងដែរ។

[១៤:០៤:៤៧]

**ស៖** ដូច្នេះឯកសារនេះ គឺជាច្បាប់ដើមដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលបាន តើមែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** សូមអរគុណ និងបន្តទៅមុខទៀតអំពីប្រភេទឯកសារនោះដែរ។ បាទ ដើម្បីប្រតិចារឹក

ឯកសារហ្នឹង D108/28231។ សូមអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់ នេះជាឯកសារមួយ ជាភាសាអង់គ្លេសតែប៉ុណ្ណឹងទេ។ ប្រហែលជាខ្ញុំត្រូវការជំនួយ។

សូមអនុញ្ញាតពេលបន្តិច ខ្ញុំចង់បង្ហាញផ្នែកខាងលើនៃឯកសារ។ តាមពិត ខ្ញុំមើលបង្ហាញទំព័រទីពីរនៃឯកសារ។ សូមអរគុណ យើងអាចដាក់ឲ្យចំកណ្ដាល ហើយចំពោះភាគីដែលមិនចេះនិយាយភាសាអង់គ្លេស។ សូមលោកមេត្តាអាននូវចំណងជើងខាងលើ ហើយនិងកថាខណ្ឌទីមួយតែប៉ុណ្ណោះ។

**ធ៖** តាមពិតខ្ញុំចង់អានជាភាសាខ្មែរជាងភាសាអង់គ្លេស។ ប៉ុន្តែខ្ញុំសូមអានឯកសារនេះមួយទៅចុះ ព្រោះជាភាសាកំណើតរបស់ខ្ញុំ ហើយម្ដាយខ្ញុំក៏ជាខ្មែរ ហើយគាត់ក៏កំពុងប្រហែលជាមើលទូរទស្សន៍ដែរ។ អ៊ីចឹងខ្ញុំមិនចង់និយាយភាសាអង់គ្លេសទៅម្ដាយខ្ញុំទេ។ អ៊ីចឹងខ្ញុំសូមអានតែឯកសារមួយនេះ ហើយលើកក្រោយសូមមេត្តាឲ្យខ្ញុំអានជាភាសាខ្មែរ។ នៅក្នុងនេះដាក់ថា(អានជាភាសាអង់គ្លេស)៖ “ចម្លើយសារភាពរបស់គិញវៀតណាម”។

**ស៖** ខ្ញុំគិតថាផ្នែកខាងក្រោយនោះ មិនត្រូវបានបកប្រែទេ សូមអនុញ្ញាតលោកអាន និយាយឡើងវិញបន្តិច។

**ធ៖** (អានជាភាសាអង់គ្លេស)៖ “ចម្លើយសារភាពរបស់គិញវៀតណាម”។

[១៤:០៧:៣៤]

**ស៖** អ៊ីចឹងយើងត្រឡប់ទៅទំព័រទីមួយនៃឯកសារនេះ។ ឥឡូវនេះសូមខាងប្រព័ន្ធសោតទស្សន៍បង្ហាញឯកសារនេះម្ដងទៀត។ សូមលោកពន្យល់តុលាការដោយសង្ខេប ថាតើកំណត់លេខយោងទាំងអស់នោះ មានន័យដូចម្ដេច? គ្រាន់តែដើម្បីឲ្យតុលាការជ្រាបច្បាស់បាទ។

**ធ៖** លេខ D3269 គឺជាលេខដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការចុះបញ្ជីឯកសារនេះ ហើយខាងក្រោមនេះ គឺមានអក្សរ SE2007 បញ្ជាក់អំពីឯកសារនេះមកពីប្រទេសស៊ុយអែតនៅក្នុងឆ្នាំ២០០៧។

**ស៖** ដោយហេតុថា ឯកសារនោះគឺមិនមានចំណងជើងដែលចង្អុលបង្ហាញថា អ្នកណាជាអ្នកធ្វើវាទេ។ តើលោកអាចប្រាប់តុលាការបានទេ ថាតើមានឯកសារអ្វីផ្សេងទៀត ដែលថានៅខាងលើទំព័រទីមួយនោះ? ថាតើលោកអាចជួយឲ្យតុលាការយល់បានច្បាស់ទេ ខាងផ្នែកខាងលើនោះ មានអក្សរមួយចំនួនថា តើមានអត្ថន័យដូចម្ដេចដែរ?

[១៤:០៨:៥១]

**ឆ៖** លោកចង់ឲ្យខ្ញុំអានអក្សរដែលមានលេខបី នៅក្បែរហ្នឹងឬក៏យ៉ាងម៉េច?

**ស៖** ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនោះនៅលើអេក្រង់ម្តងទៀត។ គ្រាន់តែឯក-- នៅខាងឆ្វេងដៃខាងលើគេមានអក្សរបី មាន អេស.ឌីប៊ែលយូ.ប៊ី (SWB) តើលោកយល់ថា តើលោកដឹងថា អក្សរបីហ្នឹងគឺជាពាក្យកាត់មកពីអ្វីដែរឬទេ?

**ឆ៖** ខ្ញុំបាទ អត់ដឹងទេបាទ។

**ស៖** បាទអរគុណ។ ឥឡូវនេះយើងនឹងបន្តទៅប្រភេទឯកសារមួយចំនួនទៀត។ ឯកសារទីមួយនោះគឺ ឯកសារ D366/7.1.516។ សូមអនុញ្ញាតដាក់បង្ហាញឯកសារនេះនៅលើអេក្រង់។

សូមអរគុណ។ បាទ សូមដាក់ឲ្យចំកណ្តាល ដើម្បីឲ្យបានឃើញទាំងអស់។ បាទ ដូចជាមិនសូវច្បាស់ទេ លោក ឆាំង យុ ក៏ប៉ុន្តែប្រហែលជាខ្ញុំអនុញ្ញាតឲ្យលោកពន្យល់ដល់តុលាការដូចដែល ដូចលោកបញ្ជាក់ខាងដើមដែរ ដូចជាឯកសារ “D” នៅខាងដើម គឺជាលេខកូដរបស់ ឌី.ស៊ី.ខេម។ តើមួយបន្ទាត់នៅខាងក្រោមនោះ តើលោកអាចអានបានទេ ដើម្បីឲ្យតុលាការបានជ្រាបនិងកត់ត្រាបាន?

[១៤:១១:០៥]

**ឆ៖** ខាងក្រោមគឺ ១៥ បបក គឺជាប្រភពឯកសារដើម ហើយឯកសារនេះបានមកពីក្រសួងមហាផ្ទៃ ហើយបើសិនជាលោកចង់បានឯកសារដើម យើងអាចយកឯកសារមួយនេះចូលទៅក្នុងទូដែក ហើយបើកមើលសំណុំរឿងលេខ ១៥ បបក លោកនឹងឃើញឯកសារមួយនៅទំព័រលេខ៩៩។

**ស៖** តទៅទៀត ឯកសារហ្នឹងបានមកពីក្រសួងមហាផ្ទៃ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានឯកសារដើមនៅនឹងខ្លួនដែរ តើមែនឬទេ?

**ឆ៖** បាទ យើងមានឯកសារដើមនៅនឹងខ្លួន។

**ស៖** ហើយសូមអនុញ្ញាតបង្ហាញឯកសារនេះម្តងទៀត ដើម្បីជាប្រយោជន៍ទៅដល់អ្នកមិនចេះភាសាខ្មែរនោះ។ សូមអនុញ្ញាតលោកអានទូវខ្លឹមសារប្រយោគពីរខាងដើម ហើយនិងផ្នែកកន្លែងដែលគេចុះហត្ថលេខានៃឯកសារនេះផងដែរ។

**ឆ៖** “ជម្រាបសូមជ្រាប ខាងភូមិភាគបូព៌ាបានផ្ញើសេចក្តីរាយការណ៍លើសកម្មភាពខ្មាំងនៅមុខកំពូលមួយច្បាប់មកជូនមន្ទីរ ដោយសូមឲ្យមន្ទីរផ្ញើជូនទៅខាងបង។ សូមបងតាមដានសភាពការណ៍នេះ ហើយមានវិធានការតាមសភាពការណ៍ជាក់ស្តែង ដោយទាក់ទងជាមួយខាងមុខកំពូលផង។ ដោយភាតរ:បដិវត្តន៍យ៉ាងកក់ក្តៅបំផុត ថ្ងៃទី២០ ខែ០៣ ឆ្នាំ១៩៧៨ ម-៨៧០”។

[១៤:១២:៥៧]

**ស៖** ផ្អែកតាមបទពិសោធន៍ ហើយនិងការសិក្សាស្រាវជ្រាវរបស់លោកថា តើលោកអាចកំណត់អត្តសញ្ញាណបានទេ ថា ម-៨៧០ ហ្នឹងតំណាងឱ្យអ្នកណា?

**ឆ៖** ដូចខ្ញុំជម្រាបលោកអ៊ីចឹង ខ្ញុំមិនមែនជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ហើយការដែលខ្ញុំយល់ដឹង ក៏ខ្ញុំយល់ដឹងតាមការអានសៀវភៅ ម-៨៧០ នេះគឺជាមន្ទីរ៨៧០។ ហើយជាទូទៅអ្នកសិក្សាស្រាវជ្រាវ គិតថាជាលេខកូដសម្ងាត់របស់ ប៉ុល ពត។

**ស៖** សូមអរគុណ។ ដើម្បីកំណត់ត្រាតុលាការសូមលោកជម្រាបតុលាការថា តើជាប្រភេទនៃឯកសារនេះ វាប្រភេទឯកសារអ្វីដែរ? ដោយសារវាមានប្រភេទច្រើន សូមអនុញ្ញាតបង្ហាញឯកសារនេះលើអេក្រង់ម្ដងទៀត។ មើលទៅដូចជាលិខិតឆ្លើយឆ្លងដែរឬទេ? សូមអនុញ្ញាតបង្ហាញឯកសារនេះតែមួយភ្លែតទេ។

[១៤:១៤:២៤]

**ឆ៖** ឯកសារនេះ គឺជាឯកសារប្រភេទទីមួយ គឺជាប្រភេទក្រដាស ជាឯកសារដើម លំដាប់ទីមួយ ហើយជាឯកសារប្រភេទឆ្លើយឆ្លងពីមន្ទីរទៅកាន់បុគ្គលម្នាក់ទៀត ហើយមានបានចម្លងជូនទៅមនុស្សពីរនាក់ទៀតនៅក្នុងឯកសារនេះ។

**ស៖** សូមអរគុណលោក។ សូមអនុញ្ញាតបន្តទៅផ្នែកមួយទៀតនៃឯកសារផងដែរ ហើយដើម្បីប្រតិចារឹកត្រឹមត្រូវ គឺឯកសារទីមួយដែលយើងនឹងបង្ហាញនោះ គឺឯកសារ D175/4.3 គឺ D175/4.3 ហើយយើងអាចបង្ហាញឯកសារនេះនៅលើអេក្រង់។ បាទ អរគុណលោក ឆាំង យុ។ លេខកូដ ហើយនិងចំណារនៅខាងស្ដាំ ខាងលើនោះ បាទវាខុសពីមុនបន្តិច តើលោកអាចពន្យល់ប្រាប់តុលាការបានទេថា តើកំណត់លេខកូដ និងកំណត់ដៃនោះ មានអត្ថន័យដូចម្ដេច?

**ឆ៖** ឯកសារនេះ គឺជាប្រភេទឯកសារនៅក្នុងសំណុំរឿង លន់ នល់ ដែលយើងហៅថា លន់ នល់ *ដូស្យេ* ឬក៏លន់ នល់ *ដុកខ្យូមិន*។ ពីដំបូងឡើង យើងប្រើអក្សរ “N” ដើម្បីចុះលេខនេះ គឺ N0001425 ប៉ុន្តែក្រោយមក យើងបានរកឃើញថាអក្សរនេះត្រូវបានប្រើប្រាស់រួចទៅហើយ។ អ៊ីចឹងក៏យើងឆូតវា ទុកឱ្យឃើញដដែលថាយើងបានដូរមកអក្សរ “L” វិញ។ នៅខាងក្រោមលេខនេះ គឺមានលេខសម្គាល់សម្រាប់ឯកសារដើម។ ប៉ុន្តែនៅក្នុងរូបមួយនេះ វាមិនច្បាស់ មិនដឹងជា ០២ ឬក៏០១ ប៉ុន្តែខ្ញុំឃើញអក្សរ “បបគ”។ “បបគ” នេះគឺជាប្រភេទសំណុំឯកសារដើមដែលយើងទទួលបានពីក្រសួង

មហាផ្ទៃដែរ។ បើសិនជាយើងអាចមើលលេខដែលច្បាស់ជាងនេះ នៅជាប់នឹងអក្សរ“បបគ” យើងអាចទៅរកឯកសារដើមនេះបានភ្លាម ដោយសារនេះជាលេខសម្គាល់។

ខ្ញុំសូមលើកការជាប់អារម្មណ៍ដែរ ដោយសារថា តុលាការបានយកឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងឯកសារផ្សេងៗទៀត បង្កើតជាលេខមួយទៀត ដូចជានៅខាងឆ្វេងនេះជាដើម ដូចជាលេខ D175/4.3 ទាំងនេះ វាកាន់តែបង្កឲ្យមានការភ័ន្តច្រឡំទៅអ្នកសិក្សាស្រាវជ្រាវក្រោយពេលដែលតុលាការបានបញ្ចប់ទៅទៀត ពីព្រោះវាបង្កើតលេខកាន់តែច្រើន។ ឥឡូវនេះ យើងទាំងអស់គ្នាស្គាល់ថាមានលេខ “L” មានលេខ “N” មានលេខ “D” ប៉ុន្តែអ្នកផ្សេងទៀតច្បាស់ជាសួរហើយ ចុះអា 002758 មកពីណា? អ្នកណាជាអ្នកដាក់លេខហ្នឹង? អ៊ីចឹងនេះអាចជាបញ្ហាសម្រាប់ថ្ងៃក្រោយដែរចំពោះការសិក្សាស្រាវជ្រាវទម្រាំតែរកឃើញលេខ ០២ បបគ។

[១៤:១៧:៤០]

**ស៖** សូមអរគុណលោក។ ចំពោះជាប្រយោជន៍ដល់អ្នកដែលមិនចេះអក្សរខ្មែរ សូមឲ្យអនុញ្ញាតលោកអាន គ្រាន់តែចំណងជើងអត្ថបទដែលបង្ហាញលើអេក្រង់នេះ។

**ធ៖** “សេចក្តីរាយការណ៍របស់គណៈម្មាធិការតំបន់៥ ប្រចាំអាទិត្យ”

**ស៖** នេះជាឯកសារមួយវែងណាស់ លោក ឆាំង យុ គឺថាមានរហូតដល់ជិត៥០ទំព័រ។ អ៊ីចឹងចង់បង្ហាញទំព័រមួយជូនលោកពិនិត្យមើល ហើយសុំអនុញ្ញាតបង្ហាញនៅលើអេក្រង់។ តើលោកអាចអានកាលបរិច្ឆេទនៅលើឯកសារនេះបានទេ?

**ធ៖** “ធ្វើនៅថ្ងៃទី២១ ខែ៥ ឆ្នាំ៧៧”។

**ស៖** លោកបានអានចំណងជើងរួចហើយដែលថា “របាយការណ៍តំបន់៥” តើលោកនៅចាំទេថាតើតំបន់៥នោះមានទីតាំងនៅកន្លែងណានៃប្រទេសកម្ពុជា?

**ធ៖** តាមពិតទៅ ខ្ញុំរស់នៅតំបន់៥អង្គាល់សម័យកម្ពុជាប្រជាធិបតេយ្យ កាលណោះគេហៅថាបាត់ដំបង ឥឡូវគេហៅបន្ទាយមានជ័យ។ ខ្ញុំរស់នៅភូមិត្រពាំងវែង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ហើយបើគិតពីខេត្តសៀមរាប ចម្ងាយប្រហែល៩០គីឡូម៉ែត្រពីខេត្តសៀមរាប។

[១៤:១៩:២២]

**ស៖** សូមអរគុណលោក។ សូមអនុញ្ញាតបង្ហាញរូបថតឯកសារមួយនៅលើអេក្រង់ ដោយរយៈពេលខ្លីទេបាទ។ នៅទំព័រចុងក្រោយ លោកបានអានកាលបរិច្ឆេទ ប៉ុន្តែនៅខាងឆ្វេងវិញ តើលោកអាច

ឃើញមានអក្សរមួយចំនួននៅហ្នឹង តើសូមឲ្យលោកអានកន្លែងខាងឆ្វេង កន្លែងខាងក្រោមហ្នឹង?

**ឆ៖** ចម្លងជូន បងលេខាភូមិភាគមួយច្បាប់ ម-៥៦០ មួយច្បាប់ ឯកសារមួយច្បាប់។

**ស៖** ដូច្នេះ លោកពិនិត្យឃើញទៅ គឺបានចង្អុលបង្ហាញថា តំបន់៥ហ្នឹង នៅក្នុងភូមិភាគពាយ័ព្យនៅក្នុងតំបន់បាត់ដំបង ហើយតើព័ត៌មាននេះគឺផ្អែកលើ ឬក៏ចុះពីអ្វីៗនៅក្នុងតំបន់នោះ ដូចជាលេខតំបន់ជាដើម តើលោកអាចជម្រាបតុលាការបានទេ?

**ឆ៖** ខ្ញុំមិនច្បាស់សំណួរ ថាឯកសារនេះ គឺយើងមើលពីខាងលើឃើញស្រាប់ហើយ គឺមកពីតំបន់៥ ចុះនៅថ្ងៃទី២១ ខែ៥ ឆ្នាំ៧៧ ហើយចម្លងជូនលេខាភូមិភាគ។ យើងដឹងហើយថា ខេត្តបាត់ដំបងគឺនៅភូមិភាគពាយព្យ។ មានមន្ទីរ៥៦០ និងឯកសារទទួលបានម្នាក់មួយច្បាប់ដែរ។

**ស៖** តើលោកចាំទេ ថាតើ ម-៥៦០ហ្នឹង មានអត្ថន័យដូចម្តេច? ជាមន្ទីរអ្វីដែរ?

**ឆ៖** ខ្ញុំមិនដឹងទេបាទ។

**ស៖** អរគុណ។ ឥឡូវនេះ យើងនឹងចូលទៅដល់ឯកសារមួយទៀត។ នេះជាឯកសារមួយ មានឯកសារលេខហ្នឹងពីរ ដែលហៅថា IS18.41 ហើយនិង D175/3.99 អ៎! ចុច94 បាទ អ៊ីចឹងសូមអនុញ្ញាតតុលាការបង្ហាញឯកសារលើអេក្រង់។ ដូច្នេះ នេះជាកំណត់នៅខាងលើខាងស្តាំនេះ តើលោកពិនិត្យឃើញថាដូចគ្នា ឬក៏ស្ថិតនៅក្នុងប្រភេទជាមួយគ្នានឹងឯកសារចុងក្រោយដែលយើងពិនិត្យអំមិញនោះ?

[១៤:២២:២៥]

**ឆ៖** ឯកសារនេះ គឺស្ថិតនៅក្នុងប្រភេទដូចគ្នា ដូចខ្ញុំជម្រាបលោកពីខាងដើមអ៊ីចឹង។ ដំបូងយើងចុះអក្សរ “N” ប៉ុន្តែមកយើងដូរមកអក្សរ “L” គឺលេខ001436 នៅក្នុងកន្លែងនេះ គឺ04 បបកគឺជាប្រភពឯកសារដើម។

**ស៖** ចំពោះជាប្រយោជន៍ដល់អ្នកមិនចេះភាសាខ្មែរ សូមលោកមេត្តាអញ្ជើញគ្រាន់តែអានចំណងជើងខាងលើទេបាទ។

**ឆ៖** សេចក្តីរាយការណ៍--។

**ស៖** នៅក្នុង-- សូមអនុញ្ញាតលោកអានបន្ទាត់មួយនៅខាងក្រោមនោះដែរ?

**ឆ៖** “គិតពីថ្ងៃទី៤ ខែ៥ ឆ្នាំ១៩៧៧ ដល់ថ្ងៃទី២៩ ខែ៥ ឆ្នាំ១៩៧៧ មានដូចខាងក្រោមនេះ៖”។

**ស៖** សូមអនុញ្ញាតយើងទៅ បង្ខិលទៅខាងក្រោមចុងនៃអត្ថបទនេះ ដើម្បីឲ្យ-- សូមអនុញ្ញាត

ឲ្យលោកអានកាលបរិច្ឆេទ ហើយនិងកន្លែងដែលគេចុះហត្ថលេខា។ សូមអរគុណ។ អ៊ីចេះ គឺឯកសារនេះ គឺជាឯកសារយោងទៅរក ម-៥៦០ តើលោកអាចបញ្ជាក់ប្រាប់តុលាការបានទេ ថាកូដដែលអក្សរ “L” នោះ ដែលជាលេខដែលលោកយោងទៅរកអ្វីដែរ?

[១៤:២៤:៣០]

**ឆៈ** លេខ L នេះ អក្សរ “L” នេះ គឺយើងយោងទៅរកប្រភពឯកសារមកពីសម័យ លន់ នល់ ដែលយើងហៅថា លន់ នល់ *ដូស្សេ*។ ដូចខ្ញុំប្រាប់ពីព្រឹកមិញអ៊ីចឹង គឺថាយើងមានការភ្ញាក់ផ្អើល ដោយសារនៅពេលយើងចាប់ផ្តើមបើកមើលសំណុំរឿងនេះម្តងមួយសន្លឹកៗ យើងរកឃើញឯកសារខ្មែរក្រហមនៅនោះដែរ។ ប៉ុន្តែដើម្បីជារក្សានូវភាពដើម គឺយើងបានប្រើឈ្មោះ “L” ដំបូងយើងប្រើឈ្មោះ “N”ទេ ប៉ុន្តែយើងបានរកឃើញថា នៅក្នុងទំព័រគន្លងនិទ្ទេស ធ្វើកាតាឡុកនេះ គឺមានកន្លែងផ្សេងគេប្រើអក្សរ “N” ហើយ អ៊ីចឹងគឺយើងប្រើអក្សរ “L” វិញ ដើម្បីតំណាងឲ្យ លន់ នល់ *ដូស្សេ*។

**សៈ** សូមអរគុណ។ តាមដែលខ្ញុំយល់សក្ខីកម្មរបស់លោកព្រឹកមិញ នៅក្នុងករណីខ្លះឯកសារដែលចេញមកពីកម្ពុជាប្រជាធិបតេយ្យនោះគឺបានកត់សម្គាល់ថា “L” ដោយហេតុថា ចូលមកជាមួយនឹងឯកសារមួយសំណុំ ដោយហេតុថា ឯកសារនោះមកជាមួយដុំ គឺថាមានឯកសារខ្លះជាឯកសាររបស់លន់ នល់ ថាតើត្រូវទេបើសិនជាខ្ញុំបញ្ជាក់អ៊ីចឹងទៅ លោកកែខ្ញុំផង។

**ឆៈ** ត្រឹមត្រូវបាទ។

[១៤:២៥:៤៥]

**សៈ** សូមអរគុណលោក។ ហើយយើងនឹងចូលទៅឯកសារមួយទៀត។ សូមអនុញ្ញាតបង្ហាញឯកសារលើអេក្រង់។ លោក ឆាំង យុ ដូច្នេះកន្លែងផ្នែកមួយគឺថា ត្រូវបានកោសលុបជាជិតខ្មៅគឺកន្លែងហ្នឹងមានឈ្មោះសាក្សី ដែលជាឯកសាររក្សាការសម្ងាត់នៅដំណាក់កាលនេះ។ ឥឡូវនេះ ឯកសារនេះគឺមិនពិនិត្យមើលទៅក៏មិនដូចសណ្ឋាន ដូចខាងដើមដែលយើងពិភាក្សាអម្បាញ់មិញទេ ជាពិសេសតើលោកអាចបង្ហាញ ឬក៏ពន្យល់តុលាការបានទេ ថាឯកសារនេះជាឯកសារដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**ឆៈ** ចាប់អារម្មណ៍ដែរ ព្រោះលោកលុប-- ដាក់អាខ្មៅហ្នឹងលុបចេញណ៎ា ប៉ុន្តែលេខនេះខ្ញុំស្គាល់។ បាទ ឯកសារខ្ញុំស្គាល់ គឺជាឯកសារប្រភេទទូរលេខ។ ឯកសារប្រភេទទូរលេខនេះ គឺបើនិយាយឲ្យខ្លីទៅ នៅអក្សរខ្មែរដាក់ទូរលេខហើយស្រាប់ លេខ១១, ៣៥៣ខ្ទង់។ ហើយឯកសារនេះ បើសិនជា

លោកមើលឲ្យជិតមែនទែន គឺជាឯកសារដែលស្កេនចេញពីឯកសារដើម ព្រោះមានពណ៌ វាមិនមែនជាឯកសារថតចេញពីឯកសារថតចម្លងទេ។

[១៤:២៧:៥២]

**ស៖** ម៉្យាងទៀត ដែលលោកពិនិត្យមើលឃើញថា ជាឯកសារស្កេន ឬក៏ថតពីឯកសារដើមដូចលោកបញ្ជាក់តើមែនទេ?

**ឆ៖** ឯកសារនេះ គឺជាឯកសារដែលស្កេនចេញពីឯកសារដើម យើងអាចមើលអំពីពណ៌ បាទ ពណ៌របស់របស់ក្រដាស ហើយនិងខាងឆ្វេង ដែលមានសរសេរជាភាសាខ្មែរដាក់ថា "មេសថ្ងូក" គឺជាពណ៌ខៀវ។ បើសិនជាឯកសារថតចម្លង លោកមិនអាចមើលឃើញពណ៌ខៀវបានទេ។ អ៊ីចឹងឯកសារនេះ គឺជាឯកសារដែលស្កេនចេញពីឯកសារដើម។

**ស៖** សូមកត់ត្រាដើម្បីកត់ *(ឮមិនច្បាស់)* គឺឯកសារ D200/3.5។ ហើយជាពិសេសគួរឲ្យចាប់អារម្មណ៍ គឺថា យើងមើលឃើញនូវចំណារ នៅខាងលើស្តាំដៃ ហើយនិងខាងឆ្វេងដៃផងដែរ។ មានលេខនៅលើហ្នឹង ប្រហែលជាលោកអាចជម្រាបតុលាការ សម្រាប់យើងខ្ញុំយល់ថាតើឯកសារ-- អ៎ តើលេខហ្នឹងដែលសរសេរផ្ទាល់ដៃហ្នឹងមានន័យដូចម្តេច?

[១៤:២៩:០៨]

**ឆ៖** សូមទោស លេខខាងស្តាំ ឬក៏លេខខាងឆ្វេង?

**ស៖** បាទបើសិនជាលោកពិនិត្យមើល លេខខាងស្តាំដៃខាងលើ។ ដូចជាលេខ១៧ នៅខាងលើហ្នឹងវាស្កេន ហើយនិងនៅខាងឆ្វេងដៃផងដែរ មានសរសេរផ្ទាល់ដៃ ដូចជាលេខ១៤ ហើយមានសរសេរអក្សរខ្មែរ តើលោកអាចបញ្ជាក់ថា សំណេរផ្ទាល់ដៃនោះគឺ មានន័យដូចម្តេច? វាជាប់មកនឹងឯកសារពីកាលណាមកដែរ?

**ឆ៖** លេខ ១៧ និងលេខ ១៤ នេះ គឺជាលេខដែលជាប់មកនឹងឯកសារនៅក្នុងទសវត្សរ៍ឆ្នាំ៨០ នៅពេលដែលក្រុមចងក្រងឯកសាររបស់ក្រសួងមហាផ្ទៃ បានធ្វើការរាប់ទំព័រ។ លេខនេះ គឺជាលេខទំព័រ ហើយមានពេលខ្លះក្រុមរាប់ទំព័រហ្នឹងអាចរាប់ច្រឡំ។ លេខនេះគឺជាលេខ ១៧ គឺជាលេខទំព័ររបស់ឯកសារ។ បានន័យថា មានលេខ ១៨, ១៩, ២០ ទៀត។ ឯកសារនេះ គឺដាក់ជាដុំ ហើយនៅក្នុងនុំងមានទូរលេខជាច្រើន ប៉ុន្តែគេរាប់ជាសរុប ថានៅក្នុងដុំមួយនេះ មានប៉ុន្មានសន្លឹក និយាយជាសន្លឹកបានស្រួលស្តាប់។ អ៊ីចឹងនេះ គឺជាសន្លឹកទី១៧ សន្លឹកទី១៧ នេះគឺទូរលេខ១១។ អ៊ីចឹងបើសិនជាខ្ញុំដឹងលេខនៅកន្លែង

ដែលមានពណ៌ខ្មៅនេះ ហើយដឹងអំពីប្រភពរបស់វា ខ្ញុំអាចទៅសំណុំមួយហ្នឹង ហើយបើករកលេខ១៧ ទំព័រ១៧ នឹងឃើញឯកសារនេះ។

[១៤:៣០:៤៨]

**ស៖** ដូច្នេះ បានន័យថា លោកជឿថាលេខហ្នឹងគេត្រូវបានសរសេរនៅក្រសួងមហាផ្ទៃ ឬក៏គេសរសេរនៅពេលដែលគេបង្កើតឯកសារនេះផ្ទាល់តែម្តង?

**ឆ៖** នៅក្រសួងមហាផ្ទៃ។

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលទៅលើឯកសារនេះ វាហាក់ដូចជាសំណេរសរសេរដៃនៅខាងឆ្វេង។ ដូច្នេះហើយខ្ញុំសូមអនុញ្ញាតឲ្យលោកអានជូនយើងខ្ញុំ ហើយខ្ញុំសូមឲ្យបញ្ចាំងឯកសារនេះនៅលើអេក្រង់។ ដូច្នេះគឺអក្សរដែលនៅជាប់លេខ១៤ ហ្នឹង សូមឲ្យលោកជួយអាន។

**ឆ៖** "មេសថ្ងក" គឺជាឈ្មោះរបស់កន្លែងមួយនៅត្តុំផ្លូវជាតិលេខ១ គឺឈ្មោះទីតាំងមួយបាទ។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ហើយអាចប្រាប់យើងប្រសិនបើមិនច្បាស់ថាតើសំណេរដៃនេះ គឺសរសេរតាំងពីបង្កើតឯកសារហ្នឹង ឬក៏នៅពេលដែលគេរកឃើញឯកសារ?

[១៤:៣២:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមទោសដែលខ្ញុំកាត់សំឡេងនៅទីនេះ កាលពីម្សិលមិញការបង្គាប់ពីអង្គជំនុំជម្រះថា ចំពោះសាក្សីរូបនេះ ដែលគាត់នឹងមកផ្តល់សក្ខីកម្មគឺនិយាយអំពីវិធីសាស្ត្រតែប៉ុណ្ណោះ។ ក៏ប៉ុន្តែនៅពេលនេះ គឺសហព្រះរាជអាជ្ញាព្យាយាមលើកឯកសារជាក់លាក់ ឲ្យបញ្ចាក់ទៅលើឯកសារ។ ការសាកសួរដូច្នេះ គឺវាហួសពីគោលបំណងរបស់យើង។ នេះជាអ្វីដែលខ្ញុំសង្កេតឃើញ។

សំណួរពីចុងក្រោយ ជាពិសេស ខ្ញុំទុកឲ្យអង្គជំនុំជម្រះពិភាក្សាគ្នាសម្រេចទៅលើចំណុចហ្នឹង។ បើសិនជាយើងសួរទៅលើឯកសារមិនជាក់លាក់ហួសពីគោលបំណងរបស់យើង មេធាវីការពារក្តីគួរតែផ្តល់ឱកាសឲ្យធ្វើដូច្នោះផងដែរ។ យើងមិនចង់ទេ យើងមិនចង់ពន្យារនីតិវិធីនោះឡើយ។ យើងចង់គោរពទៅតាមគោលការណ៍ និងសេចក្តីណែនាំរបស់អង្គជំនុំជម្រះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ យើងព្យាយាមធ្វើការបង្ហាញ ដើម្បីបញ្ជាក់ជូនឲ្យលោក ឆាំង យុ ធ្វើការបង្ហាញទៅលើចំណារនេះ ថាវាយ៉ាងម៉េចនៅលើឯកសារ។ ដូច្នេះហើយប្រសិនបើអ៊ីចឹងទេ ប្រសិនបើមានការជំទាស់ខ្ញុំសូមអាចចូលទៅសំណួរផ្សេងទៀត ឬឯកសារផ្សេងទៀត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! ហើយលោកនៅមានពេលវេលាតែប្រាំមួយនាទីទៀតទេ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណ។ យើងគិតថា ឯកសារនេះវាវែងចំពោះ ឯកសារនេះលេខ IS13.2 មានលេខផ្សេងទៀតក៏ប៉ុន្តែលេខ ៗដែល ឯកសារនេះគឺមានលេខ D232/8.3 សូមបង្ហាញឯកសារនេះ នៅលើអេក្រង់។ សូមឲ្យមន្ត្រីតុលាការជួយទាញមកខាងស្តាំ។ ជាបឋម ដើម្បីជាប្រយោជន៍ទៅដល់អ្នកមិននិយាយភាសាខ្មែរ ដូច្នេះខ្ញុំសូមឲ្យលោកធ្វើការអាន ពីរប្រយោគ ឃ្លាពីរឃ្លានៅខាងលើគេបំផុតជាភាសាខ្មែរ សូមឲ្យលោកអាន។

**ឆ៖** "ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី៩ ខែ១០ ៧៥"។

**ស៖** សូមអរគុណ។ ជាថ្មីម្តងទៀត ដោយសារតែវាមានលេខ "D" នៅលើហ្នឹង ដូច្នេះខ្ញុំយល់ថា វាជាឯកសារដែលកាន់កាប់ និងមាន ដែលនៅ ឌី.ស៊ី.ខេម មាន។ តើមែនដែរឬទេ?

**ឆ៖** បាទ លេខនេះគឺជាលេខរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងបានចុះគឺលេខ D00677។

**ស៖** សូមអរគុណច្រើន។ តើលោកអាចជម្រាបតុលាការបានដែរឬទេ តើឯកសារនេះ ខាងលោកទទួលមកពីខាងណាដែរ? ប្រសិនបើអាចបញ្ចាំងលើអេក្រង់ សូមឲ្យបបញ្ចាំងឲ្យលោក ហើយយើងទទួលឯកសារពីណាមកដែរ? ខាង ឌី.ស៊ី.ខេម បានទទួលពីណាមកដែរ?

[១៤:៣៦:២០]

**ឆ៖** ឯកសារនេះគឺយើងបានមកពីលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន ហើយយើងមានអក្សរប៉ែន "BEN" ហើយប៉ែននេះ ខ្ញុំចាំទៀត គឺអក្សររបស់បុគ្គលិកខ្ញុំម្នាក់ឈ្មោះ អែម សុខឃីម ដែលគាត់បានសរសេរ។

**ស៖** លោកបានលើកឡើងកាលពីព្រឹកមិញថា លោកបានទទួលឯកសារមួយចំនួនពីអ្នកសិក្សា

ស្រាវជ្រាវ រួមទាំងសាស្ត្រាចារ្យប្រវត្តិវិទូ ប៉ែន ឃៀរនិន ផងដែរ។ ឯកសារដែលលោកទទួលបានមកនោះ គឺឯកសារដើម ឬក៏ឯកសារថតចម្លង?

**ឆ៖** ឯកសារនេះយើងបានទទួលមកពីលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន ជាឯកសារថតចម្លង។

**ស៖** តាមអ្វីដែលលោកដឹង ជាពិសេសនៅពេលដែលលោកពិភាក្សាជាមួយនឹងលោកសាស្ត្រា-ចារ្យនោះ ថាតើលោកសាស្ត្រាចារ្យមានឯកសារហ្នឹងដើមដែរឬទេ?

[១៤:៣៧:១៤]

**ឆ៖** រឿងនេះវែងឆ្ងាយ បើសិនជាខ្ញុំ លោកចង់ឲ្យខ្ញុំពន្យល់ ហើយខ្ញុំសូមអធ្យាស្រ័យដែរ បើសិនជា ព្រោះលោកប្រធានប្រាប់ថាឲ្យ--

**ស៖** បាទ លោកអាច សូមអរអញ្ជើញលោកអាចពន្យល់បាន។

**ឆ៖** ឯកសារនេះ ពេលដែលខ្ញុំបានមកពីលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន ខ្ញុំសួរគាត់ថា ឯកសារដើមនៅកន្លែងណា? ហើយលោកក៏បានប្រាប់ថា ឯកសារនេះត្រូវបានមន្ត្រីរាជរដ្ឋាភិបាលម្នាក់ប្រគល់ជូនគាត់។ ហើយខ្ញុំបានទៅសួរមន្ត្រីរដ្ឋាភិបាលនោះទៀត ថាឯកសារនោះ លោកបានមកពីកន្លែងណា? គាត់បានប្រាប់ថា យកមកពីក្រសួងវប្បធម៌ឃោសនាការ។ ប៉ុន្តែឥឡូវនេះ រកវាអត់ឃើញ ហើយមានការជជែកគ្នារវាងអ្នកសិក្សាស្រាវជ្រាវ ថាអ្នកណាមានឯកសារដើម? ពីព្រោះឯកសារប្រភេទនេះ លោក ដាវីដ ឆេនដ៍ល័រ ក៏មានដែរ។ លោក ហ្វូលីយ៉ូ ហៀលជ្រេស ដែលជាអ្នកសរសេរជីវប្រវត្តិព្រះមហាក្សត្រក៏មានដែរ។ អ៊ីចឹងមកទល់សព្វថ្ងៃនេះ យើងមានតែឯកសារថតចម្លងទេ ដែលយើងបានមកពីអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ដូចជាលោក ប៉ែន ឃៀរនិន ជាដើម។ ខ្ញុំបានជម្រាបរឿងរ៉ាវនេះ ហូរហែ វែងឆ្ងាយជូនដល់ទៅខាង អូ.ស៊ី.អាយ.ជេ អំពីប្រវត្តិឯកសារនេះរួចហើយ។

[១៤:៣៨:២៣]

**ស៖** សូមអរគុណច្រើន ខ្ញុំដឹងថា ខ្ញុំកំពុងតែមើលពេលវេលា ដើម្បីឲ្យខ្ញុំអាចបញ្ចប់ក្នុងពេលឆាប់បន្តិចទៀតនេះ។ លោក ឆាំង យុ ប្រសិនបើលោកមើលទៅលើឯកសារទាំងឡាយ ឯកសារមួយចំនួន គឺឯកសារថតចម្លង ឯកសារមួយចំនួនជាឯកសារដើម។ ហើយលោកបានផ្តល់សក្ខីកម្មកាលពីព្រឹកមិញ ដែលថាលោកជាអ្នកចាត់ចែងពិនិត្យទៅលើឯកសារនោះជាច្រើនឆ្នាំរួចមកហើយ។ តើលោកផ្ទាល់ខ្លួនមានជួបប្រទះស្ថានភាពដែលលោកមានភាពសង្ស័យទៅលើយថាភាពនៃឯកសារទាំងអស់នោះដែរឬទេ?

**ឆ៖** មានឯកសារមួយពីរដែរ ដែលខ្ញុំសង្ស័យ ហើយខ្ញុំគិតថាអនុប្រធានរបស់ខ្ញុំក៏បាននិយាយរួចហើយ អំពីឯកសារមួយដែលទាក់ទងទៅនឹងការចំណាប់ខ្មាំងជនជាតិបរទេស នៅខេត្តកំពត ហើយឯកសារនោះខ្ញុំមានការសង្ស័យ ដោយហេតុថាជាឯកសារប្រភេទថ្មី ហើយខ្លឹមសារនៅក្នុងឯកសារនេះវាមិនមែនជាពាក្យពេចន៍ដែលប្រើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយណាមួយទៀត ឯកសារនេះធ្វើឡើងនៅក្នុងរយៈឆ្នាំ៩៤-៩៥។ អ៊ីចឹងយើងមិនច្បាស់ថា ឯកសារនេះជាឯកសាររបស់ណា។ បើយើងនិយាយអំពីរយៈកាល គឺវាផុតរយៈកាលនៅឆ្នាំ៧៥ រួចមកហើយ។ ហើយឯកសារនេះ ខ្ញុំមិនការមន្ទិលសង្ស័យមួយទៀត ដោយហេតុថា យើងមិនដឹងអ្នកណាអ្នកសរសេរទាល់តែសោះ ហើយសួរមនុស្សដែលយកមកឲ្យយើង គេមិនព្រមប្រាប់។ អ៊ីចឹងយើងទុកវាម្ដុំ។ អ៊ីចឹងនៅក្នុងឯកសារចំនួនប្រហែលជាមួយលាននេះ មានឯកសារតែមួយគត់ ដែលខ្ញុំមានការមន្ទិលសង្ស័យ។

[១៤:៣៩:៥២]

**ស៖** ដូច្នេះ ខ្ញុំចង់សុំសួរសំណួរចុងក្រោយ បន្តទៅលើចម្លើយរបស់លោក។ ដូច្នេះយើងយល់ថា ឌី.ស៊ី.ខេម មានឯកសារដូចដែលឯកសារដែលយើងរកឃើញនៅចំពោះមុខយើងនៅថ្ងៃនេះ។ តាមការស្រាវជ្រាវរបស់លោក ឯកសារទាំងអស់នោះ វាបង្ហាញថា វាជាឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យ តើមែនដែរឬទេ?

**ឆ៖** ជាការពិត ឯកសារដែលយើងមាន គឺវាបានបង្ហាញថាឯកសារនេះ វាកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចខ្ញុំជម្រាបជូនលោកមេធាវីអ៊ីចឹង ទៅតាមអត្ថន័យ ខ្លឹមសារ ពណ៌សម្បុរ កាលបរិច្ឆេទ និងអ្នកនិពន្ធឯកសារ។

[១៤:៤០:៣៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា អរគុណមេធាវី។ ឥឡូវនេះពេលវេលាសម្រាប់សហព្រះរាជអាជ្ញាសួរដល់សាក្សី លោក ឆាំង យុ ឃើញថាអស់ហើយ ហើយពេលវេលាក៏សមល្មមនឹងឈប់សម្រាកហើយដែរ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីរសៀល សូមអញ្ជើញចូលវិញដើម្បីកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ ជួយសម្របសម្រួលកន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មឲ្យបានមុខអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសួរ តាំងសំណួរចំពោះសាក្សីរូបនេះ បើសិនមាន។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ខ្ញុំនឹងលើកជាសំណួរជាដំបូង ហើយបន្ទាប់មកប្រគល់សំណួរ ប្រគល់ពេលដែលនៅបន្តទៀតជូនទៅលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរលោក ឆាំង យុ! ខ្ញុំមានសំណួរមួយចំនួន ដែលចង់សួរលោក ហើយសូមថា លោកអាចឆ្លើយចំៗសំណួរ ហើយឲ្យខ្លី បើអាចធ្វើបាន ដោយសារពេលវេលាមេធាវីនាំមុខមានរយៈពេលតែមួយម៉ោងតែប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំទាំងពីរនាក់ត្រូវបែងចែកពេលវេលានេះជាពីរ។ លោកបាននិយាយថា បេសកកម្មរបស់ ឌី.ស៊ី.ខេម គឺស្វែងរកការពិត។ អ៊ីចឹងមែនទេលោក?

**លោក ឆាំង យុ៖**

**ឆ៖** ដើម្បីការផ្សះផ្សាជាតិមួយពីអតីតកាល។

**ស៖** បាទ អរគុណ។ តើការស្វែងរកការពិតហ្នឹង មានសារៈសំខាន់យ៉ាងដូចម្ដេចខ្លះសម្រាប់លោកក៏ដូចជា ឌី.ស៊ី.ខេម?

[១៥:០៣:៣៨]

**ឆ៖** សម្រាប់ការផ្សះផ្សាជាតិ ដើម្បីផ្សះផ្សាជាតិ យើងត្រូវស្វែងរកការពិតពីអតីតកាល ហើយដើម្បីសម្រេចបាននូវការផ្សះផ្សាជាតិនេះ គឺខ្ញុំគិតថាយើងត្រូវធ្វើកិច្ចការបី។ ទីមួយ ត្រូវធ្វើឲ្យមាន

តុលាការមួយ ដើម្បីស្វែងរកជនណាមួយដែលបានប្រព្រឹត្តបទល្មើស ដែលបានធ្វើកំហុស ដែលបានធ្វើឲ្យប្រជាជនខ្មែររាប់លាននាក់ស្លាប់បាត់បង់ជីវិត។

[១៥:០៤:០១]

បញ្ហាទីពីរ ខ្ញុំគិតថាជាការចាំបាច់ណាស់ គឺឲ្យមានការចងចាំ គឺសិស្សានុសិស្ស ក្មេងជំនាន់ក្រោយត្រូវតែរៀនសូត្រអំពីប្រវត្តិសាស្ត្រនេះ។ ហើយបញ្ហាទីបី គឺចាំបាច់យើងត្រូវមានកន្លែងជាអចិន្ត្រៃយ៍មួយដើម្បីបន្តការសិក្សាស្រាវជ្រាវ ដើម្បីជាវិធីមួយក្នុងការទប់ស្កាត់អំពើនេះមិនឲ្យត្រឡប់មកវិញ។ អ៊ីចឹង ចេតនារបស់យើងតែមួយគត់ គឺដើម្បីការផ្សះផ្សា។

**ស៖** តើការផ្សះផ្សាហ្នឹងមានសារៈសំខាន់យ៉ាងណាសម្រាប់លោក?

**ឆ៖** សម្រាប់ខ្ញុំ! បាទ សម្រាប់ខ្ញុំគឺខ្ញុំគិតថា មានការសារៈសំខាន់ណាស់ ចំពោះខ្ញុំដោយសារថាក្រោយពីអំពើនេះបានកើតឡើងនៅក្នុងក្រុមគ្រួសារខ្ញុំ ជាពិសេសម្តាយខ្ញុំដែលស្លាប់--

[១៥:០៤:៤១]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី-- លោកសាក្សីកុំអាលឆ្លើយ លោក-- អញ្ជើញលោក កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោស លោកប្រធាន សូមអរគុណ។ ខ្ញុំមិនពិនិត្យឃើញថា សំណួរនេះវាទាក់ទងទៅនឹងសាក្សីត្រូវបំភ្លឺ គឺថាយើងមិនទាន់តាំងសំណួរទាក់ទងទៅបេសកកម្មរបស់មជ្ឈមណ្ឌលឯកសារ គាត់ត្រូវតែបង្ហាញត្រឹមតែសក្ខីកម្ម អំពីដំណើរការគ្រប់គ្រងឯកសារដើមបណ្តឹងរដ្ឋប្បវេណី គឺថាមិនអាចសួរគាត់ ឲ្យទៅគាត់ឲ្យយោបល់អំពីការផ្សះផ្សាជាតិ។ អានោះគឺថាជាបញ្ហាផ្សេង ដូចថាវាអាចជាហាក់ដូចជាដំណើររឿងប្រលោមលោកមួយដាច់ដោយឡែក វាមិនមែនជាគោលបំណងនៃសវនាការល្ងាចនេះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ហើយលោកមេធាវី ជំទាស់មានប្រសិទ្ធភាព។ លោកមេធាវីជាតិនៃក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺអង្គជំនុំជម្រះបានកំណត់នូវគោលបំណងនៃកិច្ចសវនាការដេញដោលសាក្សីលោក ឆាំង យុ រួចហើយ ហើយអង្គជំនុំជម្រះបានអញ្ជើញលោក ឆាំង យុ មកក្នុងនាមប្រធានស្ថាប័ន ឬក៏ប្រធានអង្គការ ឌី.ស៊ី.ខេម ដែលគាត់និយាយឲ្យតំណាងនីតិបុគ្គលអង្គការមជ្ឈ

មណ្ឌលឯកសារកម្ពុជា មិនមែនឲ្យគាត់ទទួលឆ្លើយក្នុងនាមជាសាក្សី ជារូបវន្តបុគ្គលធម្មតាទេ។ អ៊ីចឹង លើពីរចំណុចនេះ សូមលោកមេធាវីផ្តង់ការគំនិត គិតគូរពិចារណាក្នុងការតាំងសំណួរ ហើយលោក ទាមទារពេលវេលាច្រើន ប៉ុន្តែពេលវេលាដែលផ្តល់ឲ្យក្នុងការប្រើប្រាស់ គឺវាអាចមិនមានប្រសិទ្ធភាពទេ ដោយសារការសួរដេញដោលក្រៅអង្គហេតុ ឬក៏បញ្ហាដែលមិនពាក់ព័ន្ធនឹងអ្វីដែលអង្គជំនុំជម្រះកំណត់ ឲ្យធ្វើសវនាការដេញដោល។

[១៥:០៧:០០]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំគ្រាន់តែចង់លើកអំពីគោលគំនិតនៅក្នុងដឹកនាំបែប បទការងារ ធ្វើការរបស់ ឌី.ស៊ី.ខេម នេះតែប៉ុណ្ណោះ ដោយសារថាលោកជាប្រធានរបស់ ឌី.ស៊ី.ខេម ក៏ដូចជាអ្នកដឹកនាំរបស់ ឌី.ស៊ី.ខេម ដែរ។ អរគុណច្រើន ចំពោះការណែនាំរបស់លោកប្រធាន។

**សួរដោយលោក ពេជ អង្គ៖**

ខ្ញុំចង់សួរសំណួរមួយចំនួនទៀត ហើយលោកគ្រាន់តែឆ្លើយថាមែន ឬមិនមែន តែប៉ុណ្ណោះខ្លី ដើម្បីកុំឲ្យខាតពេលច្រើន។ សំណួរទាំងនេះអាចមានការឆ្លើយពីមុនហើយ ក៏ប៉ុន្តែដោយសារថាលោក ជាប្រធាននៃ ឌី.ស៊ី.ខេម លោកគឺតំណាង ឌី.ស៊ី.ខេម នៅពេលនេះ។

**ស៖** តើ ឌី.ស៊ី.ខេម ធ្លាប់បានគិតខ្លួនឯងថាជាស្ថាប័នស៊ើបអង្កេតលើបទឧក្រិដ្ឋដែលប្រព្រឹត្តក្នុង របបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? មែន ឬមិនមែន?

**លោក ឆាំង យុ៖**

**ឆ៖** ខ្ញុំគិតថា សំណួរនេះមិនអាចឆ្លើយ មែន ឬមិនមែន បានទេ។ ដោយសារថាកាលពីរយៈ កាលកន្លងមកមានការជជែកគ្នាអំពីពាក្យ ហើយលោក ហើយនិងខ្ញុំគឺជាខ្មែរដូចគ្នា។ ការចុះទៅសួរអ្នក ស្រុក ការទៅនិយាយជាមួយអ្នកស្រុក ការទៅសម្ភាសអ្នកស្រុក លោកចង់ហៅថាយ៉ាងម៉េចក៏បានដែរ។ ប៉ុន្តែគ្មានច្បាប់ណាមួយដែលកំណត់ផ្តាច់មុខថាពាក្យនេះត្រូវតែមានន័យអ៊ីចឹងទេ។ អត់មានទាល់ទេសោះ អ៊ីចឹងលោកចង់ថាស៊ើបអង្កេតក៏បាន ថាខ្ញុំចុះទៅខេត្តក៏បាន ថាខ្ញុំចុះទៅសម្ភាសអ្នកស្រុកក៏បានប៉ុន្តែ បើឆ្លើយថា "*យេស*" ហើយនិង "*ណូ*" វាទៅជារឿងមួយផ្សេងទៀត។

**ស៖** បាទ សូមអរគុណ។ តែក្នុងន័យច្បាប់។

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាស្ថាប័នច្បាប់ទេ។

**ស៖** អរគុណច្រើន។ តើ ឌី.ស៊ី.ខេម មានគោលដៅប្រមែប្រមូលឯកសារទាំងអស់ពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ពិតមែន។

**ស៖** សំណួរមួយដែលធ្លាប់ឆ្លើយដោយលោកអនុប្រធានរបស់លោកម្តងរួចហើយ ចង់សួរថា តើនៅពេលដែលនិយាយថា ឌី.ស៊ី.ខេម មិនដែលធ្វើការវិភាគលើឯកសារ។ តើកន្លែងនេះមានន័យយ៉ាងដូចម្តេច? លោកអាចពន្យល់បានខ្លី?

**ឆ៖** ដូចគ្នាដែរ បើលោកចង់ថាសិក្សា វិភាគ អាន យើងប្រើខួរក្បាល ប្រើភ្នែកដើម្បីអាន អ៊ីចឹងលោកចង់បកស្រាយថាយ៉ាងដូចម្តេចក៏បាន។ ប៉ុន្តែចំពោះយើងខ្ញុំ យើងយកឯកសារមក យើងយកមកអាន យើងយកមកសរសេរ។ អ៊ីចឹងលោកថាវិភាគក៏ដោយ យើងចង់ថាអានក៏បាន សិក្សាស្រាវជ្រាវក៏បាន។ ដើម្បីអ្វី? ដើម្បីឲ្យយើងឲ្យបានយល់ថា ហេតុអ្វីនៅក្នុងប្រវត្តិសាស្ត្រអំពីនេះបានកើតឡើង ហើយធ្វើយ៉ាងណាកុំអំពើនេះកើតឡើងម្តងទៀត។ អ៊ីចឹងយើងត្រូវតែសិក្សាវា ហើយការសិក្សានេះយើងចង់ហៅថាយ៉ាងម៉េចក៏បានដែរ។ លោក ហើយនិងខ្ញុំ ខ្ញុំនិយាយដដែល យើងខ្មែរដូចគ្នា ភាសាខ្មែរមានន័យប្រើច្រើនយ៉ាងណាស់ ជាភាសាដែលសម្បូរបែប។ លោកចង់ប្រើវិភាគក៏បាន និយាយក៏បាន សរសេរក៏បាន អានក៏បាន បានដូចៗគ្នា។ អ៊ីចឹងត្រឡប់មកវិញ គ្មានច្បាប់ណាមួយផ្តាច់មុខលើពាក្យហ្នឹងទេ ដែលមានន័យថាលោកចង់និយាយសួរមកខ្ញុំ។

[១៥:០៩:៥២]

**ស៖** បាទ សូមអរគុណ។ នៅក្នុងដំណើរការ នៅក្នុងការទទួលឯកសារប្រមូលឯកសារ ការក្លាសស្សេឯកសារធ្វើជាកាតាឡុក ហើយនិងការប្រើប្រាស់ឯកសារ ឬក៏រក្សាឯកសារ។ ថាតើ លោកមានបានធ្វើជា *ហ្កាយឡាញ* ច្បាស់លាស់សម្រាប់ណែនាំបុគ្គលិកនៅក្នុងការធ្វើកិច្ចការទាំងបីបែបនេះដែរឬទេ? ហើយ ហ្កាយឡាញនោះ ថាតើបានមានការពិភាក្សាជាទូលាយនៅក្នុង ឌី.ស៊ី.ខេម ឬក៏មានការផ្តល់ជាយោបល់ពីផ្នែកខាងក្រៅណាមួយ ទៅលើហ្កាយឡាញទាំងអស់នោះ ដើម្បីដំណើរការហ្នឹងបានល្អដែរឬទេ? ដើម្បីឲ្យនីតិវិធី ឬ ហ្កាយឡាញ ហ្នឹងបានល្អដែរឬទេ?

**ឆ៖** ដូចជាប្រហែលជាលោកចាំហើយថា នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារប្រាំប្រភេទ។ អ៊ីចឹង នៅក្នុងការប្រមូលឯកសារនីមួយៗមានវិធីខុសៗគ្នា ប៉ុន្តែនៅពេលដែលយើងបញ្ចូលទៅក្នុងកាតាឡុកឯកសារនេះ គឺមានក្បួនតែមួយទេ ភាសាអង់គ្លេសយើងហៅថា *"មេញួល"* លោកអាចរក

មេញ្ញូល នេះបាននៅក្នុងគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ អ៊ីចឹង បុគ្គលិកទាំងអស់គឺថាត្រូវបានពន្យល់ប្រាប់អំពីរបៀបធ្វើកាតាឡុកនេះ របៀបធ្វើ វើកស៊ីត របៀបបញ្ចូលទិន្នន័យ រហូតទឹងនឹងរបៀបសរសេរឈ្មោះ ចំពោះអ្នកដែលបានស្លាប់ទៅ ថាត្រូវសរសេរយ៉ាងម៉េច ដើម្បីងាយស្រួលក្នុងការស្វែងរក។ ហើយការសរសេរឈ្មោះនេះ គឺយើងបានសួរទៅអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ដោយសារថាខ្មែរយើងមួយចំនួនសរសេររបៀបជាបារាំង ហើយមួយចំនួនដែលកើតក្រោយ សរសេររបៀបជាភាសាអង់គ្លេស។

[១៥:១១:៣៤]

អ៊ីចឹង បានរកស្តង់ដាមួយធ្វើយ៉ាងណាដើម្បីពន្យល់អ្នកដែលប្រើគេហទំព័ររបស់យើង អាចស្វែងរកព័ត៌មានបានលឿន។ អ៊ីចឹងមានការសាកសួរពីអ្នកជំនាញជាន់ខ្ពស់ដែរ ក្នុងការធ្វើរបៀបសរសេរអក្សរ សរសេរឈ្មោះ ចំពោះមនុស្សដែលស្លាប់។ មានធ្វើជាគេហៅថា *"ភូសារី"* ដើម្បីធ្វើយ៉ាងណាឲ្យការបកប្រែហ្នឹង មានលក្ខណៈដូចៗគ្នា។ អ៊ីចឹង នៅក្នុងពាក្យមួយៗ ដែលយើងមិនយល់ ដូចជាពាក្យថា "បដិច្ចសមុប្បាទ" ជាពួកខ្មែរក្រហមប្រើប្រាស់ ដូចជាពាក្យ "អង្គការលើ" ឬក៏ពាក្យថា "វណ្ណៈកសិករទាប"។ អ៊ីចឹង បានបង្កើតជាស្តង់ដារមួយដើម្បីឲ្យបុគ្គលិកទាំងអស់យល់ ហើយបើសិនជារកឃើញពាក្យថ្មី យើងបញ្ចូលបន្ថែមទៅក្នុងទិន្នន័យនេះ ដើម្បីឲ្យស្រួលក្នុងការដែលយើងធ្វើការបកប្រែ ឬដូចជាការពិនិត្យឯកសារ។ អ៊ីចឹង ផ្នែកនេះក៏យើងបានសួរអ្នកជំនាញដែរ។ ថាតើមនុស្សនៅក្នុងពិភពលោកដែលនិយាយជាភាសាអង់គ្លេសអ្នកជំនាញនេះ ពាក្យ "បដិច្ចសមុប្បាទ"នេះ គេបកថាយ៉ាងដូចម្តេច? អ៊ីចឹង យើងមានសួរជំនាញដែរ ក្នុងការប្រើប្រាស់វិធីសាស្ត្រក្នុងការចងក្រងឯកសារនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុង ហ្កាយឡាញហ្នឹង មាននិយាយអំពីសារៈសំខាន់នៅក្នុងការរកឲ្យឃើញអំពីប្រភពឯកសារហ្នឹងដែរឬទេ?

[១៥:១២:៥៨]

**ឆ៖** នៅក្នុង វើកស៊ីត ចាំបាច់ត្រូវតែដាក់ប្រភពឯកសារ។ អ៊ីចឹង ត្រូវតែមានបាទ ត្រូវតែកន្លែងហ្នឹង ត្រូវតែមានតែម្តង។

**ស៖** ចំពោះឯកសារដែលលោកទទួលបានពីក្រសួងមហាផ្ទៃ ឬក៏ជាទួលស្លែង ឬក៏ដូចជាបណ្ណសារជាតិ។ តើពេលដែល ឌី.ស៊ី.ខេម ទៅទទួលឯកសារពីកន្លែងទាំងបីទាំងអស់នោះ គឺឌី.ស៊ី.ខេម

ប្រមូលឯកសារទាំង-- ឬក៏ចម្លងឯកសារទាំងអស់ដោយមិនធ្វើបែងចែកថា ឯកសារណាសំខាន់ ឬ ឯកសារណាសំខាន់ ឬក៏ឯកសារណាគួរយក ឬមិនគួរយក ឬក៏យ៉ាងម៉េច?

**ឆ៖** និយាយទៅ ឲ្យតែពី៧៥-៧៩ យកទាំងអស់បាទ យកទាំងអស់តែម្តង ឲ្យតែក្នុងរយៈកាល ហ្នឹង គឺយើងសុំយកទាំងអស់តែម្តង ហើយបើសិនជាឯកសារដែលទុកដាក់រួចហើយស្រេច ដូចជានៅ ទួលស្លែងហ្នឹង យើងមិនទៅយកឯកសារដើមហ្នឹងមកធ្វើអីទេ។ វាគ្មានហេតុផលទៅយករបស់មួយពី កន្លែងមួយទៅដាក់កន្លែងមួយទៀត។ អ៊ីចឹងយើងគ្រាន់តែថតចម្លង ឬក៏យើងអាចត្រឡប់ទៅវិញ ដោយសារថាយើងមានការអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជា អ៊ីចឹងយើងអាចត្រឡប់ទៅមើលវិញពេលណា ក៏បានដែរ។ អ៊ីចឹង យើងអត់ចាំបាច់រើសពីកន្លែងមួយទៅដាក់កន្លែងមួយទេ។ ដរាបណា ដូចជានៅក្នុង អគារ ដែលបោះបង់ចោល នៅលើដី នៅលើឥដ្ឋ អាហ្នឹងបានយើងចាប់ផ្តើមរើសប្រមូលមក ហើយ ចងក្រង ហើយថែរក្សារបស់ដើមនៅកន្លែងដែលគួរតែតម្កល់ទុក។

**ស៖** លោកបាននិយាយថា ឯកសារទាំងអស់ដែលទទួលបាន ដែល ឌី.ស៊ី.ខេម ទទួលបានពី កន្លែងណាមួយ លោកបានមានប្រសាសន៍ថា លោកបានអានស្ទើរតែទាំងអស់ ហើយអានពីរដង ឬក៏ បីដងថែមទៀតផង។

**ឆ៖** ពិតមែន។

**ស៖** ចង់ជម្រាបសួរថា ចុះចំណែកឯកសារដែលលោកមិនបានអានវិញ ថាតើលោកមានបាន គិតថា ឯកសារប្រភេទណាដែលថាលោកមិនយល់ថាលោកយល់មិនមានលទ្ធភាពសម្រាប់អាន ឬក៏មិន ត្រូវអានដែរឬទេ? ហើយតើឯកសារទាំងអស់នោះ មានអ្នកណាផ្សេងនៅក្នុង ឌី.ស៊ី.ខេម ដែលជា បុគ្គលិកអានដើម្បីពិនិត្យពីយថាភាពនៃឯកសារទាំងនោះដែរឬទេ?

**ឆ៖** ខ្ញុំអានទាំងអស់តែម្តង។ ខ្ញុំអានតែម្តង។

**ស៖** តែព្រឹកមិញលោកបាននិយាយថា មានប្រសាសន៍ថា ឯកសារទាំងអស់ដែលមាននៅក្នុង ឌី.ស៊ី.ខេម គឺលោកអានស្ទើរតែទាំងអស់។

**ឆ៖** បាទ ខ្ញុំអាន។ ខ្ញុំអានទាំងអស់។

**ស៖** អ៊ីចឹង សូម--

[១៥:១៥:២៦]

**ឆ៖** អ្ហូ! អ៊ីចឹងលោកចង់និយាយថា មានផ្សេងទៀតអ្រូស? ខ្ញុំចង់និយាយថា ខ្ញុំអានទាំងអស់

ប៉ុន្តែខ្ញុំមិនអាចចាំបានទាំងអស់បានទេ ព្រោះវាច្រើន។ ប៉ុន្តែឯកសារទាំងអស់ គឺត្រូវឆ្លងកាត់តុខ្ញុំ ទោះបីជាខ្ញុំមិនអានលម្អិត ក៏ខ្ញុំឃើញ ខ្ញុំប៉ះពាល់ឯកសារហ្នឹងដែរ។ គឺខ្ញុំបានប្រាស្រ័យទាក់ទងជាមួយនឹងឯកសារ ប៉ុន្តែបើឱ្យខ្ញុំចាំឯកសារមួយលានមានស្អីខ្លះ? ពិបាកបន្តិច ប៉ុន្តែបើសិនជាខ្ញុំនៅ*អូហ្វហ្វីស* ខ្ញុំអាចជម្រាបបានច្រើន ដោយសារថាខ្ញុំមានឯកសារ ឬក៏មានសៀវភៅដែលខ្ញុំអាចចំណាំបាន។ ដូចជាឧទាហរណ៍ នៅពេលដែលសហចៅក្រមស៊ើបអង្កេតចុះទៅសាកសួរខ្ញុំៗ ឆ្លើយអត់មានពិបាកទេ ព្រោះខ្ញុំអាចទៅរកភ្លាមៗ។ ប៉ុន្តែមកដល់ទីនេះ ខ្ញុំពិបាកថា និយាយថា ចាំទាំងអស់ វាដូចជាហួសហេតុពេក។ អ៊ីចឹងខ្ញុំចង់និយាយថា ខ្ញុំអានទាំងអស់ ប៉ុន្តែវាមិនចាំទាំងអស់ទេ។

[១៥:១៦:១១]

**សៈ** អ៊ីចឹង មានន័យថា អត់មានឯកសារណាមួយដែលចន្លោះការអាន ឬក៏ការមើល ការពិនិត្យរបស់លោកទេ?

**ឆៈ** វាអាស្រ័យទៅលើលោកឱ្យនិយមន័យពាក្យថា “ឯកសារ” ដែរ។ ដូចជាឯកសារគណនេយ្យខ្ញុំអត់អានទេ ខ្ញុំមិនដែលអានសោះឯកសារគណនេយ្យ។ ជាឯកសាររដ្ឋបាល ដែល--

**សៈ** ខ្មែរក្រហម?

**ឆៈ** អត់ទេ! ពីព្រោះពាក្យ “ឯកសារ” វាទូលំទូលាយ។ បើសិនជាលោកនិយាយពីឯកសារប្រាំប្រភេទ ខ្ញុំអានទាំងអស់។ តែបើយើងនិយាយឯកសារផ្សេងទៀត ជាឯកសាររដ្ឋបាលរបស់ការិយាល័យរាល់ថ្ងៃ ឯកសារសវនកម្ម ខ្ញុំមិនដែលអានទេ។ ខ្ញុំឱ្យបុគ្គលិកខ្ញុំអាន ហើយប្រាប់មកខ្ញុំវិញសង្ខេបថា វាមានរឿងស្អីខ្លះ។ ប៉ុន្តែបើឯកសារខ្មែរក្រហម ជាឯកសារដើម ខ្ញុំអានទាំងអស់។

[១៥:១៦:៥០]

**សៈ** បាទ ខ្ញុំសំដៅទៅលើឯកសារខ្មែរក្រហមតែប៉ុណ្ណោះ។

**ឆៈ** បាទ ទាំងអស់។

**សៈ** ខ្ញុំចង់សូមឱ្យលោកពន្យល់ អំពីចំណុចមួយដែលមាននៅក្នុងវែបសាយរបស់លោក ហើយឱ្យលោកពន្យល់ថា តើឃ្លានោះមានន័យថាយ៉ាងដូចម្ដេច?

**លោក ពេជ អង្គ៖**

បាទ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតអីគេ? ឯកសារអី? អត្តសញ្ញាណឯកសារ លេខប៉ុន្មានឯកសារហ្នឹង? ហើយមានចំណងជើងយ៉ាងដូចម្ដេច? បញ្ហានេះដូចជាច្រើនលើកច្រើនសាហើយនៅក្នុងការបង្ហាញឯកសារ។

[១៥:១៨:០២]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ឯកសារនេះ គឺជាឯកសារមួយ-- ជាទំព័រមួយនៅក្នុងគេហទំព័ររបស់ ឌី.ស៊ី.ខេម ហើយបែបដូចគ្នាត្រូវបានធ្វើដោយខាងសហព្រះរាជអាជ្ញា គឺគាត់ធ្លាប់បង្ហាញអំពីគេហទំព័រនោះ ហើយឲ្យសូមឲ្យមានការពន្យល់អំពីតំណាងខាង ឌី.ស៊ី.ខេម គឺបែបបទនេះធ្លាប់បានធ្វើរួចហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បង្ហាញច្បាស់លាស់ឯកសារស្អី? ឲ្យបានច្បាស់លាស់អត្តសញ្ញាណឯកសារ ហើយឯកសារហ្នឹងថ្មី ឬឯកសារមិន-- មាននៅក្នុងសំណុំរឿងរួចហើយ? ដើម្បីអង្គជំនុំជម្រះសម្រេចមុន ជាមុនៗនឹងអនុញ្ញាត ឬក៏មិនអនុញ្ញាត ពីព្រោះឯកសារថ្មីត្រូវឆ្លងកាត់ការសម្រេចជាមុនសិន ដើម្បីឲ្យសួរដេញដោល ឬក៏មិនអនុញ្ញាតឲ្យសួរដេញដោល ដែលមានចែងនៅក្នុងវិធាន៨៧(៤)។ ហើយបញ្ជាក់មកវិញគឺដោយយោងចង្អុលបង្ហាញទៅវិធាន៨៧(៣)។

[១៥:១៩:១៤]

**លោក ពេជ អង្គ៖**

បាទ ដូច្នេះខ្ញុំនឹងមិនព្យាយាមបង្ហាញឯកសារនោះទៀតទេ។ ខ្ញុំនឹងបន្តសំណួរតទៅទៀត។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សំណួរមួយទាក់ទងទៅនឹងឯកសារទង់បដិវត្ត តើលោកដឹងទេថា ឯកសារទង់បដិវត្តមានចំនួនប៉ុន្មានលេខដែលមាននៅក្នុង-- ដែលត្រូវបានបោះពុម្ព? ហើយតើ ឌី.ស៊ី.ខេម មានប៉ុន្មានលេខក្នុងចំណោមឯកសារទាំងអស់?

**លោក ឆាំង យុះ៖**

**ឆ៖** ដូចខ្ញុំប្រាប់ខាងសហព្រះរាជអាជ្ញាអីចឹង គឺខ្ញុំអត់បានរាប់ទេ ហើយជាទូទៅលេខទង់បដិវត្តនេះមានប្រចាំខែ។ អីចឹងបើសិនជាយើងរាប់ក្នុងមួយឆ្នាំមាន១២ខែ គួរតែមាន១២លេខ ហើយយើងមាន

ពីឆ្នាំ៧៥, ៧៦, ៧៧, ៧៨។ ខ្ញុំអាចរាប់ជូនបាន បើសិនជាលោកប្រធានអនុញ្ញាត ហើយផ្ញើជូនព័ត៌មានជូនលោក។ ប៉ុន្តែយើងមានច្រើនលេខ មិនបានគ្រប់លេខទាំងអស់ទេ ហើយមានលេខខ្លះជាលេខស្ទួន។ ឧទាហរណ៍ លេខខែកុម្ភៈ អាចមានពីរបីសៀវភៅ លេខខែមករា អាចមានពីរបីសៀវភៅអ៊ីចឹងបាទ។

[១៥:២០:៣៧]

**ស៖** ឯកសារដែលត្រូវបានប្រគល់ពី ឌី.ស៊ី.ខេម ជូនមកខាងសហព្រះរាជអាជ្ញា ឬក៏ខាងសហចៅក្រមស៊ើបអង្កេត ដែលជាឯកសារទស្សនាវដ្ដីទង់បដិវត្ត ឬក៏ទស្សនាវដ្ដីយុវជន យុវនារីហ្នឹងថា តើឯកសារទាំងអស់នោះសុទ្ធតែជាឯកសារ ដែលបានចម្លងបានត្រឹមត្រូវតាមឯកសារដែល ឌី.ស៊ី.ខេម មានដែរឬទេ?

**ឆ៖** សូមបញ្ជាក់ថា យើងផ្ដល់ឯកសារមកសហព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងមកអង្គភាពការពារជនចុងចោទ ទៅតាមសំណើដែលគាត់បានសុំ។ ហើយគ្រប់សំណើទាំងអស់ នៅពេលដែលគាត់ចុះហត្ថលេខាទទួលយក យើងបានបញ្ជាក់ថា ឯកសារមួយនេះ យកចេញមកពីឯកសារចម្លងឬក៏ឯកសារដើម ហើយគ្រប់អ្នកដែលទទួលឯកសារ គឺមានចុះហត្ថលេខាទទួលយក។ អ៊ីចឹងទាំងខាងការពារជនចុងចោទក៏មាន ខាងសហព្រះរាជអាជ្ញា ក៏ខ្ញុំបានប្រគល់ជូន ខាងក្រុមសហព្រះរាជអាជ្ញាស៊ើបអង្កេត ក៏ខ្ញុំឲ្យដែរ ហើយមានទាំងខាងដល់ *ខត ម៉ាណេចមិន* ក៏បានសុំ ក៏ខ្ញុំឲ្យ។ ជាទូទៅ ខ្ញុំប្រយ័ត្នប្រយែងណាស់ ពីព្រោះថាជួនកាលមានជាបុគ្គល មានជាបុគ្គលមកធ្វើកម្មសិក្សាអ៊ីចឹង សុំខ្លួនឯងផ្ទាល់ចាប់អារម្មណ៍រូបថត រូបអីអ៊ីចឹងអ៊្លា។ អ៊ីចឹងជាទូទៅ ខ្ញុំតម្រូវឲ្យខាងតុលាការនេះ ផ្ញើសំបុត្រទៅឲ្យខ្ញុំដែលខ្ញុំប្រគល់ទៅឲ្យ ដារ៉ា អនុប្រធានខ្ញុំជាអ្នកចាត់ចែង។ អ៊ីចឹងឯកសារឲ្យទៅគ្រប់គ្នាទៅតាមសំណើរបស់គេ។

[១៥:២២:០៩]

**ស៖** តើឯកសារទាំងឡាយ ដែលប្រគល់មកហ្នឹង គឺខាង ឌី.ស៊ី.ខេម ជាអ្នកចម្លង មានការវាយសញ្ញាសម្គាល់អីលើឯកសារហ្នឹងតែម្ដង ឬក៏ជាអ្នកដែលទៅសុំឯកសារជាអ្នកចម្លងខ្លួនឯង?

**ឆ៖** មានពីរ ទាំងពីរ។ ឯកសារខ្លះ គឺយើងបានរៀបចំហើយ យើងបានប្រគល់ទៅឲ្យសហព្រះរាជអាជ្ញា។ ឧទាហរណ៍ លោកពិនិត្យមើលហើយ ក៏ចុះហត្ថលេខាទទួល ដូចជា ខាង អូ.ស៊ី.អាយ.ជេ លោក ស្ទីវ ហេដឌ័រ គាត់ទៅអង្គុយស្កេនយកខ្លួនឯងតែម្ដង។ គាត់មិនបានទុកសំណៅដែលគាត់ស្កេនហ្នឹងឲ្យខ្ញុំទេ គាត់ស្កេនហើយគាត់ត្រឡប់មក*អូហ្វហ្វីស*គាត់វិញ។ ខាងអង្គភាពការពារជនចុងចោទ ជា

ពិសេស រីឆាត គាត់ច្រើនតែទៅយកខ្លួនឯងតែម្តង ដឹកមកខ្លួនឯងតែម្តង។ ហើយមុននឹងគាត់ដឹកមក យើងបានរាប់ឲ្យច្បាស់ ឯកសារណាខ្លះ ប៉ុន្មានទំព័រអីអ៊ីចឹង ទៅតាមសំណើដែលគាត់សុំ។ ហើយមុនប្រធានរបស់គាត់មួយទៀតហ្នឹង គាត់ធ្លាប់ធ្វើអ៊ីចឹងដូចគ្នា។ អ៊ីចឹងវាទៅតាមអ្នកដែលស្នើសុំ ហើយយើងអនុញ្ញាតបើកទូលាយ គេចង់ធ្វើរបៀបម៉េចក៏បានដែរ។

[១៥:២៣:១១]

**ស៖** ឯកសារដែលប្រគល់ជូនទៅដល់ភាគីការពារក្តី លោកធ្លាប់បានមានប្រសាសន៍អំពីបញ្ហាហ្នឹង។

**ឆ៖** បាទៗ។

**ស៖** ថាតើលោកមានធ្លាប់បិទបាំងឯកសារណាមួយពីភាគីការពារក្តីដែរឬទេ?

**ឆ៖** ខ្ញុំរៀបចំការិយាល័យមួយយ៉ាងស្អាតសម្រាប់គាត់រៀងរាល់ថ្ងៃសុក្រ ទៅពេលណាក៏បាន ចង់មើលកន្លែងណាក៏បាន គ្រប់សំណើដែលគាត់សុំ ខ្ញុំឲ្យមួយរយភាគរយ ដរាបណាគាត់មិនសុំ តែបើគាត់សុំខ្ញុំឲ្យទាំងអស់។ គ្រប់ភាគីដូចគ្នាអ៊ីចឹងដែរ ខ្ញុំជម្រាបជូនលោកហើយថា ថ្ងៃចន្ទ ថ្ងៃអង្គារ គឺ សហចៅក្រមស៊ើបអង្កេត ថ្ងៃពុធ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយជាទូទៅ ខ្ញុំកម្រឃើញលោកអញ្ជើញទៅកន្លែងខ្ញុំណាស់ ខ្ញុំឃើញខាងកម្ពុជាក្រោម ឃើញគឺផ្សេងទៅវិញ ដែលទៅស្វះស្វែងធ្វើការធ្វើងារ មានទាំងលោកសង្ឃផង។ ជាពិសេស ក្រុមមេធាវីការពារក្តី រដ្ឋប្បវេណីនេះគឺមិនសូវទៅទេ។ ហើយថ្ងៃព្រហស្បតិ៍ គឺខាងសហព្រះរាជអាជ្ញា ហើយថ្ងៃសុក្រ គឺខាងមេធាវីការពារជនចុងចោទ។ អ៊ីចឹងគេទៅពេលណាស្រេចតែចិត្ត គេចង់បានអីខ្លះ ខ្ញុំជូនភ្លាម។

[១៥:២៤:១៧]

**ស៖** សំណួរខ្ញុំនៅតែពីរសំណួរចុងក្រោយទេ បន្ទាប់មក ខ្ញុំនឹងប្រគល់ជូនដៃគូរបស់ខ្ញុំដើម្បីសួរបន្តទៀត។ ខ្ញុំឆ្ងល់ពីព្រឹកមិញលោកបានមានប្រសាសន៍ថា ប្រទេសទាំងអស់សុទ្ធតែបានផ្តល់ថវិកា តែលើកលែងតែប្រទេសមួយ ថាតើមូលហេតុអី?

**ឆ៖** គឺបារាំង។ ខ្ញុំគិតថាចម្លែកដែរ បានខ្ញុំចង់និយាយព្រឹក ហើយព្រឹកមិញខ្ញុំភ្លេចនិយាយប្រទេសអាល្លឺម៉ង់។ ប្រទេសអាល្លឺម៉ង់ ក៏ធ្លាប់ជួយមជ្ឈមណ្ឌលឯកសារកម្ពុជា បោះសៀវភៅប្រវត្តិសាស្ត្របង្រៀនកម្ពុជាប្រជាធិបតេយ្យ។ ប្រទេសបារាំងហ្នឹងយ៉ាប់តែម្តង។ ខ្ញុំមិនដឹងថា ដោយសារខ្ញុំមិនចេះភាសាបារាំងច្បាស់លាស់ ឬក៏ខ្ញុំមិនយល់ណា។ អ៊ីចឹងខ្ញុំក៏មិនសូវរវីរវល់តទៅទៀតទៅ តែខ្ញុំនិយាយព្រឹក

មិញហ្នឹង ចង់បញ្ជាក់ថាប្រទេសមួយនេះ គឺជាប្រទេសមួយដែលមិនសូវអើពើទេចំពោះបញ្ហានេះ ហើយខ្ញុំមានការភ្ញាក់ផ្អើលនៅពេលដែលប្រទេសបារាំងហ្នឹង ទៅជាអ្នកដែលជា *ខូស្ពនស៊័រ* អំពីការបង្កើតតុលាការនេះទៅវិញ។ ប៉ុន្តែប្រទេសទាំងអស់សូម្បីតែប្រទេសជប៉ុន ប្រទេសគុយវ៉ែត។ សូម្បីប្រទេសគុយវ៉ែត ក៏ធ្លាប់គាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ហើយដូចជាចេះតែចង់ចំណាយពេលវេលាចេញក្រៅអង្គហេតុ ដូចមិននៅក្នុងបរិបទនៃបញ្ហាដែលអង្គជំនុំជម្រះកំណត់ឲ្យសួរដេញដោលចំពោះសាក្សីរូបនេះទេ។ កាលទាមទារពេលវេលា ទាមទារច្រើន ប៉ុន្តែការយកពេលវេលាទៅប្រើប្រាស់ដូចជាមិនមានប្រសិទ្ធភាពទេ។ ដោយសារក្នុងការព្យាយាមតាំងសំណួររកសំណួរដែលចេញក្រៅពីអង្គហេតុ ឬក៏មិនមានការពាក់ព័ន្ធទាល់តែសោះ។

[១៥:២៦:០៧]

**លោក ពេជ អង្គ៖**

បាទលោកប្រធានខ្ញុំអស់សំណួរពេលនេះហើយ។ សូមប្រគល់ សូមអនុញ្ញាតលោកប្រធានអនុញ្ញាតឲ្យដៃគូរបស់ខ្ញុំលើកសំណួរបន្ត។ សូមអរគុណ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពភាគីទាំងអស់ សូមគោរពលោក ឆាំង យុ។ សូមអរគុណដែលបានឆ្លើយតបទៅនឹងសំណួររបស់យើងខ្ញុំ។ គេបានដឹងច្បាស់ហើយពីព្រោះថា យើងមានការផ្សព្វផ្សាយឲ្យដឹងចំពោះសំណួរដែលបានសួរទៅលើលោកនៅថ្ងៃហ្នឹង។ ហើយគេដឹងថា លោកនៅទីនេះ ហើយសំណួរទាំងអស់នេះគឺថា សំណួរពាក់ព័ន្ធទៅនឹងភាពលម្អៀងរបស់ខាង ស៊ី.ឌី.ខេម ហើយនិងការទទួលយថាភាពនៃឯកសារដែលទទួលបាននៅខាង ឌី.ស៊ី.ខេម។ ដូច្នេះ ខ្ញុំនឹងនិយាយទៅកាន់បញ្ហាសំខាន់តែម្តង។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាន ហើយនិងភាពអាចជឿជាក់បាន ហើយនិងយថាភាព ហើយជាពិសេសគឺភាពមិនលម្អៀង ភាពលម្អៀងនៃខាង ឌី.ស៊ី.ខេម, លោក ឆាំង យុ! នៅពេលដែលគេសាកសួរលោកនៅថ្ងៃទី១៩ មីនា ឆ្នាំ២០០៩ ដែលខាងសហចៅក្រមស៊ើបអង្កេតបានសាកសួរសំណួរលោកក្នុងឋានៈជាប្រធាន ស៊ី.ឌី.ខេម គឺឯកសារ D150 នៅទំព័រពីរ ហើយ ERNជាភាសា

បារាំង 00291431 ERNជាភាសាអង់គ្លេស 00294420 ERN ជាភាសាខ្មែរ 00291424។ ចំពោះសំណួរទីមួយរបស់សហចៅក្រមស៊ើបអង្កេតលោកបានឆ្លើយដូចតទៅនេះ៖ "ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនចង់បានវិធានការការពារចំពោះខ្ញុំទេ គឺសម្រាប់គ្រួសារខ្ញុំនិងបុគ្គលិកខ្ញុំ។ ជាក់ស្ដែងនៅឆ្នាំ១៩៨៩ ខ្ញុំបានទទួលការគំរាមកំហែងពី អៀង ធីរិទ្ធ ហើយនិងមានការគំរាមកំហែងផ្សេងទៀត ហើយខ្ញុំបានរាយ-ការណ៍ទៅកាន់ឧត្តមស្នងការនៃសិទ្ធិមនុស្ស ហើយនិងក្រសួងមហាផ្ទៃរួចហើយ។ ហើយប្អូនស្រីខ្ញុំក៏ទទួលបាននូវការគំរាមកំហែងដូចគ្នាដែរ ពីសំណាក់ខាងទាហានដែលមិនស្គាល់អត្តសញ្ញាណមកពីខាងប៉ៃលិន។ ដូច្នេះធ្វើឱ្យខ្ញុំចង់ធ្វើការ ឈប់ការស្រាវជ្រាវឯកសារ" ហើយលោកបានបញ្ជាក់ថា "ពីម្ដាយរបស់លោកដែរ"។ ខ្ញុំមិនទាន់សួរសំណួរផង ខ្ញុំឃើញមានការជំទាស់រួចទៅហើយ។

ខ្ញុំសូមសួរសំណួរសិន លោក ឆាំង យុ តើលោកបញ្ជាក់បានទេ អំពីការអ្វីដែលលោកឆ្លើយទៅកាន់សហចៅក្រមស៊ើបអង្កេតនេះ គឺថាលោកមានបំណងចង់បញ្ឈប់ការស្រាវជ្រាវដោយសារតែមានការគំរាមកំហែងនេះ?

[១៥:២៩:២៦]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីកុំអាល់ឆ្លើយ ហើយចាំស្ដាប់ការជំទាស់ ហើយនិងអង្គជំនុំជម្រះនឹងសម្រេចបញ្ហានេះរួច សឹមលោកឆ្លើយ ឬក៏មិនឆ្លើយអាស្រ័យលើអង្គជំនុំជម្រះជាអ្នកសម្រេច។ ហើយលោកសាក្សីមកទីនេះ គឺនិយាយ លោកនិយាយឱ្យអង្គជំនុំជម្រះស្ដាប់ អ៊ីចឹងលោកគប្បីងាកមកក្នុងន័យថា និយាយឱ្យ ផ្ដល់ព័ត៌មានឱ្យអង្គជំនុំជម្រះ ពិតមែនតែភាគីដទៃឮហើយ ប៉ុន្តែបំណងច្បាស់លាស់ហ្នឹងគឺអង្គជំនុំជម្រះអ្នកយកទៅគិតពិចារណានូវសក្ខីកម្មរបស់សាក្សី របស់អ្នកផ្សេងទៀតដែលផ្ដល់សក្ខីកម្មនៅទីនេះដើម្បីពិចារណាក្នុងការស្វែងរកការពិតនៅក្នុងរឿងក្ដីនេះ។

សូមអញ្ជើញលោកមេធាវី កាណាវាស!

**មលោក ម៉ៃខល កាណាវាស៖**

សូមអរគុនលោកប្រធាន លោក លោកស្រីចៅក្រម សូមអភ័យទោសម្ដងទៀត ដោយខ្ញុំកាត់។ ខ្ញុំជឿថា នេះគឺជាសំណួរដែលមិនពាក់ព័ន្ធទេ ពីម្សិលមិញនោះ គឺយើងបានទទួលដំណឹងពីតុលាការអ្វីៗដែលយើងធ្វើត្រូវតែស្របទៅតាមនីតិវិធី។ ការធ្វើសវនាការស្ដាប់សក្ខីកម្មរបស់លោក ឆាំង យុ គឺថានិយាយអំពីវិធីសាស្ត្រក្នុងការទទួលបាន ការកំណត់ធ្វើកាតាឡុក ហើយនិងការគ្រប់គ្រងឯកសារ ការ

បែងចែកឯកសារផ្សេងៗនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះហើយគឺថាយើងពិនិត្យមើលលើបញ្ហានោះ។

[១៥:៣០:៥៤]

សំណួរដែលគាត់សួរពេលនេះ ដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បែរជាសួរពីមូលហេតុដើមវិញ។ ប៉ុន្តែគាត់ទៅសួរ ឬក៏សំណួរដែលចម្លើយដែលគាត់បានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតទៅវិញ។ ហើយដែលថាដើម្បីឲ្យឃើញថាគាត់ចង់ផ្អាកសកម្មភាពការងាររបស់គាត់ ដោយសារថាមានហេតុការណ៍ហ្នឹង។ ក៏ប៉ុន្តែបើយើងពិនិត្យមើលករណីនេះ គាត់មិនមែនជាអ្នកស៊ើបអង្កេតទេ គាត់មិនមែនជាអ្នកបានស៊ើបអង្កេតរឿងហ្នឹងទេ។ គាត់គ្រាន់តែរកឯកសារ ដើម្បីធ្វើកាតាឡុក ដើម្បីគោលបំណងអ្នកផ្សេង ដើម្បីប្រើប្រាស់សិក្សាស្រាវជ្រាវ ក៏ប៉ុន្តែភាគីម្ខាង គឺថាយកឯកសាររបស់សហចៅក្រមស៊ើបអង្កេតយកមកប្រើនៅទីនេះ គឺនៅក្រៅវិសាលភាព។ ដូច្នេះហើយ ខ្ញុំជំទាស់បញ្ហានេះ បើមិនដូច្នោះទេ នឹងបន្តទៅនឹងគឺថាអាចក្នុងសវនាការទាំងមូលនេះ គឺថាយើងនឹងមិនយកចិត្តទុកដាក់អំពីការណែនាំរបស់អង្គជំនុំជម្រះនោះ ដែលថាចង់ឲ្យយើងអនុវត្តឲ្យស្របតាមហ្នឹង។ សូមអរគុណលោកប្រធាន អង្គសវនាការ។

[១៥:៣២:១៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី! មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត៖**

អរគុណលោកប្រធាន។ មុននឹងចៅក្រមពិភាក្សាគ្នា ខ្ញុំចង់ឆ្លើយតបចំណុចពីរ។ ទីមួយបញ្ហានីតិវិធី ច្បាស់ណាស់គឺថា ហើយអង្គជំនុំជម្រះក៏បានបញ្ជាក់ដែរ ថាយើងអាចប្រើប្រាស់កំណត់ហេតុសួរសំណួរសួរចម្លើយដោយសហចៅក្រមស៊ើបអង្កេតបាន ចំពោះសាក្សីដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ហើយការកត់សម្គាល់ទីពីររបស់ខ្ញុំនោះ គឺថាអ្វីដែលយើងខ្ញុំកំពុងតែធ្វើនោះ ហើយអ្វីដែលគេដឹងច្បាស់ទាំងអស់គ្នានេះ គឺថាសួរសំណួរពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារ។ ហើយនៅពេលដែលធ្វើបែបនេះ ខ្ញុំគិតថាវាមានសារៈសំខាន់ណាស់ក្នុងការដឹងថាតើនៅពេលណាផ្សេងទៀត គឺថាមានអ្នកផ្សេងគឺថាចង់ឲ្យបានថា គឺថាឯកសារមាននៅក្នុង ឌី.ស៊ី.ខេម ត្រូវតែមាននៅក្នុងសំណុំរឿងគឺថាជាអ្វីដែលយើងចង់បាននៅថ្ងៃនេះ។

[១៥:៣៣:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោក លោកស្រីចៅក្រម យើងឯកភាព ដែលយើងអាចយកកំណត់ហេតុពី ក.ស.ច មកធ្វើការពិនិត្យដេញដោល។ ក៏ប៉ុន្តែយើងស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុដែលយើងតាំងសំណួរ។ មិនមែនថាសក្ខីកម្មដែលសួរ និងកត់ត្រាដោយ អូ.ស៊ី.អាយ.ជេ នោះ គឺយក គួរតែយកមកសួរទាំងអស់នោះទេ យើងត្រូវតែកម្រិតទៅលើវិសាលភាពនៃអង្គហេតុ។ អ្វីដែលលោកឡើងសួរនៅពេលនេះ គឺមិនពាក់ព័ន្ធ។ ខ្ញុំយល់នូវបំណងដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចង់ធ្វើ ក៏ប៉ុន្តែអ្វីដែលធ្វើនេះ វាការគំរាមកំហែង និងធ្វើឲ្យប៉ះពាល់ទៅដល់សុចរិតភាព និងភាពជឿជាក់នៃឯកសារ។ ដូច្នេះគឺគាត់ព្យាយាមធ្វើយ៉ាងណាបំភិតបំភ័យសាក្សីរូបនេះ ហើយនិងស្ថាប័នរបស់គាត់ ដើម្បីកុំឲ្យទទួលយកឯកសារ។ កាលពីសប្តាហ៍មុន មេធាវី នួន ជា បានលើកបញ្ហានៃការជ្រៀតជ្រែកនយោបាយ ហើយវាជាចំណុចមួយដែលវាក្រៅវង្វង់ដែលខ្ញុំមិនចង់លើកឡើង។ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ហើយបញ្ហាទាំងអស់នេះ មិនចង់យកមកដេញដោលនៅទីនេះទេ។ មិនថា០៣, ០៤ វាពាក់ព័ន្ធយ៉ាងម៉េចទៅនឹងសំណុំរឿង០០២ នោះឡើយ។ ករណីពាក់ព័ន្ធទៅនឹងសំណុំរឿងទាំងពីរក្រោយនោះ គឺវាមិនពាក់ព័ន្ធនៅក្នុងអង្គហេតុនេះទេ។

[១៥:៣៤:៤៤]

ដូច្នេះ យើងខ្ញុំសូមលើកឡើងជំហរថា កុំឲ្យថាមេធាវីការពារក្តីជាអ្នកជ្រៀតជ្រែកទៅលើស្ថាប័ន ឌី.ស៊ី.ខេម ដែលថាឯកសារទាំងអស់មិនអាចយកមកប្រើបានទេ ដោយសារឯកសារទាំងនោះ វាមិនសមរម្យ។ ចម្លើយដែលបានផ្តល់ជូនដោយសាក្សីរូបនេះទៅដល់ ក.ស.ច.ស នោះគឺវាពាក់ព័ន្ធទៅនឹងចំណុចនេះ។ ក៏ប៉ុន្តែវាមិនពាក់ព័ន្ធនោះទេ។ ប៉ុន្តែអ្វីដែលយើងមកដេញដោលនៅទីនេះគឺថាឯកសារទាំងអស់នោះ វាមានយថាភាព ភាពទុកចិត្ត និងពាក់ព័ន្ធដែរឬទេ សម្រាប់ការជំនុំជម្រះរបស់យើង។ ហើយអង្គហេតុដែលវានៅក្រៅវង្វង់ នៃផ្នែកដំណាក់កាលដំបូងនោះ គឺវាជាការខាតបង់ពេលវេលាឥតប្រយោជន៍។ ដូច្នេះខ្ញុំគិតថា ប្រសិនបើយើងព្យាយាមធ្វើដូចដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយើងហាក់ដូចជារទេះភ្លើងដែលវាចូលខុសបេនអីចឹង។ ដូច្នេះយើងនឹងធ្វើអ្វីមិនគោរពទៅតាមការបង្គាប់

បញ្ហា។ សូមអរគុណ។

[១៥:៣៥:៥៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ជាដំបូងនេះគឺថា ខ្ញុំមិនមានធ្វើអីបញ្ជាក់អីនោះទេ ខ្ញុំគ្រាន់តែអាននៅកំណត់ហេតុដែលមាននៅក្នុងសំណុំរឿង។ ហើយចំពោះខាងមេធាវីការពារក្ដីដែលថា ចង់ឲ្យខ្ញុំធ្វើបែបនេះ ខ្ញុំមានការសោកស្ដាយណាស់ ខ្ញុំនឹងចូលទៅសំណួរផ្សេងទៀត។ ចំពោះខ្ញុំអត់មានបញ្ហាអ្វីទេ ខ្ញុំគ្រាន់តែអាននូវសេចក្ដីថ្លែងការណ៍របស់សាក្សីតែប៉ុណ្ណោះ។ ខ្ញុំគិតថាវាពាក់ព័ន្ធនឹងរឿង នឹងបញ្ហាហ្នឹង ប៉ុន្ដែមិនមានការរំខានអីដល់ខ្ញុំទេ ខ្ញុំអាចចូលទៅសំណួរផ្សេងទៀតបាន ប្រសិនបើលោកប្រធានអនុញ្ញាតនោះ។

[១៥:៣៦:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៩:០៧]

**ប្រធានអង្គជំនុំ៖**

ក្រោយពីពិភាក្សានៅក្នុងចំណោមសមូហភាពចៅក្រមនៃអង្គជំនុំជម្រះ អង្គជំនុំជម្រះសម្រេចបដិសេធនូវការជំទាស់របស់មេធាវីការពារក្ដី ហើយលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអាចសួរសំណួរអម្បាញ់មិញនេះបន្ថែមទៀត បន្តទៀត បើសិនជាមានបំណងបន្តសំណួរ។ ហើយដោយសារបញ្ហានេះ ក៏មានការពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការប្រព្រឹត្តទៅនៃសកម្មភាពរបស់ ឌី.ស៊ី.ខេម ដែរ។

[១៥:៣៩:៤៤]

ហើយដោយសារមានការជំទាស់តវ៉ា ហើយមានការខាតពេលវេលានោះ អង្គជំនុំជម្រះនឹងបន្ថែមពេលវេលាប្រាំមីនុត សម្រាប់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោក ឆាំង យុ ខ្ញុំបានសួរលោកថា តើលោកបញ្ជាក់អះអាងទេនូវអ្វីដែលលោកបាននិយាយនោះ គឺជាពិសេសគឺថានៅក្នុងឃ្លាដែលថា គឺថាមានការគំរាមកំហែងដើម្បីឲ្យខ្ញុំឈប់ធ្វើការស្រាវជ្រាវនៅ ឌី.ស៊ី.ខេម។ តើលោកបញ្ជាក់ពីឃ្លានេះបានទេ?

**ឆៈ** ទីមួយ ខ្ញុំអត់មានប្អូនស្រីទេ។ ប្រហែលជាមានការបកប្រែខុស។ ខ្ញុំមានតែបងស្រី ខ្ញុំជាកូនពៅ អ៊ីចឹងខ្ញុំអត់មានប្អូនស្រីទេ។ ក្នុងន័យនេះ គឺជាបងស្រីខ្ញុំ។ ហើយមានការគំរាមកំហែងបងស្រីខ្ញុំមែន ដែលឲ្យបងស្រីខ្ញុំមកប្រាប់ខ្ញុំឲ្យខ្ញុំបញ្ឈប់ មិនមែនខ្ញុំចង់ឈប់ទេ ព្រោះអ្នកគំរាមកំហែងបានប្រាប់បងស្រីខ្ញុំ ថាឲ្យខ្ញុំនេះបញ្ឈប់ការសិក្សាស្រាវជ្រាវទៅ។ ហើយសូមបញ្ជាក់ថា ការសិក្សាស្រាវជ្រាវនោះដើម្បីការផ្សះផ្សានេះ មិនមែនជារឿងប្រលោមលោកទេ គឺជារឿងសំខាន់សម្រាប់ប្រទេសកម្ពុជា។

**សៈ** លោក ឆាំង យុ តើលោកគិតថាការងាររបស់ ឌី.ស៊ី.ខេម គឺការងារស្រាវជ្រាវ និងប្រមូលឯកសារ តើអាចមានការផ្ដល់ការរំខានដល់មនុស្សមួយចំនួនដែរឬទេ ខ្ញុំមិនចង់បញ្ជាក់ឈ្មោះទេ គ្រាន់តែថាតើមានការរំខានដល់មនុស្សមួយចំនួនដែរឬទេ?

[១៥:៤១:១៨]

**ឆៈ** មានអ្នកខ្លះមិនពេញចិត្តដែរ ព្រោះយល់ថារឿងនេះ ជារឿងយូរអង្វែង ហើយក៏គ្មានកើតឡើងនៅក្នុងចំណោមអង្គការសង្គមស៊ីវិលដែរ ដែលគិតថារឿងនេះ មិនមែនជារឿងចាំបាច់ មិនមែនជារឿងប្រឈមមុខ។ ហើយអ៊ីចឹង ក៏មានការធុញទ្រាំដែរ។

**សៈ** សូមអរគុណ។ ឌី.ស៊ី.ខេម ហើយនិងលោកផ្ទាល់ គឺបានប្រកាសជាសាធារណៈជាច្រើនលើកច្រើនសាថា ធ្វើការតស៊ូប្រឆាំងនិទណ្ឌភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយនិងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ តើលោកគិតថាការប្ដេជ្ញាបែបនេះ អាចជះឥទ្ធិពលតាមរបៀបណាមួយ ទៅលើយថាភាពនៃឯកសារដែលលោកប្រមូលបាននេះដែរឬទេ? ឬក៏ទៅលើភាពដែលអាចជឿជាក់បាននៃឯកសារម្យ៉ាងវិញទៀត តើការប្ដេជ្ញាចិត្តបែបនេះ គឺអនុញ្ញាតឲ្យលោកធ្វើការ ដូចថាមានការខុសពីអ្វីដែលលោកពីគោលការណ៍នៃការស្រាវជ្រាវរបស់លោកដែរឬទេ?

[១៥:៤២:៣៤]

**ឆៈ** ខ្ញុំគិតថា ការសម្រេចចិត្តរបស់យើងក្នុងការទប់ស្កាត់អំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ អំពើផ្សេងៗនេះ គឺជាការសម្រេចចិត្តមួយដែលយើងមិនបានកែប្រែទេ។ ហើយយើងយល់ថាការធ្វើបែបនេះ គឺវាឈានជួយទៅដល់ការចងចាំ ការទប់ស្កាត់ ហើយនិងការផ្សះផ្សាជាតិ។ វាមិនអាចប៉ះពាល់ដល់ឯកសារទេ ដោយសារថាឯកសារយើងយកមក ដូចខ្ញុំប្រាប់ទៅខាងសហព្រះរាជអាជ្ញាអ៊ីចឹង គឺយើងយកមកយ៉ាងដូចម្ដេច គឺយើងរក្សាដូចធម្មតា ហើយយើងបើកជូនឲ្យសាធារណជនធ្វើការស្វែងយល់ទាំងអស់គ្នា។ មូលហេតុហ្នឹងហើយ បានខ្ញុំប្រើពាក្យថា ស្វែងរកការពិតទាំងអស់គ្នា ពីព្រោះថាវាត្រូវ

ការមនុស្សជាច្រើនចូលរួម ដើម្បីដឹងពីបញ្ហានេះ។ អ៊ីចឹងកិច្ចការរបស់យើង គឺប្រមូលឯកសារ និងចែកចាយឯកសារទៅវិញ។ ដូចជាយើងឲ្យមកតុលាការអ៊ីចឹងដែរ។

[១៥:៤៣:២៥]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកបានមានប្រសាសន៍ថា ជារឿងធម្មតាទេ ក្នុងការស្រាវរកនូវកន្លែងមួយចំនួន ហើយលោកបានលើកឡើងអំពីទួលស្លែង នៅឯកសារមួយចំនួនដែលអាចរកបាននៅកន្លែងផ្សេង។ ឧទាហរណ៍ដូចថា អាចមកពីខាងក្រសួងពាណិជ្ជកម្ម ឬក៏មកពីស្រុក។ ចំពោះទស្សនៈ វិជ្ជាជីវៈលោកផ្ទាល់ តើលោកមានការពន្យល់បែបនេះ ចំពោះបញ្ហានេះទេ?

**ឆ៖** ខ្ញុំស្ដាប់សំណួរអត់សូវបាន។ សូមទោសបាទ។

**ស៖** ខ្ញុំសួរលោកថា តើលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាឯកសារមួយចំនួនដែលមកពីស្រុក ឬក៏មកពីក្រសួងពាណិជ្ជកម្មនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរកឃើញនៅកន្លែងផ្សេងទៅវិញ ហើយលោកបាន អម្បាញ់មិញនេះលោកបាននិយាយថា គឺបានរកឃើញនៅ ឧទាហរណ៍ដូចជានៅទួលស្លែងជាដើម។ តើហេតុអ្វីបានជាបែបនេះទៅវិញ?

**ឆ៖** ខ្ញុំថានៅក្នុងរបបនោះ មានការជជែកគ្នា មានការឆ្លើយឆ្លងពីស្ថាប័នមួយទៅស្ថាប័នមួយ មានសេចក្ដីរាយការណ៍។ ហើយដូចឃើញស្រាប់ហើយថានៅក្នុងឯកសារដែលយើងនិយាយនេះ ចំណងជើងវា មានន័យថា "សេចក្ដីរាយការណ៍" អ៊ីចឹងបានន័យថានៅក្នុងស្ថាប័នមួយ ដូចជាក្រសួងពាណិជ្ជកម្មហ្នឹង អាចមានបញ្ហាអ្វីមួយកើតឡើងនៅក្នុងសមាជិករបស់ខ្លួន ហើយបានធ្វើសេចក្ដីរាយការណ៍ទៅកាន់កន្លែងមួយទៀត។ អ៊ីចឹងឯកសារនេះ វានៅកន្លែងផ្សេងៗ។

[១៥:៤៥:០៨]

**ស៖** តើលោកធ្លាប់ដែលបានរកឃើញឯកសារ ដែលថាមានលក្ខណៈខូចខាតខ្ទេចខ្ទីខ្លាំងដែរឬទេ?

**ឆ៖** មានដែរ មានឯកសារខ្លះ វាពុកផុយ បាទ វាពុកផុយ ហើយយើងមានក្រុមជំនាញដើម្បីជួសជុល។ ប៉ុន្តែជាទូទៅ យើងមិនបានជួសជុលទេ យើងរក្សាធាតុដើមរបស់វា។ នៅបណ្ណសារដ្ឋានជាតិមានអ្នកជំនាញខាងជួសជុលឯកសារ ហើយដោយយើងគិតថា ការជួសជុលឯកសារនេះ តម្រូវឲ្យមានការកត់ត្រាទុក អ្នកប៉ះពាល់ អ្នកជួសជុល។ អ៊ីចឹង ជាទូទៅ កាលណាឯកសារឃើញមកដាច់រហែកយ៉ាងដូចម្ដេច យើងទុកដូចដើមវិញអ៊ីចឹង។

**ស៖** សូមអរគុណ។ នៅពេលដែលលោករកឃើញឯកសារ ឬក៏គេបានប្រគល់ឯកសារជូន

លោកនោះ គឺថាឯកសារដែលថាមិនមានពាក់ព័ន្ធទៅនឹងជនជាប់ចោទនៃរឿងក្ដីនោះទេ ក៏ប៉ុន្តែមានពាក់ព័ន្ធទៅនឹងកម្ពុជាប្រជាធិបតេយ្យ។ តើលោក-- ខ្ញុំនិយាយអំពី ឌី.ស៊ី.ខេម តើលោកចាត់ទុកឯកសារនេះថាវាមានផលប្រយោជន៍ ហើយលោកយកគិតគូរដល់ឯកសារទាំងអស់នេះដែរឬទេ?

**ឆៈ** ឯកសារទាំងអស់ដែលកើតឡើងក្នុងរយៈពេល រយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ យើងគិតថា វាជាឯកសារសំខាន់ជាប្រវត្តិសាស្ត្រ សូម្បីតែមួយសន្លឹក សូម្បីតែមួយឃ្លា សូម្បីតែរូបមួយថតសន្លឹក។ អ៊ីចឹង ដូច្នេះឲ្យតែអ្វីកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងចំណោមប្រភេទឯកសារទាំងប្រាំ យើងប្រមូលទាំងអស់។ អ៊ីចឹងហើយបានយើងចំណាត់ថ្នាក់ឯកសារទាំងអស់នេះដោយសារមានឯកសារខ្លះទៀត និយាយអំពីរឿងស្លូងស្រូវ ឯកសារខ្លះទៀតនិយាយអំពីរឿងទឹកជំនន់ ឯកសារខ្លះទៀត និយាយពីរឿងអីផ្សេងៗ។ ប៉ុន្តែចំពោះយើង នេះជាបំណែកនៃប្រវត្តិសាស្ត្រដែលយើងយកមកផ្គុំគ្នា។ អ៊ីចឹងឯកសារណាមួយនៅក្នុងរបបនេះ គឺត្រូវតែមានសារៈសំខាន់ជាប្រវត្តិសាស្ត្រសម្រាប់យើងទាំងអស់គ្នា។

[១៥:៤៧:២០]

**សៈ** លោកប្រហែលជាបានឆ្លើយទៅនឹងសំណួរខាងមុខនេះខ្ញុំហើយ នៅពេលដែលគេស្នើឯកសារមកឲ្យលោក ឬក៏លោកបានរកឃើញនូវឯកសារដែលលើកសរសើរអំពីកម្ពុជាប្រជាធិបតេយ្យថាជារបបដែលល្អឥតខ្ចោះនោះ។ ចំពោះលោក តើលោកគិតពិចារណា-- ប្រមូលយកឯកសារទាំងអស់នោះដែរឬទេ?

**ឆៈ** មានច្រើនឯកសារប្រភេទនេះ។ ជាឯកសារនិយាយអំពីភាពថ្កុំថ្កើង ភាពរុងរឿង មហាលោតផ្លោះ មហាអស្ចារ្យនៃរបបកម្ពុជាប្រជាធិបតេយ្យ។ យើងបានប្រមូលចម្រៀង។ ចម្រៀងកម្ពុជាប្រជាធិបតេយ្យ យើងប្រមូលបានជាងមួយរយ ហើយចម្រៀងទាំងអស់នេះ គឺពីរោះៗស្ដាប់ភ្លេងខ្មែរ ហើយប៉ុន្តែសុទ្ធតែនិយាយអំពីការល្អរបស់កម្ពុជាប្រជាធិបតេយ្យ។ ចំពោះយើង គឺវាមានសារៈសំខាន់សម្រាប់ប្រវត្តិសាស្ត្រ ដើម្បីឲ្យក្មេងបានយល់ថា កាលជំនាន់នេះ ចម្រៀងវាយ៉ាងម៉េច។ សូម្បីតែសម្លៀកពាក់ក៏យើងបានប្រមូលដែរ អំពីកាល ពីជំនាន់ៗកម្ពុជាប្រជាធិបតេយ្យ។

[១៥:៤៨:២៣]

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីវិភាគទានរបស់លោកចំពោះអង្គជំនុំជម្រះ ហើយនិងភាគីដែលមានវត្តមាននៅទីនេះ។ គឺមានដូចជាសហព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណី

ហើយនិងក្រុមមេធាវីការពារក្តីទាំងបួន ប៉ុន្តែនៅថ្ងៃនេះ គឺយើងមានឃើញតែបីក្រុមទេ ខាងមេធាវីការពារក្តី។ អម្បាញ់មិញនេះ លោកបានមានប្រសាសន៍ថា គ្រប់ភាគីទាំងអស់អាចទៅរកឯកសារបាន ឬក៏ទៅពិគ្រោះយោបល់ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលោកបានមានប្រសាសន៍ថា ភាគីទាំងអស់ហ្នឹង គឺថាមានមួយថ្ងៃក្នុងមួយសប្តាហ៍។ ហើយលោកអនុប្រធានរបស់លោក ក៏បាននិយាយដែរកាលពីសប្តាហ៍មុននោះ។ ដូច្នេះ តើលោកអាចចង្អុលបង្ហាញបានទេ ថាតើមានឯកសារប្រហែលប៉ុន្មានដែរ ដែលលោកបានប្រគល់ជូនមេធាវីការពារក្តី?

[១៥:៤៩:២៤]

**ឆ៖** ខ្ញុំមានបញ្ជីនៅការិយាល័យ ប៉ុន្តែខ្ញុំអាចចាំបានខ្លះៗ។ ខ្ញុំចាំថាឯកសារពាណិជ្ជកម្មទាំងអស់ គឺខាងក្រុមមេធាវីការពារក្តីបានសុំទាំងស្រុង បានសុំឯកសារផ្សេងៗឲ្យខ្ញុំជួយរកឯកសារផ្សេងៗ រួមទាំងឯកសារមួយដែលខ្ញុំចាំ គឺឯកសារទាក់ទងនឹងរបាយការណ៍របស់ទីភ្នាក់ងារអភិវឌ្ឍន៍សហរដ្ឋអាមេរិក យូ.អេស.អេ.អាយ.ឌី ឆ្នាំ៧៥ អំពីការអត់ឃ្លាននៅក្នុងសម័យកម្ពុជា-- នៅក្នុងឆ្នាំ៧៥ បានសុំឯកសារទូរលេខដែលអះអាងថា បាត់នៅក្នុងសំណុំរឿង បានសុំឯកសារណាទាំងអស់ដែលទាក់ទងនឹងកូនក្តីរបស់ខ្លួន។ ហើយខ្ញុំបានសុំឯកសារអំពីរណ្តៅសាកសពទូទាំងប្រទេស សុំឯកសារជាច្រើនទៀត ដែលខ្ញុំជូនជាតួលេខជាក់ស្តែងនៅក្នុងថ្ងៃស្អែក បើសិនជាអង្គជំនុំជម្រះត្រូវការ។ ហើយនៅការសំណើនេះ គឺសុទ្ធតែមានលិខិតស្នាមមកក្រុមការពារក្តី ហើយខ្ញុំជូនទាំងស្រុង បាទជូនទាំងស្រុង។

[១៥:៥០:២១]

ចំពោះថា នៅក្នុងការិយាល័យរបស់ខ្ញុំមិនមែនពិភាក្សារឿងឯកសារទេ គឺគេមកធ្វើការរបស់គេ។ គ្រាន់តែពេលខ្លះគេសួរថា រកអាចនៅកន្លែង ទូណាមួយអីចឹង ហើយជាទូទៅលោក ផេសមិន ក៏ឧស្សាហ៍អញ្ជើញទៅដែរជាមួយលោក អាន់ឌ្រូ គាត់សួរពីរឿងតុទូកៅអីខ្ញុំទិញនៅកន្លែងណាអីអីចឹង ក៏មានដែរ។ គាត់ចង់ទិញសម្ភារដូចខ្ញុំប្រើប្រាស់ដោយក៏មានដែរ។ អីចឹង វាមិនមែនជារឿងពិភាក្សារឿងឯកសារទាល់តែសោះ ពីព្រោះគេមានកិច្ចការរៀងៗខ្លួនរបស់គេ។ គេធ្វើការក្រុមរបស់គេបាទ។

**ស៖** សូមអរគុណលោក ឆាំង យុ។ ខ្ញុំមិនចង់បានចំនួនពិតប្រាកដទេ គ្រាន់តែថាលោកបាននិយាយថា គឺច្រើន។ លោក វ៉ាន់ថាន់ ដាភៅ ជាអនុប្រធានរបស់លោក កាលពីសប្តាហ៍នោះ នៅជាសាធារណៈ គាត់បាននិយាយថា នៅពេលដែលមានភាគីទៅទស្សនកិច្ចនៅទីនោះ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា បុគ្គលិករបស់ ឌី.ស៊ី.ខេម គឺណែនាំតម្រង់ទិសការស្រាវជ្រាវឯកសារ ហើយនិងផ្តល់

ការពន្យល់ពាក់ព័ន្ធទៅនឹងឯកសារដែលស្វែងរក។ តើលោកអាចបញ្ជាក់ពីចំណុចនេះបានទេ?

[១៥:៥១:៣៦]

**ឆ៖** បាទ ជាទូទៅ យើងជម្រាបគាត់ ថាឯកសារទូនេះអក្សរ “L” អក្សរ “D” នៅកន្លែងណា? បើសិនជាគាត់សួរថា ឥឡូវចង់បាន-- ឧទាហរណ៍ដូចជា គាត់ចង់បានឯកសារទាក់ទងនឹងក្រាំងតាចាន់ ឧទាហរណ៍អ៊ីចឹង យើងប្រាប់ថានៅទូមួយនេះ ឬក៏គាត់ចង់ថា ឯកសាររកឈ្មោះនេះ យើងឲ្យគាត់ទៅរកឯកសារ “I” ឬក៏យើងបង្ហាញឯកសារ។ ព្រោះនៅមជ្ឈមណ្ឌលឯកសារមានបញ្ជីឯកសារជាសន្លឹកដែលគាត់អាចបើកមើលខ្លួនឯងក៏បាន។ ហើយជាទូទៅដូចខ្ញុំប្រាប់ពីខាងដើមអ៊ីចឹង គឺមិនអាចអ្នកណាម្នាក់ឲ្យត្រូវបានប្រគល់សោឲ្យទៅបើកទូដោយគ្មានការអនុញ្ញាតអំពីលោក ដារ៉ា ឬក៏សមាជិករបស់ខ្ញុំទេ។

អ៊ីចឹងមុននឹងពេលចង់បានឯកសារហើយ គឺថាយើងប្រាប់មក ដារ៉ា ថាឥឡូវខាងក្រុមមួយនេះគេចង់បានឯកសារនេះ បានគាត់ទៅចាក់សោយកមកជូន។ ហើយយកមកជូននេះ គឺយើងរាប់ចំនួនថាឯកសារមានប៉ុន្មានដែលគេចង់ត្រូវការអាន ហើយពេលអានចប់ហើយត្រូវយកប្រគល់មកឲ្យអ្នកដែលកាន់សោយកទៅដាក់ក្នុងទូវិញ។ ហើយនេះជាការណែនាំ។ ហើយយើងណែនាំទៀតថា កុំឲ្យយកម្ហូប ឬក៏កូកាកូឡាទៅហូបនៅកន្លែងធ្វើការ ព្រោះជាទូទៅគាត់ច្រើនយកអាហារទៅជាមួយដែរ។ អ៊ីចឹងយើងមើលតាំងពីសណ្ដាប់ធ្នាប់ឡើង។

[១៥:៥២:៤៧]

**ស៖** សូមអរគុណ។ លោក វ៉ាន់ថាន់ ដារ៉ា ក៏បាននិយាយមកផងដែរថា គឺថាភាគីទាំងអស់ទទួលបាននូវការប្រព្រឹត្តយ៉ាងស្មើភាពគ្នាទាំងអស់។ តើលោកយល់ស្របទៅចំពោះអ្វីដែលលោក ដារ៉ា បាននិយាយទេ?

**ឆ៖** នៅក្នុងការស្នើសុំឯកសារ ខ្ញុំគិតថា ស្មើគ្នា។ បានន័យថា ពេលសុំយើងឲ្យដូចគ្នា។ អ៊ីចឹងនៅក្នុងន័យហ្នឹង គឺស្មើគ្នា ពេលដែលខ្ញុំបានទទួលលិខិតពីក្រុមការពារជនជាប់ចោទ លិខិតពីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ពីសហព្រះរាជអាជ្ញា គឺយើងឲ្យដូចគ្នា។ យើងមិនបានគិតថា មិនឲ្យអ្នកនេះ ឬឲ្យអ្នកនោះទេ។ អ៊ីចឹងនៅក្នុងន័យការប្រគល់ឯកសារ គឺស្នើសុំ គឺឲ្យដូចគ្នា។

**ស៖** អរគុណ។ ខ្ញុំនៅសល់សំណួរមួយចំនួនទៀត ពាក់ព័ន្ធនឹងការសុំឯកសារដើមដោយភាគី។ នៅពេលនេះខ្ញុំចង់បង្ហាញវេបសាយមួយ ដែលខាងមេធាវីការពារក្ដីបានបង្ហាញកាលពីសប្ដាហ៍មុន។

ដូច្នេះ ខ្ញុំគិតថាខ្ញុំមានសិទ្ធិដូចគ្នាដែរក្នុងការបង្ហាញវេបសាយនេះ ហើយនៅលើវេបសាយនេះ ខ្ញុំចង់បង្ហាញអំពីសៀវភៅណែនាំ ឬក៏របៀបណែនាំដែលនិយាយថា តើយើងត្រូវធ្វើម៉េចដើម្បីឲ្យទទួលបានឯកសារដើម ឬក៏ឯកសារថតចម្លងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ដូច្នេះខ្ញុំសូមអនុញ្ញាតលោកប្រធានឲ្យបង្ហាញឯកសារនេះនៅលើអេក្រង់។

[១៥:៥៤:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ដូច្នេះសូមឲ្យបង្ហាញឯកសារនេះនៅលើអេក្រង់។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោក ឆាំង យុ តើលោកអាចបញ្ជាក់អះអាងទេថា មានសៀវភៅណែនាំអំពីនីតិវិធីក្នុងការផ្ដល់ឯកសារចម្លង និងច្បាប់ដើមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺថាមាននៅក្នុងវេបសាយ របស់លោក?

**ឆ៖** ការពិតមិនមានទេ។ បាទ នេះគឺជាឯកសារមួយដែលធ្វើឡើងដោយកម្មសិក្សាអ្នកច្បាប់ម្នាក់ សព្វថ្ងៃជាសាស្ត្រាចារ្យច្បាប់នៅសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ២០០៦។ ២០០៥ ខ្ញុំបានធ្វើដំណើរទៅអង្គការសហប្រជាជាតិ ហើយបានជួបអ្នកស្រី មីសែលលី ហើយនិងបានជួបជាមួយនឹងលោក ស៊ាន វិសុទ្ធ នៅពេលនោះ ហើយបានជម្រាបតុលាការថា ចាំបាច់យើងត្រូវមានកិច្ចព្រមព្រៀងមួយរវាងតុលាការ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីប្រមូល ឬក៏ស្នើសុំឯកសារ។

[១៥:៥៥:៣៣]

យើងបានព្យាយាមសូមឲ្យមានចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងនេះអស់រយៈពេលបីឆ្នាំ។ ដូច្នេះ ដោយគ្មានការឆ្លើយតបពីតុលាការក៏យើងហាក់ដូចជាទាត់ចោលគំនិតនេះ ហើយជាទូទៅយើងក៏បានជម្រាបទៅខាងសហព្រះរាជអាជ្ញា និងខាងការិយាល័យរដ្ឋបាលដែរ ថាដើម្បីសម្រួលការសិក្សាការសុំឯកសារគួរតែមានឯកសារនេះ។ អ៊ីចឹងឯកសារនេះ យើងបានធ្វើឡើងដើម្បីដាក់ជូនមកខាង អ.វ.ត.ក ដើម្បីធ្វើជាកិច្ចព្រមព្រៀងមួយជាៗការយល់ដឹងទាំងសងខាង។ ប៉ុន្តែឯកសារនេះ មិនត្រូវបាន

ខាងអ.វ.ត.ក ទទួលយកទេ។ អ៊ីចឹងខ្ញុំក៏ដាក់ផុសនៅលើវេបសាយដើម្បីជាការណែនាំ ជាការរំឭកខ្លួនឯង ដើម្បីជាការងាកទៅរក បើសិនបើជាមានសំណួរផ្សេងៗ។

[១៥:៥៦:១៦]

ហើយឯកសារនេះខ្ញុំព្យាយាមសរសេរសំបុត្រមកអ្នកស្រី មីសែលលី, លោក ស៊ាន វិសុទ្ធ ហើយជូនទៅអង្គការសហប្រជាជាតិតាំងពីឆ្នាំ២០០៥, ២០០៥, ២០០៧, ២០០៨ រហូតដល់ឆ្នាំ២០០៩ យើងក៏បោះបង់គំនិតនេះ ថាមើលទៅតុលាការប្រហែលជាមិនធ្វើកិច្ចព្រមព្រៀងណាមួយក្នុងការប្រមូលឯកសារទេ។ នៅក្នុងពេលជាមួយគ្នានេះ យើងបន្តឲ្យឯកសារដោយមិនមានប្រើប្រាស់វិធីសាស្ត្រនេះទេ។ នេះ គឺធ្វើឡើងដោយ អាលីហ្សា ខាំហ៊ី ជានិស្សិតមកពីសាកលវិទ្យាល័យហារ៉ើដ។

**ស៖** សូមអរគុណ។ តើលោកមានបានទទួលការស្នើសុំពីភាគីដែលថាសុំទទួលយកឯកសារច្បាប់ដើមដែរឬទេ?

**ឆ៖** ដូចជាគ្មានទេ មិនដែលទេ។ មិនដែលមានភាគីណាមួយសុំឯកសារដើមទេ។

[១៥:៥៧:១៨]

**ស៖** ដូច្នេះយើងអាចសន្និដ្ឋានថា ភាគីទាំងអស់គាត់មានការពេញចិត្តចំពោះឯកសារច្បាប់ចម្លងហើយ តើអ៊ីចឹងទេលោក?

**ប្រធានអង្គជំនុំ៖**

កុំអាល់ៗឆ្លើយសាក្សី!

សូមអញ្ជើញលោកមេធាវីការពារក្តីលោក អៀង សារី! សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ លោកស្រីគឺគាត់មានពេលវេលាមួយចំនួនទៀតក៏ប៉ុន្តែខ្ញុំសូមក្រោកឈរឡើងដើម្បីជំទាស់ទៅលើការតាំងសំណួររបស់គាត់ត្រង់ចំណុចនេះ។

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព។

ភាគីពាក់ព័ន្ធមិនអាចសួរបំណងឲ្យសាក្សីធ្វើសេចក្តីសន្និដ្ឋានទេ។ បញ្ហានេះអង្គជំនុំជម្រះបានជម្រាបភាគីច្រើនលើកច្រើនសាហើយ អំពីការតាំងសំណួរឲ្យសាក្សីធ្វើសេចក្តីសន្និដ្ឋាន ឬក៏បង្ហាញបញ្ចេញនូវទស្សនៈយល់ឃើញផ្ទាល់ខ្លួននោះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំនឹងសួរសំណួរតាមរបៀបផ្សេង ហើយខ្ញុំជិតចប់ហើយលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោក យុ ឆាំង តើលោកមានការតវ៉ា ឬក៏ការជំទាស់ ឬក៏ការបង្ហាញអំពីការមិនពេញចិត្ត ការខឹងសម្បាពីភាគីណាមួយដែលមានវត្តមាននៅទីនេះដែរឬទេ? គឺឧទាហរណ៍ ដូចជាពាក់ព័ន្ធនឹងវិធីសាស្ត្រការងាររបស់លោក ពាក់ព័ន្ធនឹងឯកសារថតចម្លង ដែលលោកបានផ្តល់ជូនភាគីទាំងអស់នោះ?

**លោក ឆាំង យុ៖**

**ឆ៖** អ្នកស្រីចង់និយាយថា ជនចុងចោទ ឬក៏មេធាវីរបស់ជនចុងចោទ? ឬទាំងអស់គ្នានៅទីនេះ?

**ស៖** ខ្ញុំចង់សំដៅតែទៅលើមេធាវីការពារក្តីទេ ហើយនិងសហព្រះរាជអាជ្ញាដែលមានវត្តមាននៅទីនេះ?

**ឆ៖** ខ្ញុំមិនដែលមានភាគីណាមួយដែលជំទាស់ ឬក៏មិនពេញចិត្ត ជាទូទៅគឺថាយើងមានជាមិត្តជាភក្តិ លោក ផេសមិន, លោក អាន់ឌ្រូ, លោក កាណាវាស ក៏ធ្លាប់ចូលរួមសិក្ខាសាលានៅមជ្ឈមណ្ឌលឯកសារកម្ពុជា ថាវីក ក៏ធ្លាប់ទៅ បៀលស្ទីត ក៏ធ្លាប់ទៅ។ អ៊ីចឹងខ្ញុំធ្វើការជាមួយគ្នាជាមិតជាភក្តិត្រូវតែស្វែងរកយុត្តិធម៌ទាំងអស់គ្នា។ អ៊ីចឹងខ្ញុំមិនដែលមានគំនិតណាមួយដែលមិនល្អ ឬគាត់គិតឃើញប្រតិកម្មណាមួយពីគាត់ដែរ។ ខ្ញុំក៏មិនដែលឃើញដែរ។ រួមទាំងក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផងបាទ។

[១៦:00:00]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោក ឆាំង យុ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោក ឆាំង យុ ដែលបានមកផ្តល់សក្ខីកម្មតាមការអញ្ជើញរបស់អង្គជំនុំជម្រះ ប៉ុន្តែកិច្ចដំណើរការប្រព្រឹត្តទៅមិនទាន់ចប់ទេ នៅក្នុងស្តាប់សក្ខីកម្មរបស់លោកពាក់ព័ន្ធទៅនឹងដំណើរការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកកាន់បន្ទប់សវនាការនេះ នៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹក ដើម្បីបន្តការសួរដេញដោលពាក់ព័ន្ធទៅនឹងបញ្ហាដូចបានអង្គជំនុំជម្រះបានជម្រាបជូនហើយ។

ហើយឥឡូវនេះក៏ដល់ពេលសមល្មមនឹងសម្រាកហើយដែរ ប៉ុន្តែមុននឹងសម្រាកអង្គជំនុំជម្រះសុំសួរទៅក្រុមមេធាវីការពារក្តីទាំងបីក្រុម ដោយអង្គជំនុំជម្រះបានផ្តល់ពេលវេលាជូននៅក្នុងការសួរដេញដោលចំពោះលោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាពីរថ្ងៃ ហើយបញ្ហានេះ អង្គជំនុំជម្រះមិនចង់ដឹងពេលនេះ អង្គជំនុំជម្រះសុំទុកពេល ដើម្បីឱ្យមេធាវីទាំងបីក្រុមពិភាក្សា ថាតើរយៈពេលពីរថ្ងៃដែលចែកចេញជាបីក្រុមនោះ តើក្រុមនីមួយៗប្រើប្រាស់ពេលវេលាយ៉ាងដូចម្តេច? ហើយថ្ងៃស្អែកព្រលឹមឡើងមុននឹងពេលប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា នោះអង្គជំនុំជម្រះនឹងសង្ឃឹមថានឹងទទួលបានព័ត៌មានពីក្រុមមេធាវីទាំងបីក្នុងការបែងចែក ចែករំលែកនៃពេលវេលាពីរថ្ងៃដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ។

[១៦:០២:០១]

ហើយឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការត្រឹមនេះ។ ហើយលោកមន្ត្រីរដ្ឋបាលតុលាការជួយសម្របសម្រួលការធ្វើដំណើរវិលត្រឡប់ទៅវិញរបស់សាក្សីលោក ឆាំង យុ ផង។ ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងឱ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញ ហើយនិងឱ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន។ សូមអញ្ជើញសម្រាកចុះ៕

*(ចៅក្រមចាកចេញពីបន្ទប់សវនាការ)*

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*